5. ការស្រាវជ្រាវ (៦ ក្រេឌីត)		០	០	០	០	៣	០	០	៣	៦
១.	ការស្រាវជ្រាវអប់រំ	-	-	-	-	៣	-	-	-	៣
២.	គម្រោងស្រាវជ្រាវប្រតិបត្តិ	-	-	-	-	-	-	-	៣	៣
សរុប		***១៥***	***១៨***	***១៤***	***២៣***	***១៤***	***១៤***	***១៧***	***៨***	***១២៣***

២.៣.៤. ឯកទេសគីមីវិទ្យា

តារាងទី 12៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ (ឯកទេសគីមីវិទ្យា)

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
1. ការសិក្សាពីការអប់រំ (៣២ ក្រេឌីត)		៨	៦	៨	៦	២	២	០	០	៣២
១.	ចិត្តវិទ្យាអប់រំ I	៣	-	-	-	-	-	-	-	៣
២.	ចិត្តវិទ្យាអប់រំ II	-	-	២	-	-	-	-	-	២
៣.	ការវាយតម្លៃការសិក្សា	-	-	៣	-	-	-	-	-	៣
៤.	ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ	២	-	-	-	-	-	-	-	២
៥.	មូលដ្ឋានគ្រឹះនៃការអប់រំ	-	៣	-	-	-	-	-	-	៣
៦.	គរុកោសល្យ និងការបង្រៀន	-	-	៣	-	-	-	-	-	៣

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
៧.	មគ្គទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា	-	-	-	-	-	២	-	-	២
៨.	មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត	-	៣	-	-	-	-	-	-	៣
៩.	បំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សា	-	-	-	៣	-	-	-	-	៣
១០.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន I	៣	-	-	-	-	-	-	-	៣
១១.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន II	-	-	-	៣	-	-	-	-	៣
១២.	អប់រំសិល្បៈ	-	-	-	-	២	-	-	-	២
2. ចំណេះដឹងលើមុខវិជ្ជាឯកទេស (៤៣ ក្រេឌីត)		**៧**	**៧**	**៦**	**៧**	**៥**	**៤**	**៥**	**២**	**៤៣**
១.	វិទ្យាសាស្ត្រទូទៅរូបវិទ្យា I	២	-	-	-	-	-	-	-	២
២.	វិទ្យាសាស្ត្រទូទៅគីមីវិទ្យា I	២	-	-	-	-	-	-	-	២
៣.	វិទ្យាសាស្ត្រទូទៅជីវិទ្យា I	-	២	-	-	-	-	-	-	២
៤.	វិទ្យាសាស្ត្រទូទៅផែនដីវិទ្យា I	-	២	-	-	-	-	-	-	២
៥.	មូលដ្ឋានគ្រឹះគីមីវិទ្យា I	៣	-	-	-	-	-	-	-	៣
៦.	គណិតវិទ្យាទូទៅសម្រាប់វិទ្យាសាស្ត្រ	-	៣	-	-	-	-	-	-	៣
៧.	វិទ្យាសាស្ត្រទូទៅរូបវិទ្យា II	-	-	២	-	-	-	-	-	២
៨.	វិទ្យាសាស្ត្រទូទៅគីមីវិទ្យា II	-	-	២	-	-	-	-	-	២
៩.	វិទ្យាសាស្ត្រទូទៅជីវិទ្យា II	-	-	-	២	-	-	-	-	២
១០.	វិទ្យាសាស្ត្រទូទៅផែនដីវិទ្យា II	-	-	-	២	-	-	-	-	២
១១.	មូលដ្ឋានគ្រឹះគីមីវិទ្យា II	-	-	-	៣	-	-	-	-	៣
១២.	ការអប់រំស្មែមក្នុងការបង្រៀនគីមីវិទ្យា	-	-	២	-	-	-	-	-	២
១៣.	គីមីរូប	-	-	-	-	៣	-	-	-	៣
១៤.	គីមីវិភាគ I	-	-	-	-	២	-	-	-	២
១៥.	គីមីអសរីរាង្គ I	-	-	-	-	-	២	-	-	២
១៦.	គីមីសរីរាង្គ I	-	-	-	-	-	២	-	-	២
១៧.	គីមីសរីរាង្គ II	-	-	-	-	-	-	៣	-	៣
១៨.	គីមីអសរីរាង្គ II	-	-	-	-	-	-	២	-	២
១៩.	គីមីវិភាគ II	-	-	-	-	-	-	-	២	២
3. ការសិក្សាពីកម្មវិធីសិក្សា (២០ ក្រេឌីត)		**៣**	**០**	**២**	**៣**	**៣**	**៣**	**៣**	**៣**	**២០**
១.	វិធីសាស្ត្របង្រៀនគីមីវិទ្យា I៖ វិធីសាស្ត្របង្រៀនគីមីវិទ្យា	៣	-	-	-	-	-	-	-	៣

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
២.	វិធីសាស្ត្របង្រៀនគីមីវិទ្យា II៖ ការសិក្សាកម្មវិធីសិក្សាគីមីវិទ្យា	-	-	២	-	-	-	-	-	២
៣.	វិធីសាស្ត្របង្រៀនគីមីវិទ្យា III៖ ការណែនាំការបង្រៀននិងថ្នាក់និទស្សន៍ I	-	-	-	៣	-	-	-	-	៣
៤.	វិធីសាស្ត្របង្រៀនគីមីវិទ្យា IV៖ គន្លឹះគរុកោសល្យក្នុងការបង្រៀនគីមីវិទ្យា	-	-	-	-	៣	-	-	-	៣
៥.	វិធីសាស្ត្របង្រៀនគីមីវិទ្យា V៖ ការពិភាក្សាការបង្រៀននិងថ្នាក់និទស្សន៍ II	-	-	-	-	-	៣	-	-	៣
៦.	វិធីសាស្ត្របង្រៀនគីមីវិទ្យា VI៖ ការវាយតម្លៃការសិក្សាគីមីវិទ្យា	-	-	-	-	-	-	៣	-	៣
៧.	វិធីសាស្ត្របង្រៀនគីមីវិទ្យា VII៖ ការឆ្លុះបញ្ចាំង និងការអភិវឌ្ឍក្នុងការបង្រៀនគីមីវិទ្យា	-	-	-	-	-	-	-	៣	៣
4. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)		០	២	០	៥	០	៥	១០	០	២២
១.	ការដេកពិសោធនៅសាលារៀន	-	២	-	-	-	-	-	-	២
២.	ភាពជាអ្នកជំនួយការបង្រៀន	-	-	-	៥	-	-	-	-	៥
៣.	ការអនុវត្តការបង្រៀន I	-	-	-	-	-	៥	-	-	៥
៤.	ការអនុវត្តការបង្រៀន II	-	-	-	-	-	-	១០	-	១០
5. ការស្រាវជ្រាវ (៦ ក្រេឌីត)		០	០	០	០	៣	០	០	៣	៦
១.	ការស្រាវជ្រាវអប់រំ	-	-	-	-	៣	-	-	-	៣
២.	គម្រោងស្រាវជ្រាវប្រតិបត្តិ	-	-	-	-	-	-	-	៣	៣
សរុប		*១៨*	*១៥*	*១៧*	*២០*	*១៣*	*១៤*	*១៨*	*៨*	*១២៣*

២.៣.៥. ឯកទេសជីវវិទ្យា

តារាងទី 13៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ (ឯកទេសជីវវិទ្យា)

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
1. ការសិក្សាពីការអប់រំ (៣២ ក្រេឌីត)		៨	៦	៨	៦	២	២	០	០	៣២
១.	ចិត្តវិទ្យាអប់រំ I	៣	-	-	-	-	-	-	-	៣
២.	ចិត្តវិទ្យាអប់រំ II	-	-	២	-	-	-	-	-	២
៣.	ការវាយតម្លៃការសិក្សា	-	-	៣	-	-	-	-	-	៣
៤.	ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ	២	-	-	-	-	-	-	-	២

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
៥.	មូលដ្ឋានគ្រឹះនៃការអប់រំ	-	៣	-	-	-	-	-	-	៣
៦.	គរុកោសល្យ និងការបង្រៀន	-	-	៣	-	-	-	-	-	៣
៧.	មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា	-	-	-	-	-	២	-	-	២
៨.	មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត	-	៣	-	-	-	-	-	-	៣
៩.	បំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សា	-	-	-	៣	-	-	-	-	៣
១០.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន I	៣	-	-	-	-	-	-	-	៣
១១.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន II	-	-	-	៣	-	-	-	-	៣
១២.	អប់រំសិល្បៈ	-	-	-	-	២	-	-	-	២
2. ចំណេះដឹងលើមុខវិជ្ជាឯកទេស (៤៣ ក្រេឌីត)		៤	១០	៦	៧	៦	៤	៣	៣	៤៣
១.	វិទ្យាសាស្ត្រទូទៅជីវិទ្យា I	២	-	-	-	-	-	-	-	២
២.	វិទ្យាសាស្ត្រទូទៅជីវិទ្យា II	-	-	២	-	-	-	-	-	២
៣.	វិទ្យាសាស្ត្រទូទៅគីមីវិទ្យា I	២	-	-	-	-	-	-	-	២
៤.	វិទ្យាសាស្ត្រទូទៅគីមីវិទ្យា II	-	-	២	-	-	-	-	-	២
៥.	វិទ្យាសាស្ត្រទូទៅរូបវិទ្យា I	-	២	-	-	-	-	-	-	២
៦.	វិទ្យាសាស្ត្រទូទៅរូបវិទ្យា II	-	-	-	២	-	-	-	-	២
៧.	វិទ្យាសាស្ត្រទូទៅផែនដីវិទ្យា I	-	២	-	-	-	-	-	-	២
៨.	វិទ្យាសាស្ត្រទូទៅផែនដីវិទ្យា II	-	-	-	២	-	-	-	-	២
៩.	មូលដ្ឋានគ្រឹះជីវិទ្យា I	-	៣	-	-	-	-	-	-	៣
១០.	មូលដ្ឋានគ្រឹះជីវិទ្យា II	-	-	-	៣	-	-	-	-	៣
១១.	គណិតវិទ្យាទូទៅសម្រាប់វិទ្យាសាស្ត្រ	-	៣	-	-	-	-	-	-	៣
១២.	ការអប់រំស្មេមក្នុងការបង្រៀនជីវិទ្យា	-	-	២	-	-	-	-	-	២
១៣.	រុក្ខវិទ្យា	-	-	-	-	៣	-	-	-	៣
១៤.	សត្តវិទ្យា	-	-	-	-	៣	-	-	-	៣
១៥.	មីក្រុបវិទ្យា	-	-	-	-	-	២	-	-	២
១៦.	អេកូឡូស៊ី	-	-	-	-	-	២	-	-	២
១៧.	គីមីជីវៈ	-	-	-	-	-	-	៣	-	៣
១៨.	សេនេទិច	-	-	-	-	-	-	-	៣	៣
3. ការសិក្សាពីកម្មវិធីសិក្សា (២០ ក្រេឌីត)		៣	០	២	៣	៣	៣	៣	៣	២០
១.	វិធីសាស្ត្របង្រៀនជីវិទ្យា I៖ វិធីសាស្ត្របង្រៀនជីវិទ្យា	៣	-	-	-	-	-	-	-	៣

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
២.	វិធីសាស្ត្របង្រៀនជីវវិទ្យា II៖ ការសិក្សាកម្មវិធីសិក្សាជីវវិទ្យា	-	-	២	-	-	-	-	-	២
៣.	វិធីសាស្ត្របង្រៀនជីវវិទ្យា III៖ ការណែនាំការបង្រៀន និងថ្នាក់និទស្សន៍ I	-	-	-	៣	-	-	-	-	៣
៤.	វិធីសាស្ត្របង្រៀនជីវវិទ្យា IV៖ គន្លឹះគរុកោសល្យក្នុងការបង្រៀនជីវវិទ្យា	-	-	-	-	៣	-	-	-	៣
៥.	វិធីសាស្ត្របង្រៀនជីវវិទ្យា V៖ ការពិភាក្សាការបង្រៀន និងថ្នាក់និទស្សន៍ II	-	-	-	-	-	៣	-	-	៣
៦.	វិធីសាស្ត្របង្រៀនជីវវិទ្យា VI៖ ការវាយតម្លៃការសិក្សាជីវវិទ្យា	-	-	-	-	-	-	៣	-	៣
៧.	វិធីសាស្ត្របង្រៀនជីវវិទ្យា VII៖ ការឆ្លុះបញ្ចាំង និងការអភិវឌ្ឍក្នុងការបង្រៀនជីវវិទ្យា	-	-	-	-	-	-	-	៣	៣
4. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)		០	២	០	៥	០	៥	១០	០	២២
១.	ការដេកពិសោធនៅសាលារៀន	-	២	-	-	-	-	-	-	២
២.	ភាពជាអ្នកជំនួយការបង្រៀន	-	-	-	៥	-	-	-	-	៥
៣.	ការអនុវត្តការបង្រៀន I	-	-	-	-	-	៥	-	-	៥
៤.	ការអនុវត្តការបង្រៀន II	-	-	-	-	-	-	១០	-	១០
5. ការស្រាវជ្រាវ (៦ ក្រេឌីត)		០	០	០	០	៣	០	០	៣	៦
១.	ការស្រាវជ្រាវអប់រំ	-	-	-	-	៣	-	-	-	៣
២.	គម្រោងស្រាវជ្រាវប្រតិបត្តិ	-	-	-	-	-	-	-	៣	៣
សរុប		*១៥*	*១៨*	*១៦*	*២១*	*១៤*	*១៤*	*១៦*	*៩*	*១២៣*

២.៣.៦. ឯកទេសផែនដីនិងបរិស្ថានវិទ្យា

តារាងទី 14៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ (ឯកទេសផែនដីនិងបរិស្ថានវិទ្យា)

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
1. ការសិក្សាពីការអប់រំ (៣២ ក្រេឌីត)		៨	៦	៨	៦	២	២	០	០	៣២
១.	ចិត្តវិទ្យាអប់រំ I	៣	-	-	-	-	-	-	-	៣
២.	ចិត្តវិទ្យាអប់រំ II	-	-	២	-	-	-	-	-	២
៣.	ការវាយតម្លៃការសិក្សា	-	-	៣	-	-	-	-	-	៣
៤.	ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ	២	-	-	-	-	-	-	-	២
៥.	មូលដ្ឋានគ្រឹះនៃការអប់រំ	-	៣	-	-	-	-	-	-	៣

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
៦.	គរុកោសល្យ និងការបង្រៀន	-	-	៣	-	-	-	-	-	៣
៧.	មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា	-	-	-	-	-	២	-	-	២
៨.	មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត	-	៣	-	-	-	-	-	-	៣
៩.	បំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សា	-	-	-	៣	-	-	-	-	៣
១០.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន I	៣	-	-	-	-	-	-	-	៣
១១.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន II	-	-	-	៣	-	-	-	-	៣
១២.	អប់រំសិល្បៈ	-	-	-	-	២	-	-	-	២
2. ចំណេះដឹងលើមុខវិជ្ជាឯកទេស (៤៣ ក្រេឌីត)		**៦**	**៨**	**៤**	**៩**	**៦**	**៣**	**៥**	**២**	**៤៣**
១.	វិទ្យាសាស្ត្រទូទៅជីវិទ្យា I	២	-	-	-	-	-	-	-	២
២.	វិទ្យាសាស្ត្រទូទៅរូបវិទ្យា I	-	២	-	-	-	-	-	-	២
៣.	វិទ្យាសាស្ត្រទូទៅគីមីវិទ្យា I	២	-	-	-	-	-	-	-	២
៤.	វិទ្យាសាស្ត្រទូទៅផែនដីវិទ្យា និងបរិស្ថានវិទ្យា I	២	-	-	-	-	-	-	-	២
៥.	គណិតវិទ្យាទូទៅសម្រាប់វិទ្យាសាស្ត្រ	-	៣	-	-	-	-	-	-	៣
៦.	វិទ្យាសាស្ត្រទូទៅជីវិទ្យា II	-	-	២	-	-	-	-	-	២
៧.	វិទ្យាសាស្ត្រទូទៅរូបវិទ្យា II	-	-	២	-	-	-	-	-	២
៨.	វិទ្យាសាស្ត្រទូទៅគីមីវិទ្យា II	-	-	-	២	-	-	-	-	២
៩.	វិទ្យាសាស្ត្រទូទៅផែនដីវិទ្យា និងបរិស្ថានវិទ្យា II	-	-	-	២	-	-	-	-	២
១០.	មូលដ្ឋានគ្រឹះផែនដីវិទ្យា និងបរិស្ថានវិទ្យា II	-	៣	-	-	-	-	-	-	៣
១១.	មូលដ្ឋានគ្រឹះផែនដីវិទ្យា និងបរិស្ថានវិទ្យា II	-	-	-	៣	-	-	-	-	៣
១២.	ការអប់រំស្មេមក្នុងការបង្រៀនផែនដីវិទ្យា	-	-	-	២	-	-	-	-	២
១៣.	សាគរវិទ្យា	-	-	-	-	៣	-	-	-	៣
១៤.	ឧតុភូតវិទ្យា	-	-	-	-	៣	-	-	-	៣
១៥.	តារាវិទ្យា	-	-	-	-	-	-	-	២	២
១៦.	វិទ្យាសាស្ត្របរិស្ថាន I	-	-	-	-	-	៣	-	-	៣
១៧.	ធរណីវិទ្យា	-	-	-	-	-	-	៣	-	៣
១៨.	វិទ្យាសាស្ត្របរិស្ថាន II	-	-	-	-	-	-	២	-	២
3. ការសិក្សាពីកម្មវិធីសិក្សា (២០ ក្រេឌីត)		**៣**	**២**	**០**	**៣**	**៣**	**៣**	**២**	**២**	**២០**
១.	វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា I៖ វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា	៣	-		-	-	-	-	-	៣
២.	វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា II៖ ការសិក្សាកម្មវិធីសិក្សាផែនដីនិងបរិស្ថានវិទ្យា		២	-		-	-	-	-	២

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
៣.	វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា III៖ ការណែនាំការបង្រៀន និងថ្នាក់និទស្សន៍ I	-	-	-	៣	-		-	-	៣
៤.	វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា IV៖ គន្លឹះគរុកោសល្យក្នុងការបង្រៀនផែនដីនិងបរិស្ថានវិទ្យា	-	-	-	-	៣	-	-		៣
៥.	វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា V៖ ការពិភាក្សាការបង្រៀន និងថ្នាក់និទស្សន៍ II	-	-	-	-	-	៣	-	-	៣
៦.	វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា VI៖ ការវាយតម្លៃការសិក្សាផែនដីនិងបរិស្ថានវិទ្យា	-	-		-	-	-	៣	-	៣
៧.	វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា VII៖ ការឆ្លុះបញ្ចាំង និងការអភិវឌ្ឍក្នុងការបង្រៀន	-	-	-	-		-	-	៣	៣
4. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)		០	២	០	៥	០	៥	១០	០	២២
១.	បទពិសោធនៅសាលារៀន	-	២	-	-	-	-	-	-	២
២.	ភាពជាអ្នកជំនួយការបង្រៀន	-	-	-	៥	-	-	-	-	៥
៣.	ការអនុវត្តការបង្រៀន I	-	-	-	-	-	៥	-	-	៥
៤.	ការអនុវត្តការបង្រៀន II	-	-	-	-	-	-	១០	-	១០
5. ការស្រាវជ្រាវ (៦ ក្រេឌីត)		០	០	០	០	៣	០	០	៣	៦
១.	ការស្រាវជ្រាវអប់រំ	-	-	-	-	៣	-	-	-	៣
២.	គម្រោងស្រាវជ្រាវប្រតិបត្តិ	-	-	-	-	-	-	-	៣	៣
សរុប		*១៧*	*១៨*	*១២*	*២៣*	*១៤*	*១៣*	*១៧*	*៧*	*១២៣*

២.៣.៧. ឯកទេសប្រវត្តិវិទ្យា-ភូមិវិទ្យា

តារាងទី 15៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ (ឯកទេសប្រវត្តិវិទ្យា-ភូមិវិទ្យា)

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
1. ការសិក្សាពីការអប់រំ (៣២ ក្រេឌីត)		៨	៦	៨	៦	២	២	០	០	៣២
១.	ចិត្តវិទ្យាអប់រំ I	៣	-	-	-	-	-	-	-	៣
២.	ចិត្តវិទ្យាអប់រំ II	-	-	២	-	-	-	-	-	២
៣.	ការវាយតម្លៃការសិក្សា	-	-	៣	-	-	-	-	-	៣
៤.	ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ	២	-	-	-	-	-	-	-	២
៥.	មូលដ្ឋានគ្រឹះនៃការអប់រំ	-	៣	-	-	-	-	-	-	៣
៦.	គរុកោសល្យ និងការបង្រៀន	-	-	៣	-	-	-	-	-	៣

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
៧.	មគ្គទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា	-	-	-	-	-	២	-	-	២
៨.	មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត	-	៣	-	-	-	-	-	-	៣
៩.	បំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សា	-	-	-	៣	-	-	-	-	៣
១០.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន I	៣	-	-	-	-	-	-	-	៣
១១.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន II	-	-	-	៣	-	-	-	-	៣
១២.	អប់រំសិល្បៈ	-	-	-	-	២	-	-	-	២
2. ចំណេះដឹងលើមុខវិជ្ជាឯកទេស (៤៣ ក្រេឌីត)		៦	៥	៣	៥	៦	៦	៦	៦	៤៣
ឯកទេសប្រវត្តិវិទ្យា (២៤ ក្រេឌីត)	ទ្រឹស្តីប្រវត្តិវិទ្យា និងការស្រាវជ្រាវប្រវត្តិសាស្ត្រ	៣	-	-	-	-	-	-	-	៣
	ប្រវត្តិសាស្ត្រខ្មែរសម័យមុនអង្គរ	-	៣	-	-	-	-	-	-	៣
	ប្រវត្តិសាស្ត្រខ្មែរសម័យអង្គរ និងក្រោយអង្គរ	-	-	៣	-	-	-	-	-	៣
	ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍សម័យបុរាណ និងសម័យអាណានិគម	-	-	-	៣	-	-	-	-	៣
	ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍សម័យទំនើប	-	-	-	-	៣	-	-	-	៣
	ប្រវត្តិសាស្ត្រពិភពលោកបុរាណសម័យ និងមជ្ឈិមសម័យ	-	-	-	-	-	៣	-	-	៣
	ប្រវត្តិសាស្ត្រខ្មែរសម័យទំនើប	-	-	-	-	-	-	៣	-	៣
	ប្រវត្តិសាស្ត្រពិភពលោកសម័យទំនើប	-	-	-	-	-	-	-	៣	៣
ឯកទេសភូមិវិទ្យា (១៩ ក្រេឌីត)	ភូមិវិទ្យារូបទូទៅ	៣	-	-	-	-	-	-	-	៣
	ភូមិវិទ្យាមនុស្សទូទៅ	-	២	-	-	-	-	-	-	២
	ភូមិវិទ្យារូបប្រទេសកម្ពុជា	-	-	-	២	-	-	-	-	២
	ភូមិវិទ្យាមនុស្ស និងសេដ្ឋកិច្ចកម្ពុជា	-	-	-	-	៣	-	-	-	៣
	ផែនទីវិទ្យា	-	-	-	-	-	៣	-	-	៣
	ប្រជាសាស្ត្រ	-	-	-	-	-	-	៣	-	៣
	ភូមិវិទ្យាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍	-	-	-	-	-	-	-	៣	៣
3. ការសិក្សាពីកម្មវិធីសិក្សា (២០ ក្រេឌីត)		២	២	៦	០	៦	៤	០	០	២០
ប្រវត្តិវិទ្យា (១០ ក្រេឌីត)	វិធីសាស្ត្របង្រៀនប្រវត្តិវិទ្យា I	-	២	-	-	-	-	-	-	២
	វិធីសាស្ត្របង្រៀនប្រវត្តិវិទ្យា II	-	-	៣	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀនប្រវត្តិវិទ្យា III	-	-	-	-	៣	-	-	-	៣
	ការវាយតម្លៃការសិក្សាមុខវិជ្ជាប្រវត្តិវិទ្យា	-	-	-	-	-	២	-	-	២
ភូមិវិទ្យា	វិធីសាស្ត្របង្រៀនភូមិវិទ្យា I	២	-	-	-	-	-	-	-	២

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
(១០ ក្រេឌីត)	វិធីសាស្ត្របង្រៀនភូមិវិទ្យា II	-	-	៣	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀនភូមិវិទ្យា III	-	-	-	-	៣	-	-	-	៣
	ការវាយតម្លៃការសិក្សាមុខវិជ្ជាភូមិវិទ្យា	-	-	-	-	-	២	-	-	២
4. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)		០	២	០	៥	០	៥	១០	០	២២
១.	បទពិសោធនៅសាលារៀន	-	២	-	-	-	-	-	-	២
២.	ភាពជាអ្នកជំនួយការបង្រៀន	-	-	-	៥	-	-	-	-	៥
៣.	ការអនុវត្តការបង្រៀន I	-	-	-	-	-	៥	-	-	៥
៤.	ការអនុវត្តការបង្រៀន II	-	-	-	-	-	-	១០	-	១០
5. ការស្រាវជ្រាវ (៦ ក្រេឌីត)		០	០	០	០	៣	០	០	៣	៦
១.	ការស្រាវជ្រាវអប់រំ	-	-	-	-	៣	-	-	-	៣
២.	គម្រោងស្រាវជ្រាវប្រតិបត្តិ	-	-	-	-	-	-	-	៣	៣
សរុប		*១៨*	*១៦*	*១៧*	*១៦*	*១៦*	*១៥*	*១៦*	*៩*	*១២៣*

២.៣.៨. ឯកទេសសីលធម៌-ពលរដ្ឋវិជ្ជា-គេហសេដ្ឋកិច្ចវិទ្យា

តារាងទី 16៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ (ឯកទេសសីលធម៌-ពលរដ្ឋវិជ្ជា-គេហសេដ្ឋកិច្ចវិទ្យា)

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
1. ការសិក្សាពីការអប់រំ (៣២ ក្រេឌីត)		៨	៦	៨	៦	២	២	០	០	៣២
១.	ចិត្តវិទ្យាអប់រំ I	៣	-	-	-	-	-	-	-	៣
២.	ចិត្តវិទ្យាអប់រំ II	-	-	២	-	-	-	-	-	២
៣.	ការវាយតម្លៃការសិក្សា	-	-	៣	-	-	-	-	-	៣
៤.	ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ	២	-	-	-	-	-	-	-	២
៥.	មូលដ្ឋានគ្រឹះនៃការអប់រំ	-	៣	-	-	-	-	-	-	៣
៦.	គរុកោសល្យ និងការបង្រៀន	-	-	៣	-	-	-	-	-	៣
៧.	មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា	-	-	-	-	-	២	-	-	២
៨.	មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត	-	៣	-	-	-	-	-	-	៣
៩.	បំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សា	-	-	-	៣	-	-	-	-	៣
១០.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន I	៣	-	-	-	-	-	-	-	៣

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
១១.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន II	-	-	-	៣	-	-	-	-	៣
១២.	អប់រំសិល្បៈ	-	-	-	-	២	-	-	-	២
2. ចំណេះដឹងលើមុខវិជ្ជាឯកទេស (៤៣ ក្រេឌីត)		៥	៦	៦	៣	៦	៥	៦	៦	៤៣
សីលធម៌-ពលរដ្ឋវិជ្ជា (២៤ ក្រេឌីត)	សញ្ញាណទស្សនវិជ្ជា	៣	-	-	-	-	-	-	-	៣
	ប្រវត្តិទស្សនវិជ្ជាបស្ចិមប្រទេស	-	៣	-	-	-	-	-	-	៣
	ទស្សនវិជ្ជាមនុស្ស	-	-	៣	-	-	-	-	-	៣
	ទស្សនវិជ្ជាអប់រំ	-	-	-	៣	-	-	-	-	៣
	ទស្សនវិជ្ជាបូព៌ាប្រទេស I	-	-	-	-	៣	-	-	-	៣
	ទស្សនវិជ្ជាបូព៌ាប្រទេស II	-	-	-	-	-	៣	-	-	៣
	ទ្រឹស្តីសីលវិជ្ជា I	-	-	-	-	-	-	៣	-	៣
	ទ្រឹស្តីសីលវិជ្ជា II	-	-	-	-	-	-	-	៣	៣
គេហសេដ្ឋកិច្ចវិទ្យា (១៩ ក្រេឌីត)	សុវត្ថិភាពចំណីអាហារ និងគេហដ្ឋាន	២	-	-	-	-	-	-	-	២
	វិជ្ជាធ្វើម្ហូប	-	៣	-	-	-	-	-	-	៣
	វិជ្ជាដេរប៉ាក់ I	-	-	៣	-	-	-	-	-	៣
	វិជ្ជាដេរប៉ាក់ II	-	-	-	-	៣	-	-	-	៣
	មីក្រូសេដ្ឋកិច្ច	-	-	-	-	-	២	-	-	២
	ម៉ាក្រូសេដ្ឋកិច្ច	-	-	-	-	-	-	៣	-	៣
	អាជីវកម្មខ្នាតតូច និងសហគ្រិនភាព	-	-	-	-	-	-	-	៣	៣
3. ការសិក្សាពីកម្មវិធីសិក្សា (២០ ក្រេឌីត)		២	២	៣	៣	៦	៤	០	០	២០
សីលធម៌-ពលរដ្ឋវិជ្ជា (១០ ក្រេឌីត)	វិធីសាស្ត្របង្រៀនសីលធម៌-ពលរដ្ឋវិជ្ជា I	២	-	-	-	-	-	-	-	២
	វិធីសាស្ត្របង្រៀនសីលធម៌-ពលរដ្ឋវិជ្ជា II	-	-	៣	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀនសីលធម៌-ពលរដ្ឋវិជ្ជា III	-	-	-	-	៣	-	-	-	៣
	ការរៀបតម្លៃការសិក្សាមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា	-	-	-	-	-	២	-	-	២
គេហសេដ្ឋកិច្ចវិទ្យា (១០ ក្រេឌីត)	វិធីសាស្ត្របង្រៀនគេហសេដ្ឋកិច្ចវិទ្យា I	-	២	-	-	-	-	-	-	២
	វិធីសាស្ត្របង្រៀនគេហសេដ្ឋកិច្ចវិទ្យា II	-	-	-	៣	-	-	-	-	៣
	វិធីសាស្ត្របង្រៀនគេហសេដ្ឋកិច្ចវិទ្យា III	-	-	-	-	៣	-	-	-	៣
	ការរៀបតម្លៃការសិក្សាមុខវិជ្ជាគេហសេដ្ឋកិច្ចវិទ្យា	-	-	-	-	-	២	-	-	២
4. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)		០	២	០	៥	០	៥	១០	០	២២
១.	បទពិសោធនៅសាលារៀន	-	២	-	-	-	-	-	-	២
២.	ភាពជាអ្នកជំនួយការបង្រៀន	-	-	-	៥	-	-	-	-	៥

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
៣.	ការអនុវត្តការបង្រៀន I	-	-	-	-	-	៥	-	-	៥
៤.	ការអនុវត្តការបង្រៀន II	-	-	-	-	-	-	១០	-	១០
5. ការស្រាវជ្រាវ (៦ ក្រេឌីត)		០	០	០	០	៣	០	០	៣	៦
១.	ការស្រាវជ្រាវអប់រំ	-	-	-	-	៣	-	-	-	៣
២.	គម្រោងស្រាវជ្រាវប្រតិបត្តិ	-	-	-	-	-	-	-	៣	៣
សរុប		*១៥*	*១៩*	*១៧*	*១៧*	*១៥*	*១៨*	*១៦*	*៦*	*១២៣*

២.៣.៩. ឯកទេសអប់រំសុខភាព-គេហសេដ្ឋកិច្ចវិទ្យា

តារាងទី 17៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ (ឯកទេសអប់រំសុខភាព-គេហសេដ្ឋកិច្ចវិទ្យា)

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
1. ការសិក្សាពីការអប់រំ (៣២ ក្រេឌីត)		៨	៦	៨	៦	២	២	០	០	៣២
១.	ចិត្តវិទ្យាអប់រំ I	៣	-	-	-	-	-	-	-	៣
២.	ចិត្តវិទ្យាអប់រំ II	-	-	២	-	-	-	-	-	២
៣.	ការវាយតម្លៃការសិក្សា	-	-	៣	-	-	-	-	-	៣
៤.	ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ	២	-	-	-	-	-	-	-	២
៥.	មូលដ្ឋានគ្រឹះនៃការអប់រំ	-	៣	-	-	-	-	-	-	៣
៦.	គរុកោសល្យ និងការបង្រៀន	-	-	៣	-	-	-	-	-	៣
៧.	មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា	-	-	-	-	-	២	-	-	២
៨.	មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត	-	៣	-	-	-	-	-	-	៣
៩.	បំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សា	-	-	-	៣	-	-	-	-	៣
១០.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន I	៣	-	-	-	-	-	-	-	៣
១១.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន II	-	-	-	៣	-	-	-	-	៣
១២.	អប់រំសិល្បៈ	-	-	-	-	២	-	-	-	២
2. ចំណេះដឹងលើមុខវិជ្ជាឯកទេស (៤៣ ក្រេឌីត)		៥	៥	៦	៣	៦	៧	៥	៦	៤៣
អប់រំសុខភាព	កាយវិភាគសាស្ត្រវិទ្យា និងសរីរវិទ្យា	២	-	-	-	-	-	-	-	២
	សុខភាព និងជំងឺកុមារ	៣		-	-	-	-	-	-	៣
	សុខភាពសិក្សា និងសុវត្ថិភាពសាលារៀន	-	៣		-	-	-	-	-	៣

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
(២៤ ក្រេឌីត)	អាហារូបត្ថម្ភ មីក្រូសារីរាង្គ ការឆ្លងមេរោគ និងភាពស៊ាំ	-	-	៣		-	-	-	-	៣
	សុខភាពមនុស្សវ័យជំទង់ ៖ ការអភិវឌ្ឍ និងសុខភាពនៅពេលពេញវ័យ និងការអប់រំសុខភាពផ្លូវភេទទូលំទូលាយ	-	-		៣		-	-	-	៣
	សុខភាពផ្លូវចិត្ត និងជំងឺផ្លូវចិត្ត	-	-	-		៣	-	-	-	៣
	ការគ្រប់គ្រងសុខភាពសិក្សា	-	-	-		-	២	-	-	២
	ការអប់រំសុខភាព	-	-	-	-			២	-	២
	អនាម័យ និងសុខភាពសាធារណៈ	-	-	-	-	-		-	៣	៣
គេហសេដ្ឋកិច្ច វិទ្យា (១៩ ក្រេឌីត)	សុវត្ថិភាពចំណីអាហារ និងគេហដ្ឋាន	-	២	-	-	-	-	-	-	២
	វិជ្ជាធ្វើម្ហូប	-	-	៣	-	-	-	-	-	៣
	វិជ្ជាដេរប៉ាក់ I	-	-	-	-	៣	-	-	-	៣
	វិជ្ជាដេរប៉ាក់ II	-	-	-	-	-	៣	-	-	៣
	មីក្រូសេដ្ឋកិច្ច	-	-	-	-	-	២	-	-	២
	ម៉ាក្រូសេដ្ឋកិច្ច	-	-	-	-	-	-	៣	-	៣
	អាជីវកម្មខ្នាតតូច និងសហគ្រិនភាព	-	-	-	-	-	-	-	៣	៣
3. ការសិក្សាពីកម្មវិធីសិក្សា (២០ ក្រេឌីត)		២	២	៣	៣	៦	២	២	០	២០
អប់រំសុខភាព (១០ ក្រេឌីត)	កម្មវិធីសិក្សា និងបញ្ញត្តិនៃការបង្រៀន និងរៀនមុខវិជ្ជាអប់រំសុខភាព	២	-	-	-	-	-	-	-	២
	វិធីសាស្ត្របង្រៀនសុខភាពសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ I	-		៣	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀនសុខភាពសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ II	-	-		-	៣	-	-	-	៣
	ការវាយតម្លៃការសិក្សាមុខវិជ្ជាអប់រំសុខភាព	-	-	-	-		-	២	-	២
គេហសេដ្ឋកិច្ច វិទ្យា (១០ ក្រេឌីត)	វិធីសាស្ត្របង្រៀនគេហសេដ្ឋកិច្ចវិទ្យា I	-	២	-	-	-	-	-	-	២
	វិធីសាស្ត្របង្រៀនគេហសេដ្ឋកិច្ចវិទ្យា II	-	-	-	៣	-	-	-	-	៣
	វិធីសាស្ត្របង្រៀនគេហសេដ្ឋកិច្ចវិទ្យា III	-	-	-	-	៣	-	-	-	៣
	ការវាយតម្លៃការសិក្សាមុខវិជ្ជា គេហសេដ្ឋកិច្ចវិទ្យា	-	-	-	-	-	២	-	-	២
4. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)		០	២	០	៥	០	៥	១០	០	២២
១.	បទពិសោធនៅសាលារៀន	-	២	-	-	-	-	-	-	២
២.	ភាពជាអ្នកជំនួយការបង្រៀន	-	-	-	៥	-	-	-	-	៥
៣.	ការអនុវត្តការបង្រៀន I	-	-	-	-	-	៥	-	-	៥
៤.	ការអនុវត្តការបង្រៀន II	-	-	-	-	-	-	១០	-	១០

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
5. ការស្រាវជ្រាវ (៦ ក្រេឌីត)		០	០	០	០	៣	០	០	៣	៦
១.	ការស្រាវជ្រាវអប់រំ	-	-	-	-	៣	-	-	-	៣
២.	គម្រោងស្រាវជ្រាវប្រតិបត្តិ	-	-	-	-	-	-	-	៣	៣
សរុប		*១៩*	*២៣*	*២០*	*១៦*	*១៤*	*១២*	*១៣*	*៦*	*១២៣*

២.៣.១០. ឯកទេសអប់រំសិល្បៈ

តារាងទី 18៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ (ឯកទេសអប់រំសិល្បៈ)

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
1. ការសិក្សាពីការអប់រំ (៣២ ក្រេឌីត)		៨	៦	៨	៦	២	២	០	០	៣២
១.	ចិត្តវិទ្យាអប់រំ I	៣	-	-	-	-	-	-	-	៣
២.	ចិត្តវិទ្យាអប់រំ II	-	-	២	-	-	-	-	-	២
៣.	ការវាយតម្លៃការសិក្សា	-	-	៣	-	-	-	-	-	៣
៤.	ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ	២	-	-	-	-	-	-	-	២
៥.	មូលដ្ឋានគ្រឹះនៃការអប់រំ	-	៣	-	-	-	-	-	-	៣
៦.	គរុកោសល្យ និងការបង្រៀន	-	-	៣	-	-	-	-	-	៣
៧.	មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា	-	-	-	-	-	២	-	-	២
៨.	មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត	-	៣	-	-	-	-	-	-	៣
៩.	បំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សា	-	-	-	៣	-	-	-	-	៣
១០.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន I	៣	-	-	-	-	-	-	-	៣
១១.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន II	-	-	-	៣	-	-	-	-	៣
១២.	អប់រំសិល្បៈ	-	-	-	-	២	-	-	-	២
2. ចំណេះដឹងលើមុខវិជ្ជាឯកទេស (៤៣ ក្រេឌីត)		៧	៦	៦	៣	៦	៦	៦	៣	៤៣
១.	ប្រវត្តិសិល្បៈ និងមូលដ្ឋានគ្រឹះគំនូរ	២	-	-	-	-	-	-	-	២
២.	មូលដ្ឋានគ្រឹះហត្ថកម្ម	២	-	-	-	-	-	-	-	២
៣.	ប្រវត្តិសិល្បៈ និងមូលដ្ឋានគ្រឹះតន្ត្រី	៣	-	-	-	-	-	-	-	៣
៤.	ប្រវត្តិសិល្បៈ និងមូលដ្ឋានគ្រឹះរបាំ	-	៣	-	-	-	-	-	-	៣
៥.	មូលដ្ឋានគ្រឹះគំនូរពណ៌	-	-	៣	-	-	-	-	-	៣
៦.	ហត្ថកម្មបែបប្រពៃណី	-	៣	-	-	-	-	-	-	៣

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
៧.	ឧបករណ៍ភ្លេង និងចម្រៀង	-	-	៣	-	-	-	-	-	៣
៨.	របាំព្រះរាជទ្រព្យ	-	-	-	៣	-	-	-	-	៣
៩.	គំនូរពណ៌ប្រេង	-	-	-	-	៣	-	-	-	៣
១០.	ហត្ថកម្មបង្កើសម្ភារៈប្រើប្រាស់	-	-	-	-	-	៣	-	-	៣
១១.	ការប្រគុំតន្ត្រី និងចម្រៀង	-	-	-	-	៣	-	-	-	៣
១២.	របាំប្រពៃណី	-	-	-	-	-	៣	-	-	៣
១៣.	ស្នាដៃគំនូរនិងពិព័រណ៌	-	-	-	-	-	-	៣	-	៣
១៤.	ការនិពន្ធតន្ត្រី	-	-	-	-	-	-	៣	-	៣
១៥.	របាំប្រជាប្រិយ	-	-	-	-	-	-	-	៣	៣
3. ការសិក្សាពីកម្មវិធីសិក្សា (២០ ក្រេឌីត)		០	២	៣	៣	៦	៣	៣	០	២០
១.	វិធីសាស្ត្របង្រៀនសិល្បៈ I ៖ កម្មវិធីសិក្សា និងបញ្ញត្តិនៃការបង្រៀននិងរៀនមុខវិជ្ជាអប់រំសិល្បៈ	-	២	-	-	-	-	-	-	២
២.	វិធីសាស្ត្របង្រៀនសិល្បៈ II ៖ វិធីសាស្ត្របង្រៀនគំនូរ-ហត្ថកម្ម	-	-	៣	-	-	-	-	-	៣
៣.	វិធីសាស្ត្របង្រៀនសិល្បៈ III ៖ វិធីសាស្ត្របង្រៀនតន្ត្រី	-	-	-	៣	-	-	-	-	៣
៤.	វិធីសាស្ត្របង្រៀនសិល្បៈ IV ៖ វិធីសាស្ត្របង្រៀនរបាំ	-	-	-	-	៣	-	-	-	៣
៥.	វិធីសាស្ត្របង្រៀនសិល្បៈ V ៖ ការវាយតម្លៃការសិក្សាផ្នែកគំនូរ-ហត្ថកម្ម	-	-	-	-	៣	-	-	-	៣
៦.	វិធីសាស្ត្របង្រៀនសិល្បៈ VI ៖ ការវាយតម្លៃការសិក្សាផ្នែកតន្ត្រី	-	-	-	-	-	៣	-	-	៣
៧.	វិធីសាស្ត្របង្រៀនសិល្បៈ VII ៖ ការវាយតម្លៃការសិក្សាផ្នែករបាំ	-	-	-	-	-	-	៣	-	៣
4. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)		០	២	០	៥	០	៥	១០	០	២២
១.	បទពិសោធនៅសាលារៀន	-	២	-	-	-	-	-	-	២
២.	ភាពជាអ្នកជំនួយការបង្រៀន	-	-	-	៥	-	-	-	-	៥
៣.	ការអនុវត្តការបង្រៀន I	-	-	-	-	-	៥	-	-	៥
៤.	ការអនុវត្តការបង្រៀន II	-	-	-	-	-	-	១០	-	១០
5. ការស្រាវជ្រាវ (៦ ក្រេឌីត)		០	០	០	០	៣	០	០	៣	៦
១.	ការស្រាវជ្រាវអប់រំ	-	-	-	-	៣	-	-	-	៣
២.	គម្រោងស្រាវជ្រាវប្រតិបត្តិ	-	-	-	-	-	-	-	៣	៣
សរុប		*១៥*	*១៦*	*១៧*	*១៧*	*១៧*	*១៦*	*១៩*	*៦*	*១២៣*

២.៣.១១. ឯកទេសភាសាអង់គ្លេស-ICT

តារាងទី 19៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ (ឯកទេសភាសាអង់គ្លេស-ICT)

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
1. ការសិក្សាពីការអប់រំ (៣២ ក្រេឌីត)		៨	៦	៨	៦	២	២	០	០	៣២
១.	ចិត្តវិទ្យាអប់រំ I	៣	-	-	-	-	-	-	-	៣
២.	ចិត្តវិទ្យាអប់រំ II	-	-	២	-	-	-	-	-	២
៣.	ការវាយតម្លៃការសិក្សា	-	-	៣	-	-	-	-	-	៣
៤.	ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ	២	-	-	-	-	-	-	-	២
៥.	មូលដ្ឋានគ្រឹះនៃការអប់រំ	-	៣	-	-	-	-	-	-	៣
៦.	គរុកោសល្យ និងការបង្រៀន	-	-	៣	-	-	-	-	-	៣
៧.	មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា	-	-	-	-	-	២	-	-	២
៨.	មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត	-	៣	-	-	-	-	-	-	៣
៩.	បំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សា	-	-	-	៣	-	-	-	-	៣
១០.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន I	៣	-	-	-	-	-	-	-	៣
១១.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន II	-	-	-	៣	-	-	-	-	៣
១២.	អប់រំសិល្បៈ	-	-	-	-	២	-	-	-	២
2. ចំណេះដឹងលើមុខវិជ្ជាឯកទេស (៤៣ ក្រេឌីត)		៥	០	៦	៦	៨	៦	៦	៦	៤៣
ឯកទេសភាសាអង់គ្លេស (២៤ ក្រេឌីត)	Core English I	៣	-	-	-	-	-	-	-	៣
	Core English II	-	-	៣	-	-	-	-	-	៣
	Core English III	-	-	-	-	២	-	-	-	២
	Core English IV	-	-	-	-	-	-	២	-	២
	Cultural Studies	-	-	-	-	-	៣	-	-	៣
	Literature Studies	-	-	-	-	-	-	-	៣	៣
	Academic Writing I	-	-	-	៣	-	-	-	-	៣
	Academic Writing II	-	-	-	-	៣	-	-	-	៣
	Academic Writing III	-	-	-	-	-	-	២	-	២
ឯកទេស ICT (១៩ ក្រេឌីត)	ការណែនាំអំពីវិទ្យាសាស្ត្រកុំព្យូទ័រ	២	-	-	-	-	-	-	-	២
	ការថែទាំ និងជួសជុលកុំព្យូទ័រ	-	-	-	-	-	-	២	-	២
	ការណែនាំអំពីមូលដ្ឋានទិន្នន័យ	-	-	-	៣	-	-	-	-	៣
	ការអប់រំពហុមេឌា	-	-	៣	-	-	-	-	-	៣
	ទំនាក់ទំនងទិន្នន័យ និងបណ្តាញកុំព្យូទ័រ	-	-	-	-	៣	-	-	-	៣

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
	ការសរសេរកម្មវិធីបញ្ញាសិប្បនិម្មិត	-	-	-	-	-	៣	-	-	៣
	ការអប់រំ STEAM តាមរយៈ ICT	-	-	-	-	-	-	-	៣	៣
3. ការសិក្សាពីកម្មវិធីសិក្សា (២០ ក្រេឌីត)		៥	៨	៣	០	៤	០	០	០	២០
ឯកទេសភាសាអង់គ្លេស (១០ ក្រេឌីត)	វិធីសាស្ត្របង្រៀនភាសាអង់គ្លេស I (Receptive Skills)	៣	-	-	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀនភាសាអង់គ្លេស II (Productive Skills)	-	៣	-	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀនអង់គ្លេស III (Techniques and Principles in Language Teaching)	-	២	-	-	-	-	-	-	២
	ការវាយតម្លៃការសិក្សា (Assessment)	-	-	-	-	២	-	-	-	២
ឯកទេស ICT (១០ ក្រេឌីត)	វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ I	២	-	-	-	-	-	-	-	២
	វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ II	-	៣	-	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ III	-	-	៣	-	-	-	-	-	៣
	ការវាយតម្លៃការសិក្សាមុខវិជ្ជា ICT	-	-	-	-	២	-	-	-	២
4. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)		០	២	០	៥	០	៥	១០	០	២២
១.	ការដេកពិសោធនៅសាលារៀន	-	២	-	-	-	-	-	-	២
២.	ភាពជាអ្នកជំនួយការបង្រៀន	-	-	-	៥	-	-	-	-	៥
៣.	ការអនុវត្តការបង្រៀន I	-	-	-	-	-	៥	-	-	៥
៤.	ការអនុវត្តការបង្រៀន II	-	-	-	-	-	-	១០	-	១០
5. ការស្រាវជ្រាវ (៦ ក្រេឌីត)		០	០	០	០	៣	០	០	៣	៦
១.	ការស្រាវជ្រាវអប់រំ	-	-	-	-	៣	-	-	-	៣
២.	គម្រោងស្រាវជ្រាវប្រតិបត្តិ	-	-	-	-	-	-	-	៣	៣
សរុប		*១៨*	*១៦*	*១៧*	*១៧*	*១៧*	*១៣*	*២២*	*៣*	*១២៣*

២.៣.១២. ឯកទេស ICT-ភាសាអង់គ្លេស

តារាងទី 20៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ (ឯកទេស ICT-ភាសាអង់គ្លេស)

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
1. ការសិក្សាពីការអប់រំ (៣២ ក្រេឌីត)		៨	៦	៨	៦	២	២	០	០	៣២
១.	ចិត្តវិទ្យាអប់រំ I	៣	-	-	-	-	-	-	-	៣
២.	ចិត្តវិទ្យាអប់រំ II	-	-	២	-	-	-	-	-	២
៣.	ការវាយតម្លៃការសិក្សា	-	-	៣	-	-	-	-	-	៣
៤.	ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ	២	-	-	-	-	-	-	-	២
៥.	មូលដ្ឋានគ្រឹះនៃការអប់រំ	-	៣	-	-	-	-	-	-	៣
៦.	គរុកោសល្យ និងការបង្រៀន	-	-	៣	-	-	-	-	-	៣
៧.	មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា	-	-	-	-	-	២	-	-	២
៨.	មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត	-	៣	-	-	-	-	-	-	៣
៩.	បំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សា	-	-	-	៣	-	-	-	-	៣
១០.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន I	៣	-	-	-	-	-	-	-	៣
១១.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន II	-	-	-	៣	-	-	-	-	៣
១២.	អប់រំសិល្បៈ	-	-	-	-	២	-	-	-	២
2. ចំណេះដឹងលើមុខវិជ្ជាឯកទេស (៤៣ ក្រេឌីត)		៦	៦	៦	៣	៨	៦	៥	៣	៤៣
ឯកទេស ICT (២៤ ក្រេឌីត)	ការណែនាំអំពីវិទ្យាសាស្ត្រកុំព្យូទ័រ	៣	-	-	-	-	-	-	-	៣
	ការថែទាំ និងជួសជុលកុំព្យូទ័រ	-	៣	-	-	-	-	-	-	៣
	ការណែនាំអំពីមូលដ្ឋានទិន្នន័យ	-	-	-	៣	-	-	-	-	៣
	ការអប់រំពហុមេឌា	-	-	៣	-	-	-	-	-	៣
	ទំនាក់ទំនងទិន្នន័យ និងបណ្តាញកុំព្យូទ័រ	-	-	-	-	-	-	៣	-	៣
	ការសរសេរកម្មវិធីបញ្ញាសិប្បនិម្មិត	-	-	-	-	៣	-	-	-	៣
	ការសរសេរកូដកម្មវិធីភាសា Python	-	-	-	-	-	-	-	៣	៣
	ការអប់រំ STEAM តាមរយៈ ICT	-	-	-	-	-	៣	-	-	៣
ឯកទេសភាសាអង់គ្លេស (១៩ ក្រេឌីត)	Core English I	-	-	៣	-	-	-	-	-	៣
	Core English II	-	-	-	-	២	-	-	-	២
	Core English III	-	-	-	-	-	-	២	-	២
	Cultural Studies	-	-	-	-	៣	-	-	-	៣
	Literature Studies	-	-	-	-	-	៣	-	-	៣
	Academic Writing I	៣	-	-	-	-	-	-	-	៣
	Academic Writing II	-	៣	-	-	-	-	-	-	៣

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
3. ការសិក្សាពីកម្មវិធីសិក្សា (២០ ក្រេឌីត)		៣	៣	៥	២	៤	៣	០	០	២០
ឯកទេស ICT (១០ ក្រេឌីត)	វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ I	២	-	-	-	-	-	-	-	២
	វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ II	-	-	៣	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ III	-	-	-	-	៣	-	-	-	៣
	ការវាយតម្លៃការសិក្សាមុខវិជ្ជា ICT	-	-	-	-	-	២	-	-	២
ឯកទេសភាសាអង់គ្លេស (១០ ក្រេឌីត)	វិធីសាស្ត្របង្រៀនភាសាអង់គ្លេស I (Receptive Skills)	-	៣	-	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀនភាសាអង់គ្លេស II (Productive Skills)	-	-	៣	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀនអង់គ្លេស III (Techniques and Principles in Language Teaching)	-	-	-	២	-	-	-	-	២
	ការវាយតម្លៃការសិក្សា (Assessment)	-	-	-	-	២	-	-	-	២
4. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)		០	២	០	៥	០	៥	១០	០	២២
១.	ការដេកពិសោធនៅសាលារៀន	-	២	-	-	-	-	-	-	២
២.	ភាពជាអ្នកជំនួយការបង្រៀន	-	-	-	៥	-	-	-	-	៥
៣.	ការអនុវត្តការបង្រៀន I	-	-	-	-	-	៥	-	-	៥
៤.	ការអនុវត្តការបង្រៀន II	-	-	-	-	-	-	១០	-	១០
5. ការស្រាវជ្រាវ (៦ ក្រេឌីត)		០	០	០	០	៣	០	០	៣	៦
១.	ការស្រាវជ្រាវអប់រំ	-	-	-	-	៣	-	-	-	៣
២.	គម្រោងស្រាវជ្រាវប្រតិបត្តិ	-	-	-	-	-	-	-	៣	៣
សរុប		*១៧*	*១៧*	*១៩*	*១៦*	*១៧*	*១៦*	*១៨*	*៣*	*១២៣*

២.៣.១៣. ឯកទេសភាសាបារាំង-ICT

តារាងទី 21៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ (ឯកទេសភាសាបារាំង-ICT)

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
1. ការសិក្សាពីការអប់រំ (៣២ ក្រេឌីត)		៨	៦	៨	៦	២	២	០	០	៣២
១.	ចិត្តវិទ្យាអប់រំ I	៣	-	-	-	-	-	-	-	៣
២.	ចិត្តវិទ្យាអប់រំ II	-	-	២	-	-	-	-	-	២

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
៣.	ការវាយតម្លៃការសិក្សា	-	-	៣	-	-	-	-	-	៣
៤.	ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ	២	-	-	-	-	-	-	-	២
៥.	មូលដ្ឋានគ្រឹះនៃការអប់រំ	-	៣	-	-	-	-	-	-	៣
៦.	គរុកោសល្យ និងការបង្រៀន	-	-	៣	-	-	-	-	-	៣
៧.	មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា	-	-	-	-	-	២	-	-	២
៨.	មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត	-	៣	-	-	-	-	-	-	៣
៩.	បំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សា	-	-	-	៣	-	-	-	-	៣
១០.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន I	៣	-	-	-	-	-	-	-	៣
១១.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន II	-	-	-	៣	-	-	-	-	៣
១២.	អប់រំសិល្បៈ	-	-	-	-	២	-	-	-	២
2. ចំណេះដឹងលើមុខវិជ្ជាឯកទេស (៤៣ ក្រេឌីត)		**៥**	**៣**	**៦**	**៦**	**៦**	**៩**	**៥**	**៣**	**៤៣**
ឯកទេសភាសាបារាំង (២៤ ក្រេឌីត)	Langue Française I	៣	-	-	-	-	-	-	-	៣
	Langue Française II	-	-	៣	-	-	-	-	-	៣
	Langue Française III	-	-	-	៣	-	-	-	-	៣
	Phonétique	-	៣	-	-	-	-	-	-	៣
	Civilisation / Vidéo	-	-	-	-	៣	-	-	-	៣
	Initiation à la littérature	-	-	-	-	-	៣	-	-	៣
	Rédaction académique I	-	-	-	-	-	៣	-	-	៣
	Rédaction académique II	-	-	-	-	-	-	៣	-	៣
ឯកទេស ICT (១៩ ក្រេឌីត)	ការណែនាំអំពីវិទ្យាសាស្ត្រកុំព្យូទ័រ	២	-	-	-	-	-	-	-	២
	ការថែទាំ និងជួសជុលកុំព្យូទ័រ	-	-	-	-	-	-	២	-	២
	ការណែនាំអំពីមូលដ្ឋានទិន្នន័យ	-	-	-	៣	-	-	-	-	៣
	ការអប់រំពហុមេឌា	-	-	៣	-	-	-	-	-	៣
	ទំនាក់ទំនងទិន្នន័យ និងបណ្តាញកុំព្យូទ័រ	-	-	-	-	៣	-	-	-	៣
	ការសរសេរកម្មវិធីបញ្ញាសិប្បនិម្មិត	-	-	-	-	-	៣	-	-	៣
	ការអប់រំ STEAM តាមរយៈ ICT	-	-	-	-	-	-	-	៣	៣
3. ការសិក្សាពីកម្មវិធីសិក្សា (២០ ក្រេឌីត)		**២**	**៦**	**៥**	**០**	**៥**	**២**	**០**	**០**	**២០**
ឯកទេសភាសាបារាំង	វិធីសាស្ត្របង្រៀនភាសាបារាំង I	-	៣	-	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀនភាសាបារាំង II	-	-	២	-	-	-	-	-	២
	វិធីសាស្ត្របង្រៀនភាសាបារាំង III	-	-	-	-	៣	-	-	-	៣

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
(១០ ក្រេឌីត)	វិធីសាស្ត្របង្រៀនភាសាបារាំង IV	-	-	-	-	-	២	-	-	២
ឯកទេស ICT (១០ ក្រេឌីត)	វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍ I	២	-	-	-	-	-	-	-	២
	វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍ II	-	៣	-	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍ III	-	-	៣	-	-	-	-	-	៣
	ការវាយតម្លៃការសិក្សាមុខវិជ្ជា ICT	-	-	-	-	២	-	-	-	២
4. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)		០	២	០	៥	០	៥	១០	០	២២
១.	ការដេកពិសោធនៅសាលារៀន	-	២	-	-	-	-	-	-	២
២.	ភាពជាអ្នកជំនួយការបង្រៀន	-	-	-	៥	-	-	-	-	៥
៣.	ការអនុវត្តការបង្រៀន I	-	-	-	-	-	៥	-	-	៥
៤.	ការអនុវត្តការបង្រៀន II	-	-	-	-	-	-	១០	-	១០
5. ការស្រាវជ្រាវ (៦ ក្រេឌីត)		០	០	០	០	៣	០	០	៣	៦
១.	ការស្រាវជ្រាវអប់រំ	-	-	-	-	៣	-	-	-	៣
២.	គម្រោងស្រាវជ្រាវប្រតិបត្តិ	-	-	-	-	-	-	-	៣	៣
សរុប		*១៥*	*១៧*	*១៩*	*១៧*	*១៦*	*១៨*	*១៥*	*៦*	*១២៣*

២.៣.១៤. ឯកទេស ICT-ភាសាបារាំង

តារាងទី 22៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ (ឯកទេស ICT-ភាសាបារាំង)

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
1. ការសិក្សាពីការអប់រំ (៣២ ក្រេឌីត)		៨	៦	៨	៦	២	២	០	០	៣២
១.	ចិត្តវិទ្យាអប់រំ I	៣	-	-	-	-	-	-	-	៣
២.	ចិត្តវិទ្យាអប់រំ II	-	-	២	-	-	-	-	-	២
៣.	ការវាយតម្លៃការសិក្សា	-	-	៣	-	-	-	-	-	៣
៤.	ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ	២	-	-	-	-	-	-	-	២
៥.	មូលដ្ឋានគ្រឹះនៃការអប់រំ	-	៣	-	-	-	-	-	-	៣
៦.	គរុកោសល្យ និងការបង្រៀន	-	-	៣	-	-	-	-	-	៣
៧.	មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា	-	-	-	-	-	២	-	-	២

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
៨.	មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត	-	៣	-	-	-	-	-	-	៣
៩.	បំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សា	-	-	-	៣	-	-	-	-	៣
១០.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន I	៣	-	-	-	-	-	-	-	៣
១១.	បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ការបង្រៀន និងរៀន II	-	-	-	៣	-	-	-	-	៣
១២.	អប់រំសិល្បៈ	-	-	-	-	២	-	-	-	២
2. ចំណេះដឹងលើមុខវិជ្ជាឯកទេស (៤៣ ក្រេឌីត)		**៦**	**៥**	**៥**	**៥**	**៧**	**៥**	**៧**	**៣**	**៤៣**
ឯកទេសបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) (២៤ ក្រេឌីត)	ការណែនាំអំពីវិទ្យាសាស្ត្រកុំព្យូទ័រ	៣	-	-	-	-	-	-	-	៣
	ការថែទាំ និងជួសជុលកុំព្យូទ័រ	-	៣	-	-	-	-	-	-	៣
	ការណែនាំអំពីមូលដ្ឋានទិន្នន័យ	-	-	-	៣	-	-	-	-	៣
	ការអប់រំពហុមេឌា	-	-	៣	-	-	-	-	-	៣
	ទំនាក់ទំនងទិន្នន័យ និងបណ្តាញកុំព្យូទ័រ	-	-	-	-	-	-	៣	-	៣
	ការសរសេរកម្មវិធីបញ្ញាសិប្បនិម្មិត	-	-	-	-	៣	-	-	-	៣
	ការសរសេរកូដកម្មវិធីភាសា Python	-	-	-	-	-	-	-	៣	៣
	ការអប់រំ STEAM តាមរយៈ ICT	-	-	-	-	-	៣	-	-	៣
ឯកទេសភាសាបារាំង (១៩ ក្រេឌីត)	Langue Française I	៣	-	-	-	-	-	-	-	៣
	Langue Française II	-	-	-	-	៣	-	-	-	៣
	Phonétique	-	២	-	-	-	-	-	-	៣
	Civilisation / Vidéo	-	-	២	-	-	-	-	-	២
	Initiation à la littérature	-	-	-	៣	-	-	-	-	២
	Rédaction académique I	-	-	-	-	-	៣	-	-	២
	Rédaction académique III	-	-	-	-	-	-	៣	-	៣
3. ការសិក្សាពីកម្មវិធីសិក្សា (២០ ក្រេឌីត)		**២**	**៦**	**៦**	**០**	**៤**	**២**	**០**	**០**	**២០**
ឯកទេសបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) (១០ ក្រេឌីត)	វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ I	២	-	-	-	-	-	-	-	២
	វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ II	-	៣	-	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ III	-	-	៣	-	-	-	-	-	៣
	ការវាយតម្លៃការសិក្សាមុខវិជ្ជា ICT	-	-	-	-	២	-	-	-	២
ភាសាបារាំង (១០ ក្រេឌីត)	វិធីសាស្ត្របង្រៀនភាសាបារាំង I	-	៣	-	-	-	-	-	-	៣
	វិធីសាស្ត្របង្រៀនភាសាបារាំង II	-	-	៣	-	-	-	-	-	៣

ល.រ.	បណ្តុំ/មុខវិជ្ជាសិក្សា	ឆ្នាំទី១		ឆ្នាំទី២		ឆ្នាំទី៣		ឆ្នាំទី៤		ក្រេឌីតសរុប
		ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	ឆ១	ឆ២	
	វិធីសាស្ត្របង្រៀនភាសាបារាំង III	-	-	-	-	២	-	-	-	២
	វិធីសាស្ត្របង្រៀនភាសាបារាំង IV	-	-	-	-	-	២	-	-	២
4. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)		០	២	០	៥	០	៥	១០	០	២២
១.	ការដឹកពិសោធនៅសាលារៀន	-	២	-	-	-	-	-	-	២
២.	ភាពជាអ្នកជំនួយការបង្រៀន	-	-	-	៥	-	-	-	-	៥
៣.	ការអនុវត្តការបង្រៀន I	-	-	-	-	-	៥	-	-	៥
៤.	ការអនុវត្តការបង្រៀន II	-	-	-	-	-	-	១០	-	១០
5. ការស្រាវជ្រាវ (៦ ក្រេឌីត)		០	០	០	០	៣	០	០	៣	៦
	ការស្រាវជ្រាវអប់រំ	-	-	-	-	៣	-	-	-	៣
	គម្រោងស្រាវជ្រាវប្រតិបត្តិ	-	-	-	-	-	-	-	៣	៣
សរុប		***១៦***	***១៩***	***១៩***	***១៧***	***១៥***	***១៥***	***១៦***	***៦***	***១២៣***

ជំពូកទី៣

ការវាយតម្លៃ

ការវាយតម្លៃការសិក្សាទូទៅ និងការប្រឡងត្រូវអនុវត្តតាមលក្ខខណ្ឌរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀន ដែលបានកំណត់ដោយផ្អែកលើសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

៣.១. មធ្យមភាគពិន្ទុនិទ្ទេស (GPA)

រូបមន្តគណនារកមធ្យមនៃពិន្ទុនិទ្ទេសសរុប(GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប(GPA) ស្មើនឹងផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point-P) និងតម្លៃក្រេឌីតនៃមុខវិជ្ជានីមួយៗ (Attempted Credit Value-C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកពីគ្រប់មុខវិជ្ជា។

$$GPA = \frac{\sum(P \times C)}{\sum C}$$

បន្ទាប់ពីបញ្ចប់ការសិក្សាតាមមុខវិជ្ជានីមួយៗ គរុនិស្សិតត្រូវចូលរួមវាយតម្លៃភាពពេញចិត្ត (Satisfaction Survey) នូវមុខវិជ្ជា និងគ្រូឧទ្ទេសទទួលបន្ទុក ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំតាមមុខវិជ្ជានីមួយៗ។

ការវាយតម្លៃផ្ទៃក្នុង ធ្វើឡើងដោយការិយាល័យជានាគុណភាពផ្ទៃក្នុងនៃគ្រឹះស្ថានអប់រំគ្រូបង្រៀនក្នុងគោលបំណងជានាឱ្យបាននូវគុណភាព ប្រសិទ្ធភាព និងភាពឆ្លើយតបនឹងបច្ចុប្បន្នភាពនៃកម្មវិធីអប់រំ។

៣.២. ប្រព័ន្ធពិន្ទុ និងនិទ្ទេស

គរុនិស្សិតម្នាក់ៗត្រូវតែបញ្ចប់មុខវិជ្ជានីមួយៗ ដែលតម្រូវនៅក្នុងកម្មវិធីអប់រំ។ រាល់ការវាយតម្លៃគរុនិស្សិតត្រូវបានកំណត់តាមរយៈការឱ្យពិន្ទុ និងការដាក់មូលវិចារដូចមានចែងខាងក្រោម៖

ក. ការដាក់ពិន្ទុ៖ ពិន្ទុត្រូវបានកំណត់ពី ០.០០ ដល់ ១០០.០០ [មធ្យមភាគ នៃពិន្ទុនិទ្ទេសសរុប (GPA) ដែលកំណត់ថាជាប់ គឺចាប់ពីមធ្យមភាគពិន្ទុ ៥០.០០ ឬ GPA ២.០០ ឡើងទៅ]។

ខ. ការដាក់មូលវិចារ៖ ការដាក់មូលវិចារត្រូវឱ្យស្របទៅនឹងពិន្ទុដូចខាងក្រោម៖

តារាងទី 23៖ ប្រព័ន្ធពិន្ទុ និងនិទ្ទេស

ពិន្ទុជាភាគរយ (%)	និទ្ទេសជាអក្សរ	ពិន្ទុនិទ្ទេស	និទ្ទេស
៨៥%-១០០%	A	៤.០០	ល្អប្រសើរ
៨០%-៨៤%	B+	៣.៥០	ល្អណាស់
៧០%-៧៩%	B	៣.០០	ល្អ
៦៥%-៦៩%	C+	២.៥០	ល្អបង្គួរ
៥០%-៦៤%	C	២.០០	មធ្យម
<៥០%	D	១.៥០	ធ្លាក់

ការវាយតម្លៃការសិក្សាត្រូវអនុវត្តតាមលក្ខខណ្ឌរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀន ដែលរួមមានការវាយតម្លៃតាមដំណាក់ (Formative Assessment) និងការវាយតម្លៃបញ្ចប់ (Summative Assessment)។

៣.៣. ការវាយតម្លៃមុខវិជ្ជាបង្រៀន

ការវាយតម្លៃមុខវិជ្ជាបង្រៀនរួមមានទម្រង់ផ្សេងៗជាច្រើនដូចជា វត្តមាន ការចូលរួមសកម្មភាពសិក្សា កិច្ចការសំណេរ ការធ្វើបទបង្ហាញ តេស្ត និងការប្រឡងបញ្ចប់មុខវិជ្ជា។

តារាងទី 24៖ ការវាយតម្លៃមុខវិជ្ជាបង្រៀន

ល.រ.	ទម្រង់នៃការវាយតម្លៃ	ភាគរយ (%)
១.	វត្តមាន	១០
២.	ការចូលរួមសកម្មភាពសិក្សា	២០
៣.	ការវាយតម្លៃអំឡុងពេលសិក្សា	៣០
៤.	ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា	៤០
សរុប		**១០០**

** សម្គាល់៖ គ្រូឧទ្ទេសមានសិទ្ធិក្នុងការរៀបចំការវាយតម្លៃតាមមុខវិជ្ជាទទួលបន្ទុកដោយមានភាពបត់បែន និងឆ្លើយតបជាមួយលទ្ធផល សិក្សារំពឹងទុកនៃមុខវិជ្ជានីមួយៗ។*

៣.៣.១. វត្តមាន

វត្តមានរបស់គរុនិស្សិត ត្រូវបានវាយតម្លៃតាមរយៈការចូលរួមស្តាប់បទឧទ្ទេស ការបង្ហាត់បង្ហាញ និងព្រឹត្តិការណ៍ដទៃទៀតតាមការកំណត់នៃមុខវិជ្ជាសិក្សា។

គរុនិស្សិតដែលបានចូលរៀនមុខវិជ្ជាសិក្សានីមួយៗ ចាំបាច់ត្រូវមានវត្តមានយ៉ាងតិចបំផុត៨០% ដើម្បីអាចចូលរួមប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ប៉ុន្តែមានករណីលើកលែងចំពោះគរុនិស្សិតមួយចំនួនដោយផ្អែកលើហេតុផលផ្អែកវេជ្ជសាស្ត្រជាក់ស្តែង ឬកាលៈទេសៈសមស្របដទៃទៀតអាស្រ័យទៅតាមបទប្បញ្ញត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា។

៣.៣.២. ការចូលរួមសកម្មភាពសិក្សា

ការវាយតម្លៃសកម្មភាពសិក្សា ផ្អែកលើភាពទៀងទាត់ និងភាពសកម្មនៃការចូលរួមប្រកបដោយគុណភាពរបស់គរុនិស្សិតក្នុងអំឡុងពេលសិក្សាដូចជា ការផ្លាស់ប្តូរបទពិសោធជាមួយគ្រូឧទ្ទេស និងមិត្តរួមក្រុមក្នុងការចែករំលែកគំនិត ធនធានសិក្សា ការផ្តល់មតិយោបល់ និងព័ត៌មានត្រឡប់។

៣.៣.៣. ការវាយតម្លៃអំឡុងពេលសិក្សា

ការវាយតម្លៃអំឡុងពេលសិក្សាផ្អែកលើគុណភាពនៃកិច្ចការដែលបានទទួលតាមរយៈការវាយតម្លៃតាមដំណាក់មានដូចជា៖

- កិច្ចការសំណេរ
- ការធ្វើបទបង្ហាញ
- គម្រោង ឬកិច្ចការស្រាវជ្រាវ
- ការធ្វើតេស្តពាក់កណ្តាលឆមាស

ការរៀបចំកិច្ចការវាយតម្លៃគួរតែបន្សឹគ្នាជាមួយកិច្ចការវាយតម្លៃស្វ័យឆ្លុះបញ្ចាំង ដែលត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីឱ្យគុនិស្សិតត្រៀមខ្លួនសម្រាប់អាជីពវិជ្ជាជីវៈដោយផ្អែកលើការសិក្សាពេញមួយជីវិត។

គុនិស្សិតដែលបានចូលរៀនមុខវិជ្ជាសិក្សានីមួយៗត្រូវបំពេញ និង/ឬប្រគល់កិច្ចការប្រឡងទាំងអស់ដើម្បីអាចចូលរួមប្រឡងបញ្ចប់មុខវិជ្ជាសិក្សា។

៣.៣.៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា

ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សាជាការវាយតម្លៃបញ្ចប់នៃមុខវិជ្ជាសិក្សាទាំងអស់។ ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សានឹងត្រូវធ្វើឡើងនៅសប្តាហ៍ប្រឡងនៃឆមាស ឬឆ្នាំសិក្សានីមួយៗដែលមុខវិជ្ជាសិក្សាត្រូវបានបង្រៀន។

ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សាមានដូចជា៖

- កិច្ចការសំណេរ
- កិច្ចការសំណួរចម្លើយខ្លីៗ
- កិច្ចការសំណួរចម្លើយពហុជ្រើសរើស
- កិច្ចការស្រាវជ្រាវ
- ការធ្វើបទបង្ហាញ

គុនិស្សិតដែលបានចូលរៀនមុខវិជ្ជាសិក្សានីមួយៗ ចាំបាច់ត្រូវប្រឡងបញ្ចប់មុខវិជ្ជានោះដើម្បីបានទទួលពិន្ទុបញ្ចប់។ គុនិស្សិតប្រឡងធ្លាក់មុខវិជ្ជាសិក្សាណាមួយ ពួកគេអាចប្រឡងឡើងវិញបានតែមួយលើកប៉ុណ្ណោះ។ ក្នុងករណីប្រឡងឡើងវិញធ្លាក់ គុនិស្សិតត្រូវរៀនមុខវិជ្ជានោះឡើងវិញដើម្បីមានសិទ្ធិប្រឡងបញ្ចប់។ គុនិស្សិតលួចចម្លងស្នាដៃនៃកិច្ចការណាមួយនឹងត្រូវទទួលពិន្ទុសូន្យលើកិច្ចការនោះ។

៣.៤. ការវាយតម្លៃកម្មសិក្សាគរុកោសល្យ

ការវាយតម្លៃកម្មសិក្សាគរុកោសល្យរួមមាន វត្តមាន សកម្មភាពចូលរួមធ្វើកិច្ចតែងការបង្រៀន ការបង្រៀនក្នុងថ្នាក់រៀន និងសកម្មភាពសាលារៀនដទៃទៀត ព្រមទាំងការរក្សាទុកផលបត្រកម្មសិក្សាគរុកោសល្យផ្អែកលើផែនការសិក្សាវិជ្ជាជីវៈ។

សមាសភាគកម្មសិក្សាគរុកោសល្យនីមួយៗ នឹងត្រូវបានវាយតម្លៃដោយគ្រឹះស្ថានអប់រំគ្រូបង្រៀនសហការជាមួយសាលារៀនដែលគុនិស្សិតចុះកម្មសិក្សាគរុកោសល្យ។

តារាងទី 25៖ ការវាយតម្លៃកម្មសិក្សាគរុកោសល្យ

ល.រ.	ទម្រង់នៃការវាយតម្លៃ	ភាគរយ (%)
១.	វត្តមានអំឡុងពេលកម្មសិក្សាគរុកោសល្យ	១០
២.	សកម្មភាពចូលរួមក្នុងកម្មសិក្សាគរុកោសល្យ	២០
៣.	ការវាយតម្លៃអំឡុងពេលបំពេញកម្មសិក្សាគរុកោសល្យ	៣០
៤.	ផលបត្រកម្មសិក្សាគរុកោសល្យ	៤០
សរុប		**១០០**

៣.៤.១. វត្តមានអំឡុងពេលកម្មសិក្សាគរុកោសល្យ

វត្តមានក្នុងពេលកម្មសិក្សាគរុកោសល្យនឹងត្រូវវាយតម្លៃផ្អែកលើ វត្តមានរបស់គរុនិស្សិតចូលរួមការប្រឹក្សាគរុកោសល្យ ការសង្កេតថ្នាក់រៀន រយៈពេលនៃការបង្រៀនតាមកាលវិភាគដែលបានកំណត់ ការប្រជុំចាំបាច់ និងព្រឹត្តិការណ៍នានានៅសាលារៀន។

គរុនិស្សិតត្រូវមានវត្តមានយ៉ាងតិច ៨០% សម្រាប់កម្មសិក្សាគរុកោសល្យប្រចាំឆ្នាំនីមួយៗ ដើម្បីអាចចូលរួមប្រឡងបញ្ចប់កម្មវិធីអប់រំ។ ប៉ុន្តែមានករណីលើកលែងចំពោះបុគ្គលមួយចំនួនដោយសារហេតុផលផ្នែកវេជ្ជសាស្ត្រ ហេតុផលផ្ទាល់ខ្លួន ឬដោយសារកាលៈទេសៈសមស្របដទៃទៀត អាស្រ័យទៅតាមបទប្បញ្ញត្តិរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀន។

៣.៤.២ សកម្មភាពចូលរួមអំឡុងពេលកម្មសិក្សាគរុកោសល្យ

សកម្មភាពចូលរួមអំឡុងពេលកម្មសិក្សាគរុកោសល្យនឹងត្រូវវាយតម្លៃផ្អែកលើការចូលរួម និងគុណភាពនៃការចូលរួមរបស់គរុនិស្សិតនៅក្នុងអំឡុងពេលចុះកម្មសិក្សាគរុកោសល្យក្នុងឆ្នាំនីមួយៗ។

សកម្មភាពចូលរួមក្នុងកម្មសិក្សាគរុកោសល្យរួមមាន ការចូលរួមអនុវត្តសកម្មភាពតាមសាលារៀនដែលបានកំណត់ ការផ្លាស់ប្តូរបទពិសោធជាមួយគ្រូបង្រៀននៅសាលារៀននិងមិត្តរួមក្រុម ការចូលរួមចំណែកក្នុងការវាយតម្លៃលទ្ធផលកម្មសិក្សាគរុកោសល្យ ការចែករំលែកគំនិតឬធនធាន ការផ្តល់មតិយោបល់ និងព័ត៌មានត្រឡប់ទៅកាន់គ្រូបង្រៀននៅសាលារៀននិងមិត្តរួមក្រុម។

ការវាយតម្លៃសកម្មភាពចូលរួមកម្មសិក្សាគរុកោសល្យផ្តោតលើគុណភាពនៃការចូលរួម៖

- អំឡុងពេល និងក្រោយពេលសង្កេតការបង្រៀន
- នៅក្នុងការប្រឹក្សាគរុកោសល្យ ឬសកម្មភាពពិភាក្សាក្រុម
- នៅក្នុងសកម្មភាពសហការរវាងមិត្តរួមក្រុម
- សកម្មភាពនៅក្នុងសាលារៀន ឬសហគមន៍

៣.៤.៣. ការវាយតម្លៃអំឡុងពេលកម្មសិក្សាគរុកោសល្យ

ការវាយតម្លៃអំឡុងពេលកម្មសិក្សាគរុកោសល្យនឹងត្រូវផ្អែកលើ គុណភាពកិច្ចការ ឬពិន្ទុដែលទទួលបានពីការបំពេញកិច្ចការក្នុងអំឡុងពេលចុះកម្មសិក្សាគរុកោសល្យដែលជាផ្នែកមួយនៃការវាយតម្លៃកិច្ចការតាមដំណាក់ក្នុងឆ្នាំនីមួយៗ។

ការវាយតម្លៃអំឡុងពេលបំពេញកម្មសិក្សាគរុកោសល្យរួមមាន៖

- ការវាយតម្លៃលើកិច្ចតែងការបង្រៀន ផែនការសកម្មភាព ឬធនធានឯកសារដទៃទៀត
- ការវាយតម្លៃលើការអនុវត្តការបង្រៀន ដែលមានការសង្កេត និងវាយតម្លៃ
- ការវាយតម្លៃផ្អែកលើកម្រិតនៃការអភិវឌ្ឍវិជ្ជាជីវៈនៅអំឡុងពេលកម្មសិក្សាគរុកោសល្យ
- ការវាយតម្លៃផ្អែកលើការវាយតម្លៃវិជ្ជាជីវៈជាប្រចាំដោយនាយកសាលារៀន

៣.៤.៤. ផលបត្រកម្មសិក្សាគរុកោសល្យ

ការវាយតម្លៃបញ្ចប់នៃសមាសភាគកម្មសិក្សាគរុកោសល្យក្នុងឆ្នាំនីមួយៗផ្អែកលើ ការប្រគល់ផលបត្រកម្មសិក្សាគរុកោសល្យ។

គរុនិស្សិតត្រូវរក្សាផលបត្ររបស់ខ្លួនក្នុងអំឡុងពេលកម្មសិក្សាគរុកោសល្យក្នុងឆ្នាំនីមួយៗ។ ផលបត្ររួមមាន ភស្តុតាងនៃសកម្មភាពដែលបានអនុវត្ត កិច្ចតែងការបង្រៀន និងការបង្រៀន រួមទាំងការឆ្លុះបញ្ចាំងពីចំណុចខ្លាំង ចំណុចខ្វះខាត និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។

មាតិកាផលបត្រកម្មសិក្សាគរុកោសល្យរួមមាន៖

- កំណត់ហេតុពីការឆ្លុះបញ្ចាំងលើការបង្រៀនប្រចាំថ្ងៃ
- កំណត់ត្រាពីមេរៀនដែលបានសង្កេត
- កិច្ចតែងការបង្រៀន ផែនការសកម្មភាព និងធនធានដទៃទៀត
- ខ្លឹមសារសង្ខេបនៃការប្រឹក្សាគរុកោសល្យ និងសកម្មភាពជាមួយមិត្តរួមក្រុម
- ឯកសារថតចម្លងការវាយតម្លៃពីគ្រូណែនាំ និងព្រឹត្តិបត្រសង្កេតការបង្រៀន
- កំណត់ត្រាស្វ័យឆ្លុះបញ្ចាំងផ្តោតលើចំណុចខ្លាំង ចំណុចដែលត្រូវកែលម្អ និងវិធីកែលម្អ
- ការសង្កេតលើទិដ្ឋភាពផ្សេងៗក្នុងសាលារៀនរួមមាន ការគ្រប់គ្រងនិងរដ្ឋបាល ការចូលរួមរបស់សហគមន៍ និងទំនាក់ទំនងរវាងអ្នកអាណាព្យាបាលជាមួយគ្រូបង្រៀន ។ល។

ទម្រង់ផលបត្រកម្មសិក្សាគរុកោសល្យត្រូវផ្អែកលើផែនការសិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនម្នាក់ៗដែលតម្រូវដោយសៀវភៅណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

៣.៥. ការវាយតម្លៃលើគម្រោងស្រាវជ្រាវប្រតិបត្តិ

គរុនិស្សិតម្នាក់ៗត្រូវរៀបចំសំណើ និងអនុវត្តគម្រោងស្រាវជ្រាវប្រតិបត្តិ ដែលពាក់ព័ន្ធនឹងការបង្រៀននិងរៀនស្របតាមបរិបទជាក់ស្តែងនៅក្នុងសាលារៀនដែលខ្លួនចុះកម្មសិក្សាគរុកោសល្យ។ គម្រោងស្រាវជ្រាវប្រតិបត្តិនេះត្រូវមានការពិនិត្យតាមដាន និងណែនាំពីគ្រូឧទ្ទេសដឹកនាំស្រាវជ្រាវនៃគ្រឹះស្ថានអប់រំគ្រូបង្រៀនដើម្បីធានាបាននូវគុណភាពនៃដំណើរការស្រាវជ្រាវ និងការសរសេររបាយការណ៍ស្រាវជ្រាវឱ្យបានត្រឹមត្រូវតាមស្តង់ដាបច្ចេកទេស។

តារាងទី 26៖ ការវាយតម្លៃគម្រោងស្រាវជ្រាវប្រតិបត្តិ

ល.រ.	**ទម្រង់នៃការវាយតម្លៃ**	**ភាគរយ (%)**
១.	សំណើស្រាវជ្រាវ	១០
២.	ការវាយតម្លៃពីវឌ្ឍនភាពនៃការស្រាវជ្រាវ (ជួបប្រជុំជាមួយគ្រូដឹកនាំយ៉ាងតិចចំនួន ៤ដងក្នុងមួយខែ)	២០
៣.	ការការពារគម្រោងស្រាវជ្រាវនិងប្រគល់របាយការណ៍បញ្ចប់	៧០
សរុប		**១០០**

បន្ទាប់ពីបានពិភាក្សាលើកដំបូងជាមួយគ្រូឧទ្ទេសដឹកនាំ គរុនិស្សិតត្រូវដាក់សេចក្តីព្រាងដំបូងនៃសំណើស្រាវជ្រាវរបស់ខ្លួនដើម្បីទទួលបានការត្រួតពិនិត្យ។ សំណើស្រាវជ្រាវរួមមាន៖

- ប្រធានបទស្រាវជ្រាវ
- គម្រោងស្រាវជ្រាវ
- ក្របខ័ណ្ឌពេលវេលានៃការស្រាវជ្រាវ

ក្រោយពីទទួលបានមតិយោបល់កែលម្អ គរុនិស្សិតត្រូវប្រគល់សេចក្តីព្រាងចុងក្រោយនៃសំណើស្រាវជ្រាវ។ គរុនិស្សិតត្រូវប្រគល់របាយការណ៍ស្រាវជ្រាវចុងក្រោយ ក្រោយពីទទួលបានមតិយោបល់កែលម្អក្នុងកិច្ចប្រជុំវាយតម្លៃចុងក្រោយ។

គរុនិស្សិតត្រូវបញ្ចប់ និងប្រគល់របាយការណ៍ស្រាវជ្រាវមុននឹងអាចចូលប្រឡងបញ្ចប់ការសិក្សាបាន។ ករណីមិនបានបំពេញគ្រប់លក្ខខណ្ឌក្នុងការស្រាវជ្រាវទេ គរុនិស្សិតមិនអាចបញ្ចប់ការសិក្សាបានទេ។

៣.៦. ការវាយតម្លៃលើសុចរិតភាព វិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា

ការវាយតម្លៃផ្នែកនេះត្រូវផ្អែកលើការពិនិត្យតាមដានជាក់ស្តែង ដូចជាការគោរពបទបញ្ជាផ្ទៃក្នុង វត្តមាន មករៀនទៀងទាត់ ការយកចិត្តទុក ដាក់ក្នុងសកម្មភាពសិក្សា ការស្រាវជ្រាវ ការទទួលខុសត្រូវលើភារកិច្ចដែលបានប្រគល់ជូន ព្រមទាំងស្មារតីសាមគ្គីភាព និងសីលធម៌នៃការរស់នៅទាំងក្នុង និងក្រៅគ្រឹះស្ថាន អប់រំគ្រូបង្រៀន។

សេចក្តីសម្រេចលើការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមរយៈយោបល់ឯកភាពមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យដោយផ្អែកលើកម្រិតនៃលក្ខណៈសម្បត្តិដាក់ស្តែងរបស់គរុនិស្សិតម្នាក់ៗ និងយោងតាមបទបញ្ជាផ្ទៃក្នុងជាធរមានរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀន។

៣.៧. ការផ្តល់សញ្ញាបត្រ

គរុនិស្សិតត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ដើម្បីបញ្ចប់ការសិក្សា និងទទួលបានសញ្ញាបត្រ៖

1. សិក្សាគ្រប់ចំនួនក្រេឌីតដែលបានកំណត់ក្នុងកម្មវិធីអប់រំគ្រូបង្រៀនអនុវិទ្យាល័យតាមប្រព័ន្ធ ១២+៤ ដោយជោគជ័យ
2. បំពេញកម្មសិក្សាគរុកោសល្យដោយជោគជ័យ
3. មានចំណេះដឹងភាសាបរទេសកម្រិតមធ្យម (Intermediate level)។ គ្រឹះស្ថានអប់រំគ្រូបង្រៀនត្រូវវាយតម្លៃកម្រិតសមត្ថភាពភាសាបរទេសរបស់គរុនិស្សិតនៅដើមឆ្នាំទី១ និងរៀបចំវគ្គសិក្សាតាមតម្រូវការរបស់គរុនិស្សិតឱ្យមានសមត្ថភាពភាសាបរទេសកម្រិតមធ្យម មុនពេលបញ្ចប់ការសិក្សា
4. ការពារបញ្ចប់គម្រោងស្រាវជ្រាវប្រតិបត្តិដោយជោគជ័យ
5. ប្រឡងបញ្ចប់កម្មវិធីអប់រំគ្រូបង្រៀនជាប់ជាស្ថាពរ។

គរុនិស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ នឹងទទួលបាន **«បរិញ្ញាបត្រអប់រំជំនាញជីវៈគ្រូបង្រៀនអនុវិទ្យាល័យ»**។

ជំពូកទី៤
ការពណ៌នាមុខវិជ្ជា

៤.១. ការសិក្សាពីរឆ្នាំ (៣២ ក្រេឌីត)

៤.១.១. ចិត្តវិទ្យាអប់រំ I [៣ (៣-០-៦)]

មុខវិជ្ជាចិត្តវិទ្យាអប់រំ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវទិដ្ឋភាពទូទៅនៃចិត្តវិទ្យាអប់រំសម្រាប់ការបង្រៀននិងរៀន និងឫសគល់និងភាពចាំបាច់នៃចិត្តវិទ្យាអប់រំសម្រាប់តួនាទីជាគ្រូបង្រៀន។ ខ្លឹមសារមុខវិជ្ជានេះរួមមាន ទ្រឹស្តីនៃការរៀន (ទ្រឹស្តីអាកប្បកិរិយានិយម ទ្រឹស្តីពុទ្ធិនិយម ទ្រឹស្តីស្ថាបនានិយម...) ទ្រឹស្តីអភិវឌ្ឍសីលធម៌ ភាពចម្រុះនៃការសិក្សារបស់សិស្ស ទ្រឹស្តីដំណើរការទទួលយកព័ត៌មាន និងការអប់រំបរិយាបន្នជាដើម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពអនុវត្តទ្រឹស្តីចិត្តវិទ្យាអប់រំក្នុងការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព សមធម៌ និងបរិយាបន្ន។

៤.១.២. ចិត្តវិទ្យាអប់រំ II [២ (២-០-៤)]

មុខវិជ្ជាចិត្តវិទ្យាអប់រំ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវការសិក្សាបន្ថែមលើទ្រឹស្តីនានា បន្តពីទ្រឹស្តីដែលមានក្នុងចិត្តវិទ្យាអប់រំ I និងការអនុវត្តទ្រឹស្តីតាមរយៈករណីសិក្សា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារដូចជា ទស្សនទានពុទ្ធិនៃការសិក្សា ដំណើរការពុទ្ធិដែលស្មុគស្មាញ ទស្សនៈសង្គមនៃការសិក្សា ការលើកទឹកចិត្តក្នុងការបង្រៀននិងរៀន និងបរិយាបន្នអប់រំ។ លើសពីនេះមុខវិជ្ជានេះផ្តោតលើការអនុវត្តទ្រឹស្តីចិត្តវិទ្យាអប់រំ I ក្នុងការបង្រៀននិងរៀន ដើម្បីដោះស្រាយបញ្ហា ច្នៃប្រឌិតបង្កើតថ្មី និងបង្កើតបរិយាកាសសិក្សាវិជ្ជមាន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានចំណេះដឹង និងបំណិនក្នុងការអនុវត្តទ្រឹស្តីអាកប្បកិរិយា ទ្រឹស្តីអភិវឌ្ឍពុទ្ធិ ទ្រឹស្តីស្ថាបនានិយម ការគិតប្រកបដោយវិចារណញ្ញាណ និងទ្រឹស្តីផ្សេងៗទៀតនៃចិត្តវិទ្យាអប់រំក្នុងការបង្រៀននិងរៀន។

៤.១.៣. ការវាយតម្លៃការសិក្សា [៣ (៣-០-៦)]

មុខវិជ្ជាការវាយតម្លៃការសិក្សាមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការវាយតម្លៃការសិក្សារបស់សិស្សស្របតាមតម្រូវការរបស់សិស្សដែលមានសមត្ថភាពចម្រុះ និងវប្បធម៌ផ្សេងគ្នា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារដូចជា ទិដ្ឋភាពទូទៅនៃការវាយតម្លៃការសិក្សា ប្រភេទផ្សេងៗនៃការវាយតម្លៃ វិធីរៀបចំ និងផលិតឧបករណ៍វាយតម្លៃដែលមានសុពលភាពនិងភាពជឿជាក់ ក្របខ័ណ្ឌសំណួរតេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្សនៅអនុវិទ្យាល័យ ការបង្កើតតេស្តស្តង់ដានិងតេស្តអន្តរជាតិ (PISA) ការបង្កើតលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃលើចិត្តចលនា បំណិនក្នុងការប្រតិបត្តិ បំណិនក្នុងការគិត និងឥរិយាបថរបស់សិស្ស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្កើតតេស្តស្តង់ដា រៀបចំតេស្តលក្ខណៈអន្តរជាតិ (PISA) លើផ្នែកអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រប្រកបដោយសុពលភាព ភាពជឿជាក់ និងមានប្រសិទ្ធភាព និងសរសេរនិទ្ទេសបទសម្រាប់វាយតម្លៃបំណិនសម្បទានិងចរិយាសម្បទា។

៤.១.៤. ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ [២ (២-០-៤)]

មុខវិជ្ជាការប្រតិបត្តិ និងការឆ្លុះបញ្ចាំងវិជ្ជាជីវៈ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវបញ្ញត្តិខ្លឹមសារនៃការអនុវត្តការងារជាគ្រូបង្រៀន និងការឆ្លុះបញ្ចាំងក្រោយការបង្រៀននិងរៀន ដើម្បីអភិវឌ្ឍបំណិននិងភាពជឿជាក់

ក្នុងការបង្រៀន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារដូចជា តួនាទីនិងទំនួលខុសត្រូវក្នុងនាមជាគ្រូបង្រៀន ស្តង់ដាគុណសម្បទាគរុនិស្សិត ការស្វ័យវាយតម្លៃគរុនិស្សិតធៀបនឹងស្តង់ដាវិជ្ជាជីវៈ ការស្វ័យឆ្លុះបញ្ចាំងនិងលំនាំសន្ទនាឆ្លុះបញ្ចាំង ការឆ្លុះបញ្ចាំងជាបុគ្គលនិងជាក្រុម ការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន តួនាទីគ្រូឧទ្ទេសដឹកនាំនិងគ្រូណែនាំ និងការបំពេញផលបត្រជាដើម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពផ្សារភ្ជាប់រវាងទ្រឹស្តី ការប្រតិបត្តិ និងការឆ្លុះបញ្ចាំងវិជ្ជាជីវៈប្រកបដោយភាពជឿជាក់ ដើម្បីបង្កើនទំនាក់ទំនងល្អនិងភាពជិតស្និទ្ធជាមួយមាតាបិតាសិស្ស។

៤.១.៥. មូលដ្ឋានគ្រឹះនៃការអប់រំ [៣ (៣-០-៦)]

មុខវិជ្ជាមូលដ្ឋានគ្រឹះនៃការអប់រំ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើការអប់រំទូទៅ បរិបទសង្គម និងចំណេះដឹងមូលដ្ឋាននៃការអប់រំក្នុងកម្មវិធីអប់រំគ្រូបង្រៀន។ មុខវិជ្ជានេះ ផ្តោតលើខ្លឹមសារដូចជា ទស្សនវិជ្ជាអប់រំ ប្រវត្តិនៃការអភិវឌ្ឍការអប់រំ ការសិក្សាពហុវប្បធម៌ យេនឌ័រ ការអប់រំភាពជាពលរដ្ឋសកល ស្តង់ដាសាលាមធ្យមសិក្សាគំរូ បរិបទសង្គមនៃការបង្រៀននិងរៀន ការគ្រប់គ្រងតាមសាលារៀន និងរដ្ឋបាលសិក្សា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់បញ្ញត្តិមូលដ្ឋាននៃការអប់រំផ្សារភ្ជាប់ទៅនឹងការបង្រៀននិងរៀន។

៤.១.៦. គរុកោសល្យ និងការបង្រៀន [៣ (៣-០-៦)]

មុខវិជ្ជាគរុកោសល្យនិងការបង្រៀន មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិន អំពីការបង្រៀនតាមបែបសកម្ម អន្តរបុគ្គល ការគិតប្រកបដោយវិចារណញ្ញាណ ការវិភាគ និងតំរិយោបថទទួលខុសត្រូវក្នុងអាជីពជាគ្រូបង្រៀននៅអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារដូចជា គោលការណ៍គរុកោសល្យ វិធីសាស្ត្របង្រៀនតាមបែបសកម្ម (ការបង្រៀនដោយផ្អែកលើសន្លឹកកិច្ចការ ការសិក្សាដោយផ្អែកលើបញ្ហា ការសិក្សាតាមបែបគម្រោង និងការសិក្សាតាមបែបសហការ) ប្រធានបទទាំង៥នៃប្រសិទ្ធភាពក្នុងការគ្រប់គ្រងថ្នាក់រៀន ការឆ្លើយតបចំពោះតម្រូវការរបស់សិស្ស និងវិធីបង្រៀននិងរៀនបែបចិត្តសង្គម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការបង្រៀនស្របតាមស្តង់ដាកម្មវិធីសិក្សាជាតិ និងតម្រូវការរបស់សិស្ស បង្កើតបរិយាកាសសិក្សាដែលមានការចូលរួមនិងគាំទ្រប្រកបដោយសមធម៌និងបរិយាបន្ន គ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព និងទទួលខុសត្រូវក្នុងការបង្រៀននិងរៀនប្រកបដោយវិជ្ជាជីវៈ។

៤.១.៧. មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា [២ (២-០-៤)]

មុខវិជ្ជាមគ្គុទេសក៍អាជីពនិងការផ្តល់ប្រឹក្សា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋាននៃកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា និងជួយគរុនិស្សិតឱ្យប្រើប្រាស់និងអភិវឌ្ឍកម្មវិធីនេះក្នុងការងារជាគ្រូបង្រៀននាពេលអនាគត។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារដូចជា ទិដ្ឋភាពទូទៅនៃការសិក្សាមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាកម្រិតសាលាចំណេះទូទៅ គោលការណ៍ ដំណើរការ និងនីតិវិធីនៃការផ្តល់ការប្រឹក្សា ព្រមទាំងទ្រឹស្តីនានាដែលជួយគាំទ្រការផ្តល់ការប្រឹក្សា វដ្តការងារ និងជីវិតប្រចាំថ្ងៃ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពគាំទ្រការសិក្សា និងការអភិវឌ្ឍបញ្ញារបស់សិស្ស ហើយជួយសិស្សក្នុងការជ្រើសរើសមុខវិជ្ជាសិក្សា មុខរបរ ឬអាជីពសមស្រប និងដំណោះស្រាយផ្សេងៗ ព្រមជាមួយនឹងការគាំទ្រផ្លូវចិត្ត។

៤.១.៨. មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត [៣ (៣-០-៦)]

មុខវិជ្ជាមូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្តមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវការសិក្សាពីនិយមន័យ គោលការណ៍ បញ្ញត្តិគន្លឹះ និងទ្រឹស្តីនានាទាក់ទងនឹងកម្មវិធីសិក្សា។ មុខវិជ្ជានេះផ្តោតលើ សមាសភាគ

កម្មវិធីសិក្សា ប្រភេទកម្មវិធីសិក្សា ដំណើរការអភិវឌ្ឍកម្មវិធីសិក្សា ការអនុវត្តកម្មវិធីសិក្សា ការវិភាគនិង វាយតម្លៃកម្មវិធីសិក្សា បញ្ហាប្រឈម និងនិន្នាការនៃការអភិវឌ្ឍកម្មវិធីសិក្សា ព្រមទាំងដំហានគំរូនៃដំណើរ ការអភិវឌ្ឍកម្មវិធីសិក្សា ការអភិវឌ្ឍកម្មវិធីសិក្សាដោយយកសាលារៀនជាមូលដ្ឋាន និងការកែលម្អកម្មវិធីសិក្សា ឱ្យកាន់តែមានភាពប្រសើរ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវាយតម្លៃ កម្មវិធីសិក្សាលម្អិត សង្គតិភាពនៃសមាសភាគនានាក្នុងកម្មវិធីសិក្សាលម្អិត និងសៀវភៅសិក្សាគោល អនុវត្តកម្មវិធី សិក្សាបានល្អប្រសើរ កែសម្រួលការអនុវត្តការបង្រៀននិងរៀន និងអាចបង្កើតមុខវិជ្ជាថ្មីសមស្របនឹងបរិបទ បង្រៀនជាក់ស្តែង។

៤.១.៩. បំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សា [៣ (២-២-៥)]

មុខវិជ្ជាបំណិនជីវិត ការប្រែប្រួលអាកាសធាតុ សុខភាពសិក្សាមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវការ យល់ដឹងលើបញ្ញត្តិនិងវិធីសាស្ត្របង្រៀនមេរៀនបំណិនជីវិត ការប្រែប្រួលអាកាសធាតុ និងសុខភាពសិក្សា។ ម៉ូឌុលបំណិនជីវិត ផ្តោតលើបញ្ញត្តិ និងទ្រឹស្តីអប់រំបំណិនជីវិត ក្នុងបរិបទប្រទេសកម្ពុជានិងសាកលលោក ព្រមទាំងវិធីសាស្ត្របង្រៀនដែលគាំទ្រការបណ្តុះបំណិនសតវត្សរ៍ទី២១ ឬបំណិនទន់ដល់សិស្សានុសិស្សនៅ អនុវិទ្យាល័យ។ ម៉ូឌុលអប់រំសុខភាព ផ្តោតលើចំណេះដឹងលើទម្លាប់ការរស់នៅប្រកបដោយសុខមាលភាព ការបង្ការនិងការពារពីជំងឺឆ្លង ផលប៉ះពាល់នៃគ្រឿងញៀន ការសង្គ្រោះបឋមនៅសាលារៀន ការអភិវឌ្ឍផ្លូវកាយនិង ចិត្តរបស់វ័យជំទង់ និងសុវត្ថិភាពសាលារៀន។ ម៉ូឌុលការប្រែប្រួលអាកាសធាតុផ្តោតលើទិដ្ឋភាពទូទៅ បុព្វហេតុ ផលប៉ះពាល់ និងវិធីដោះស្រាយការប្រែប្រួលអាកាសធាតុ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹង មានសមត្ថភាពបកស្រាយពីបញ្ញត្តិ និងទិដ្ឋភាពទូទៅនៃការអប់រំបំណិនជីវិត ការអប់រំសុខភាព និងការប្រែប្រួល អាកាសធាតុបានច្បាស់លាស់ ព្រមទាំងមានជំនាញដឹកនាំសកម្មភាពបង្រៀននិងរៀន ដែលផ្សារភ្ជាប់ចំណេះដឹង បំណិនជីវិតតាមមូលដ្ឋាន ការអប់រំសុខភាព និងការប្រែប្រួលអាកាសធាតុដល់ សិស្សានុសិស្សនៅ អនុវិទ្យាល័យ។

៤.១.១០. បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន I [៣ (២-២-៥)]

មុខវិជ្ជា បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀននិងរៀន I មានគោលបំណងផ្តល់ ឱ្យគរុនិស្សិតនូវចំណេះដឹង និងជំនាញក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងឧបករណ៍ បញ្ញាសិប្បនិម្មិត ដើម្បីជំរុញការរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារសំខាន់ៗ ដូចជា ១) ការរៀបចំផែនការបង្រៀន និងឯកសារបង្រៀននិងរៀនដោយប្រើប្រាស់បញ្ញាសិប្បនិម្មិត ២) ការ ធ្វើការបែបសហការលើប្រព័ន្ធអ៊ីនធឺណិត និង ៣) ការប្រើប្រាស់ឯកសារនានាដោយមិនរំលោភលើសិទ្ធិអ្នក និពន្ធដែលជាតម្រូវការចាំបាច់សម្រាប់គ្រូបង្រៀនសតវត្សរ៍ទី២១ និងភាពជាពលរដ្ឋឌីជីថល។ នៅពេលបញ្ចប់ មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងបញ្ញាសិប្បនិម្មិត ប្រកបដោយក្រមសីលធម៌ និងការទទួលខុសត្រូវក្នុងបរិបទអប់រំ និងឧត្តមានុវត្តន៍ ដើម្បីបង្កើនការចូលរួម សកម្មរបស់សិស្ស តាមរយៈការអនុវត្តជាក់ស្តែងក្នុងថ្នាក់រៀន។

៤.១.១១. បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន II [៣ (២-២-៥)]

មុខវិជ្ជា បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន II មានគោលបំណងផ្តល់ ឱ្យគរុនិស្សិតនូវចំណេះដឹង និងជំនាញក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ប្រកបដោយ ប្រសិទ្ធភាពក្នុងដំណើរការបង្រៀននិងរៀន។ មុខវិជ្ជានេះផ្តោតលើការបង្កើតឯកសារបង្រៀននិងរៀន ការគិតតាម

បែបកុំព្យូទ័រ ការស្រាវជ្រាវ និងការប្រើប្រាស់ឯកសារនានាដែលជាតម្រូវការពិសេសសម្រាប់គ្រូបង្រៀនក្នុងសតវត្សរ៍ទី២១ និងភាពជាពលរដ្ឋឌីជីថល។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដើម្បីបង្កើនការចូលរួមរបស់សិស្ស និងលើកកម្ពស់ការរៀនសកម្មតាមរយៈការធ្វើបទបង្ហាញ និងការអនុវត្តជាក់ស្តែងក្នុងថ្នាក់រៀន។

៤.១.១២. អប់រំសិល្បៈ [២ (១-២-៣)]

មុខវិជ្ជា អប់រំសិល្បៈមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវមូលដ្ឋានគ្រឹះ និងដំណើរការនៃការបង្រៀននិងរៀនសិល្បៈក្នុងទម្រង់ផ្សេងៗ រួមមានសិល្បៈតន្ត្រី សូនរូប របាំ និងទស្សនីយភាព សំដៅជំរុញភាពច្នៃប្រឌិត ការស្រមើលស្រមៃ និងការយល់ដឹងអំពីវប្បធម៌ក្នុងចំណោមសិស្ស។ មុខវិជ្ជានេះផ្តោតលើ សិល្បៈច្រើនទម្រង់ ដូចជា សិល្បៈតន្ត្រី របាំ សូនរូប ទស្សនីយភាព និងវិធីសាស្ត្របង្រៀនសិល្បៈ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពដឹកនាំការបង្រៀន អប់រំសិល្បៈក្នុងទម្រង់ផ្សេងៗប្រកបដោយភាពច្នៃប្រឌិត។

៤.២. ចំណេះដឹងលើមុខវិជ្ជាឯកទេស (៤៣ ក្រេឌីត)

៤.២.១. ឯកទេសអក្សរសាស្ត្រខ្មែរ

៤.២.១.១. ភាសាវិទ្យាទូទៅ [៣ (៣-០-៦)]

មុខវិជ្ជាភាសាវិទ្យាទូទៅមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងភាសាវិទ្យាទូទៅ និងការសិក្សាភាសាមានលក្ខណៈជាប្រព័ន្ធតាមបែបវិទ្យាសាស្ត្រ។ មុខវិជ្ជានេះផ្តោតលើ ប្រវត្តិ ទ្រឹស្តី មែកធាងភាសាវិទ្យា និងភាសាវិទ្យាអនុវត្តន៍។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគភាសា ដើម្បីដោះស្រាយបញ្ហានៅក្នុងសូរវិទ្យា-សទ្ទតាវិទ្យា វចនវិទ្យា សម្ព័ន្ធវិទ្យា ន័យវិទ្យា និងបម្រែបម្រួលភាសា។

៤.២.១.២. សូរវិទ្យា និងសទ្ទតាវិទ្យា [៣ (៣-០-៦)]

មុខវិជ្ជាសូរវិទ្យា និងសទ្ទតាវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋាននៃការសិក្សាប្រព័ន្ធសូរនៃភាសាតាមលក្ខណៈវិទ្យាសាស្ត្រ។ មុខវិជ្ជានេះផ្តោតលើ សូរវិទ្យាបន្លឺ សូរវិទ្យាអាគូស្ទីក សូរវិទ្យាឮ ការវិភាគប្រព័ន្ធសូរនៃភាសាខ្មែរ ការប្រើប្រាស់អក្ខរក្រមសូរវិទ្យាអន្តរជាតិ (API) ការញែកពីភាពខុសគ្នារវាងសូរ និងសទ្ទតា ព្យាង្គ និងការយល់ដឹងពីតួនាទីប្រព័ន្ធសូរក្នុងការសិក្សាភាសាខ្មែរ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់របៀបពិពណ៌នាការបង្កើតសូរ ការធ្វើចំណាត់ថ្នាក់សូរ និងកត់ត្រាសូរភាសាខ្មែរដោយប្រើអក្ខរក្រមសូរវិទ្យាអន្តរជាតិ (API)។

៤.២.១.៣. វចនវិទ្យា [៣ (៣-០-៦)]

មុខវិជ្ជាវចនវិទ្យាមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានគ្រឹះក្នុងការសិក្សា និងការប្រើប្រាស់ពាក្យ។ មុខវិជ្ជានេះផ្តោតលើសញ្ញាណទូទៅនៃវចនវិទ្យា ការបង្កើតពាក្យ ដើមកំណើតពាក្យ ទម្រង់ពាក្យ សទិសសព្ទ វេរចនសព្ទ បដិសព្ទ ការប្រើប្រាស់ពាក្យក្នុងភាសា និងទំនាក់ទំនងរវាងវចនវិទ្យា និងមែកធាងភាសាវិទ្យា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគ និងប្រើប្រាស់វចនវិទ្យាតាមរយៈ ការរួមបញ្ចូលទ្រឹស្តីនិងការអនុវត្តក្នុងវាក្យសព្ទខ្មែរ។

៤.២.១.៤. ន័យវិទ្យា [៣ (៣-០-៦)]

មុខវិជ្ជា ន័យវិទ្យាមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋាននៃការសិក្សាទ្រឹស្តីន័យវិទ្យា និងសិក្សាន័យភាសារបស់មនុស្ស។ មុខវិជ្ជានេះផ្តោតលើ ន័យវិទ្យា ន័យវចនៈ ទិដ្ឋភាពនៃន័យវិទ្យាក្នុងភាសា

របៀបវិភាគអត្ថន័យទៅតាមទិដ្ឋភាពន័យនៃភាសារួមមាន ពាក្យ ឃ្លា ប្រយោគ និងអត្ថបទជាដើម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគន័យនៃភាសាតាមបរិបទនៃការប្រើប្រាស់ ដោយផ្អែកលើទ្រឹស្តីន័យវិទ្យា។

៤.២.១.៥. សម្ព័ន្ធវិទ្យា [៣ (៣-០-៦)]

មុខវិជ្ជាសម្ព័ន្ធវិទ្យាមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋាននៃការបង្កើតកន្សោមពាក្យ ឃ្លា ល្បះបានត្រឹមត្រូវតាមក្បួនខ្នាតភាសា។ មុខវិជ្ជានេះផ្តោតលើសម្ព័ន្ធនិងមុខងារពាក្យ ការបង្កើតកន្សោមពាក្យ ល្បះ ប្រភេទល្បះ បែបនៃល្បះ ការតាងល្បះ វណ្ណយុត្ត (មួយចំនួន) និងវណ្ណវាទ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្កើតល្បះ វិភាគ និងកែសម្រួលល្បះបានត្រឹមត្រូវ។

៤.២.១.៦. វេយ្យាករណ៍ខ្មែរ [៣ (៣-០-៦)]

មុខវិជ្ជា វេយ្យាករណ៍ខ្មែរ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋាននៃការសិក្សាស៊ីជម្រៅអំពីទ្រឹស្តីទូទៅនៃវេយ្យាករណ៍ និងក្បួនភាសាខ្មែរ។ មុខវិជ្ជានេះផ្តោតលើ ការវិភាគពីទម្លាប់វាចា ក្បួននៃការប្រើប្រាស់ភាសាខ្មែរដូចជា ព្យញ្ជនៈ ស្រៈ វណ្ណយុត្ត ព្យាង្គ ពាក្យ កន្សោមពាក្យ ឃ្លា ល្បះ កថាខណ្ឌ អត្ថបទ និងលក្ខណៈពិសេសនៃភាសាខ្មែរ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគនិងប្រើប្រាស់វចនានុក្រមខ្មែរ ពាក្យ ប្រយោគ បានត្រឹមត្រូវ តាមក្បួនច្បាប់ភាសា។

៤.២.១.៧. វិជ្ជាតែងនិពន្ធ I [២ (២-០-៤)]

មុខវិជ្ជាវិជ្ជាតែងនិពន្ធ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានទាក់ទងនឹងរបៀបនិងវិធីសាស្ត្រសរសេរតាក់តែងអត្ថបទគ្រប់ទម្រង់។ មុខវិជ្ជានេះផ្តោតលើ ខ្លឹមសារសំខាន់ៗដូចជា លក្ខណៈទូទៅនៃការនិពន្ធ វិធីសាស្ត្រនៃការតែងនិពន្ធ រួមមានតាក់តែងលិខិតរដ្ឋបាលទៅតាមទម្រង់ផ្សេងៗ ការតែងកំណាព្យនិងកម្រងកែវជាដើម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពតាក់តែងនិពន្ធស្នាដៃគាំទ្រដល់ការបង្រៀនភាសាខ្មែរ។

៤.២.១.៨. បរមាធិប្បាយ [៣ (៣-០-៦)]

មុខវិជ្ជាបរមាធិប្បាយ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនមូលដ្ឋានក្នុងការសរសេរបទអត្ថាធិប្បាយ សំណេរតែងសេចក្តី សំណេរបែបវិទ្យាសាស្ត្រដើម្បីជួយពង្រីកការគិតរបស់ខ្លួនឱ្យកាន់តែមានគំនិតទូលំទូលាយ។ មុខវិជ្ជានេះផ្តោតលើវិធីសាស្ត្របង្កើតប្រធានបទ លក្ខណៈ ប្រភេទ និងរបៀបតាក់តែងបរមាធិប្បាយ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពសរសេរតែងសេចក្តីនិងបទអត្ថាធិប្បាយផ្សេងៗត្រូវតាមក្បួនខ្នាតវេយ្យាករណ៍ដើម្បីពង្រឹងដល់ការបង្រៀន ពង្រីកចំណេះដឹង និងបំណិនបន្ថែមលើមុខជំនាញផ្សេងៗ។

៤.២.១.៩. វិជ្ជាតែងនិពន្ធ II [២ (២-០-៤)]

មុខវិជ្ជា វិជ្ជាតែងនិពន្ធ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងទាក់ទងនឹងវិធីសាស្ត្រក្នុងការតាក់តែងនិពន្ធស្នាដៃអក្សរសិល្ប៍គ្រប់ទម្រង់។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារសំខាន់ៗដូចជា លក្ខណៈនិងគោលបំណងអ្នកនិពន្ធ ទម្រង់នៃការតែងនិពន្ធរឿងខ្លី អត្ថបទល្ខោន ប្រលោមលោក រចនាសម្ព័ន្ធ នៃការសរសេររឿង របៀបនៃការតាក់តែងរឿងជាដើម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពតែងនិពន្ធស្នាដៃអក្សរសិល្ប៍ផ្សេងៗទៅតាមតម្រូវការជាក់ស្តែងក្នុងការបង្រៀនភាសាខ្មែរ។

៤.២.១.១០. ប្រវត្តិអក្សរសិល្ប៍ខ្មែរ [៣ (៣-០-៦)]

មុខវិជ្ជា ប្រវត្តិអក្សរសិល្ប៍ខ្មែរមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានអំពីការវិវត្ត អក្សរសិល្ប៍ខ្មែរតាមសម័យកាលប្រវត្តិសាស្ត្រ។ មុខវិជ្ជានេះផ្តោតលើ ដំណើរវិវត្តគោលគំនិតរបស់អ្នកនិពន្ធ និង ស្នាដៃអក្សរសិល្ប៍ខ្មែរតាមប្រវត្តិសាស្ត្រខ្មែររួមមាន សម័យនគរភ្នំ សម័យចេនឡា សម័យអង្គរ សម័យលង្វែក សម័យឧដុង្គ សម័យអាណានិគមបារាំង និងសម័យទំនើប។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹង មានសមត្ថភាពវិភាគពីការវិវត្តស្នាដៃអក្សរសិល្ប៍ ប្រភពនៃស្នាដៃអក្សរសិល្ប៍ និងខ្លឹមសារគោលនៃអត្ថបទ រឿងនីមួយៗ។

៤.២.១.១១. ទ្រឹស្តីអក្សរសិល្ប៍ I [៣ (៣-០-៦)]

មុខវិជ្ជាទ្រឹស្តីអក្សរសិល្ប៍ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានអំពីទិដ្ឋភាពទូទៅ និងទ្រឹស្តីផ្សេងៗនៃអក្សរសិល្ប៍។ មុខវិជ្ជានេះផ្តោតលើសញ្ញាណទូទៅនៃអក្សរសិល្ប៍រួមមានការកិច្ច ការវិវត្តនៃទ្រឹស្តី លក្ខណៈ ប្រភព ប្រភេទ កម្មវត្ថុ គំរូលោកីយ៍សច្ចៈ សោភ័ណអក្សរសិល្ប៍ជាដើម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សា នេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់ទ្រឹស្តីអក្សរសិល្ប៍ឆ្លុះបញ្ចាំងស្នាដៃអក្សរសិល្ប៍ដើម្បីផ្តល់ទស្សនទាន ដល់ការសិក្សា។

៤.២.១.១២. អក្សរសិល្ប៍ប្រជាប្រិយ [៣ (៣-០-៦)]

មុខវិជ្ជា អក្សរសិល្ប៍ប្រជាប្រិយ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋាននៃការសិក្សា អក្សរសិល្ប៍ប្រជាប្រិយដើម្បីរកឱ្យឃើញតម្លៃអត្តសញ្ញាណជាតិ និងវប្បធម៌ប្រជាប្រិយ។ មុខវិជ្ជានេះផ្តោតលើ និយមន័យ គោលបំណង ប្រភព ប្រភេទអក្សរសិល្ប៍ប្រជាប្រិយរួមមាន ដំណាលកថា ពាក្យចួន និងរបាំ ប្រជាប្រិយ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់ខ្លឹមសារ និងឧត្តមគតិនៃ អក្សរសិល្ប៍ប្រជាប្រិយក្នុងការបង្រៀនមុខវិជ្ជាភាសាខ្មែរ។

៤.២.១.១៣. ទ្រឹស្តីអក្សរសិល្ប៍ II [៣ (៣-០-៦)]

មុខវិជ្ជា ទ្រឹស្តីអក្សរសិល្ប៍ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានទ្រឹស្តីទូទៅនៃ អក្សរសិល្ប៍ដើម្បីវិភាគស្នាដៃអក្សរសិល្ប៍។ មុខវិជ្ជានេះផ្តោតលើការសិក្សាអំពីទិដ្ឋភាពទូទៅនៃស្នាដៃនីមួយៗ ការកំណត់ពីលក្ខណៈអក្សរសិល្ប៍ រូបារម្មណ៍អក្សរសិល្ប៍ តួយ៉ាងនីយកម្មសិល្បៈ និងចលនាអក្សរសិល្ប៍។ នៅ ពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពក្នុងការប្រើប្រាស់ទ្រឹស្តីអក្សរសិល្ប៍សម្រាប់ការបង្រៀន និងរៀននៅកម្រិតអនុវិទ្យាល័យ។

៤.២.១.១៤. ការវិភាគស្នាដៃអក្សរសិល្ប៍ [៣ (៣-០-៦)]

មុខវិជ្ជា ការវិភាគស្នាដៃអក្សរសិល្ប៍មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានអំពីការវិភាគ ស្នាដៃអក្សរសិល្ប៍។ មុខវិជ្ជានេះផ្តោតលើការវិភាគ និងរិះគន់ទិដ្ឋភាពទូទៅនៃស្នាដៃអក្សរសិល្ប៍នីមួយៗ។ នៅពេល បញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគ និងរិះគន់ទិដ្ឋភាពទូទៅនៃស្នាដៃអក្សរសិល្ប៍នីមួយៗ។

៤.២.១.១៥. អក្សរសិល្ប៍បរទេស [៣ (៣-០-៦)]

មុខវិជ្ជា អក្សរសិល្ប៍បរទេសមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីការវិវត្តនៃទស្សនវិជ្ជា និងឥទ្ធិពលអក្សរសិល្ប៍បរទេសមួយចំនួនក្នុងតំបន់ និងក្នុងសាកលលោក។ មុខវិជ្ជានេះផ្តោតលើការសិក្សាអំពី

ទិដ្ឋភាពទូទៅនៃស្នាដៃអក្សរសិល្ប៍បរទេសទាក់ទងនឹងការវិវត្តនៃសង្គម ចរន្តអក្សរសិល្ប៍ និន្នាការ និងតថភាពសង្គមនៅក្នុងអក្សរសិល្ប៍បរទេស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគ និងឆ្លុះបញ្ចាំងបរិបទសង្គម វប្បធម៌ អរិយធម៌បរទេស និងការតែងនិពន្ធស្នាដៃជាតិសាសន៍ដទៃ ដើម្បីជាមូលដ្ឋានក្នុងការប្រៀបធៀបអក្សរសិល្ប៍។

៤.២.២. ឯកទេសគណិតវិទ្យា

៤.២.២.១. មូលដ្ឋានគ្រឹះគណិតវិទ្យាមធ្យមសិក្សាបឋមភូមិ I [៣ (៣-០-៦)]

មុខវិជ្ជា មូលដ្ឋានគ្រឹះគណិតវិទ្យាមធ្យមសិក្សាបឋមភូមិ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងគណិតវិទ្យាលើផ្នែក ចំនួន រង្វាស់រង្វាល់ និងពីជគណិត។ មុខវិជ្ជានេះផ្តោតលើ ចំនួនគត់ ចំនួនគត់រ៉ឹឡាទីប ចំនួនសនិទាន ចំនួនអសនិទាន ចំនួនពិត រង្វាស់រង្វាល់ កន្សោមពីជគណិត សមីការ និងវិសមីការដឺក្រេទី១និងដឺក្រេទី២មានមួយអញ្ញាត អនុគមន៍ពីជគណិត និងអនុគមន៍ត្រីកោណមាត្រ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយទៅលើបញ្ញត្តិខាងលើ ដើម្បីដោះស្រាយបញ្ហាក្នុងវិជ្ជាជីវៈបង្រៀន និងជីវភាពប្រចាំថ្ងៃ។

៤.២.២.២. មូលដ្ឋានគ្រឹះគណិតវិទ្យាមធ្យមសិក្សាបឋមភូមិ II [៣ (៣-០-៦)]

មុខវិជ្ជា មូលដ្ឋានគ្រឹះគណិតវិទ្យាមធ្យមសិក្សាបឋមភូមិ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងផ្នែកធរណីមាត្រ។ មុខវិជ្ជានេះផ្តោតលើ សញ្ញាណដំបូងនៃរូបធរណីមាត្រ រូបធរណីមាត្រដែលមានវិមាត្រពីរ និងរូបធរណីមាត្រដែលមានវិមាត្របី។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយទៅលើបញ្ញត្តិខាងលើ និងអនុវត្តក្នុងការដោះស្រាយបញ្ហាក្នុងវិជ្ជាជីវៈបង្រៀន និងជីវភាពប្រចាំថ្ងៃ។

៤.២.២.៣. ពីជគណិតទូទៅ I [២ (២-០-៤)]

មុខវិជ្ជាពីជគណិតទូទៅ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើពីជគណិតអរូបី។ មុខវិជ្ជានេះផ្តោតលើ តក្កវិទ្យា សម្រាយបញ្ជាក់ក្នុងគណិតវិទ្យា សំណុំ ទំនាក់ទំនងទ្វេធាតុ អនុគមន៍ អនុវត្តន៍ទំនាក់ទំនងសមមូល និងទំនាក់ទំនងលំដាប់។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពគិតតាមបែបតក្កវិទ្យា ដែលទាក់ទងនឹងខ្លឹមសារមេរៀនខាងលើ និងការអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

៤.២.២.៤. ពីជគណិតទូទៅ II [២ (២-០-៤)]

មុខវិជ្ជាពីជគណិតទូទៅ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើទម្រង់សំខាន់ៗនៃពីជគណិតអរូបី។ មុខវិជ្ជានេះផ្តោតលើ ប្រមាណវិធីក្នុង ប្រមាណវិធីក្រៅ ក្រុម កង កាយ និងកងពហុធា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពអនុវត្ត និងវិភាគទម្រង់នៃសំណុំចំពោះប្រមាណវិធីក្នុងនិងប្រមាណវិធីក្រៅដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងពីជគណិតអរូបីដូចជា ក្រុម កង កាយ និងកងពហុធា បានត្រឹមត្រូវ និងមានហេតុផល។

៤.២.២.៥. គណិតគណនា I [២ (២-០-៤)]

មុខវិជ្ជា គណិតគណនា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការគណនា ការដោះស្រាយបញ្ហា ការបកស្រាយ និងការអនុវត្តក្នុងវិស័យនានា។ មុខវិជ្ជានេះផ្តោតលើចំណេះដឹង និងការអនុវត្តគោលការណ៍គណិតវិទ្យាសំខាន់ៗដូចជា អនុគមន៍ ស្នឹតនិងស៊េរី លីមីតនិងដេរីវេ ដែលជាគ្រឹះសម្រាប់

ការសិក្សាគណិតវិទ្យាកម្រិតខ្ពស់ និងមុខវិជ្ជាពាក់ព័ន្ធផ្សេងៗ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយខ្លឹមសារខាងលើបានត្រឹមត្រូវ និងមានហេតុផលច្បាស់លាស់។ លើសពីនេះ គរុនិស្សិតក៏មានសមត្ថភាពប្រើប្រាស់គោលការណ៍គណិតគណនាទាំងនេះក្នុងការដោះស្រាយបញ្ហា និងអនុវត្តនៅក្នុងមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ និងវិស័យផ្សេងៗ ប្រកបដោយភាពជឿជាក់។

៤.២.២.៦. គណិតគណនា II [៣ (៣-០-៦)]

មុខវិជ្ជា គណិតគណនា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនអំពីការគណនា អាំងតេក្រាល និងសមីការឌីផេរ៉ង់ស្យែលដែលបន្តពីគណិតគណនា I ។ មុខវិជ្ជានេះផ្តោតលើអាំងតេក្រាលនិងការអនុវត្តនិវិធីសាស្ត្រគណនាអាំងតេក្រាលនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល អនុគមន៍ឡូការីត អនុគមន៍ត្រីកោណមាត្រ អនុគមន៍អ៊ីពែបូលនិងអនុគមន៍ច្រាស និងការដោះស្រាយសមីការឌីផេរ៉ង់ស្យែល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយខ្លឹមសារខាងលើបានត្រឹមត្រូវ និងមានហេតុផលច្បាស់លាស់។ លើសពីនេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់គោលការណ៍អាំងតេក្រាល និងសមីការឌីផេរ៉ង់ស្យែល ក្នុងការអនុវត្តនៅក្នុងមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ និងវិស័យផ្សេងៗប្រកបដោយទំនុកចិត្ត។

៤.២.២.៧. គណិតគណនា III [៣ (៣-០-៦)]

មុខវិជ្ជាគណិតគណនា III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងក្នុងការវិភាគលើគណិតគណនា។ មុខវិជ្ជានេះផ្តោតលើ ការប្រៀបធៀបអនុគមន៍ពន្លាតកំណត់ ស៊េរីស្វ័យគុណ អាំងតេក្រាល Improper អនុគមន៍ច្រើនអថេរ និងដេរីវេដោយផ្នែកនិងពហុអាំងតេក្រាល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយ និងវិភាគខ្លឹមសារខាងលើដោយមានហេតុផលច្បាស់លាស់ក្នុងការគណនា វិភាគ និងអនុវត្តក្នុងវិស័យផ្សេងៗប្រកបដោយទំនុកចិត្តនិងសិក្សាស្រាវជ្រាវលើជំនាញឯកទេសបន្ត។

៤.២.២.៨. ពីជគណិតលីនេអ៊ែរ I [២ (២-០-៤)]

មុខវិជ្ជា ពីជគណិតលីនេអ៊ែរ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើពីជគណិតលីនេអ៊ែរ។ មុខវិជ្ជានេះផ្តោតលើ ម៉ាទ្រីសនិងពីជគណិតនៃម៉ាទ្រីស ដេទែមីណង់ ប្រព័ន្ធសមីការលីនេអ៊ែរ និងអនុវត្តលីនេអ៊ែរនិងម៉ាទ្រីស លំហវ៉ិចទ័រទូទៅ គោលនិងវិមាត្រនៃលំហវ៉ិចទ័រ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព គណនា បកស្រាយ វិភាគ អនុវត្តខ្លឹមសារដែលទាក់ទងនឹងពីជគណិតលីនេអ៊ែរខាងលើដោយមានហេតុផលច្បាស់លាស់សម្រាប់អនុវត្តក្នុងមុខវិជ្ជាផ្សេងៗ និងប្រើប្រាស់សម្រាប់ការសិក្សាស្រាវជ្រាវលើជំនាញឯកទេសបន្ត។

៤.២.២.៩. ពីជគណិតលីនេអ៊ែរ II [២ (២-០-៤)]

មុខវិជ្ជា ពីជគណិតលីនេអ៊ែរ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើពីជគណិតលីនេអ៊ែរ។ មុខវិជ្ជានេះផ្តោតលើ ការបំលែងលីនេអ៊ែរ Eigenvalues និង Eigenvectors អង្កត់ទ្រូងកម្ម លំហផលគុណក្នុង អនុគមន៍លីនេអ៊ែរ Gram-Schmidt Process, QR-Decomposition និងលំហឧយអាល់។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព គណនា បកស្រាយ វិភាគ អនុវត្តខ្លឹមសារដែលទាក់ទងនឹងពីជគណិតលីនេអ៊ែរខាងលើដោយមានហេតុផលច្បាស់លាស់សម្រាប់អនុវត្តក្នុងមុខវិជ្ជាផ្សេងៗ និងប្រើប្រាស់សម្រាប់ការសិក្សាស្រាវជ្រាវលើជំនាញឯកទេសបន្ត។

៤.២.២.១០. ធរណីមាត្រវិភាគ [៣ (៣-០-៦)]

មុខវិជ្ជា ធរណីមាត្រវិភាគ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនអំពីធរណីមាត្រវិភាគ។ មុខវិជ្ជានេះផ្តោតលើ វិចទ័រក្នុងប្លង់ ផលគុណស្កាលែក្នុងប្លង់ តម្រុយដេកាតក្នុងប្លង់ ប្រព័ន្ធកូអរដោនេប៉ូលែ បំលែងរូបក្នុងប្លង់ សមីការនៃខ្សែកោងក្នុងប្លង់ សមីការប៉ារ៉ាម៉ែត្រខ្សែកោង សមីការក្នុងប្រព័ន្ធកូអរដោនេប៉ូលែ ខ្សែកោងដឺក្រេទី១ ខ្សែកោងដឺក្រេទី២ បង្រួមនៃសមីការខ្សែកោងដឺក្រេទី២ វិចទ័រក្នុងលំហ បារីសង់ ផលគុណស្កាលែ ផលគុណវិចទ័រ ផលគុណចម្រុះ ផ្ទៃដឺក្រេទី១ ផ្ទៃដឺក្រេទី២ និងប្រព័ន្ធកូអរដោនេស៊ីឡាំង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព គណនា បកស្រាយ វិភាគ និងអនុវត្តខ្លឹមសារមេរៀននីមួយៗខាងលើដោយមានហេតុផលច្បាស់លាស់សម្រាប់អនុវត្តក្នុងមុខវិជ្ជាផ្សេងៗ ដើម្បីជាគ្រឹះដ៏រឹងមាំសម្រាប់ជួយដល់ការសិក្សាស្រាវជ្រាវបន្តលើជំនាញឯកទេស។

៤.២.២.១១. ប្រូបាប៊ីលីតេ និងស្ថិតិ I [៣ (៣-០-៦)]

មុខវិជ្ជា ប្រូបាប៊ីលីតេ និងស្ថិតិ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានគ្រឹះអំពីស្ថិតិវិបបពិពណ៌នា ប្រូបាប៊ីលីតេ និងរបាយប្រូបាប៊ីលីតេ។ មុខវិជ្ជានេះផ្តោតលើ ការប្រមូលទិន្នន័យ ការរៀបចំទិន្នន័យ ការបង្ហាញទិន្នន័យ ការបកស្រាយទិន្នន័យ គោលការណ៍របាប់តាមចម្លាស់បន្សំ សញ្ញាណប្រូបាបលីតេនៃព្រឹត្តិការណ៍ចៃដន្យ ប្រូបាប៊ីលីតេមានលក្ខខណ្ឌ អថេរចៃដន្យដាច់ អថេរចៃដន្យជាប់ និងរបាយនៃលំហគំរូចៃដន្យ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយស្ថិតិវិបបពិពណ៌នា និងប្រូបាប៊ីលីតេ និងបំណិនក្នុងការប្រមូល រៀបចំ វិភាគ និងបកស្រាយទិន្នន័យដោយប្រើប្រាស់បច្ចេកវិទ្យា។

៤.២.២.១២. ប្រូបាប៊ីលីតេ និងស្ថិតិ II [៣ (៣-០-៦)]

មុខវិជ្ជា ប្រូបាប៊ីលីតេ និងស្ថិតិ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងបន្ថែមលើមុខវិជ្ជាប្រូបាប៊ីលីតេ និងស្ថិតិច្រើនអថេរ។ មុខវិជ្ជានេះផ្តោតលើ របាយអថេរចៃដន្យរួម ផលបូកអថេរចៃដន្យដែលមិនជាប់ទាក់ទងគ្នា អនុគមន៍នៃអថេរចៃដន្យ អនុគមន៍បង្កើតម៉ូម៉ង់ ចន្លោះជឿជាក់នៃលំហគំរូទោលនិងទ្វេ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពគណនា វិភាគ និងបកស្រាយទិន្នន័យច្រើនអថេរដែលស្ថិតក្នុងរបាយផ្សេងដោយប្រើប្រាស់បច្ចេកវិទ្យា និងដោះស្រាយបញ្ហាជាក់ស្តែងក្នុងជីវភាពប្រចាំថ្ងៃប្រកបដោយទំនុកចិត្ត។

៤.២.២.១៣. ប្រូបាប៊ីលីតេ និងស្ថិតិ III [៣ (៣-០-៦)]

មុខវិជ្ជា ប្រូបាប៊ីលីតេ និងស្ថិតិIII មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងបន្ថែមឱ្យកាន់តែស៊ីជម្រៅលើការអនុវត្តស្ថិតិវិភាគ។ មុខវិជ្ជានេះផ្តោតលើ ប៉ារ៉ាមែត្រ និងចន្លោះជឿជាក់ តេស្តសម្មតិកម្មទោលនិងទ្វេ តេស្តទាក់ទងនឹងមធ្យមករណីដែលស្គាល់វ៉ារ្យង់និងមិនស្គាល់វ៉ារ្យង់ ទំនាក់ទំនងលីនេអ៊ែរមួយអថេរ រង្វាស់ទំនាក់ទំនង ANOVA ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់ចំណេះដឹងទាំងនេះក្នុងការគណនា ធ្វើតេស្តសម្មតិកម្ម វិភាគ បកស្រាយទិន្នន័យនៅក្នុងការស្រាវជ្រាវ ដោយប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការគណនា និងដោះស្រាយបញ្ហាជាក់ស្តែងក្នុងជីវភាពប្រចាំថ្ងៃ ប្រកបដោយទំនុកចិត្ត។

៤.២.២.១៤. វិភាគទូទៅ I [៣ (៣-០-៦)]

មុខវិជ្ជា វិភាគទូទៅ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើមូលដ្ឋានគ្រឹះបន្ថែមទៅលើការវិភាគទូទៅ។ មុខវិជ្ជានេះផ្តោតលើ គំនិតមូលដ្ឋានលើការវិភាគរួមមាន តូប៉ូវិទ្យា ភាពជាប់

ភាពមានឌីផេរ៉ង់ស្យែល អាំងតេក្រាលលើខ្សែកោង និងអាំងតេក្រាលលើផ្ទៃ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព គណនា បកស្រាយ និងវិភាគខ្លឹមសារមេរៀននីមួយៗតាមរយៈការវែកញែកដោយមានហេតុផលច្បាស់លាស់ ហើយចំណេះដឹងទាំងនេះជាគ្រឹះដ៏រឹងមាំសម្រាប់ជួយដល់ការសិក្សាស្រាវជ្រាវបន្តលើមុខវិជ្ជាឯកទេស។

៤.២.២.១៥. វិភាគទូទៅ II [៣ (៣-០-៦)]

មុខវិជ្ជា វិភាគទូទៅ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនបន្ថែមទៀតលើការវិភាគ។ មុខវិជ្ជានេះផ្តោតលើ អនុគមន៍អថេរកុំផ្លិច ស្វ៊ីតនិងស៊េរីអថេរកុំផ្លិច អនុគមន៍វិភាគ អនុគមន៍ Holomorphic អាំងតេក្រាលអនុគមន៍កុំផ្លិច ស៊េរីអនុគមន៍វិភាគ និង Singularity និងទ្រឹស្តីបទរីស៊ីឌុយ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព គណនា បកស្រាយ និងវិភាគខ្លឹមសារមេរៀននីមួយៗតាមរយៈការវែកញែកដោយមានហេតុផលច្បាស់លាស់ ដើម្បីជាគ្រឹះដ៏រឹងមាំសម្រាប់ជួយដល់ការសិក្សាស្រាវជ្រាវបន្តលើជំនាញឯកទេស។

៤.២.២.១៦. គណនាឌីផេរ៉ង់ស្យែល [៣ (៣-០-៦)]

មុខវិជ្ជាគណនាឌីផេរ៉ង់ស្យែល មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីទ្រឹស្តីនៃការវិភាគគណនា ការដោះស្រាយសមីការឌីផេរ៉ង់ស្យែល និងការស្រាយបញ្ជាក់រូបមន្តសំខាន់ៗនៃឌីផេរ៉ង់ស្យែលក្នុងលំហ Banach។ មុខវិជ្ជានេះផ្តោតលើ ការដោះស្រាយសមីការឌីផេរ៉ង់ស្យែលលើលំហណម អនុវត្តន៍មានឌីផេរ៉ង់ស្យែល ទ្រឹស្តីបទកំណើនមានកំណត់ ទ្រឹស្តីបទចម្រាស អនុគមន៍អាំភ្លីស៊ីត ដេរីវេលំដាប់ខ្ពស់ ទម្រង់ឌីផេរ៉ង់ស្យែល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព គណនា បកស្រាយ និងវិភាគខ្លឹមសារមេរៀននីមួយៗតាមរយៈការវែកញែកដោយមានហេតុផលច្បាស់លាស់ ដើម្បីជាគ្រឹះដ៏រឹងមាំសម្រាប់ជួយដល់ការសិក្សាស្រាវជ្រាវបន្តលើមុខវិជ្ជាឯកទេស។

៤.២.៣. ឯកទេសវិទ្យាសាស្ត្រ

៤.២.៣.១. មុខវិជ្ជាសម្រាប់វិទ្យាសាស្ត្រទូទៅ

៤.២.៣.១.១. វិទ្យាសាស្ត្រទូទៅរូបវិទ្យា I [២ (២-០-៤)]

មុខវិជ្ជាវិទ្យាសាស្ត្រទូទៅរូបវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើបញ្ញត្តិបាតុភូតរូបវិទ្យានិងការពិសោធន៍វិទ្យាសាស្ត្រតាមរយៈការសិក្សាលើទ្រឹស្តីសំខាន់ៗដែលពណ៌នាពីលក្ខណៈរូបនៃរូបធាតុ និងបាតុភូតរូបវិទ្យាជុំវិញខ្លួន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារ ការរីកនៃអង្គធាតុ បរិមាណកម្តៅ បន្ទុកអគ្គិសនី តង់ស្យុង និងរេស៊ីស្តង់ ព្រមទាំងគោលការណ៍គ្រឹះនៃសម្ពាធក្នុងអង្គធាតុរឹង សន្ទនីយ និងសម្ពាធបរិយាកាស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយពីបញ្ញត្តិ បាតុភូត និងទ្រឹស្តីនៃខ្លឹមសារមេរៀននីមួយៗបានយ៉ាងច្បាស់លាស់ ដើម្បីយកទៅអនុវត្តក្នុងការបង្រៀន និងដោះស្រាយបញ្ហាក្នុងជីវភាពរស់នៅ។

៤.២.៣.១.២. វិទ្យាសាស្ត្រទូទៅគីមីវិទ្យា I [២ (២-០-៤)]

មុខវិជ្ជា វិទ្យាសាស្ត្រទូទៅគីមីវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងជាមូលដ្ឋានអំពីបញ្ញាត្តិគីមីវិទ្យា និងបំណិនមន្ទីរពិសោធន៍ដែលចាំបាច់សម្រាប់ការសិក្សាវិទ្យាសាស្ត្រ។ មុខវិជ្ជានេះផ្តោតលើបច្ចេកទេសវាស់វែង តួលេខជាក់លាក់ ការចាត់ថ្នាក់រូបធាតុ ធាតុគីមី តារាងខួបនៃធាតុគីមី និង វិធីសាស្ត្រវែកញែក

ល្បាយ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយបញ្ហាត្តិ មូលដ្ឋានអំពីរូបធាតុ ធ្វើពិសោធន៍ប្រកបដោយសុវត្ថិភាព បច្ចេកទេសសមស្រប និងការវាស់វែងត្រឹមត្រូវ។

៤.២.៣.១.៣. វិទ្យាសាស្ត្រទូទៅជីវិទ្យា I [២ (២-០-៤)]

មុខវិជ្ជា វិទ្យាសាស្ត្រទូទៅជីវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីការសិក្សាវិទ្យាសាស្ត្រ រចនាសម្ព័ន្ធរូបផ្ទុំ និងអន្តរកម្មនៃសារពាង្គកាយមានជីវិត។ មុខវិជ្ជានេះផ្តោតលើ ការសិក្សាវិទ្យាសាស្ត្រ មូលដ្ឋានគ្រឹះនៃជីវិត នានាភាពនៃការៈរស់ អន្តរកម្មនិងការវិវត្តិរបស់ការៈរស់។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រទូទៅជីវិទ្យា I សម្រាប់ការបង្រៀននិងរៀន ការស្រាវជ្រាវ និងការអនុវត្តនៅក្នុងជីវភាពប្រចាំថ្ងៃ។

៤.២.៣.១.៤. វិទ្យាសាស្ត្រទូទៅផែនដីវិទ្យា I [២ (២-០-៤)]

មុខវិជ្ជា វិទ្យាសាស្ត្រទូទៅផែនដីវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងផ្នែកផែនដីនិងបរិស្ថានវិទ្យា សម្រាប់ជាជំនួយក្នុងការសិក្សាមុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យា និងមុខវិជ្ជាដែលពាក់ព័ន្ធផ្សេងទៀត។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាមូលដ្ឋានដូចជា មណ្ឌលសិលា មណ្ឌលទឹក មណ្ឌលបរិយាកាស មណ្ឌលជីវៈ និងបរិស្ថាន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់ចំណេះដឹងផ្នែកផែនដីនិងបរិស្ថានវិទ្យាក្នុងការអនុវត្តលើមុខវិជ្ជាឯកទេស និងការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ។

៤.២.៣.១.៥. គណិតវិទ្យាទូទៅសម្រាប់វិទ្យាសាស្ត្រ [៣ (៣-០-៦)]

មុខវិជ្ជា គណិតវិទ្យាទូទៅសម្រាប់វិទ្យាសាស្ត្រ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានគ្រឹះគណិតវិទ្យាសម្រាប់ការប្រើប្រាស់ក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ។ មុខវិជ្ជានេះផ្តោតលើ ការដោះស្រាយសមីការនិងវិសមីការ អនុគមន៍ លីមីតនៃអនុគមន៍ ដេរីវេនៃអនុគមន៍ អាំងតេក្រាល សមីការឌីផេរ៉ង់ស្យែល ធរណីមាត្រក្នុងលំហ ប្រូបាប៊ីលីតេ និងស្ថិតិ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់ចំណេះដឹងមូលដ្ឋានគ្រឹះគណិតវិទ្យាខាងលើក្នុងការអនុវត្តលើមុខវិជ្ជាឯកទេសរបស់ខ្លួន និងការស្រាវជ្រាវប្រកបដោយទំនុកចិត្ត។

៤.២.៣.១.៦. វិទ្យាសាស្ត្រទូទៅរូបវិទ្យា II [២ (២-០-៤)]

មុខវិជ្ជា វិទ្យាសាស្ត្រទូទៅរូបវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងគ្រឹះលើបាតុភូតក្នុងការកំណត់ទ្រឹស្តីផ្នែកមេកានិក ម៉ាញេទិក និងអុបទិក ព្រមទាំងពិសោធន៍វិទ្យាសាស្ត្រ ។ មុខវិជ្ជានេះផ្តោតលើការសិក្សាអំពី ល្បឿនខណៈនិងសំទុះ ទម្លាក់សេរី ច្បាប់ញូតុន កម្មន្ត ថាមពលស៊ីនេទិក អានុភាព ដែនម៉ាញេទិក ព្រមទាំងបាតុភូតអុបទិចដូចជា ដំណាលត្រង់នៃពន្លឺ ចំណាំងផ្លាត ចំណាំងបែរនៃពន្លឺ និងលក្ខណៈនៃឡង់ទី។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព បកស្រាយពីបាតុភូតក្នុងការកំណត់បញ្ញត្តិ និងទ្រឹស្តីនៃខ្លឹមសារមេរៀននីមួយៗបានយ៉ាងច្បាស់លាស់ និងប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហាក្នុងជីវភាពរស់នៅនិងបច្ចេកទេសបានច្បាស់លាស់។

៤.២.៣.១.៧. វិទ្យាសាស្ត្រទូទៅគីមីវិទ្យា II [២ (២-០-៤)]

មុខវិជ្ជា វិទ្យាសាស្ត្រទូទៅគីមីវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីគោលការណ៍គីមីជាមូលដ្ឋានតាមរយៈការសិក្សាអំពីគីមីវិទ្យាខ្យល់និងទឹក អាស៊ីតនិងបាស និងសេចក្តីណែនាំអំពីសមាសធាតុសរីរាង្គ។ មុខវិជ្ជានេះផ្តោតលើ សមាសធាតុក្នុងបរិយាកាសនិងសារធាតុបំពុល លក្ខណៈនៃទឹកនិងសូលុយស្យុង

លក្ខណៈគីមីនៃអុកស៊ីសែននិងអ៊ីដ្រូសែន និងទ្រឹស្តីអាស៊ីត-បាសសំខាន់ៗ។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពពន្យល់ពីដំណើរការប្រែប្រួលក្នុងបរិស្ថាននិងគីមីវិភាគប្រតិកម្មងាយៗ និងបកស្រាយបញ្ហាគីមីផ្សេងៗក្នុងបរិបទជីវិតពិតបានយ៉ាងច្បាស់លាស់។

៤.២.៣.១.៨. វិទ្យាសាស្ត្រទូទៅជីវិទ្យា II [២ (២-០-៤)]

មុខវិជ្ជា វិទ្យាសាស្ត្រទូទៅជីវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងបន្ថែមទៅលើវិទ្យាសាស្ត្រទូទៅជីវិទ្យា I ។ មុខវិជ្ជានេះផ្តោតលើ មូលដ្ឋានគ្រឹះនៃតម្រូវការរបស់សារពាង្គកាយ ប្រព័ន្ធសារពាង្គកាយ ជំងឺនិងការថែទាំសុខភាពរបស់រុក្ខជាតិ និងសត្វ។ នៅពេលបញ្ចប់នៃមុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រទូទៅជីវិទ្យា II ក្នុងការបង្រៀននិងរៀន ការអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ និងការថែទាំសុខភាព។

៤.២.៣.១.៩. វិទ្យាសាស្ត្រទូទៅផែនដីវិទ្យា II [២ (២-០-៤)]

មុខវិជ្ជាវិទ្យាសាស្ត្រទូទៅផែនដីវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីធាតុអាកាសកត្តាជះឥទ្ធិពលនិងបញ្ហាបរិស្ថាន ដើម្បីអភិវឌ្ឍជំនាញសង្កេត វាស់វែង និងស្មារតីការពារបរិស្ថាន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារដូចជា ធាតុអាកាស តំបន់អាកាសធាតុ ការប្រែប្រួលអាកាសធាតុ បញ្ហាការបំពុល និងការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសព្រៃលិចទឹកនៅកម្ពុជា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពពន្យល់ វិភាគ និងអនុវត្តចំណេះដឹងក្នុងការដោះស្រាយបញ្ហាបរិស្ថាន និងចូលរួមអភិរក្សបរិស្ថានបានយ៉ាងមានប្រសិទ្ធភាព។

៤.២.៣.២. ឯកទេសរូបវិទ្យា

៤.២.៣.២.១. ការអប់រំស្មែមក្នុងការបង្រៀនរូបវិទ្យា [២ (១-២-៣)]

មុខវិជ្ជា ការអប់រំស្មែមក្នុងការបង្រៀនរូបវិទ្យាមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានគ្រឹះលើផ្នែក ការអប់រំស្មែម ជំនាញរចនា និងរបៀបបង្រៀនតាមបែប STEM ភ្ជាប់ទៅនឹងខ្លឹមសារមេរៀនស្របតាមកម្មវិធីសិក្សា។ មុខវិជ្ជានេះផ្តោតលើ ការរួមបញ្ចូលមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា វិធីដោះស្រាយបញ្ហា និងការសិក្សាតាមបែបគម្រោង។ ក្រោយបញ្ចប់មុខវិជ្ជាសិក្សានេះគរុនិស្សិតនឹងមានសមត្ថភាពដោះស្រាយបញ្ហាក្នុងសហគមន៍ដោយប្រើប្រាស់ចំណេះដឹង STEM ប្រកបដោយប្រសិទ្ធិភាព។

៤.២.៣.២.២. មូលដ្ឋានគ្រឹះរូបវិទ្យា I [៣ (២-២-៥)]

មុខវិជ្ជា មូលដ្ឋានគ្រឹះរូបវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើទ្រឹស្តីសំខាន់ៗបាតុភូតធម្មជាតិ និងពិសោធន៍វិទ្យាសាស្ត្រ។ មុខវិជ្ជានេះផ្តោតលើ ការវាស់វែងស៊ីនេម៉ាទិច ទំនាក់ទំនងរវាងកម្លាំងនិងចលនា កម្មន្ត ថាមពល អានុភាព បរិមាណចលនា ម៉ាស៊ីនងាយ ព្រមទាំងគោលការណ៍គ្រឹះនៃទែម៉ូឌីណាមិច និងលក្ខណៈកម្តៅនៃរូបធាតុ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយបាតុភូត បញ្ញត្តិ និងទ្រឹស្តីនៃខ្លឹមសារមេរៀននីមួយៗបានយ៉ាងច្បាស់លាស់ ដើម្បីយកទៅអនុវត្តក្នុងវិជ្ជាជីវៈបង្រៀនឱ្យមានប្រសិទ្ធភាព។

៤.២.៣.២.៣. មូលដ្ឋានគ្រឹះរូបវិទ្យា II [៣ (២-២-៥)]

មុខវិជ្ជា មូលដ្ឋានគ្រឹះរូបវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងផ្នែកអេឡិចត្រូម៉ាញេទិចតាមរយៈការសិក្សាលើទ្រឹស្តីសំខាន់ៗដែលពណ៌នាពីអន្តរកម្មរវាងបន្ទុក និងដែនក្នុងលំហ។ មុខវិជ្ជានេះផ្តោតលើបន្ទុកនិងដែនអគ្គិសនី ច្បាប់ហ្គោស ប៉ូតង់ស្យែល កុងដង់សាទ័រ ចរន្តអគ្គិសនីនិងរេស៊ីស្តង់ ដែនម៉ាញេទិច

អាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច ព្រមទាំងគោលការណ៍ដំណើរការរបស់បូប៊ីន ត្រង់ស្ទ័ និងសៀគ្វី RLC។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយពីបញ្ញត្តិ បាតុភូត និងទ្រឹស្តីនៃខ្លឹមសារមេរៀននីមួយៗបានយ៉ាងច្បាស់លាស់ ដើម្បីក្លាយជាគ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ក្នុងការផ្ទេរចំណេះដឹងផ្នែកវិទ្យាសាស្ត្រពិត។

៤.២.៣.២.៤. មេកានិចអង្គធាតុរឹង និងមេកានិចសន្ទនីយ៍ [៣ (២-២-៥)]

មុខវិជ្ជា មេកានិចអង្គធាតុរឹង និងមេកានិចសន្ទនីយ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានគ្រឹះអំពីលក្ខណៈរូបនៃសារធាតុរាវ និងគោលការណ៍គ្រឹះនៃលំហូរសន្ទនីយតាមរយៈការសិក្សាលើទ្រឹស្តីសំខាន់ៗ។ មុខវិជ្ជានេះផ្តោតលើការសិក្សាអំពី ម៉ាសមាឌ ម៉ាសមាឌធៀប កម្លាំងមាឌ ទម្ងន់មាឌ កម្លាំងផ្ទៃ សម្ពាធ សមីការគ្រឹះនៃស្តាទិចសន្ទនីយ និងឌីណាមិចសន្ទនីយ អត្រាលំហូរ សមីការជាប់ សមីការបែនូលី ច្បាប់តូរីសែលី និងច្បាប់ពសឺយ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយពីបញ្ញត្តិ បាតុភូត និងទ្រឹស្តីនៃខ្លឹមសារមេរៀននីមួយៗបានយ៉ាងច្បាស់លាស់ដើម្បីយកទៅអនុវត្តក្នុងការបង្រៀននិងដោះស្រាយបញ្ហាបច្ចេកទេសក្នុងជីវភាពរស់នៅ។

៤.២.៣.២.៥. រលកមេកានិច និងរលកអេឡិចត្រូម៉ាញេទិច [៣ (២-២-៥)]

មុខវិជ្ជា រលកមេកានិច និងរលកអេឡិចត្រូម៉ាញេទិច មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងស៊ីជម្រៅអំពីការផ្សារភ្ជាប់គ្នារវាងទ្រឹស្តីអគ្គិសនី និងម៉ាញេទិច តាមរយៈសមីការគ្រឹះរបស់ម៉ាក់ស្វែលទាំងបួន។ មុខវិជ្ជានេះផ្តោតលើការសិក្សាអំពី ច្បាប់ហ្គោសសម្រាប់ដែនអគ្គិសនី ច្បាប់ហ្គោសសម្រាប់ដែនម៉ាញេទិច ច្បាប់អំពែ និងច្បាប់ផារ៉ាដេ រួមទាំងការវិវត្តនៃទ្រឹស្តីទាំងនេះទៅជារលកអេឡិចត្រូម៉ាញេទិច។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយពីគោលការណ៍នៃបច្ចេកវិទ្យាទំនើបៗដូចជា ប្រព័ន្ធអ៊ីនធឺណិត វិទ្យុ ទូរទស្សន៍ ឧបករណ៍អុបទិច និងការអនុវត្តរលកអេឡិចត្រូម៉ាញេទិចក្នុងវិស័យសុខាភិបាល។

៤.២.៣.២.៦. រូបវិទ្យាទំនើប [២ (២-០-៤)]

មុខវិជ្ជា រូបវិទ្យាទំនើប មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានគ្រឹះរូបវិទ្យាទំនើបតាមរយៈការបង្ហាញបាតុភូតក្នុងធម្មជាតិ។ មុខវិជ្ជានេះផ្តោតលើការសិក្សាចំណេះដឹងដោយប្រើទ្រឹស្តីដែលពណ៌នាពីមូលដ្ឋានគ្រឹះនៃធៀបភាព (Relativity Theory) រូបវិទ្យាអាតូម និងនុយក្លេអ៊ែរ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព បកស្រាយពីបញ្ញត្តិ បាតុភូត និងទ្រឹស្តីនៃខ្លឹមសារមេរៀន ។

៤.២.៣.២.៧. ឡាស៊ែ និងផូតូនិច (Laser and Photonics) [២ (២-០-៤)]

មុខវិជ្ជា ឡាស៊ែរ និងផូតូនិចមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងគ្រឹះអំពីការប្រើប្រាស់ពន្លឺសម្រាប់ការបញ្ជូនទិន្នន័យ និងទំនាក់ទំនងក្នុងបច្ចេកវិទ្យាទំនើប។ មុខវិជ្ជានេះផ្តោតលើការសិក្សាអំពីការបង្កើតពន្លឺ ទំនាក់ទំនងខ្សែកាបអុបទិច ការត្រួតពិនិត្យអុបទិច ព្រមទាំងការចាប់យកសញ្ញាពន្លឺក្នុងសឺមីកុងឌុចទ័រ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយពីបញ្ញត្តិ បាតុភូត និងទ្រឹស្តីនៃខ្លឹមសារមេរៀននេះ។

៤.២.៣.២.៨. រូបវិទ្យាអង្គធាតុរឹង [២ (២-០-៤)]

មុខវិជ្ជា រូបវិទ្យាអង្គធាតុរឹង មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីប្រវត្តិនៃការប្រើប្រាស់សម្ភារៈ និងឧបករណ៍ដែលធ្វើពីអង្គធាតុរឹងផ្សេងៗ។ មុខវិជ្ជានេះផ្តោតលើ វិទ្យាសាស្ត្រនៃរូបធាតុ ទម្រង់អាតូម

និងការចងសម្ព័ន្ធទម្រង់ក្រាមនៃអង្គធាតុរឹង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព បកស្រាយពីបញ្ញត្តិ បាតុភូត ទ្រឹស្តីនៃខ្លឹមសារមេរៀននេះ។

៤.២.៣.២.៩. អេឡិចត្រូនិក [២ (១-២-៣)]

មុខវិជ្ជា អេឡិចត្រូនិក មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានគ្រឹះនៃគ្រឿងអគ្គិសនី និង អេឡិចត្រូនិក និងការប្រើប្រាស់របស់វា។ មុខវិជ្ជានេះផ្តោតលើ ទ្រឹស្តីដែលព័ណ៌នាពីមូលដ្ឋានគ្រឹះ បង់ប៉ាឡង់ បង់ចម្លង ចន្លោះថាមពល នីវ៉ូថាមពល និងបង់ថាមពល សឺមីកុងឌុចទ័រ ឌីយ៉ូត Power Supply ត្រង់ស៊ីស្ទ័រ សៀគ្វី Op Amp ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយពីបញ្ញត្តិ បាតុភូត ទ្រឹស្តី នៃខ្លឹមសារមេរៀន ដើម្បីពន្យល់ពីគោលការណ៍ដំណើរការនៃគ្រឿងអគ្គិសនីនិងអេឡិចត្រូនិក និងអាចប្រើប្រាស់ គ្រឿងអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយប្រសិទ្ធភាព។

៤.២.៣.២.១០. មេកានិចកង់ទិក [២ (២-០-៤)]

មុខវិជ្ជា មេកានិចកង់ទិក មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានគ្រឹះមេកានិចកង់ទិក ដែលប្រើប្រាស់ជាចំណេះដឹងកម្រិតខ្ពស់ផ្នែករូបវិទ្យាទំនើប។ មុខវិជ្ជានេះផ្តោតលើទ្រឹស្តីដែលពណ៌នាពីមូលដ្ឋាន គ្រឹះកង់ទិកដូចជា ធម្មជាតិរលកនៃភាគល្អិត សមីការស្រូឌីងហ្គ័រ រនាំងប៉ូតង់ស្យែល តម្លៃផ្ទាល់ ភាគល្អិតក្នុង អណ្តូងប៉ូតង់ស្យែលលំយោលអាក់ម៉ូនិក។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព បកស្រាយពីបញ្ញត្តិ បាតុភូត ទ្រឹស្តីនៃខ្លឹមសារមេរៀន។

៤.២.៣.៣. ឯកទេសគីមីវិទ្យា

៤.២.៣.៣.១. មូលដ្ឋានគ្រឹះគីមីវិទ្យា I [៣ (២-២-៥)]

មុខវិជ្ជា មូលដ្ឋានគ្រឹះគីមីវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីគីមីទូទៅ ពាក់ព័ន្ធ នឹងបរិមាណរូបធាតុ ថាមពលនៃប្រតិកម្មគីមី និងការពិសោធមូលដ្ឋាន។ មុខវិជ្ជានេះផ្តោតលើ ស្ទីស្យូមេទ្រី ច្បាប់ ឧស្ម័ន ទ្រឹស្តីស៊ីនេទិចនៃម៉ូលេគុល គោលការណ៍គ្រឹះនៃទែរម៉ូគីមីទាក់ទងនឹងលំហូរថាមពល និងបំប្លែងគីមីផ្សារ ភ្ជាប់ជាមួយការពិសោធន៍។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពគណនាបរិមាណ រូបធាតុ បកស្រាយលក្ខណៈឧស្ម័ន និងវិភាគការបំប្លែងថាមពលនៅក្នុងប្រព័ន្ធគីមីផ្អែកលើការពិសោធន៍។

៤.២.៣.៣.២. មូលដ្ឋានគ្រឹះគីមីវិទ្យា II [៣ (២-២-៥)]

មុខវិជ្ជា មូលដ្ឋានគ្រឹះគីមីវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងបន្ថែមអំពីទំនាក់ ទំនងបរិមាណក្នុងប្រតិកម្មគីមី ស៊េរីសកម្មភាពនៃធាតុ ប្រព័ន្ធលំនឹង និងការពិសោធ។ មុខវិជ្ជានេះផ្តោតលើ ទំនោរនៃធាតុគីមីក្នុងតារាងខួប ស៊ីនេទិចនៃប្រតិកម្មគីមី និងលំនឹងនិងកត្តាដែលមានឥទ្ធិពលលើលំនឹងគីមី។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយលក្ខណៈតារាងខួប វិភាគល្បឿន និងចលនការប្រតិកម្ម និងព្យាករណ៍ពីវិសាលភាពនិងទិសដៅនៃប្រតិកម្មគីមីផ្អែកលើការពិសោធ។

៤.២.៣.៣.៣. ការអប់រំស្មែមក្នុងការបង្រៀនគីមីវិទ្យា [២ (១-២-៣)]

មុខវិជ្ជា ការអប់រំស្មែមក្នុងការបង្រៀនគីមីវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង មូលដ្ឋានគ្រឹះលើផ្នែកការអប់រំស្មែម ជំនាញរចនា និងរបៀបបង្រៀនតាមបែប STEM ភ្ជាប់ទៅនឹងខ្លឹមសារមេរៀន ស្របតាមកម្មវិធីសិក្សា។ មុខវិជ្ជានេះផ្តោតលើការរួមបញ្ចូលមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

វិធីដោះស្រាយបញ្ហា និងការសិក្សាតាមបែបគម្រោង។ ក្រោយបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពដោះស្រាយបញ្ហាក្នុងសហគមន៍ដោយប្រើប្រាស់ចំណេះដឹង STEM ប្រកបដោយប្រសិទ្ធិភាព។

៤.២.៣.៣.៤. គីមីរូប [៣ (២-២-៥)]

មុខវិជ្ជា គីមីរូប មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងផ្នែកទែម៉ូឌីណាមិចអេឡិចត្រូគីមី និងការពិសោធ។ មុខវិជ្ជានេះផ្តោតលើប្រតិកម្មអុកស៊ីដូរេដុកម្មតាមលំនាំគីមីផ្សេងៗ លំនាំអេឡិចត្រូគីមីក្នុងថ្មពិល និងអគ្គីសនីវិភាគសូលុយស្យុង អគ្គីសនីវិភាគកម្តៅរលាយ និងច្បាប់ផារ៉ាដេ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយចំណេះដឹងមូលដ្ឋានគ្រឹះនៃគីមីរូប និងអនុវត្តបញ្ញត្តិនិងទ្រឹស្តីនានាក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

៤.២.៣.៣.៥. គីមីវិភាគ I [២ (២-០-៤)]

មុខវិជ្ជា គីមីវិភាគ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវបញ្ញត្តិមូលដ្ឋានលើគោលការណ៍ និងវិធីសាស្ត្រនៃការវិភាគ។ មុខវិជ្ជានេះផ្តោតលើប្រតិកម្មបង្កើតកករ ប្រតិកម្មអាស៊ីត-បាស ប្រតិកម្មអុកស៊ីដូរេដុកម្ម និងសូលុយស្យុងតំប៉ុង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពធ្វើចំណែកថ្នាក់ប្រភេទប្រតិកម្មគីមីផ្សេងៗ ធ្វើការគណនាបរិមាណរូបធាតុតាមស្ទីស្យូមេទ្រី បំណិនវិភាគ និងដោះស្រាយបញ្ហាផ្សារភ្ជាប់ទ្រឹស្តីគីមីទៅនឹងការអនុវត្តជាក់ស្តែង។

៤.២.៣.៣.៦. គីមីអសរីរាង្គ I [២ (២-០-៤)]

មុខវិជ្ជា គីមីអសរីរាង្គ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវបញ្ញត្តិមូលដ្ឋាននៃសម្ព័ន្ធគីមី និងលក្ខណៈនៃសមាសធាតុអសរីរាង្គ។ មុខវិជ្ជានេះផ្តោតលើ សម្ព័ន្ធគីមី ទម្រង់ឡឺវីស ទ្រឹស្តីចម្រានគូរអេឡិចត្រុង (VSEPR) អ៊ីប្រឺតកម្ម អុកស៊ីត អាស៊ីត បាស អំបិល និងលោហៈ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយ និងអនុវត្តបញ្ញត្តិមូលដ្ឋាននៃគីមីអសរីរាង្គក្នុងបន្ទប់ពិសោធន៍ និងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

៤.២.៣.៣.៧. គីមីសរីរាង្គ I [២ (២-០-៤)]

មុខវិជ្ជា គីមីសរីរាង្គ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងផ្នែកទម្រង់ម៉ូលេគុលសរីរាង្គ ធរណីមាត្រនៃម៉ូលេគុល និងលក្ខណៈនៃសមាសធាតុសរីរាង្គ។ មុខវិជ្ជានេះផ្តោតលើ រូបមន្តទូទៅ លក្ខណៈរូប លក្ខណៈគីមី ទង្វើនិងបម្រើបម្រាស់អ៊ីដ្រូកាបួ និងសមាសធាតុសរីរាង្គដែលមានធាតុអុកស៊ីសែន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយ និងអនុវត្តបញ្ញត្តិមូលដ្ឋាននៃគីមីសរីរាង្គក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

៤.២.៣.៣.៨. គីមីសរីរាង្គ II [៣ (២-២-៥)]

មុខវិជ្ជា គីមីសរីរាង្គ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងបន្ថែមផ្នែកសមាសធាតុសរីរាង្គដែលមានធាតុអុកស៊ីសែន និងអាសូតក្នុងម៉ូលេគុល និងការពិសោធ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារ សមាសធាតុសរីរាង្គដូចជា រូបមន្តទូទៅ លក្ខណៈរូប លក្ខណៈគីមី ទង្វើ និងបម្រើបម្រាស់សមាសធាតុសរីរាង្គ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយ និងអនុវត្តបញ្ញត្តិមូលដ្ឋាននៃគីមីសរីរាង្គក្នុងបន្ទប់ពិសោធន៍ និងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

៤.២.៣.៣.៩. គីមីអសរីរាង្គ II [២ (២-០-៤)]

មុខវិជ្ជា គីមីអសរីរាង្គ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងស៊ីជម្រៅអំពីធាតុតំណាង និងធាតុឆ្លង នៅក្នុងតារាងខួបនៃធាតុគីមី។ មុខវិជ្ជានេះផ្តោតលើ លក្ខណៈ សមាសធាតុ និងការអនុវត្តនៃធាតុពីប្លុក s, p, d និង f ដោយបញ្ជាក់ពីទំនោរក្នុងតារាងខួប ប្រតិកម្មភាព និងការប្រើប្រាស់ធាតុគីមីក្នុងឧស្សាហកម្ម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយលក្ខណៈធាតុគីមី និងបង្ហាញហេតុផលបែបវិទ្យាសាស្ត្រអំពីការព្យាករណ៍ប្រតិកម្មគីមីក្នុងការអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

៤.២.៣.៣.១០. គីមីវិភាគ II [២ (២-០-៤)]

មុខវិជ្ជា គីមីវិភាគ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើការវិភាគគីមីដើម្បីកំណត់បរិមាណរូបធាតុ និងបច្ចេកទេសអត្រាកម្ម។ មុខវិជ្ជានេះផ្តោតលើ ការរៀបចំសូលុយស្យុងស្តង់ដា ការរក្សាទុកសូលុយស្យុងវិភាគ អត្រាកម្មអាស៊ីត-បាស អត្រាកម្មរេដុក និង អត្រាកម្មបង្កើតកករ ដោយរួមបញ្ចូលសកម្មភាពពិសោធន៍ កត់ត្រា និងបកស្រាយទិន្នន័យអត្រាកម្ម គូស និងវិភាគខ្សែកោងអត្រាកម្ម និងអនុវត្តការគណនាដើម្បីកំណត់កំហាប់សូលុយស្យុង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពអនុវត្តអត្រាកម្ម បកស្រាយទិន្នន័យ វិភាគ និងដោះស្រាយបញ្ហា ផ្សារភ្ជាប់ទ្រឹស្តីគីមីទៅនឹងការអនុវត្តជាក់ស្តែង។

៤.២.៣.៤. ឯកទេសជីវិទ្យា

៤.២.៣.៤.១. មូលដ្ឋានគ្រឹះជីវិទ្យា I [៣ (២-២-៥)]

មុខវិជ្ជា មូលដ្ឋានគ្រឹះជីវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការសិក្សាអំពីកោសិកា និងប្រព័ន្ធចំណែកថ្នាក់ការ:រស់។ មុខវិជ្ជានេះផ្តោតលើ ការសិក្សាអំពីកោសិកាវិទ្យា ប្រព័ន្ធចំណែកថ្នាក់ការ:រស់ និងការពិសោធ។ នៅពេលបញ្ចប់នៃមុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពពណ៌នាពីបញ្ញត្តិសំខាន់ៗក្នុងមុខវិជ្ជាមូលដ្ឋានគ្រឹះជីវិទ្យា I និងមានបំណិនបែបវិទ្យាសាស្ត្រក្នុងការអនុវត្ត ពិសោធន៍ងាយៗលើប្រធានបទការសង្កេតកោសិកា ការធ្វើចំណែកថ្នាក់ការ:រស់ និងការសិក្សាអំពីករណីសិក្សា។

៤.២.៣.៤.២. មូលដ្ឋានគ្រឹះជីវិទ្យា II [៣ (២-២-៥)]

មុខវិជ្ជា មូលដ្ឋានគ្រឹះជីវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងនិងបំណិនមូលដ្ឋានសម្រាប់ការអនុវត្តវិទ្យាសាស្ត្រជីវិទ្យា។ មុខវិជ្ជានេះផ្តោតលើ ជីវិទ្យាក្នុងវិស័យកសិកម្ម ដំណើរមេតាបូលីសថេរលំនឹងរបស់សត្វនិងរុក្ខជាតិ និងការពិសោធ។ នៅពេលបញ្ចប់នៃមុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយបញ្ញត្តិ និងប្រើប្រាស់ចំណេះដឹងមូលដ្ឋានគ្រឹះជីវិទ្យា II នៅក្នុងវិជ្ជាជីវៈគ្រូបង្រៀនឯកទេសជីវិទ្យានិងការអនុវត្តជាក់ស្តែងក្នុងជីវភាពប្រចាំថ្ងៃ។

៤.២.៣.៤.៣. ការអប់រំស្ទឹមក្នុងការបង្រៀនជីវិទ្យា [២ (១-២-៣)]

មុខវិជ្ជា ការអប់រំស្ទឹមក្នុងការបង្រៀនជីវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានគ្រឹះលើផ្នែកការអប់រំស្ទឹម ជំនាញរចនា និងរបៀបបង្រៀនតាមបែបស្ទឹម (STEM) ផ្សារភ្ជាប់ទៅនឹងខ្លឹមសារមេរៀនស្របតាមកម្មវិធីសិក្សាកម្រិតមូលដ្ឋាន។ មុខវិជ្ជានេះផ្តោតលើការ រួមបញ្ចូលមុខវិជ្ជាវិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ការសិក្សាតាមបែបដោះស្រាយបញ្ហា និងការសិក្សាតាមបែបគម្រោង។ ក្រោយបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពដោះស្រាយបញ្ហាក្នុងសហគមន៍តាមរយៈការប្រើប្រាស់ចំណេះដឹងស្ទឹមប្រកបដោយប្រសិទ្ធិភាព។

៤.២.៣.៤.៤. រុក្ខវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា រុក្ខវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីការសិក្សាបញ្ញត្តិ និងការពិសោធអំពីរុក្ខជាតិ។ មុខវិជ្ជានេះផ្តោតលើ រូបសាស្ត្រវិទ្យា កាយវិភាគវិទ្យា សរីរៈវិទ្យា លក្ខណៈអេកូឡូស៊ីរបស់រុក្ខជាតិ និងការពិសោធ។ នៅពេលបញ្ចប់នៃមុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយ និងប្រើប្រាស់បញ្ញត្តិអំពីរុក្ខវិទ្យាក្នុងការបង្រៀននិងរៀន និងអភិវឌ្ឍបំណិនអនុវត្តការពិសោធ និងការប្រើប្រាស់ចំណេះដឹង ផ្សារភ្ជាប់ទៅនឹងជីវភាពប្រចាំថ្ងៃ។

៤.២.៣.៤.៥. សត្តវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា សត្តវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីការសិក្សាបញ្ញត្តិនិង ការពិសោធអំពីសត្វ។ មុខវិជ្ជានេះផ្តោតលើ រូបសាស្ត្រវិទ្យា កាយវិភាគវិទ្យា សរីរៈវិទ្យា លក្ខណៈ អេកូឡូស៊ីរបស់សត្វ និងការពិសោធ។ នៅពេលបញ្ចប់នៃមុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព បកស្រាយនិងប្រើប្រាស់បញ្ញត្តិអំពីសត្វសម្រាប់ការបង្រៀននិងរៀន អភិវឌ្ឍបំណិនពិសោធន៍ និងការអនុវត្តប្រើប្រាស់ចំណេះដឹងផ្សារភ្ជាប់ទៅនឹងជីវភាពប្រចាំថ្ងៃ។

៤.២.៣.៤.៦. មីក្រុបវិទ្យា [២ (១-២-៣)]

មុខវិជ្ជា មីក្រុបវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវ ចំណេះដឹងមូលដ្ឋានអំពី មីក្រូសារពាង្គកាយ។ មុខវិជ្ជានេះផ្តោតលើ លក្ខណៈទូទៅ ចំណែកថ្នាក់ លក្ខខណ្ឌអេកូឡូស៊ីនៃ មីក្រូសារពាង្គកាយ ទំនាក់ទំនងមីក្រូសារពាង្គកាយជាមួយនឹងបរិស្ថាន និងការពិសោធអំពីមីក្រូសារពាង្គកាយ។ នៅពេលបញ្ចប់នៃមុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់បញ្ញត្តិអំពីមីក្រុបវិទ្យាក្នុងការបង្រៀននិងរៀន និងអនុវត្តប្រើប្រាស់មីក្រូសារពាង្គកាយក្នុងជីវភាពជាក់ស្តែង។

៤.២.៣.៤.៧. អេកូឡូស៊ី [២ (២-០-៤)]

មុខវិជ្ជា អេកូឡូស៊ី មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើបញ្ញត្តិអំពីអេកូឡូស៊ីនៃមណ្ឌលជីវៈ។ មុខវិជ្ជានេះផ្តោតលើ ប្រព័ន្ធមណ្ឌលជីវៈ និងបញ្ហាបរិស្ថាន។ នៅពេលបញ្ចប់មុខវិជ្ជា សិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់បញ្ញត្តិអំពីអេកូឡូស៊ីក្នុងការបង្រៀននិងរៀន វិភាគ និងឆ្លុះបញ្ចាំងពីដំណោះស្រាយបញ្ហាបរិស្ថានក្នុងសហគមន៍ជាក់ស្តែង។

៤.២.៣.៤.៨. គីមីជីវៈ [៣ (៣-០-៦)]

មុខវិជ្ជា គីមីជីវៈ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានអំពីគីមីជីវៈនៅក្នុងសារពាង្គកាយរបស់ការៈរស់។ មុខវិជ្ជានេះផ្តោតលើ ទម្រង់ និងមុខងារម៉ូលេគុលជីវៈ មេតាបូលីស អង់ស៊ីម និងម៉ូលេគុលសេណេទិកជាដើម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់ចំណេះដឹងអំពីគីមីជីវៈសម្រាប់ការបង្រៀននិងរៀន និងអនុវត្តផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ។

៤.២.៣.៤.៩. សេណេទិច [៣ (៣-០-៦)]

មុខវិជ្ជា សេណេទិក មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីបញ្ញត្តិសំខាន់ៗក្នុងផ្នែកសេណេទិកនៅក្នុងសារពាង្គកាយមានជីវិត។ មុខវិជ្ជានេះផ្តោតលើ សម្ភារៈតំណពូជ ច្បាប់តំណពូជ បច្ចេកវិទ្យាជីវៈ និងទំនាក់ទំនងហ្សែនទៅនឹងសុខភាព និងការវិវត្តរបស់ការៈរស់។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់បញ្ញត្តិគោលរបស់សេណេទិកក្នុងការបង្រៀននិងរៀន ឆ្លុះបញ្ចាំងនិងរកដំណោះស្រាយ

លើបញ្ហាពាក់ព័ន្ធនឹងកត្តាតំណពូជនិងបម្រែបម្រួលនៃហ្សែន និងអនុវត្តបច្ចេកវិទ្យាជីវៈដើម្បីរួមចំណែកដល់ភាពជឿនលឿននៃវិទ្យាសាស្ត្រសម្រាប់ប្រើប្រាស់ក្នុងសង្គមជាក់ស្តែង។

៤.២.៣.៥. ឯកទេសផែនដីនិងបរិស្ថានវិទ្យា

៤.២.៣.៥.១. មូលដ្ឋានគ្រឹះផែនដីវិទ្យា និងបរិស្ថានវិទ្យា I [៣ (៣-០-៦)]

មុខវិជ្ជា មូលដ្ឋានគ្រឹះផែនដីវិទ្យា និងបរិស្ថានវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីប្រព័ន្ធព្រះអាទិត្យ ការកកើតភពផែនដី និងដំណើរការផ្ទៃក្នុង និងផ្ទៃក្រៅនៃផែនដី ដើម្បីអភិវឌ្ឍសមត្ថភាពសិស្សក្នុងការយល់ដឹង និងវិភាគបាតុភូតធម្មជាតិផ្សេងៗ។ មុខវិជ្ជានេះផ្តោតលើ រចនាសម្ព័ន្ធស្រទាប់ផែនដី (ស្នូល ម៉ង់តូ និងសំបក) ទ្រឹស្តីផ្លាកតិចតូនិច បាតុភូតភូមិសាស្ត្រដូចជា រញ្ជួយដីនិងភ្នំភ្លើង ការសិក្សាប្រភេទថ្ម និងវ៉ែវដ្តទឹក ស្រទាប់បរិយាកាស និងប្រព័ន្ធអេកូឡូស៊ី។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពពន្យល់ពីដំណើរការធម្មជាតិទាក់ទងនឹងផែនដី ប្រើប្រាស់ចំណេះដឹងក្នុងជីវភាពប្រចាំថ្ងៃ និងយល់ដឹងអំពីសារៈសំខាន់នៃការការពារបរិស្ថាននិងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

៤.២.៣.៥.២. មូលដ្ឋានគ្រឹះផែនដីវិទ្យា និងបរិស្ថានវិទ្យា II [៣ (៣-០-៦)]

មុខវិជ្ជា មូលដ្ឋានគ្រឹះផែនដីវិទ្យា និងបរិស្ថានវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងផ្តោតលើការអនុវត្តគោលការណ៍វិទ្យាសាស្ត្រ ដើម្បីស្វែងយល់ វិភាគ និងដោះស្រាយបញ្ហាបរិស្ថានស្មុគស្មាញនានា។ មុខវិជ្ជានេះផ្តោតលើប្រធានបទសំខាន់ៗដូចជា ថាមវន្តនៃអាកាសធាតុ ការប្រែប្រួលបរិស្ថានសកលលោក (Global Environmental Change) ការបំពុល (ទឹក ដី ខ្យល់) សុវត្ថិភាពចំណីអាហារ និងការវាយតម្លៃហានិភ័យ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពពន្យល់ពីការគ្រប់គ្រងធនធានធម្មជាតិ ការអភិវឌ្ឍប្រកបដោយចីរភាព និងវិធីសាស្ត្រតាមដានគុណភាពបរិស្ថាន (Environmental Monitoring) តាមរយៈការអនុវត្តជាក់ស្តែង។

៤.២.៣.៥.៣. ការអប់រំស្មែមក្នុងការបង្រៀនផែនដីវិទ្យា [២ (១-២-៣)]

មុខវិជ្ជា អប់រំស្មែមក្នុងការបង្រៀនផែនដីវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើផ្នែកការអប់រំស្មែម ជំនាញរចនា និងរបៀបបង្រៀនតាមបែប STEM ភ្ជាប់ទៅនឹងខ្លឹមសារមេរៀនកម្រិតមូលដ្ឋានផែនដី និងបរិស្ថានវិទ្យា។ មុខវិជ្ជានេះផ្តោតលើការរួមបញ្ចូលមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា វិធីដោះស្រាយបញ្ហា និងការសិក្សាតាមបែបគម្រោង ដែលភ្ជាប់ខ្លឹមសារមេរៀននិងបញ្ហាក្នុងជីវភាពប្រចាំថ្ងៃ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពដោះស្រាយបញ្ហា ច្នៃប្រឌិត អនុវត្តជាក់ស្តែងលើគម្រោងស្រាវជ្រាវដោយដាក់បញ្ចូលក្នុងការអប់រំស្មែម គិតបែបវិភាគ បង្រៀនដោយការរចនាមេរៀន STEM ប្រើសម្ភារៈមូលដ្ឋាន វាយតម្លៃសមត្ថភាពសិស្ស និងដោះស្រាយបញ្ហាក្នុងសហគមន៍ដោយប្រើប្រាស់ចំណេះដឹង STEM ប្រកបដោយប្រសិទ្ធិភាព។

៤.២.៣.៥.៤. សាគរវិទ្យា [៣ (៣-០-៦)]

មុខវិជ្ជា សាគរវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីលក្ខណៈ ទម្រង់ និងសារៈសំខាន់នៃមហាសមុទ្រនៅលើផែនដី។ មុខវិជ្ជានេះផ្តោតលើ ការស្វែងយល់អំពីរចនាសម្ព័ន្ធរបស់មហាសមុទ្រ ទិដ្ឋភាព និងធនធានធម្មជាតិនៅក្នុងសមុទ្រ។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពពន្យល់

អំពីសមុទ្រនៅលើផែនដី វាយតម្លៃតួនាទីនៃមហាសមុទ្រចំពោះជីវិតនិងអាកាសធាតុ និងបកស្រាយបាតុភូតសមុទ្រផ្សេងៗដូចជា ខ្សែទឹក រលក និងដំនោរបៃបវិទ្យាសាស្ត្រ។

៤.២.៣.៥.៥. ឧតុភូតវិទ្យា [៣ (៣-០-៦)]

មុខវិជ្ជា ឧតុភូតវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីរចនាសម្ព័ន្ធ និងតួនាទីសំខាន់នៃបរិយាកាសក្នុងការរក្សាជីវិតលើផែនដី។ មុខវិជ្ជានេះផ្តោតលើការសិក្សាអំពីបាតុភូតធម្មជាតិដែលកើតឡើងក្នុងបរិយាកាសដូចជា សម្ពាធខ្យល់ ខ្យល់បក់ ព្យុះ ភ្លៀង ពពក និងការប្រែប្រួលអាកាសធាតុដែលមានឥទ្ធិពលដល់សកម្មភាពមនុស្ស និងបរិស្ថាន។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពពន្យល់បានអំពីមុខងាររបស់បរិយាកាស វាយតម្លៃ និងបកស្រាយបាតុភូតអាកាសធាតុផ្សេងៗដូចជាព្យុះ ភ្លៀង និងការប្រែប្រួលអាកាសធាតុ អនុវត្តចំណេះដឹងក្នុងការព្យាករណ៍ឬសិក្សាអាកាសធាតុប្រចាំថ្ងៃ បង្ហាញទស្សនៈវិជ្ជមានចំពោះការរក្សាបរិយាកាសស្អាត និងអភិវឌ្ឍចំណេះដឹងបន្ថែមក្នុងការស្រាវជ្រាវផ្នែកបរិស្ថាននាពេលអនាគត។

៤.២.៣.៥.៦. តារាវិទ្យា [២ (២-០-៤)]

មុខវិជ្ជា តារាវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីបាតុភូតអាកាស ប្រព័ន្ធព្រះអាទិត្យ និងសកលទាំងមូល។ មុខវិជ្ជានេះផ្តោតលើកំណកំណើត និងការវិវត្តនៃកព ផ្កាយ តារា និងសកល ដើម្បីបង្កើតការយល់ដឹងអំពីតួនាទីនៃវិទ្យាសាស្ត្រអវកាសក្នុងជីវិត និងសង្គម។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពពន្យល់អំពីទម្រង់ និងដំណើរការរបស់ប្រព័ន្ធព្រះអាទិត្យ វាយតម្លៃបាតុភូតអវកាស និងអាចប្រើប្រាស់ចំណេះដឹងនេះក្នុងការសង្កេត វិភាគ និងស្រាវជ្រាវបញ្ហាផ្នែកអវកាស។

៤.២.៣.៥.៧. វិទ្យាសាស្ត្របរិស្ថានI [៣ (៣-០-៦)]

មុខវិជ្ជា វិទ្យាសាស្ត្របរិស្ថានវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតមានចំណេះដឹងអំពីបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ដែលជាមូលដ្ឋានសម្រាប់ជីវិតមនុស្ស និងសត្វនៅលើផែនដី។ មុខវិជ្ជានេះផ្តោតលើការសិក្សារចនាសម្ព័ន្ធ និងប្រព័ន្ធធម្មជាតិ បាតុភូតធម្មជាតិ ផលប៉ះពាល់នៃសកម្មភាពមនុស្ស និងវិធីសាស្ត្រការពារនិងអភិរក្សបរិស្ថាន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគទំនាក់ទំនងរវាងប្រព័ន្ធបរិស្ថាននិងវដ្តដីរភូគព្ភគីមី និងផលប៉ះពាល់នៃសកម្មភាពមនុស្សលើធនធានធម្មជាតិ និងអនុវត្តវិធានការអភិរក្សបរិស្ថាន។

៤.២.៣.៥.៨. ធរណីវិទ្យា [៣ (៣-០-៦)]

មុខវិជ្ជា ធរណីវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងវិភាគ និងបកស្រាយអំពីទម្រង់និងប្រព័ន្ធធម្មជាតិរបស់ផែនដី។ មុខវិជ្ជានេះផ្តោតលើ រ៉ែ សិលា ផូស៊ីល ផ្លាកតិចតូនិក ដី និងលំហូរទឹក។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពពន្យល់អំពីដំណើរការផ្លាស់ប្តូរធម្មជាតិរបស់ផែនដី កំណត់អត្តសញ្ញាណនិងវិភាគធនធានធម្មជាតិបានត្រឹមត្រូវ និងអនុវត្តចំណេះដឹងក្នុងការរក្សានិងប្រើប្រាស់ធនធានធម្មជាតិនៅតាមតំបន់ផ្សេងៗ ដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនិងការយកចិត្តទុកដាក់លើបរិស្ថាន ព្រមទាំងបង្ហាញឥរិយាបទវិជ្ជមានក្នុងការរក្សា និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

៤.២.៣.៥.៩. វិទ្យាសាស្ត្របរិស្ថាន II [២ (២-០-៤)]

មុខវិជ្ជា វិទ្យាសាស្ត្របរិស្ថាន II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងស៊ីជម្រៅអំពីបរិស្ថាននិងអាកាសធាតុដូចជា ការបំពុលខ្យល់ កំណើនកម្តៅលើផែនដី ភ្លៀងអាស៊ីត ការគ្រប់គ្រងសំណល់ និង

ព្រៃឈើ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារដូចជា មូលហេតុនិងផលប៉ះពាល់របស់បរិស្ថានទៅលើជីវិតមនុស្ស សត្វ និងធនធានធម្មជាតិ ព្រមទាំងការគ្រប់គ្រងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ(DRRM)។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគស៊ីជម្រៅពីបញ្ហាបរិស្ថាននិងការប្រែប្រួលអាកាសធាតុ យល់ដឹងពីតួនាទីនិងភារកិច្ចរបស់ខ្លួនក្នុងការរក្សានិងអភិរក្សធនធានធម្មជាតិ អនុវត្តវិធានការកាត់បន្ថយនិងការបន្សាំដូចជាការចូលរួមក្នុងសកម្មភាព DRRM ដើម្បីទប់ស្កាត់ហានិភ័យនិងការប្រែប្រួលបរិស្ថាន និងបង្ហាញទស្សនៈវិជ្ជមានក្នុងការអភិរក្សធនធាននិងបរិស្ថានសម្រាប់ជីវិតអនាគតប្រកបដោយចីរភាព។

៤.២.៤. ឯកទេសប្រវត្តិវិទ្យា-ភូមិវិទ្យា

៤.២.៤.១. មុខវិជ្ជាប្រវត្តិវិទ្យា

៤.២.៤.១.១. ទ្រឹស្តីប្រវត្តិវិទ្យា និងការស្រាវជ្រាវប្រវត្តិសាស្ត្រ [៣ (៣-០-៦)]

មុខវិជ្ជា ទ្រឹស្តីប្រវត្តិវិទ្យា និងការស្រាវជ្រាវប្រវត្តិសាស្ត្រ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានពីទ្រឹស្តីប្រវត្តិសាស្ត្រនានា វិធីប្រើប្រាស់ប្រភពឯកសារ និងការចងក្រងឯកសារប្រវត្តិសាស្ត្រ។ មុខវិជ្ជានេះផ្តោតលើ ទ្រឹស្តីប្រវត្តិសាស្ត្រក្រិកបុរាណ ទ្រឹស្តីប្រវត្តិសាស្ត្រចិនបុរាណ ទ្រឹស្តីប្រវត្តិសាស្ត្របែបសាសនា ទ្រឹស្តីប្រវត្តិសាស្ត្របែបវិទ្យាសាស្ត្រ ទ្រឹស្តីប្រវត្តិសាស្ត្របែបសង្គម ទ្រឹស្តីប្រវត្តិសាស្ត្របែបម៉ាក្ស៊ីសនិយម ទ្រឹស្តីប្រវត្តិសាស្ត្រសម័យទំនើប វិធីបែងចែកប្រភពឯកសារ វិធីសង្ខេបអត្ថបទឬមេរៀន និងវិធីចុះប្រភពឯកសារយោង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រៀបធៀបទ្រឹស្តីប្រវត្តិសាស្ត្រ វិភាគប្រភពឯកសារប្រវត្តិសាស្ត្រដែលប្រើប្រាស់សម្រាប់ការស្រាវជ្រាវ និងចងក្រងឯកសារមេរៀនប្រវត្តិសាស្ត្រដោយមានប្រភពឯកសារយោងច្បាស់លាស់ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

៤.២.៤.១.២. ប្រវត្តិសាស្ត្រខ្មែរសម័យមុនអង្គរ [៣ (៣-០-៦)]

មុខវិជ្ជា ប្រវត្តិសាស្ត្រខ្មែរសម័យមុនអង្គរ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងការវិភាគពីការវិវត្តនៃផ្នត់គំនិតរបស់បុព្វបុរសខ្មែរសម័យមុនអង្គរ។ មុខវិជ្ជានេះផ្តោតលើមូលដ្ឋានគ្រឹះប្រវត្តិវិទ្យា កាលវិទ្យា បុរេប្រវត្តិសាស្ត្រកម្ពុជា សម័យហ្វូណាន និងសម័យចេនឡា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពកំណត់បានពីសារៈសំខាន់នៃការអប់រំប្រវត្តិសាស្ត្រ ប្រើប្រាស់កាលវិទ្យា និងបកស្រាយពីការវិវត្តផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គមខ្មែរសម័យមុនអង្គរ។

៤.២.៤.១.៣. ប្រវត្តិសាស្ត្រខ្មែរសម័យអង្គរ និងក្រោយអង្គរ [៣ (៣-០-៦)]

មុខវិជ្ជា ប្រវត្តិសាស្ត្រខ្មែរសម័យអង្គរ និងក្រោយអង្គរ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងនិងបំណិនវិភាគពីការវិវត្តនៃសង្គមខ្មែរសម័យអង្គរ និងសម័យក្រោយអង្គរ។ មុខវិជ្ជានេះផ្តោតលើការចាប់ផ្តើមនៃចក្រភពអង្គរ ការកសាងក្រុងយសោធរបុរៈ ការរីកចម្រើននៃសម័យអង្គរ ការធ្លាក់ចុះនៃសម័យអង្គរ សម័យចតុមុខនិងរាជវង្ស សម័យលង្វែកនិងការពង្រឹងអនុភាពឡើងវិញ និងរាជវង្សនៅសម័យឧដុង្គ និងការបាត់បង់ទឹកដី។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគពីកត្តាដែលនាំឱ្យសម័យអង្គរមានការរីកចម្រើននិងធ្លាក់ចុះ មូលហេតុនៃការផ្លាស់ប្តូររាជធានី រាជវង្ស និងការបាត់បង់ទឹកដីនៅសម័យក្រោយអង្គរ។

៤.២.៤.១.៤. ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍សម័យបុរាណ និងសម័យអាណានិគម [៣ (៣-០-៦)]

មុខវិជ្ជា ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍សម័យបុរាណ និងសម័យអាណានិគម មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនវិភាគអំពីការរីកចម្រើន និងការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធនយោបាយ

សេដ្ឋកិច្ច និងសង្គមក្នុងតំបន់អាស៊ីអាគ្នេយ៍។ មុខវិជ្ជានេះផ្តោតលើបុរេប្រវត្តិសាស្ត្រនិងការកកើតរដ្ឋដំបូង ទំនាក់ទំនងរវាងបណ្តារដ្ឋក្នុងតំបន់ ឥទ្ធិពលពាណិជ្ជកម្មនិងវប្បធម៌ពីរដ្ឋខាងក្រៅ និងការឈានចូលមកដល់នៃមហាអំណាចអាណានិគមអឺរ៉ុប។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគពីការវិវត្តនៃរដ្ឋបុរាណក្នុងតំបន់អាស៊ីអាគ្នេយ៍ និងឥទ្ធិពលនៃអរិយធម៌បរទេសមកលើរចនាសម្ព័ន្ធនយោបាយនិងជំនឿសាសនាប្រកបដោយតក្កវិជ្ជាប្រវត្តិសាស្ត្រ។

៤.២.៤.១.៥. ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍សម័យទំនើប [៣ (៣-០-៦)]

មុខវិជ្ជា ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍សម័យទំនើប មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនវិភាគអំពីដំណើរការកសាងជាតិនៃបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្រោយទទួលបានឯករាជ្យពីអាណានិគម។ មុខវិជ្ជានេះផ្តោតលើ ចលនាជាតិនិយមនិងការទាមទារឯករាជ្យ ការកសាងជាតិនិងបញ្ហាប្រឈមក្រោយឯករាជ្យ ការប្រឈមមុខនឹងសង្គ្រាមត្រជាក់ ការផ្លាស់ប្តូររបបនយោបាយ ការអភិវឌ្ឍសេដ្ឋកិច្ច និងការបង្កើតសហគមន៍អាស៊ាននិងសមាហរណកម្មក្នុងតំបន់។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគនិងបកស្រាយពីដំណើរទាមទារឯករាជ្យនិងបញ្ហាប្រឈមនៃការកសាងជាតិ ឥទ្ធិពលនៃភូមិសាស្ត្រនយោបាយក្នុងសម័យសង្គ្រាមត្រជាក់ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នយោបាយនិងសេដ្ឋកិច្ចរបស់បណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។

៤.២.៤.១.៦. ប្រវត្តិសាស្ត្រពិភពលោកបុរាណសម័យ និងមជ្ឈិមសម័យ [៣ (៣-០-៦)]

មុខវិជ្ជា ប្រវត្តិសាស្ត្រពិភពលោកបុរាណសម័យ និងមជ្ឈិមសម័យមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីការកកើត និងការវិវត្តនៃអរិយធម៌ធំៗក្នុងពិភពលោកចាប់ពីសម័យបុរេប្រវត្តិ រហូតដល់ទីបញ្ចប់នៃមជ្ឈិមសម័យនៅអឺរ៉ុប។ មុខវិជ្ជានេះផ្តោតលើ ការរៀបចំរចនាសម្ព័ន្ធសង្គម ជំនឿសាសនា ច្បាប់ និងបច្ចេកវិទ្យានៃរដ្ឋបុរាណ (អេហ្ស៊ីប ក្រិច រ៉ូម មជ្ឈិមបូព៌ ឥណ្ឌា ចិន...) ដែលជាគ្រឹះនៃពិភពលោកទំនើប។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពសិក្សាផងដែរពីការផ្លាស់ប្តូរនៃអរិយធម៌ចាប់ពីការដួលរលំនៃចក្រភពរ៉ូម ការរីកដុះដាលនៃសាសនាគ្រិស្ត និងឥស្លាម របបសក្តិភូមិ ការលេចឡើងនៃរដ្ឋ-ជាតិ(nation state)នៅអឺរ៉ុប ព្រមទាំងទំនាក់ទំនងពាណិជ្ជកម្មតាមផ្លូវសូត្រ។

៤.២.៤.១.៧. ប្រវត្តិសាស្ត្រខ្មែរសម័យទំនើប [៣ (៣-០-៦)]

មុខវិជ្ជា ប្រវត្តិសាស្ត្រខ្មែរសម័យទំនើប មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងការវិភាគស៊ីជម្រៅអំពីការប្រែប្រួលនៃរចនាសម្ព័ន្ធនយោបាយ សង្គម និងសេដ្ឋកិច្ចកម្ពុជាក្នុងសម័យទំនើប។ មុខវិជ្ជានេះផ្តោតលើរបបអាណាព្យាបាលបារាំងនិងចលនាតស៊ូដើម្បីឯករាជ្យ សម័យសង្គមរាស្ត្រនិយមនិងនយោបាយអព្យាក្រឹត របបសាធារណរដ្ឋខ្មែរនិងឥទ្ធិពលសង្គ្រាមត្រជាក់ របបកម្ពុជាប្រជាធិបតេយ្យនិងសោកនាដកម្មក្នុងសង្គមការស្តារជាតិឡើងវិញ សន្តិភាពតាមរយៈនយោបាយឈ្នះ-ឈ្នះ និងការអភិវឌ្ឍកម្ពុជាក្នុងយុគសម័យបច្ចុប្បន្ន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគ និងសន្និដ្ឋានពីរបត់នយោបាយ និងយុទ្ធសាស្ត្រដែលកម្ពុជាប្រើប្រាស់ក្នុងការរស់រាន និងអភិវឌ្ឍខ្លួនក្នុងបរិបទតំបន់ និងសកលលោក។

៤.២.៤.១.៨. ប្រវត្តិសាស្ត្រពិភពលោកសម័យទំនើប [៣ (៣-០-៦)]

មុខវិជ្ជា ប្រវត្តិសាស្ត្រពិភពលោកសម័យទំនើប មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងសមត្ថភាពវិភាគស៊ីជម្រៅអំពីការវិវត្តនៃប្រវត្តិសាស្ត្រពិភពលោកចាប់ពីបដិវត្តន៍ឧស្សាហកម្ម រហូតដល់សណ្តាប់ធ្នាប់

ពិភពលោកបច្ចុប្បន្ន។ មុខវិជ្ជានេះផ្តោតលើ ការផ្លាស់ប្តូរនៃរបបនយោបាយ មនោគមវិជ្ជា សេដ្ឋកិច្ច និងទំនាក់ទំនងអន្តរជាតិដែលបានរៀបចំទម្រង់ពិភពលោកដូចបច្ចុប្បន្នរួមមាន បដិវត្តន៍ឧស្សាហកម្មចក្រភពនិយមនិងអាណានិគមនិយមនៅអាស៊ីនិងអាហ្វ្រិក សង្គ្រាមលោកលើកទី១និងទី២ សង្គ្រាមត្រជាក់និងការបែងចែកពិភពលោក ការបង្កើតអង្គការសហប្រជាជាតិនិងដំណើរការសកលភាវូបនីយកម្ម ជម្លោះភូមិសាស្ត្រនយោបាយថ្មីៗ ការងើបឡើងនៃមហាអំណាចសេដ្ឋកិច្ចអាស៊ី និងបញ្ហាប្រឈមសកល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយពី ឫសគល់នៃបដិវត្តន៍ វិភាគឥទ្ធិពលមនោគមវិជ្ជានិងវាយតម្លៃយុទ្ធសាស្ត្ររបស់មហាអំណាច (សហរដ្ឋអាមេរិក ចិន រុស្ស៊ី ។ល។) និងតួនាទីរបស់អង្គការអន្តរជាតិ (UN និង ASEAN) ក្នុងការរក្សាសន្តិសុខសកល។

៤.២.៤.២. មុខវិជ្ជាភូមិវិទ្យា

៤.២.៤.២.១. ភូមិវិទ្យារូបទូទៅ [៣ (៣-០-៦)]

មុខវិជ្ជា ភូមិវិទ្យារូបទូទៅ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងទាក់ទងនឹងលក្ខណៈរូប និងនានាភាពដែលបានកើតឡើងនៅលើភពផែនដីយើងរស់នៅ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន សេចក្តីផ្តើមភូមិវិទ្យារូប ផែនដីជាភពដែលរីល ថាមពលព្រះអាទិត្យនិងការដុតកម្តៅបរិយាកាស ប្រព័ន្ធធាតុអាកាស អាកាសធាតុសកល រង្វង់មហាសមុទ្រ ការប្រែប្រួលអាកាសធាតុសកល ធាតុផ្សំនៃផែនដី ផ្លាកតិចតូនិក តិចតូនិក សកម្មភាពភ្នំភ្លើង របិច និងចលនាចុះជម្រាល សណ្ឋានដីកំណត់រូបរាងដោយលំហូរទឹកលើផ្ទៃទ្វីបរលក ខ្យល់បក់ ដី ភាវរស់ និងទេសភាព។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពពន្យល់ពីលក្ខណៈនិងទំហំភូមិវិទ្យារូបជាមុខវិជ្ជាវិទ្យាសាស្ត្រមួយ តាមដានពីឥទ្ធិពលនៃបម្រែបម្រួលជាប្រវត្តិសាស្ត្រចម្បងៗនិងការវិវត្តគំនិតនៅក្នុងភូមិវិទ្យានាពេលបច្ចុប្បន្ននិងពេលអនាគត ពិភាក្សាអំពីមូលហេតុដែលភូមិវិទ្យារូបមានទំនាក់ទំនងទៅនឹងបញ្ហាមនុស្ស បញ្ហាបរិស្ថានជាច្រើន និងកំណត់នូវមណ្ឌលទាំងបួនរបស់ផែនដី។

៤.២.៤.២.២. ភូមិវិទ្យាមនុស្សទូទៅ [២ (២-០-៤)]

មុខវិជ្ជា ភូមិវិទ្យាមនុស្សទូទៅ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងទូលំទូលាយអំពីមូលហេតុនៃកំណើនប្រជាជន និងផលប៉ះពាល់ព្រមទាំងមានវិធានការសមស្របក្នុងការសម្របខ្លួនទៅនឹងមជ្ឈដ្ឋានសង្គមជាក់ស្តែង។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទំនាក់ទំនងរវាងភូមិវិទ្យាមនុស្ស និងមុខវិជ្ជាដទៃទៀត ការប្រៀបធៀបភូមិវិទ្យាមនុស្សសម័យបុរាណនិងភូមិវិទ្យាមនុស្សសម័យទំនើប ការយល់ដឹងពីលក្ខណៈជាតិ ភាសា និងជំនឿសាសនានីមួយៗរបស់ប្រទេសនានានៅលើពិភពលោក។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពយល់ដឹងពីលក្ខណៈជាតិ ភាសា និងជំនឿសាសនានីមួយៗរបស់ប្រទេសនានានៅលើពិភពលោក និងយល់ដឹងពីមូលហេតុនៃកំណើនប្រជាជននិងវិធានការសមស្របក្នុងការការពារឥទ្ធិពលអាកាសធាតុលើមនុស្ស។

៤.២.៤.២.៣. ភូមិវិទ្យារូបប្រទេសកម្ពុជា [២ (២-០-៤)]

មុខវិជ្ជា ភូមិវិទ្យារូបប្រទេសកម្ពុជា មានគោលបំណងផ្តល់ដល់គរុនិស្សិតនូវចំណេះដឹងអំពីស្ថានភាពភូមិសាស្ត្រ លក្ខខ័ណ្ឌធម្មជាតិ និងសក្តានុពលសេដ្ឋកិច្ចនៃសណ្ឋានដីកម្ពុជាបានកាន់តែស៊ីជម្រៅ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទីតាំងភូមិសាស្ត្រប្រទេសកម្ពុជា សណ្ឋានដីប្រទេសកម្ពុជា អាកាសធាតុប្រទេសកម្ពុជា

និងធនធានធម្មជាតិប្រទេសកម្ពុជា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតអាចធ្វើការបកស្រាយបានពីសក្តានុពលនៃស្ថានភាពភូមិសាស្ត្រ និងលក្ខខ័ណ្ឌធម្មជាតិប្រទេសកម្ពុជា។

៤.២.៤.២.៤. ភូមិវិទ្យាសេដ្ឋកិច្ច និងមនុស្សកម្ពុជា [៣ (៣-០-៦)]

មុខវិជ្ជា ភូមិវិទ្យាសេដ្ឋកិច្ចនិងមនុស្សកម្ពុជា មានគោលបំណងផ្តល់ដល់គរុនិស្សិតនូវចំណេះដឹងអំពីស្ថានភាពភូមិសាស្ត្រ លក្ខខណ្ឌធម្មជាតិ សង្គមនិងសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន សេដ្ឋកិច្ចប្រទេសកម្ពុជា និងមនុស្សកម្ពុជា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតអាចបកស្រាយបានពីរបាយប្រជាជនទៅតាមតំបន់ភូមិសាស្ត្រនិងស្ថានភាពក្នុងសង្គមនៅក្នុងប្រទេសកម្ពុជា និងមានស្មារតីថែរក្សាការពារនិងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសុវត្ថិភាពនិងនិរន្តរភាពយូរអង្វែង។

៤.២.៤.២.៥. ផែនទីវិទ្យា [៣ (៣-០-៦)]

មុខវិជ្ជា ផែនទីវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងទូលំទូលាយពីលក្ខណៈនៃផែនទី និងបំណិនក្នុងការគូស អាន និងប្រើប្រាស់ផែនទី។ មុខវិជ្ជានេះផ្តោតលើ សញ្ញាណដំបូងនៃផែនទីវិទ្យា ប្រវត្តិវិវឌ្ឍន៍របស់ផែនទី ផែនដីភូគោលភូមិសាស្ត្រ របៀបរកទិស មូលដ្ឋានគណិតវិទ្យារបស់ផែនទី សញ្ញាផែនទី វិធីបង្ហាញនៅលើផែនទី ចំណោលផែនទី ផែនទីភូមិវិទ្យា បំណែងចែកសៀវភៅផែនទីវិទ្យា និងបំណែងចែកផែនទីភូមិវិទ្យា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពប្រៀបធៀបផែនទីវិទ្យាសម័យបុរាណ និងផែនទីវិទ្យាសម័យទំនើប និងបកស្រាយបានពីលក្ខណៈពិសេសនៃការបង្កើតនិងការប្រើប្រាស់ផែនទីប្រកបដោយភាពត្រឹមត្រូវ និងច្បាស់លាស់។

៤.២.៤.២.៦. ប្រជាសាស្ត្រ [៣ (៣-០-៦)]

មុខវិជ្ជាប្រជាសាស្ត្រមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនមូលដ្ឋានទាក់ទងនឹងទម្រង់ និងទិន្នន័យប្រជាជន។ មុខវិជ្ជានេះផ្តោតលើ បញ្ញត្តិផ្សេងៗនៃប្រជាសាស្ត្រ ប្រវត្តិប្រជាសាស្ត្រ ប្រភពទិន្នន័យប្រជាសាស្ត្រ សូចនាករប្រជាសាស្ត្រ អន្តរកាលប្រជាសាស្ត្រ ការកំណត់អាយុ (អាយុគំរូ អាយុមធ្យម អាយុមេដ្យាន) ព្រមទាំងមូលហេតុ និងផលវិបាកនៃការស្លាប់របស់កុមារ និងមាតា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពគណនាប្រភេទនៃរង្វាស់សូចនាករប្រជាសាស្ត្រ បកស្រាយពីអន្តរកាលប្រជាសាស្ត្រនៃប្រទេសមួយចំនួនលើសកលលោក ព្រមទាំងវិភាគពីផលវិបាកផ្សេងៗចំពោះសង្គមជាតិដែលបណ្តាលមកពីអត្រាមរណភាពខ្ពស់របស់កុមារ និងមាតា។

៤.២.៤.២.៧. ភូមិវិទ្យាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍ [៣ (៣-០-៦)]

មុខវិជ្ជា ភូមិវិទ្យាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនវិភាគពីកម្រិតនៃការអភិវឌ្ឍនៃបណ្តាប្រទេសនានាលើពិភពលោក តាមរយៈសូចនាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ មុខវិជ្ជានេះផ្តោតលើ បញ្ញត្តិនៃពាក្យប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ភាពខុសប្លែកគ្នា ព្រមទាំងបញ្ហាប្រឈមនានារបស់បណ្តាប្រទេសទាំងនោះ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពវិភាគ ប្រៀបធៀប និងវាយតម្លៃពីកម្រិតនៃការអភិវឌ្ឍ និងបញ្ហាប្រឈមនៃប្រទេសនានា ព្រមទាំងមានស្មារតីទទួលខុសត្រូវក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិខ្លួន។

៤.២.៥. ឯកទេសសីលធម៌ពលរដ្ឋវិជ្ជា-គេហសេដ្ឋកិច្ចវិទ្យា

៤.២.៥.១. មុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា

៤.២.៥.១.១. សញ្ញាណទស្សនវិជ្ជា [៣ (៣-០-៦)]

មុខវិជ្ជា សញ្ញាណទស្សនវិជ្ជា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋាននៃសញ្ញាណទស្សនវិជ្ជា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ធម្មជាតិនិងទីតាំងទស្សនវិជ្ជាក្នុងសង្គម វិស័យទស្សនវិជ្ជា វិធីនៃការសិក្សាអង្កេត ធម្មជាតិមនុស្ស តម្លៃ សីលវិជ្ជា ទស្សនវិជ្ជាសង្គម ទស្សនវិជ្ជានយោបាយ បញ្ហាតម្លៃនៃការបង្កើតថ្មី ល្បិចទូទៅនៃគំនិត ទំនោរធម្មជាតិមនុស្ស ឆន្ទៈ ករណីយកិច្ច កាតព្វកិច្ច ចិត្តញ្ញាណ សីលញ្ញាណ ការទទួលខុសត្រូវ និងវិបាកវិនិច្ឆ័យ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពគិតស៊ីជម្រៅពីសារៈសំខាន់របស់សញ្ញាណទស្សនវិជ្ជា ដើម្បីក្លាយជាមនុស្សប្រកបដោយគុណតម្លៃនិងអាចអភិវឌ្ឍខ្លួននៅក្នុងសង្គមបានយ៉ាងងាយស្រួល។

៤.២.៥.១.២. ប្រវត្តិទស្សនវិជ្ជាបស្ចិមប្រទេស [៣ (៣-០-៦)]

មុខវិជ្ជា ប្រវត្តិទស្សនវិជ្ជាបស្ចិមប្រទេស មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីប្រវត្តិទស្សនវិជ្ជា គំនិត និងទ្រឹស្តីរបស់ទស្សនវិទូបស្ចឹមប្រទេសក្រិកសម័យបុរាណនិងទំនើប។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការកកើតនៃទស្សនវិជ្ជាក្រិចបុរាណ ទស្សនវិជ្ជាក្រិចបុរាណសម័យនៅពេលចាប់កំណើតនៃរបបទាសភាព ទស្សនវិជ្ជាក្រិចបុរាណសម័យក្នុងពេលក្រិករុងរឿងបំផុត សម័យទ្រុឌទ្រោមនៃរបបទាសភាពនៅក្រិចបុរាណសម័យ និងទស្សនវិជ្ជាក្នុងសម័យក្រិចនីយកម្ម ព្រមទាំងសិក្សាពីទស្សនវិទូក្រិចសម័យទំនើបមួយចំនួនដូចជា ចន ឡក តូម៉ាស ហូប ហ្សង់ ហ្សាក់រូស្សូ នីកូឡូ ម៉ាកាវែល្លី រីណេដេកាត អ៊ីម៉ានុអែល កាន្ត ហេហ្គែល កាល់ ម៉ាក្ស និងចន ស្តាតមីល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតទទួលបានចំណេះដឹងមូលដ្ឋាននៃទស្សនវិជ្ជាបស្ចិមប្រទេស និងមានសមត្ថភាពយកបញ្ញត្តិនិងទ្រឹស្តីនានាទៅអនុវត្តក្នុងការបង្រៀននិងរៀន។

៤.២.៥.១.៣. ទស្សនវិជ្ជាមនុស្ស [៣ (៣-០-៦)]

មុខវិជ្ជា ទស្សនវិជ្ជាមនុស្ស មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីទិដ្ឋភាពទូទៅនៃទស្សនវិជ្ជាមនុស្ស។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន អត្ថន័យនៃទស្សនវិជ្ជា អត្ថន័យនៃទស្សនវិជ្ជាមនុស្ស បញ្ហានានាក្នុងទស្សនវិជ្ជាមនុស្ស អត្ថន័យនៃលក្ខខណ្ឌមនុស្ស មនុស្សជាការៈនៃការស្វែងរកអត្ថន័យ (អត្ថិភាពនិយម) មនុស្សជាការៈ ក្នុងពិភពលោក អត្ថន័យនៃធម្មជាតិមនុស្ស ធម្មជាតិមនុស្សយោងតាមពួកទស្សនវិទូក្រិច ធម្មជាតិមនុស្សយោងតាមអាអ៊ូហ្គូស្ទីនូសនិងអាគ្វីណាស ធម្មជាតិមនុស្សយោងតាមហ្វ្រឺដ និងធម្មជាតិមនុស្សយោងតាមពួកវិត្តនិយម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតទទួលបានចំណេះដឹងមូលដ្ឋានគ្រឹះនៃទស្សនវិជ្ជាមនុស្សនិងមាន សមត្ថភាពយកបញ្ញត្តិនិងទ្រឹស្តីនានាទៅអនុវត្តក្នុងការបង្រៀននិងរៀន។

៤.២.៥.១.៤. ទស្សនវិជ្ជាអប់រំ [៣ (៣-០-៦)]

មុខវិជ្ជា ទស្សនវិជ្ជាអប់រំ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីទិដ្ឋភាពទូទៅនៃទស្សនវិជ្ជាអប់រំសម្រាប់ការបង្រៀននិងរៀន និងឬសគល់និងភាពចាំបាច់នៃទស្សនវិជ្ជាអប់រំសម្រាប់ការ បង្រៀន និងរៀន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន លំនាំដើមនៃទស្សនវិជ្ជាអប់រំ បញ្ញត្តិអប់រំ និងប្រភេទនៃការអប់រំ ទំនាក់ទំនងរវាងមែកធាងទស្សនវិជ្ជា និងការអប់រំ ទ្រឹស្តីនៃការអប់រំ គំនិតទស្សនវិជ្ជាស្តីពីការអប់រំមនុស្សជំទង់

គរុវិទូនានា និងទ្រឹស្តីពុទ្ធិទស្សនវិទូបុរាណសម័យ ប្លាតុង គរុវិទូសម័យទំនើប(ស.វទី១៩-២០) ចនដ្យូវី ការអប់រំពលរដ្ឋប្រជាធិបតេយ្យ ចនស្ទូអាតមីល សេរីភាពនិងការអប់រំ ចនឡក គំនិតមួយចំនួនទាក់ទងនឹងការអប់រំ ប៉ៅឡូហ្វ្រៃរេ គរុកោសល្យនៃការគោបសង្កត់ ហេនហ្គច ហ្គាដេមើ ទ្រឹស្តីពុទ្ធិ និងការអប់រំ(ឯកវប្បធម៌និងពហុវប្បធម៌) អឺម៉ានុយអែល ឡឺវីណាស ការអប់រំសីលធម៌ តួនាទីគ្រូបង្រៀននិងសិស្ស(តាមគោលវិធីសិស្សមជ្ឈមណ្ឌល) កាលជេសស្តេ ជីវិតបែបទស្សនវិជ្ជា ការអប់រំសតវត្សរ៍ទី២១ ការជំរុញទឹកចិត្ត ការបង្រៀននិងការរៀន និងការអភិវឌ្ឍជំនាញការគិតប្រកបដោយការត្រិះរិះ។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតទទួលបានចំណេះដឹងមូលដ្ឋានគ្រឹះនៃទស្សនវិជ្ជាអប់រំ និងមានសមត្ថភាព យកបញ្ញត្តិ និងទ្រឹស្តីនានាទៅអនុវត្តក្នុងការបង្រៀននិងរៀន។

៤.២.៥.១.៥. ទស្សនវិជ្ជាបូព៌ាប្រទេស I [៣ (៣-០-៦)]

មុខវិជ្ជា ទស្សនវិជ្ជាបូព៌ាប្រទេស I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីទិដ្ឋភាពទូទៅនៃទស្សនវិជ្ជាបូព៌ាប្រទេស ឬសគល់សំខាន់ៗនៅក្នុងទស្សនវិជ្ជាឥណ្ឌា (ទស្សនវិជ្ជាហិណ្ឌូ ជេន ព្រះពុទ្ធ)។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទស្សនវិជ្ជាហិណ្ឌូ ទស្សនវិជ្ជាជេន និងទស្សនវិជ្ជាព្រះពុទ្ធ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតទទួលបានចំណេះដឹងមូលដ្ឋានអំពីទស្សនវិជ្ជាឥណ្ឌា ដែលជាទស្សនវិជ្ជាបូព៌ាប្រទេស និងមានសមត្ថភាព យកទ្រឹស្តីនានាទៅអនុវត្តក្នុងការបង្រៀននិងរៀន។

៤.២.៥.១.៦. ទស្សនវិជ្ជាបូព៌ាប្រទេស II [៣ (៣-០-៦)]

មុខវិជ្ជា ទស្សនវិជ្ជាបូព៌ាប្រទេស II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីឬសគល់សំខាន់ៗនៅក្នុងទស្សនវិជ្ជាបូព៌ាប្រទេសផ្នែកទី២ ដែលទាក់ទងនឹងទស្សនវិជ្ជាឥស្លាម ខុងជឺ និងទស្សនវិជ្ជាជប៉ុន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទស្សនវិជ្ជាខុងជឺ ទស្សនវិជ្ជាជប៉ុន និងទស្សនវិជ្ជាឥស្លាម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតទទួលបានចំណេះដឹងមូលដ្ឋានអំពីទស្សនវិជ្ជាបូព៌ាប្រទេសផ្នែកទី២ និងមានសមត្ថភាពយកទ្រឹស្តីនានាទៅអនុវត្តក្នុងការបង្រៀននិងរៀន។

៤.២.៥.១.៧. ទ្រឹស្តីសីលវិជ្ជា I [៣ (៣-០-៦)]

មុខវិជ្ជា ទ្រឹស្តីសីលវិជ្ជា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីអត្ថន័យនិងដើមកំណើតនៃទ្រឹស្តីសីលធម៌និងសារៈសំខាន់របស់វា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វិទ្យាសាស្ត្រសីលធម៌ គោលបំណងចុងក្រោយរបស់មនុស្ស ទង្វើរបស់មនុស្ស ចេតនា ប្រភពនៃសីលធម៌ និងធម្មជាតិនៃសីលធម៌។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតទទួលបានចំណេះដឹងមូលដ្ឋានអំពីទ្រឹស្តីសីលវិជ្ជា និងមានសមត្ថភាពយកបញ្ញាត្តិ និងទ្រឹស្តីសីលវិជ្ជាទៅអនុវត្តក្នុងការបង្រៀននិងរៀន។

៤.២.៥.១.៨. ទ្រឹស្តីសីលវិជ្ជា II [៣ (៣-០-៦)]

មុខវិជ្ជា ទ្រឹស្តីសីលវិជ្ជា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីសារៈសំខាន់នៃសីលធម៌ព្រមទាំងកាតព្វកិច្ចរបស់សីលធម៌នៅក្នុងសង្គម។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ច្បាប់ធម្មជាតិ មនសិការ កាតព្វកិច្ចសីលធម៌ វិបាកវិនិច្ឆ័យ ច្បាប់វិជ្ជមាន គុណធម៌ និងគុណធម៌៤ជាមូលដ្ឋាន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតទទួលបានចំណេះដឹងមូលដ្ឋាននៃទ្រឹស្តីសីលវិជ្ជាផ្នែកទី២ និង ចេះបង្កើតនូវតម្លៃសីលធម៌ផ្ទាល់ខ្លួនសម្រាប់អាជីពការងារ និងការវាយតម្លៃប្រកបដោយសុភវិនិច្ឆ័យនៅក្នុងជីវភាពរស់នៅក្នុងការបង្រៀន។

៤.២.៥.២. មុខវិជ្ជាគេហសេដ្ឋកិច្ចវិទ្យា

៤.២.៥.២.១. សុវត្ថិភាពចំណីអាហារ និងគេហដ្ឋាន [២ (២-០-៤)]

មុខវិជ្ជា សុវត្ថិភាពចំណីអាហារ និងគេហដ្ឋាន មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនមូលដ្ឋាននៃការរៀបចំចំណីអាហារ និងគេហដ្ឋានប្រកបដោយសុវត្ថិភាព។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន សុវត្ថិភាពចំណីអាហារនិងគេហដ្ឋាន ការតុបតែងលម្អ សោភ័ណនិងបដិសណ្ឋារកិច្ច និងគីមីអាហារ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពជ្រើសរើស និងរៀបចំចំណីអាហារ គេហដ្ឋានប្រកបដោយសុវត្ថិភាព ដែលអាចយកទៅអនុវត្តក្នុងការបង្រៀននិងរៀន និងជីវភាពរស់នៅជាក់ស្តែង។

៤.២.៥.២.២. វិជ្ជាធ្វើម្ហូប [៣ (២-២-៥)]

មុខវិជ្ជា វិជ្ជាធ្វើម្ហូប មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនមូលដ្ឋាននៃការរៀបចំគ្រឿងផ្សំ របៀបចម្អិន និងការរៀបចំអាហារ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន សម្លនំបញ្ចុក ហាហ្មុកត្រី ញាំ ភ្លាបាយសាច់មាន់ សាច់គោអាំង សង់ខ្យាល្មៅ និងបបរត្នោត។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពរៀបចំម្ហូបអាហារ បង្អែមដែលមានរសជាតិឈ្ងុយឆ្ងាញ់ អនាម័យនិងសោភណភាពតាមរយៈការអនុវត្តជាក់ស្តែង។

៤.២.៥.២.៣. វិជ្ជាដេរប៉ាក់ I [៣ (២-២-៥)]

មុខវិជ្ជា វិជ្ជាដេរប៉ាក់ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនមូលដ្ឋាននៃការដេរប៉ាក់ដោយដៃ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ថ្នេរដៃសំខាន់ៗ ថ្នេរឆិត ថ្នេរថយឡាំង ថ្នេរឆិតបង្កប់ ថ្នេរឆិតខ្វែង បំណិនមូលដ្ឋានក្នុងការប៉ាក់ក្បាច់ទូទៅ និងការប្រើប្រាស់ម្ជុលតម្កក់។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពក្នុងការដេរប៉ាក់ដោយដៃតាមរយៈការអនុវត្តជាក់ស្តែង។

៤.២.៥.២.៤. វិជ្ជាដេរប៉ាក់ II [៣ (២-២-៥)]

មុខវិជ្ជា វិជ្ជាដេរប៉ាក់ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនមូលដ្ឋាននៃការដេរដោយម៉ាស៊ីន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន មុខងារនិងរបៀបប្រើប្រាស់ម៉ាស៊ីនដេរ ការកាត់ដេរសម្ភារៈប្រើប្រាស់ងាយៗ អាវទារក និងសម្លៀកបំពាក់។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពកាត់ដេរសម្ភារៈ និងសម្លៀកបំពាក់ងាយៗ ដោយប្រើប្រាស់ម៉ាស៊ីនដេរ។

៤.២.៥.២.៥. មីក្រូសេដ្ឋកិច្ច [២ (២-០-៤)]

មុខវិជ្ជា មីក្រូសេដ្ឋកិច្ច មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនមូលដ្ឋាននៃមីក្រូសេដ្ឋកិច្ច។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ពាណិជ្ជកម្ម ទីផ្សារ ការផ្គត់ផ្គង់ តម្រូវការ ភាពយឺត និងគោលនយោបាយរបស់រដ្ឋាភិបាល ភាពលើស ភាពខ្វះ ទំនិញសាធារណៈ ធនធានរួម ថ្លៃដើម និងផលិតកម្មនៅក្នុងទីផ្សារប្រកួតប្រជែង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមាន សមត្ថភាពបកស្រាយអំពីសារៈសំខាន់ និងបញ្ហានៅក្នុងមីក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានក្នុងការសម្រេចចិត្តបានត្រឹមត្រូវលើការជ្រើសរើសទំនិញ និងសេវាកម្ម។

៤.២.៥.២.៦. ម៉ាក្រូសេដ្ឋកិច្ច [៣ (៣-០-៦)]

មុខវិជ្ជា ម៉ាក្រូសេដ្ឋកិច្ច មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនមូលដ្ឋាននៃម៉ាក្រូសេដ្ឋកិច្ច។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការវាស់វែងចំណូលចំណាយរបស់ជាតិ ផលិតកម្មនិងកំណើន

ការសន្សំ ការវិនិយោគ និកម្មភាព កំណើនលុយនិងអតិផរណា តម្រូវការនិងការផ្គត់ផ្គង់សរុប និងឥទ្ធិពល នៃគោលនយោបាយហិរញ្ញវត្ថុ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព បកស្រាយ អំពីការគ្រប់គ្រងសេដ្ឋកិច្ច និងវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាហិរញ្ញវត្ថុ។

៤.២.៥.២.៧. អាជីវកម្មខ្នាតតូច និងសហគ្រិនភាព [៣ (៣-០-៦)]

មុខវិជ្ជា អាជីវកម្មខ្នាតតូចនិងសហគ្រិនភាព មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និង បំណិនមូលដ្ឋាននៃអាជីវកម្មខ្នាតតូច និងសហគ្រិនភាព។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការវាស់វែង ការគ្រប់គ្រងបុគ្គលិក ទីផ្សារ ហិរញ្ញវត្ថុ យុទ្ធសាស្ត្រ កម្មសិទ្ធិបញ្ញានៅក្នុងអាជីវកម្មខ្នាតតូច ដំណើរការនិង ក្រមសីលធម៌នៃសហគ្រាស គ្រួសារនិងសហគ្រិនភាព ផែនការអាជីវកម្ម ផែនការយុទ្ធសាស្ត្រ ទម្រង់ម្ចាស់ អាជីវកម្មនិងអាជីវកម្មមានស្រាប់ យុទ្ធសាស្ត្រថ្លៃនិងកម្ចី ការបង្កើតផែនការហិរញ្ញវត្ថុ ការគ្រប់គ្រងលំហូរ សាច់ប្រាក់ និងធនធានហិរញ្ញវត្ថុ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំ ផែនការអាជីវកម្មបែបគ្រួសារ ឬអាជីវកម្មខ្នាតតូច។

៤.២.៦. ឯកទេសអប់រំសុខភាព-គេហសេដ្ឋកិច្ចវិទ្យា

៤.២.៦.១. មុខវិជ្ជាអប់រំសុខភាព

៤.២.៦.១.១. កាយវិភាគវិទ្យា និងសរីរវិទ្យា [២ (២-០-៤)]

មុខវិជ្ជា កាយវិភាគវិទ្យា និងសរីរវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិន មូលដ្ឋាននៃកាយវិភាគវិទ្យា និងសរីរវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទម្រង់រូបធ្មុំនៃសារពាង្គកាយ មនុស្ស ទំនាក់ទំនងរវាងរចនាសម្ព័ន្ធនិងមុខងារនៃរាងកាយមនុស្ស យន្តការនៃការរក្សាថេរលំនឹងរាងកាយ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព ពន្យល់ពីទំនាក់ទំនងរវាងទម្រង់រូបសាស្ត្រ និង មុខងារដើរសាស្ត្រនៃផ្នែកនីមួយៗរបស់មនុស្ស និងវិធានការសុខភាពនានា ដែលមានឥទ្ធិពលទៅលើជីវិតរស់នៅ ប្រចាំថ្ងៃ។

៤.២.៦.១.២. សុខភាព និងជំងឺកុមារ [៣ (៣-០-៦)]

មុខវិជ្ជា សុខភាព និងជំងឺកុមារ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនមូលដ្ឋាន ក្នុងការគាំទ្រសុខុមាលភាពកុមារ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទិដ្ឋភាពនៃសុខភាពកុមារ បរិស្ថាន ជុំវិញក្នុងការរស់នៅ ការលូតលាស់និងការអភិវឌ្ឍរបស់កុមារ ជំងឺផ្សេងៗដែលកើតមានលើកុមារ សេវា សុខាភិបាល ការថែទាំវេជ្ជសាស្ត្រ និងគោលនយោបាយសុខាភិបាលមាតានិងកុមារ។ នៅពេលបញ្ចប់មុខវិជ្ជា សិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពក្នុងការបកស្រាយពីការលូតលាស់និងការអភិឌ្ឍរបស់កុមារ និង វិធីសាស្ត្រគាំទ្រសុខភាពកុមារ។

៤.២.៦.១.៣. សុខភាព និងសុវត្ថិភាពសាលារៀន [៣ (៣-០-៦)]

មុខវិជ្ជា សុខភាពសិក្សា និងសុវត្ថិភាពសាលារៀន មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនមូលដ្ឋានពីវិធានការអនុវត្តជាក់ស្តែងនៃសុខភាពសិក្សា និងសុវត្ថិភាពសាលារៀនសម្រាប់ការលូតលាស់ និងការអភិវឌ្ឍពេញលេញរបស់កុមារ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន រចនាសម្ព័ន្ធនៃសុខភាពសិក្សា សុវត្ថិភាពសាលារៀន ទំនាក់ទំនងរវាងសុខភាពសិក្សានិងសុវត្ថិភាពសាលារៀន វិធានការអនុវត្តន៍ និងការ រៀបចំផែនការសម្រាប់សុខភាពសិក្សា និងសុវត្ថិភាពសាលារៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិត

នឹងមានសមត្ថភាពវិភាគពីសុខភាពសិក្សានិងសុវត្ថិភាពសាលារៀន និងរៀបចំផែនការអភិវឌ្ឍបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព។

៤.២.៦.១.៤. អាហារូបត្ថម្ភ មីក្រូសរីរាង្គ ការឆ្លងមេរោគ និងភាពស៊ាំ [៣ (៣-០-៦)]

មុខវិជ្ជា អាហារូបត្ថម្ភ មីក្រូសរីរាង្គ ការឆ្លងមេរោគ និងភាពស៊ាំ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនមូលដ្ឋានពីអាហារូបត្ថម្ភ និងរបាំងការពារប្រឆាំងនឹងការបង្កមេរោគនៅក្នុងរាងកាយ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន មូលដ្ឋានគ្រឹះនៃថេរលំនឹងរាងកាយ តួនាទីនៃសារធាតុ ចិញ្ចឹមសម្រាប់រាងកាយ ការឆ្លងមេរោគ ប្រព័ន្ធភាពស៊ាំរបស់សារពាង្គកាយ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយពីអាហារូបត្ថម្ភ សុវត្ថិភាពចំណីអាហារ ទំនាក់ទំនងរវាងអាហារូបត្ថម្ភនិងប្រព័ន្ធភាពស៊ាំ និងតួនាទីមីក្រូនិងម៉ាក្រូសរីរាង្គ។

៤.២.៦.១.៥. សុខភាពវ័យជំទង់ [៣ (៣-០-៦)]

មុខវិជ្ជា សុខភាពវ័យជំទង់ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនមូលដ្ឋាននៃការអភិវឌ្ឍ និងសុខភាពនៅពេលពេញវ័យ ការអប់រំសុខភាពបន្តពូជ និងផ្លូវភេទគ្រប់ជ្រុងជ្រោយ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ដំណាក់កាលនិងលក្ខណៈនៃការអភិវឌ្ឍផ្លូវចិត្តនិងរាងកាយអំឡុងវ័យជំទង់ លក្ខណៈនៃបញ្ហាសុខភាពផ្លូវចិត្តនិងរាងកាយ ដំណើរការអភិវឌ្ឍសុខភាពផ្លូវភេទនិងការមានផ្ទៃពោះ ការបង្កនិងបង្ការរោគក្នុងពេលពេញវ័យ សុខភាពផ្លូវភេទនិងបញ្ហាសង្គម និងបញ្ហាប្រឈមនិងការគាំទ្រសុខភាពវ័យជំទង់។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយពីការអភិវឌ្ឍរាងកាយ ផ្លូវភេទនិងផ្លូវចិត្ត អាកប្បកិរិយាផ្លូវភេទនិងការឆ្លងជំងឺ និងការអនុវត្តការថែទាំសុខភាពរាងកាយ សុខភាពបន្តពូជ និងសុខភាពផ្លូវចិត្ត។

៤.២.៦.១.៦. សុខភាពផ្លូវចិត្ត [៣ (៣-០-៦)]

មុខវិជ្ជា សុខភាពផ្លូវចិត្ត មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីបញ្ញត្តិនៃចិត្ត និងយន្តការនៃសុខភាពផ្លូវចិត្តដើម្បីគាំទ្រដល់ការរៀននិងបង្រៀន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន មូលដ្ឋានគ្រឹះនៃសុខភាពផ្លូវចិត្ត បញ្ហាសុខភាពផ្លូវចិត្តបច្ចុប្បន្នរបស់យុវវ័យ (ការញៀនអ៊ីនធឺណិត ការធ្វើបាបខ្លួនឯងនិងការធ្វើអត្តឃាត ការគំរាមកំហែង អំពើហិង្សា ការរំលោភបំពាន) ជំងឺផ្លូវចិត្តប្រភេទផ្សេងៗ (ជំងឺពាក់ព័ន្ធនឹងគ្រឿងស្រវឹង ឆ្កួតជ្រូក ជំងឺវង្វេង ជំងឺបាក់ស្បាត និងជំងឺវិកលចរិត ឬធ្លាក់ទឹកចិត្ត) និងផ្តល់ជំនួយគាំទ្រផ្លូវចិត្តបឋមដល់សិស្ស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានចំណេះដឹងស៊ីជម្រៅពីស្ថានភាពផ្លូវចិត្តខុសៗគ្នារបស់អ្នកសិក្សានិងអាចកែសម្រួលយុទ្ធវិធីបង្រៀន ឬការគាំទ្រឱ្យត្រូវនឹងស្ថានភាពជាក់ស្តែង និងមានសមត្ថភាពប្រើប្រាស់វិធីសាស្ត្រដោះស្រាយ ដើម្បីឆ្លើយតបនឹងតម្រូវការផ្លូវចិត្ត និងបង្កើនការយល់ដឹងពីកត្តាដែលជះឥទ្ធិពលដល់ការសិក្សាដូចជា កត្តាសង្គម និងចិត្តរំភើបជាដើម ។

៤.២.៦.១.៧. ការគ្រប់គ្រងសុខភាពសិក្សា [២ (២-០-៤)]

មុខវិជ្ជា ការគ្រប់គ្រងសុខភាពសិក្សា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនចាំបាច់សម្រាប់ការគ្រប់គ្រងសុខភាពនៅក្នុងសាលារៀន និងការឆ្លើយតបចំពោះស្ថានភាពបន្ទាន់ផ្សេងៗ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន មូលដ្ឋានគ្រឹះនៃការសង្គ្រោះបឋម បច្ចេកទេសសង្គ្រោះបឋមជាក់ស្តែង (ការអនុវត្តវិធីសាស្ត្រ PRICE, CPR....) ការតាមដានការលូតលាស់របស់កុមារ ការគ្រប់គ្រង និងសុវត្ថិភាពសាលារៀន។

នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតយល់ដឹងស៊ីជម្រៅពីរបៀបសង្គ្រោះបឋម និងការសម្រេចចិត្តបានត្រឹមត្រូវក្នុងស្ថានភាពជាក់ស្តែងប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការគ្រប់គ្រងបន្ទប់សុខភាព ដើម្បីឆ្លើយតបបានយ៉ាងសមស្រប ចំពោះកុមារដែលមាន បញ្ហាសុខភាពទាំងផ្លូវកាយ និងផ្លូវចិត្ត ព្រមទាំងអាចរៀបចំផែនការលើកកម្ពស់សុខភាព និងសុវត្ថិភាពនៅក្នុងបរិស្ថានសាលារៀនទាំងមូលបានយ៉ាងមានប្រសិទ្ធភាព។

៤.២.៦.១.៨. ការអប់រំសុខភាព [២ (២-០-៤)]

មុខវិជ្ជា អប់រំសុខភាព មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងនៃការផ្លាស់ប្តូរអាកប្បកិរិយារបស់មនុស្សទាក់ទងនឹងសុខភាពនិងការអនុវត្តទ្រឹស្តីវិទ្យាសាស្ត្រក្នុងបរិបទអប់រំ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទ្រឹស្តីវិទ្យាសាស្ត្រអាកប្បកិរិយាសុខភាព ការបង្កើតទម្លាប់រស់នៅស្អាត ការអប់រំបង្ការហានិភ័យ បរិបទវប្បធម៌សង្គម (ការសិក្សាទ្រឹស្តីអប់រំសុខភាពផ្សាភ្ជាប់នឹងប្រវត្តិវប្បធម៌របស់ប្រជាជនកម្ពុជា)។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតយល់ដឹងស៊ីជម្រៅពីទម្រង់នៃការអប់រំសុខភាពដែលសមស្រប ទៅតាមដំណាក់កាលអភិវឌ្ឍន៍ និងបរិបទសង្គមជាក់ស្តែង។ លើសពីនេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់វិធីសាស្ត្រ និងយុទ្ធវិធីអប់រំបានត្រឹមត្រូវ ដើម្បីជួយឱ្យអ្នកសិក្សាផ្លាស់ប្តូរឥរិយាបថ រស់នៅដោយមានសុខភាពល្អ និងបង្កើនការយល់ដឹងពីកត្តាសង្គមដែលជះឥទ្ធិពលដល់សុខុមាលភាពទាំងផ្លូវកាយ និងផ្លូវចិត្ត។

៤.២.៦.១.៩. សុខភាពផ្លូវចិត្ត [៣ (៣-០-៦)]

មុខវិជ្ជា សុខភាពផ្លូវចិត្ត មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីបញ្ញត្តិនៃចិត្ត និងយន្តការនៃសុខភាពផ្លូវចិត្តដើម្បីគាំទ្រដល់ការរៀននិងបង្រៀន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន មូលដ្ឋានគ្រឹះនៃសុខភាពផ្លូវចិត្ត បញ្ហាសុខភាពផ្លូវចិត្តបច្ចុប្បន្នរបស់យុវវ័យ (ការញៀនអ៊ីនធឺណិត ការធ្វើបាបខ្លួនឯងនិងការធ្វើអត្តឃាត ការគំរាមកំហែង អំពើហិង្សា ការរំលោភបំពាន) ជំងឺផ្លូវចិត្តប្រភេទផ្សេងៗ (ជំងឺពាក់ព័ន្ធនឹងគ្រឿងស្រវឹងឆ្គួតជ្រួក ជំងឺវង្វេង ជំងឺបាក់ស្បាត និងជំងឺវិកលចរិត ឬជ្រាក់ទឹកចិត្ត) និងផ្តល់ជំនួយគាំទ្រផ្លូវចិត្តបឋមដល់សិស្ស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពយល់ដឹងស៊ីជម្រៅពីស្ថានភាពផ្លូវចិត្តខុសៗគ្នារបស់អ្នកសិក្សា និងអាចកែសម្រួលយុទ្ធវិធីបង្រៀន ឬការគាំទ្រឱ្យត្រូវនឹងស្ថានភាពជាក់ស្តែង ។ លើសពីនេះគរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់វិធីសាស្ត្រដោះស្រាយ ដើម្បីឆ្លើយតបនឹងតម្រូវការផ្លូវចិត្ត និងបង្កើនការយល់ដឹងពីកត្តាដែលជះឥទ្ធិពលដល់ការសិក្សាដូចជា កត្តាសង្គម និងចិត្តរំភើបជាដើម ។

៤.២.៦.២. មុខវិជ្ជាគេហសេដ្ឋកិច្ចវិទ្យា (ដូច៤.២.៥.២. ខាងលើ)

៤.២.៧. ឯកទេសអប់រំសិល្បៈ

៤.២.៧.១. ប្រវត្តិសិល្បៈ និងមូលដ្ឋានគ្រឹះគំនូរ [២ (១-២-៣)]

មុខវិជ្ជា ប្រវត្តិសិល្បៈ និងមូលដ្ឋានគ្រឹះគំនូរ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងយ៉ាងទូលំទូលាយពីប្រវត្តិសិល្បៈ និងគោលការណ៍សំខាន់ៗនៃការគូរគំនូរសម្រាប់ការបង្រៀន និងរៀន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន សញ្ញាណនៃសិល្បៈខ្មែរនិងសកលលោក ការវិវត្តនៃសិល្បៈខ្មែរនិងសកលលោក ភាពខុសគ្នានៃរចនាបថមួយទៅរចនាបថមួយ ទិដ្ឋភាពទូទៅនៃសិល្បៈសកលលោកនិងសិល្បៈខ្មែរ ភាពខុសគ្នានៃសិល្បៈពីប្រទេសមួយទៅប្រទេសមួយ ភាពស្រស់ស្អាតនៃសិល្បៈ គំនូសបន្ទាត់ រូបរាង ទម្រង់ ការផ្ទុំទម្រង់ ការវាស់ប៉ាន់ប្រមាណ ការរៀបចំប្លង់ នេត្រាទស្សន៍ ពន្លឺស្រមោល កាយវិភាគសាស្ត្រពណ៌។ នៅពេលបញ្ចប់

មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានចំណេះដឹងមូលដ្ឋានផ្នែកប្រវត្តិសិល្បៈ និងមូលដ្ឋានគ្រឹះគំនូរសម្រាប់យកទៅអនុវត្តក្នុងការបង្រៀន និងរៀន។

៤.២.៧.២. មូលដ្ឋានគ្រឹះហត្ថកម្ម [២ (១-២-៣)]

មុខវិជ្ជា មូលដ្ឋានគ្រឹះហត្ថកម្ម មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនទាក់ទងនឹងការវិវត្តនៃហត្ថកម្មបែបប្រពៃណីនិងទំនើប និងការបង្កើតគំនិតច្នៃប្រឌិតពាក់ព័ន្ធទាំងហត្ថកម្មបែបប្រពៃណី និងហត្ថកម្មទំនើបសម្រាប់ការបង្រៀននិងរៀននៅអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន សញ្ញាណនៃសិល្បៈខ្មែរនិងសកលដៃល្អរួមគ្នាក្នុងការបង្កើតគំនិតថ្មីមួយផ្សេងទៀត និងបច្ចេកទេសក្នុងការកាត់បិតបត់ ផ្គុំតភ្ជាប់ដោយប្រើវត្ថុធាតុដើម និងវត្ថុធាតុដៃលអាចកែរច្នៃប្រើប្រាស់ឡើងវិញ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព វិភាគ និងបង្កើតស្នាដៃហត្ថកម្មសម្រាប់ការបង្រៀននិងរៀនស្របតាមតម្រូវការរបស់សិស្ស ព្រមទាំងផ្តល់តម្លៃដល់ការការពារបរិស្ថាន និងថែរក្សាវប្បធម៌ប្រពៃណី។

៤.២.៧.៣. ប្រវត្តិសិល្បៈ និងមូលដ្ឋានគ្រឹះតន្ត្រី [៣ (២-២-៥)]

មុខវិជ្ជា ប្រវត្តិសិល្បៈ និងមូលដ្ឋានគ្រឹះតន្ត្រី មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនទាក់ទងនឹងការវិវត្តនៃតន្ត្រីតាមសម័យកាលនីមួយៗជុំវិញពិភពលោក និងប្រើឧបករណ៍ភ្លេងសម្រាប់បង្រៀននិងរៀននៅអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការវិវត្តនៃតន្ត្រី សញ្ញាណទូទៅនៃ អក្សរភ្លេង ខ្នាតចង្វាក់ និងការប្រើប្រាស់ឧបករណ៍ភ្លេង (ផ្តោតលើឧបករណ៍ព្យាណូ) និងវិធីសាស្ត្របង្រៀនតន្ត្រី។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពពន្យល់ពីការវិវត្តតន្ត្រី និងប្រើឧបករណ៍ភ្លេង (ព្យាណូ) និងវិធីសាស្ត្របង្រៀនតន្ត្រី កម្រិតមូលដ្ឋាននៅអនុវិទ្យាល័យ។

៤.២.៧.៤. ប្រវត្តិសិល្បៈ និងមូលដ្ឋានគ្រឹះរបាំ [៣ (២-២-៥)]

មុខវិជ្ជា ប្រវត្តិសិល្បៈ និងមូលដ្ឋានគ្រឹះរបាំ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនទាក់ទងនឹងទម្រង់របាំខ្មែរ និងដំណើរវិវត្តន៍នៃទម្រង់ក្បាច់ខ្នាតជ័ត្រឹមត្រូវរបស់វប្បធម៌ប្រពៃណីខ្មែរ។ មុខវិជ្ជានេះផ្តោតលើ ប្រវត្តិសិល្បៈរបាំ ក្បាច់បាតរបាំ ដៃលមានបញ្ចូលចលនាក្បាច់ដៃ ក្បាល ដងខ្លួន ជើង និងការរៀបចំលំហនៃការសម្តែង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្រៀនក្បាច់បាតរបាំដៃលងាយយល់។

៤.២.៧.៥. មូលដ្ឋានគ្រឹះគំនូរពណ៌ [៣ (២-២-៥)]

មុខវិជ្ជា មូលដ្ឋានគ្រឹះគំនូរពណ៌ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនទាក់ទងនឹងទ្រឹស្តីពណ៌ ការអនុវត្តលាយពណ៌ និងគូរគំនូរសម្រាប់គាំទ្រការបង្រៀននិងរៀននៅអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទ្រឹស្តីពណ៌ របៀបលាយពណ៌ផ្សេង ការប្រើប្រាស់ជក់ ឬឧបករណ៍គូរ អនុវត្តបច្ចេកទេសលាយពណ៌ និងបញ្ចូលពណ៌។ នៅពេលបញ្ចប់ការសិក្សាមុខវិជ្ជានេះ គរុនិស្សិតមានសមត្ថភាពពន្យល់ទ្រឹស្តីពណ៌ និងគូរគំនូរពណ៌បានត្រឹមត្រូវ។

៤.២.៧.៦. ហត្ថកម្មបែបប្រពៃណី [៣ (២-២-៥)]

មុខវិជ្ជា ហត្ថកម្មបែបប្រពៃណី មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនទាក់ទងនឹងការជ្រើសរើសសម្ភារៈ អនុវត្តតាមបច្ចេកទេសប្រពៃណី និងបង្កើតគំនិតច្នៃប្រឌិត ព្រមទាំងចូលរួមថែរក្សាការពារវប្បធម៌ប្រពៃណីជាតិ សម្រាប់ការបង្រៀននិងរៀននៅអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើ

ខ្លឹមសាររួមមាន ការណែនាំទូទៅអំពីហត្ថកម្មបែបប្រពៃណី និយមន័យ និងសារៈសំខាន់ ប្រភេទនៃហត្ថកម្ម ក្នុងស្រុក តម្លៃវប្បធម៌ និងប្រពៃណីជាតិសម្ភារៈ និងឧបករណ៍ ប្រភេទសម្ភារៈធម្មជាតិ (ឈើ ស្លឹកឈើ ខ្សាច់ ស្មៅ ក្រដាស...) ឧបករណ៍ប្រើប្រាស់ (កន្ត្រៃ ការ៉ ខ្សែ ដៃកចាក់...) វិធីប្រើប្រាស់ និងការថែរក្សាបច្ចេកទេសមូលដ្ឋាន ការកាត់ បិទ បត់ និងត្បាញ ការដេរ និងការចង ការតុបតែង និងការរៀបចំរូបរាង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពពន្យល់ពីសារៈសំខាន់នៃហត្ថកម្មបែបប្រពៃណី និងតម្លៃវប្បធម៌ជាតិ ស្គាល់ប្រភេទ សម្ភារៈ និងឧបករណ៍ ប្រើក្នុងហត្ថកម្ម ស្គាល់ជំហានមូលដ្ឋានក្នុងការបង្កើតស្នាដៃបែបប្រពៃណី អនុវត្តការបង្កើតស្នាដៃដោយដៃ តាមបែបប្រពៃណី ប្រើប្រាស់សម្ភារៈ និងឧបករណ៍បានយ៉ាងមានសុវត្ថិភាព មានភាពច្នៃប្រឌិត និងការតុបតែង នៅក្នុងស្នាដៃ អាចធ្វើការងារជាក្រុម។

៤.២.៧.៧. ឧបករណ៍ភ្លេង និងចម្រៀង [៣ (២-២-៥)]

មុខវិជ្ជា ឧបករណ៍ភ្លេង និងចម្រៀង មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនអំពីឧបករណ៍ភ្លេង និងចម្រៀង ឧបករណ៍ភ្លេងដែលមានភាពស្រដៀងគ្នាជាមួយឧបករណ៍ភ្លេងខ្មែរ នៅតាមតំបន់សំខាន់ៗជុំវិញពិភពលោកដូចជានៅទ្វីបអាមេរិច តំបន់មេហ្សូប៉ូតាមា បច្ចឹមប្រទេស និងអាស៊ី។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការស្តាប់ ចង្វាក់ អក្សរភ្លេង និងពេល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពបែងចែកនិងកំណត់បានត្រឹមត្រូវអំពីប្រភេទឧទបករណ៍ភ្លេង និងសហការគ្នាក្នុងការអនុវត្តបានត្រឹមត្រូវតាមរយៈការស្តាប់ចង្វាក់ ពេលវេលា នៃអក្សរភ្លេងនីមួយៗ។

៤.២.៧.៨. របាំព្រះរាជទ្រព្យ [៣ (២-២-៥)]

មុខវិជ្ជា របាំព្រះរាជទ្រព្យ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីទ្រឹស្តីមូលដ្ឋាននៃរបាំបុរាណខ្មែរ ចលនាក្បាច់ដៃ ជើង ដងខ្លួន ដែលជាភាសាកាយវិការ នឹងអាចបង្រៀនបានតាមកម្មវិធីសិក្សា។ មុខវិជ្ជានេះផ្តោតលើ ក្បាច់បាតមូលដ្ឋានរបាំបុរាណ អត្ថន័យក្បាច់ ចលនា និងសម្លៀកបំពាក់។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពបង្រៀនរបាំបុរាណខ្មែរ ចែករំលែកបន្តទៅសហគមន៍ និងមានស្មារតីថែរក្សារបាំបុរាណខ្មែរ។

៤.២.៧.៩. គំនូរពណ៌ប្រេង [៣ (២-២-៥)]

មុខវិជ្ជា គំនូរពណ៌ប្រេង មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិន ក្នុងការប្រើប្រាស់ពណ៌ប្រេងដើម្បីបង្កើតស្នាដៃគំនូរ អភិវឌ្ឍការច្នៃប្រឌិត ភាពប៉ិនប្រសប់ក្នុងការសង្កេត ព្រមទាំងយល់ដឹងពីតម្លៃសិល្បៈ និងវប្បធម៌។ មុខវិជ្ជានេះ ផ្តោតលើ លក្ខណៈនៃពណ៌ប្រេង ឧបករណ៍ប្រើប្រាស់ បច្ចេកទេសលាយពណ៌ ការបង្កើតពន្លឺនិងស្រមោល ការរៀបចំប្លង់ និងការគូររូបធម្មជាតិ មនុស្ស សត្វ ទេសភាព ដើម្បីបង្ហាញពីអារម្មណ៍និងគំនិត។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាព គូរគំនូរពណ៌ប្រេងបានត្រឹមត្រូវ បង្កើតស្នាដៃផ្ទាល់ខ្លួនសម្រាប់តាំងពិព័រណ៍ឬប្រកបជាអាជីព និងអាចបង្រៀនមុខវិជ្ជានេះប្រកបដោយប្រសិទ្ធភាព។

៤.២.៧.១០. ហត្ថកម្មបង្គុំសម្ភារៈប្រើប្រាស់ [៣ (២-២-៥)]

មុខវិជ្ជា ហត្ថកម្មបង្គុំសម្ភារៈប្រើប្រាស់ (Craft Materials and Tools) មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការផ្សារភ្ជាប់ជំនាញសិល្បៈហត្ថកម្មទៅនឹងវិស័យស្ថាបត្យកម្ម តាមរយៈការសិក្សាទ្រឹស្តី និងការអនុវត្តបច្ចេកទេសផ្តុំដោយប្រើប្រាស់សម្ភារៈងាយៗ ឬសម្ភារៈកែច្នៃឡើងវិញ។ មុខវិជ្ជានេះផ្តោតលើការសិក្សាពីបច្ចេកទេសបង្គុំសំណង់ស្ថាបត្យកម្មពីបុរាណ ការច្នៃប្រឌិតសម្ភារៈដែលអាចប្រើប្រាស់ឡើងវិញ

បច្ចេកទេសផ្គុំសម្ភារៈឱ្យបានត្រឹមត្រូវនិងរឹងមាំ ការវាយតម្លៃស្នាដៃ ព្រមទាំងការចែករំលែកបទពិសោធតាមរយៈការធ្វើបទបង្ហាញ និងវិធីសាស្ត្របង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាព បង្កើតស្នាដៃគំរូសំណង់ស្ថាបត្យកម្ម (ដោយប្រើប្រាស់ក្រដាស កំណាត់ឈើ ឬឫស្សីជាដើម) អាចចងក្រងជាឯកសារស្រាវជ្រាវខ្លី។ ព្រមទាំងអាចដោះស្រាយបញ្ហាប្រឈម និងចែករំលែកចំណេះដឹងនេះបន្តដល់សិស្សបានយ៉ាងល្អប្រសើរ។

៤.២.៧.១១. ការប្រគុំតន្ត្រី និងចម្រៀង [៣ (២-២-៥)]

មុខវិជ្ជា ការប្រគុំតន្ត្រី និងចម្រៀង មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិន ក្នុងការសហការគ្នាប្រគុំតន្ត្រីនិងច្រៀងរួមគ្នាប្រកបដោយភាពសប្បាយរីករាយ បច្ចេកទេសប្រើប្រាស់ឧបករណ៍តន្ត្រីចម្រុះ ព្រមទាំងការតាក់តែងអត្ថបទចម្រៀងថ្មីដោយផ្អែកលើលំនាំដើម (ដូចជាបទអបអរសាទរ ឬបទនគររាជជាដើម)។ មុខវិជ្ជានេះផ្តោតលើ ការអាននិងសង្កេតអក្សរភ្លេង (ណោតភ្លេង) ការកំណត់ពេលវេលានិងចង្វាក់ ព្រមទាំងការហ្វឹកហាត់លេងឧបករណ៍តន្ត្រីបណ្តើរនិងច្រៀងរួមគ្នាបណ្តើរ។ នៅពេលបញ្ចប់ មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាព សហការគ្នាជាក្រុមតូចដើម្បីប្រគុំតន្ត្រី និងច្រៀងបទចម្រៀងដែលបានរៀនរួចយ៉ាងស្ទាត់ជំនាញ ព្រមទាំងអាចតាក់តែងអត្ថបទចម្រៀងខ្លីៗប្រចាំក្រុមនីមួយៗបានយ៉ាងល្អប្រសើរ។

៤.២.៧.១២. របាំប្រពៃណី [៣ (២-២-៥)]

មុខវិជ្ជា របាំប្រជាប្រិយ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីប្រពៃណីទំនៀមទម្លាប់ប្រជាជនតាមតំបន់នានាទូទាំងប្រទេស បច្ចេកទេសរបាំ និងចូលរួមចំណែកថែរក្សាសម្បត្តិមរតកដូនតាខ្មែរ។ មុខវិជ្ជានេះផ្តោតលើ ការហ្វឹកហាត់ចលនាចង្វាក់ទៅតាមក្បួនខ្នាតបច្ចេកទេសជាក់លាក់ ការបែងចែកក្រុមសិក្សាស្រាវជ្រាវលើរបាំប្រពៃណីណាមួយ ព្រមទាំងការធ្វើបទបង្ហាញពីបច្ចេកទេសនិងវិធីសាស្ត្រក្នុងការបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាព សម្តែងរបាំប្រជាប្រិយដែលបានជ្រើសរើសបានយ៉ាងរស់រវើក ចងក្រងជាឯកសារស្រាវជ្រាវខ្លីៗអំពីរបាំ ព្រមទាំងទទួលបានវិធីសាស្ត្រច្បាស់លាស់សម្រាប់យកទៅបង្រៀនសិស្សបន្តបានយ៉ាងមានប្រសិទ្ធភាព។

៤.២.៧.១៣. ស្នាដៃគំនូរ និងពិព័រណ៍ [៣ (២-២-៥)]

មុខវិជ្ជា ស្នាដៃគំនូរ និងពិព័រណ៍ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការបង្កើតស្នាដៃសិល្បៈគំនូរ ដឹកនាំការងារសិល្បៈ និងរៀបចំកម្មវិធីពិព័រណ៍ស្នាដៃសិល្បៈនៅក្នុងគ្រឹះស្ថានសិក្សាឬសហគមន៍។ មុខវិជ្ជានេះផ្តោតលើ ការអភិវឌ្ឍសមត្ថភាពកម្រិតខ្ពស់ក្នុងការបង្កើត "ស្នាដៃគំនូរឯក" ដោយរួមបញ្ចូលទ្រឹស្តីសិល្បៈ បច្ចេកទេសពណ៌ ការបញ្ចេញមតិច្នៃប្រឌិត និងយុទ្ធសាស្ត្រនៃការរៀបចំពិព័រណ៍សិល្បៈ (ចាប់ពីការជ្រើសរើសប្រធានបទ ការរៀបចំទីតាំង ការតាំងបង្ហាញ រហូតដល់ការវាយតម្លៃសោភ័ណភាព)។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាព វិភាគនិងអនុវត្តទ្រឹស្តីសោភ័ណភាពដើម្បីបង្កើតស្នាដៃសិល្បៈ (Art Series) ដែលឆ្លុះបញ្ចាំងពីអត្តសញ្ញាណផ្ទាល់ខ្លួន រៀបចំនិងគ្រប់គ្រងពិព័រណ៍សិល្បៈដោយជោគជ័យ ព្រមទាំងអាចវាយតម្លៃនិងរិះគន់ស្នាដៃសិល្បៈ (Art Criticism) ប្រកបដោយវិជ្ជាជីវៈ។

៤.២.៧.១៤. ការនិពន្ធតន្ត្រី [៣ (២-២-៥)]

មុខវិជ្ជា ការនិពន្ធតន្ត្រី មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិន ក្នុងការរៀបចំសំឡេងប្រកបដោយភាពច្នៃប្រឌិត ដើម្បីបង្កើតជាស្នាដៃតន្ត្រីថ្មីមួយដែលអាចប្រើប្រាស់បានជាទូទៅក្នុងទម្រង់ខ្លីៗនិងងាយៗ។ មុខវិជ្ជានេះផ្តោតលើ ការស្វែងយល់ពីទ្រឹស្តីតន្ត្រី ការអនុវត្តប្រើប្រាស់ឧបករណ៍តន្ត្រី ការអភិវឌ្ឍ

បំណិនស្តាប់និងស្រាវជ្រាវ ការបង្កើតចង្វាក់ ភ្លេង រចនាសម្ព័ន្ធតន្ត្រី ព្រមទាំងការចងក្រងកំណត់ចំណាំ (តន្ត្រីសន្លឹក) ឬថតសំឡេងដើម្បីបង្ហាញអារម្មណ៍និងរឿងរ៉ាវ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពបង្កើតស្នាដៃតន្ត្រីថ្មីមួយផ្ទាល់ខ្លួនដែលមានចរិតអប់រំសម្រាប់សិស្សអនុវិទ្យាល័យ។

៤.២.៧.១៥. របាំប្រជាប្រិយ [៣ (២-២-៥)]

មុខវិជ្ជា របាំប្រជាប្រិយ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិន ក្នុងការស្វែងយល់អំពីវប្បធម៌និងប្រពៃណីជាតិ បណ្តុះសមត្ថភាពពាំនិងការសម្តែង អភិវឌ្ឍភាពជឿជាក់ ការងារជាក្រុម ព្រមទាំងចូលរួមថែរក្សានិងបង្រៀនបន្ត។ មុខវិជ្ជានេះផ្តោតលើ ប្រវត្តិនៃរបាំប្រជាប្រិយ ប្រភេទរបាំ ក្បាច់របាំមូលដ្ឋាន លំហាត់រាំនិងការសម្តែងជាក្រុម។នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពពន្យល់អំពីប្រវត្តិនិងសារៈសំខាន់នៃរបាំប្រជាប្រិយ បង្ហាញក្បាច់របាំមូលដ្ឋានបានត្រឹមត្រូវ ចូលរួមសម្តែងជាក្រុមបានយ៉ាងល្អ ព្រមទាំងចេះគោរពនិងចូលរួមថែរក្សាវប្បធម៌ជាតិ។

៤.២.៨. ឯកទេសភាសាអង់គ្លេស-បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

៤.២.៨.១. មុខវិជ្ជាភាសាអង់គ្លេស

៤.២.៨.១.១. Core English I [៣ (៣-០-៦)]

Core English I aims to provide student teachers with fundamental knowledge of using the English language at the pre-intermediate level. The content of this course includes grammar, pronunciation, vocabulary, and the four macro skills: listening, speaking, reading, and writing. By the end of this course, student teachers will be competent in using the English language for communication in their daily life.

មុខវិជ្ជា Core English I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងក្នុងការប្រើភាសាអង់គ្លេសកម្រិត pre-intermediate។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វេយ្យាករណ៍ ការបញ្ចេញសំឡេង វាក្យសព្ទ និងជំនាញសំខាន់ៗទាំងបួន៖ ស្តាប់ និយាយ អាន និងសរសេរ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងក្នុងជីវភាពប្រចាំថ្ងៃ។

៤.២.៨.១.២. Core English II [៣ (៣-០-៦)]

Core English II aims to provide student teachers with fundamental knowledge of using the English language at the intermediate level. The content of this course includes grammar, pronunciation, vocabulary, and the four macro skills: listening, speaking, reading, and writing. By the end of this course, student teachers will be competent in using the English language for communication in their daily life.

មុខវិជ្ជា Core English II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងនៃការប្រើភាសាអង់គ្លេសកម្រិត intermediate។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វេយ្យាករណ៍ ការបញ្ចេញសំឡេង វាក្យសព្ទ និងជំនាញ សំខាន់ៗទាំងបួន៖ ស្តាប់ និយាយ អាន និងសរសេរ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងក្នុងជីវភាពប្រចាំថ្ងៃ។

៤.២.៨.១.៣. Core English III [២ (២-០-៤)]

Core English III aims to provide student teachers with fundamental knowledge of using the English language at the upper-intermediate level. The content of this course includes

grammar, pronunciation, vocabulary, and the four macro skills: listening, speaking, reading, and writing. By the end of this course, student teachers will be competent in using the English language for communication in their daily life.

មុខវិជ្ជា Core English III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងនៃការប្រើភាសាអង់គ្លេសកម្រិត upper-intermediate។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វេយ្យាករណ៍ ការបញ្ចេញសំឡេង វាក្យសព្ទ និងជំនាញសំខាន់ៗទាំងបួន៖ ស្តាប់ និយាយ អាន និងសរសេរ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមាន សមត្ថភាពប្រើភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងក្នុងជីវភាពប្រចាំថ្ងៃ។

៤.២.៨.១.៤. Core English IV [២ (២-០-៤)]

Core English IV aims to provide student teachers with fundamental knowledge of using the English language at the advanced level. The content of this course includes grammar, pronunciation, vocabulary, and the four macro skills: listening, speaking, reading, and writing. By the end of this course, student teachers will be competent in using the English language for communication in their daily life.

មុខវិជ្ជា Core English IV មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងនៃការប្រើភាសាអង់គ្លេសកម្រិត advanced។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វេយ្យាករណ៍ ការបញ្ចេញសំឡេង វាក្យសព្ទ និងជំនាញសំខាន់ៗទាំងបួន៖ ស្តាប់ និយាយ អាន និងសរសេរ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមាន សមត្ថភាពប្រើភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងក្នុងជីវភាពប្រចាំថ្ងៃ។

៤.២.៨.១.៥. Cultural Studies [៣ (៣-០-៦)]

Cultural Studies aims to provide student teachers with knowledge of diverse cultures. The content of this course includes respect, social communication, history, religion, and the identities of cultural diversity. By the end of this course, student teachers will be able to interpret multicultural concepts and how culture influences education.

មុខវិជ្ជា Cultural Studies មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីវប្បធម៌ចម្រុះ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការគោរព ទំនាក់ទំនងសង្គម ប្រវត្តិសាស្ត្រ សាសនា និងអត្តសញ្ញាណនៃវប្បធម៌ចម្រុះ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបកស្រាយបញ្ហាត្តិផ្សេងៗទាក់ទងនឹងវប្បធម៌ ចម្រុះ និងរបៀបដែលវប្បធម៌មានឥទ្ធិពលលើការអប់រំ។

៤.២.៨.១.៦. Literature Studies [៣ (៣-០-៦)]

Literature Studies aims to cultivate a deep understanding of literary texts through critical thinking and the exploration of historical, cultural, and social contexts. The content of this course includes the study of a diverse range of literary works, including folklore, short stories, and narratives. By the end of this course, student teachers will have gained the ability to analyze literary works scientifically, interpret personal perspectives with clarity, and appreciate linguistic nuances—forming an essential foundation for advanced literary studies and related fields.

មុខវិជ្ជា Literature Studies មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីអត្ថបទអក្សរសិល្ប៍តាមរយៈការគិតបែបស៊ីជម្រៅនិងការស្វែងយល់អំពីបរិបទប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គម។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ស្នាដៃអក្សរសិល្ប៍ចម្រុះ រួមមានរឿងព្រេងនិទាន រឿងខ្លី និងនិទានកថាផ្សេងៗ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគស្នាដៃអក្សរសិល្ប៍តាមបែបវិទ្យាសាស្ត្រ ការបកស្រាយទស្សនទានផ្ទាល់ខ្លួនប្រកបដោយភាពច្បាស់លាស់ និងការផ្តល់តម្លៃលើការប្រើភាសា ដែលជាមូលដ្ឋានគ្រឹះសម្រាប់ត្រៀមលក្ខណៈឆ្ពោះទៅរកការសិក្សាអក្សរសិល្ប៍កម្រិតខ្ពស់ និងមុខវិជ្ជាជំទៃទៀតដែលពាក់ព័ន្ធ។

៤.២.៨.១.៧. Academic Writing I [៣ (២-២-៥)]

Academic Writing I aims to provide knowledge and skills in sentence writing for student teachers. The content of this course covers a solid foundation in grammatical areas and sentence elements, including verb forms, parts of speech, clause and sentence structures, punctuations, linking words, elements and types of sentences. By the end of this course, student teachers will gain the ability to construct sentences accurately and appropriately.

មុខវិជ្ជា Academic Writing I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនសរសេរល្អ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន មូលដ្ឋានគ្រឹះវេយ្យាករណ៍និងសមាសធាតុនៃប្រយោគ៖ ទម្រង់កិរិយាសព្ទ ថ្នាក់ពាក្យ សម្ព័ន្ធល្អ វណ្ណយុត្ត ពាក្យឬឃ្លាភ្ជាប់សេចក្តី ធាតុនិងប្រភេទនៃល្អ។ នៅពេលបញ្ចប់ មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពក្នុងការសរសេរល្អបានត្រឹមត្រូវ។

៤.២.៨.១.៨. Academic Writing II [៣ (២-២-៥)]

Academic Writing II aims to provide knowledge and skills in sentence writing for student teachers. The content of this course covers elements and types of paragraphs. By the end of this course, student teachers will gain the ability to construct paragraphs accurately and appropriately.

មុខវិជ្ជា Academic Writing II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនសរសេរកថាខណ្ឌ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ធាតុ និងប្រភេទកថាខណ្ឌ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពក្នុងការសរសេរកថាខណ្ឌបានត្រឹមត្រូវ។

៤.២.៨.១.៩. Academic Writing III [២ (១-២-៣)]

Academic Writing III aims to provide knowledge and skills in sentence writing for student teachers. The content of this course covers elements and types of essays. By the end of this course, student teachers will gain the ability to construct essays accurately and appropriately.

មុខវិជ្ជា Academic Writing III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនសរសេរកថាខណ្ឌ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ធាតុ និងប្រភេទតែងសេចក្តី។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពក្នុងការសរសេរតែងសេចក្តីបានត្រឹមត្រូវ។

៤.២.៨.២. មុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

៤.២.៨.២.១. ការណែនាំអំពីវិទ្យាសាស្ត្រកុំព្យូទ័រ [២ (២-០-៤)]

មុខវិជ្ជា ការណែនាំអំពីវិទ្យាសាស្ត្រកុំព្យូទ័រ មានគោលបំណងផ្តល់ឱ្យគុរុនិស្សិតនូវចំណេះដឹងអំពីគោលគំនិត គោលការណ៍គ្រឹះនៃវិទ្យាសាស្ត្រកុំព្យូទ័រ និងរបៀបអនុវត្តទ្រឹស្តីវិទ្យាសាស្ត្រកុំព្យូទ័រក្នុងការបង្រៀន និងរៀន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារសំខាន់ៗរួមមាន បដិវត្តកម្មកុំព្យូទ័រ គណិតវិទ្យាសម្រាប់កុំព្យូទ័រ ស្ថាបត្យកម្មកុំព្យូទ័រ ប្រព័ន្ធប្រតិបត្តិការ បណ្តាញនិងអ៊ីនធឺណិត វិធីសាស្ត្រដោះស្រាយ ភាសាសរសេរកម្មវិធី ទិន្នន័យអរូបីយ ប្រព័ន្ធមូលដ្ឋានទិន្នន័យ វិស្វកម្មសុសវែរនិងការគ្រប់គ្រងគម្រោង កុំព្យូទ័រក្រាហ្វិក បញ្ញាសិប្បនិម្មិត។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គុរុនិស្សិតនឹងយល់ដឹងស៊ីជម្រៅអំពីគោលការណ៍ស្នូលនៃវិទ្យាសាស្ត្រកុំព្យូទ័រចាប់ពីគណិតវិទ្យាមូលដ្ឋាន និងស្ថាបត្យកម្មកុំព្យូទ័រ រហូតដល់ប្រធានបទកម្រិតខ្ពស់ដូចជាការសរសេរកូដកម្មវិធី និងបញ្ញាសិប្បនិម្មិត។

៤.២.៨.២.២. ការថែទាំ និងជួសជុលកុំព្យូទ័រ [២ (១-២-៣)]

មុខវិជ្ជា ការថែទាំនិងជួសជុលកុំព្យូទ័រ មានគោលបំណងផ្តល់ឱ្យគុរុនិស្សិតនូវចំណេះដឹង និងជំនាញក្នុងការដំឡើង ថែទាំ គ្រប់គ្រង ជួសជុលប្រព័ន្ធកុំព្យូទ័រ និងដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងកុំព្យូទ័រ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារសំខាន់ៗរួមមាន សមាសភាគកុំព្យូទ័រ សុវត្ថិភាពនិងការថែទាំហាដវែរនិងសុសវែរ និងដំណោះស្រាយបញ្ហាផ្សេងៗទាក់ទងនឹងហាដវែរនិងសុសវែរ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គុរុនិស្សិតមានសមត្ថភាពថែទាំនិងជួសជុលកុំព្យូទ័រប្រកបដោយសុវត្ថិភាព។

៤.២.៨.២.៣. ការណែនាំអំពីមូលដ្ឋានទិន្នន័យ [៣ (២-២-៥)]

មុខវិជ្ជា ការណែនាំអំពីមូលដ្ឋានទិន្នន័យ មានគោលបំណងផ្តល់ឱ្យគុរុនិស្សិតនូវចំណេះដឹង និងជំនាញក្នុងការរៀបចំមូលដ្ឋានទិន្នន័យ កំណត់រចនាសម្ព័ន្ធទិន្នន័យ និងការគ្រប់គ្រងទិន្នន័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារសំខាន់ៗរួមមាន គំរូទំនាក់ទំនង (Relational Model) ភាសារុករកទិន្នន័យ (Structured Query Language) និងការណែនាំអំពីការសរសេរកម្មវិធីគេហទំព័រផ្ទាល់ខ្លួនផ្នែកសៀវភៅណ៍ (Personal Home Page)។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គុរុនិស្សិតនឹងមានសមត្ថភាពរៀបចំមូលដ្ឋានទិន្នន័យ និងការកំណត់រចនាសម្ព័ន្ធទិន្នន័យបានច្បាស់លាស់។

៤.២.៨.២.៤. ការអប់រំពហុមេឌា [៣ (២-២-៥)]

មុខវិជ្ជា ការអប់រំពហុមេឌា មានគោលបំណងផ្តល់ឱ្យគុរុនិស្សិតនូវចំណេះដឹង និងជំនាញជាមូលដ្ឋានក្នុងការអនុវត្តផ្នែកពហុមេឌា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារសំខាន់ៗរួមមាន ការណែនាំអំពីគោលការណ៍និងការប្រើប្រាស់ពហុមេឌា ការអនុវត្តជាក់ស្តែងផ្នែកក្រាហ្វិកកុំព្យូទ័រដោយប្រើប្រាស់កម្មវិធី Adobe Photoshop និងការសិក្សាអំពីមូលដ្ឋានគ្រឹះនៃការសរសេរកូដកម្មវិធីវេបសាយ រួមមាន HTML CSS និង JavaScript។ នៅពេលបញ្ចប់មុខវិជ្ជានេះ គុរុនិស្សិតនឹងមានសមត្ថភាពបង្កើត កែសម្រួល និងប្រើប្រាស់ពហុមេឌាក្នុងបរិយាកាសឌីជីថល។

៤.២.៨.២.៥. ទំនាក់ទំនងទិន្នន័យ និងបណ្តាញកុំព្យូទ័រ [៣ (២-២-៥)]

មុខវិជ្ជា ទំនាក់ទំនងទិន្នន័យនិងបណ្តាញកុំព្យូទ័រ មានគោលបំណងផ្តល់ឱ្យគុរុនិស្សិតនូវចំណេះដឹងនិងជំនាញអំពីគំរូ OSI និង TCP/IP បច្ចេកវិទ្យាសម្រាប់ទំនាក់ទំនងទិន្នន័យ និងបណ្តាញកុំព្យូទ័រ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារសំខាន់ៗរួមមាន ការណែនាំអំពីទំនាក់ទំនងទិន្នន័យ ប្រភេទបណ្តាញ គំរូបណ្តាញ និង

សន្តិសុខសាយប័រ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំបណ្តាញទំនាក់ទំនងទិន្នន័យ និងបណ្តាញកុំព្យូទ័រ សម្រាប់យកទៅអនុវត្តក្នុងការបង្រៀននិងរៀន។

៤.២.៨.២.៦. ការសរសេរកម្មវិធីបញ្ញាសិប្បនិម្មិត [៣ (២-២-៥)]

មុខវិជ្ជា ការសរសេរកម្មវិធីបញ្ញាសិប្បនិម្មិត មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការសរសេរកូដកម្មវិធីបញ្ញាសិប្បនិម្មិត (AI) សម្រាប់ការបង្រៀននិងរៀន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារសំខាន់ៗរួមមាន ចំណេះដឹងជាមូលដ្ឋាននៃបញ្ញាសិប្បនិម្មិត និងការសរសេរកូដកម្មវិធីអប់រំលើថ្នាលកូដប្លុក (Scratch Block-Based Programming, Teachable Machine, PRG AI Scratch, និង ENTRY)។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពក្នុងការបង្កើតកម្មវិធីបញ្ញាសិប្បនិម្មិតកម្រិតដំបូងដែលអាចយល់ពីសំឡេង ស្គាល់រូបភាព និងការវិភាគអត្ថបទ។

៤.២.៨.២.៧. ការអប់រំ STEAM តាមរយៈ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ [៣ (២-២-៥)]

មុខវិជ្ជាការអប់រំ STEAM តាមរយៈបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការអនុវត្តមុខវិជ្ជាស្ទឹម (STEAM) ជាក់ស្តែង ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារសំខាន់ៗរួមមាន គំនិតរួមបញ្ចូលគ្នានៃធាតុផ្សំ STEAM ទាំងប្រាំ ក្របខ័ណ្ឌគំរូ STEAM និងរបៀបដែល បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើរតួជាឧបករណ៍សំខាន់ក្នុងការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមាន សមត្ថភាពពន្យល់ និងអនុវត្តគោលការណ៍ STEAM តាមរយៈការប្រើប្រាស់ឧបករណ៍ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីបង្កើតគម្រោងអប់រំ។

៤.២.៩. ឯកទេសបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍-ភាសាអង់គ្លេស

៤.២.៩.១. មុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

៤.២.៩.១.១. ការណែនាំអំពីវិទ្យាសាស្ត្រកុំព្យូទ័រ [៣ (៣-០-៦)] (សូមមើល ៤.២.៨.២.១)

៤.២.៩.១.២. ការថែទាំ និងជួសជុលកុំព្យូទ័រ [៣ (២-២-៥)] (សូមមើល ៤.២.៨.២.២)

៤.២.៩.១.៣. ការណែនាំអំពីមូលដ្ឋានទិន្នន័យ [៣ (២-២-៥)] (សូមមើល ៤.២.៨.២.៣)

៤.២.៩.១.៤. ការអប់រំពហុមេឌា [៣ (២-២-៥)] (សូមមើល ៤.២.៨.២.៤)

៤.២.៩.១.៥. ទំនាក់ទំនងទិន្នន័យ និងបណ្តាញកុំព្យូទ័រ [៣ (២-២-៥)] (សូមមើល ៤.២.៨.២.៥)

៤.២.៩.១.៦. ការសរសេរកម្មវិធីបញ្ញាសិប្បនិម្មិត [៣ (២-២-៥)] (សូមមើល ៤.២.៨.២.៦)

៤.២.៩.១.៧. ការសរសេរកូដកម្មវិធីភាសា Python [៣ (២-២-៥)]

មុខវិជ្ជា ការសរសេរកូដកម្មវិធីភាសា Python មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងជំនាញក្នុងការសរសេរកូដកម្មវិធីភាសា Python។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារសំខាន់ៗរួមមាន អថេរ (variables) ប្រភេទទិន្នន័យ (data types) រចនាសម្ព័ន្ធត្រួតពិនិត្យ (control structures) អនុគមន៍ (functions) រចនាសម្ព័ន្ធទិន្នន័យ និងការសរសេរកូដកម្មវិធីផ្តែកលើវត្ថុ (Object-oriented Programming)។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្កើតកម្មវិធីអប់រំតាមរយៈការសរសេរ និងកែកំហុសនៅលើកម្មវិធីភាសា Python។

៤.២.៩.១.៨. ការអប់រំ STEAM តាមរយៈ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ [៣ (២-២- ៥)]

(សូមមើល ៤.២.៨.២.៧)

៤.២.៩.២. មុខវិជ្ជាភាសាអង់គ្លេស

៤.២.៩.២.១. Core English I [៣ (៣-០-៦)] (សូមមើល ៤.២.៨.១.១)

៤.២.៩.២.២. Core English II [២(២-០-៤)] (សូមមើល ៤.២.៨.១.២)

៤.២.៩.២.៣. Core English III [២ (២-០-៤)] (សូមមើល ៤.២.៨.១.៣)

៤.២.៩.២.៥. Cultural Studies [៣ (៣-០-៦)] (សូមមើល ៤.២.៨.១.៥)

៤.២.៩.២.៦. Literature Studies [៣ (៣-០-៦)] (សូមមើល ៤.២.៨.១.៦)

៤.២.៩.២.៧. Academic Writing I [៣ (២-២-៥)] (សូមមើល ៤.២.៨.១.៧)

៤.២.៩.២.៨. Academic Writing II [៣ (២-២-៥)] (សូមមើល ៤.២.៨.១.៨)

៤.២.១០. ឯកទេសភាសាបារាំង-ICT

៤.២.១០.១. មុខវិជ្ជាភាសាបារាំង

៤.២.១០.១.១. Langue Française I [៣ (៣-០-៦)]

Langue Française I est conçu dans le but de renforcer et d'élargir les compétences linguistiques afin de permettre aux étudiants-professeurs de développer les quatres compétences de communication : la compréhension orale et écrite, la production orale et écrite, communication, grammaire et vocabulaire selon des contextes sociaux. Cette matière met l'accent sur la compréhension de textes et de dialogues plus complexes, portant sur divers thèmes. Elle vise également à développer la capacité à décrire, expliquer et raconter de manière simple dans des situations de la vie quotidienne. Le cours prévoit aussi l'utilisation de différentes structures grammaticales, notamment (le passé composé, l'imparfait, le futur et le conditionnel), ainsi que l'enrichissement du vocabulaire nécessaire pour l'expression orale et écrite. Après l'acquisition, les étudiants-professeurs seront capables d'utiliser leurs connaissances et compétences pour écouter, lire, parler et comprendre des textes simples mais structurés. Ils pourront décrire, analyser, présenter des expériences simples et d'échanger des idées dans les situations courantes.

មុខវិជ្ជា Langue Française I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតពង្រឹងសមត្ថភាព ស្តាប់ អាន និយាយ សរសេរ ដោយប្រើប្រាស់ ការបញ្ចេញសំឡេង វេយ្យាករណ៍ និងវាក្យសព្ទតាមបរិបទសង្គម។ មុខវិជ្ជានេះផ្តោតលើការសិក្សាពីអត្ថបទ និងបទសន្ទនាដែលមានភាពស្មុគស្មាញដោយផ្អែកលើប្រធានបទជាច្រើនទាក់ទងលើការពិពណ៌នា ពន្យល់ និងនិទាន យ៉ាងសាមញ្ញ ដោយមានហេតុផលច្បាស់លាស់។ ការសិក្សានេះក៏ផ្តោតទៅលើការប្រើប្រាស់ រចនាសម្ព័ន្ធវេយ្យាករណ៍ កាលវេលា ដូចជា passé composé, imparfait, futur, conditionnel ព្រមទាំងពង្រីកការប្រើប្រាស់វាក្យសព្ទចាំបាច់ សម្រាប់សមត្ថភាពនិយាយ និងសរសេរ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតអាចប្រើប្រាស់ចំណេះដឹង និងជំនាញស្តាប់ អាន និយាយ សរសេរ ដោយធ្វើសកម្មភាពពណ៌នា វិភាគ បង្ហាញបទពិសោធន៍ និងការផ្លាស់ប្តូរគំនិតក្នុងស្ថានភាពប្រចាំថ្ងៃ។

៤.២.១០.១.២. Langue Française II [៣ (៣-០-៦)]

Langue Française II est conçue dans le but de renforcer et d'élargir les compétences des étudiants-professeurs afin qu'ils puissent communiquer de manière autonome, démontrer leurs capacités et présenter des arguments simples mais clairement justifiés, dans des situations variées et dans la société actuelle. Cette matière met l'accent sur l'expression d'opinions personnelles, les réponses et les discussions autour de sujets sociaux, l'expression des sentiments (accord ou désaccord), ainsi que l'utilisation de registres de langue différents (formel et informel). Elle vise également à familiariser les étudiants-professeurs avec des structures grammaticales plus avancées. À l'issue de ce cours, les étudiants-professeurs seront capables de comprendre le contenu de courts textes, de conversations et de discussions portant sur des sujets relativement complexes (concrets ou abstraits). Ils pourront participer à des discussions sur des thèmes variés, exprimer leur opinion (accord ou désaccord), rédiger des textes structurés et utiliser de manière appropriée les registres de langue formel et informel. មុខវិជ្ជា Langue Française II មានគោលបំណងពង្រឹង និងពង្រីកសមត្ថភាពគុរុនិស្សិតក្នុងការទំនាក់ទំនងដោយឯករាជ្យ បង្ហាញសមត្ថភាព និងការផ្តល់អំណះអំណាងបែបសាមញ្ញ ដោយមានហេតុផលច្បាស់លាស់ នៅក្នុងស្ថានភាពរស់នៅប្រចាំថ្ងៃ និងក្នុងសង្គម។ មុខវិជ្ជានេះផ្តោតលើការផ្តល់យោបល់ផ្ទាល់ខ្លួន ការឆ្លើយតប និងការពិភាក្សាលើប្រធានបទសង្គម ការបង្ហាញអារម្មណ៍ (គាំទ្រ ឬមិនគាំទ្រ) ការប្រើប្រាស់ភាសាបែប (ផ្លូវការ និងមិនផ្លូវការ) ការស្វែងយល់ពីការប្រើប្រាស់រចនាសម្ព័ន្ធវេយ្យាករណ៍កម្រិតខ្ពស់ជាងមុន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គុរុនិស្សិតអាចយល់ពីខ្លឹមសារនៃអត្ថបទខ្លី។ ការសន្ទនា ការពិភាក្សាទៅលើប្រធានបទបែបស្មុគស្មាញ (រូបី ឬអរូបី) និងអាចចូលរួមពិភាក្សាលើប្រធានបទចម្រុះ ការបញ្ចេញយោបល់ (ស្រប ឬមិនស្រប) សរសេរអត្ថបទមានរចនាសម្ព័ន្ធច្បាស់លាស់ ដោយប្រើប្រាស់ភាពសមរម្យរវាងភាសាផ្លូវការ និងមិនផ្លូវការ។

៤.២.១០.១.៣. Langue Française III [៣ (៣-០-៦)]

Langue Francaise III est conçue dans le but de renforcer et d'élargir les compétences linguistiques afin de permettre aux étudiants-professeurs de développer les quatres compétences de communication: la compréhension orale et écrite, la production orale et écrite, afin que les étudiants-professeurs puissent communiquer avec aisance, expliquer des idées, exprimer clairement leurs opinions et comprendre efficacement des textes complexes. Cette matière porte sur divers thèmes tels que la société, les médias, la culture, le travail et différents défis contemporains. Elle permet aux étudiants-professeurs de traiter des sujets complexes, de comprendre des documents authentiques et de produire des discours ou des textes variés, de différents types, bien structurés et riches en contenu. À l'issue de ce cours, les étudiants-professeurs seront capables de comprendre et de discuter avec aisance de sujets complexes, d'exprimer et de défendre leurs opinions, ainsi que d'expliquer leurs idées de manière équilibrée et cohérente. Ils pourront également rédiger des textes ou des commentaires bien

structurés, avec un vocabulaire riche, et utiliser la grammaire de manière correcte et maîtrisée à un niveau avancé.

មុខវិជ្ជា Langue Française III មានគោលបំណងផ្តល់ឱ្យគុរនិស្សិតពង្រឹងសមត្ថភាពលើជំនាញស្តាប់ អាន និយាយ និងសរសេរ ក្នុងការប្រាស្រ័យទាក់ទងបានយ៉ាងស្ទាត់ជំនាញ ចេះអធិប្បាយ អាចបង្ហាញមតិ យោបល់ឲ្យបានច្បាស់លាស់ និងអាចយល់អត្ថបទស៊ីជម្រៅ។ មុខវិជ្ជានេះផ្តោតលើប្រធានបទជាច្រើនដូចជា សង្គម ប្រព័ន្ធផ្សព្វផ្សាយ វប្បធម៌ ការងារ និងបញ្ហាប្រឈមនានា... ការដោះស្រាយលើប្រធានបទស្មុគស្មាញ ការយល់ដឹងពីឯកសារដើមទូទៅ (documents authentiques) ការតាក់តែងសុន្ទរកថា ឬអត្ថបទដែលសម្បូរបែបដែលមានលក្ខណៈខុសៗគ្នា និងមានរចនាសម្ព័ន្ធល្អ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គុរនិស្សិតអាចយល់ដឹងនិងពិភាក្សាលើប្រធានបទស្មុគស្មាញបានយ៉ាងរលូន អាចបង្ហាញនិងការពារមតិយោបល់របស់ខ្លួនបានយ៉ាងច្បាស់លាស់ ព្រមទាំងអាចបង្ហាញពីគំនិតរបស់ខ្លួនឱ្យមានតុល្យភាព។ បន្ថែមពីនេះ គុរនិស្សិតក៏អាចសរសេរអត្ថបទឬអត្ថាធិប្បាយដែលមានរចនាសម្ព័ន្ធល្អ ដោយអាចប្រើប្រាស់វាក្យសព្ទសម្បូរបែប ការប្រើប្រាស់វេយ្យាករណ៍បានត្រឹមត្រូវ។

៤.២.១០.១.៤. Phonétique [៣ (៣-០-៦)]

Le module phonétique vise à améliorer la prononciation des étudiants-professeurs de français et leur maîtrise de l'API (Alphabet Phonétique International), en tenant compte des difficultés des apprenants khmérophones. Il développe aussi leur capacité à utiliser la phonétique dans l'enseignement. Ce module propose des activités de discrimination auditive, de prononciation et d'étude des sons difficiles, avec l'appui d'outils technologiques. Il inclut également le travail sur l'intonation, la compréhension orale et des simulations communicatives. À la fin de ce cours, les étudiants-professeurs seront capables de distinguer et produire correctement les sons du français, et d'expliquer les bases de la phonétique. Ils pourront aussi comprendre des documents oraux et utiliser des outils pour améliorer leur prononciation et celle de leurs étudiants-professeurs.

មុខវិជ្ជា Phonétique មានគោលបំណងលើកកម្ពស់សមត្ថភាពបញ្ចេញសំឡេងភាសាបារាំងរបស់ គុរនិស្សិត និងការយល់ដឹងអំពីអក្ខរក្រមសូរសព្ទអន្តរជាតិ (API) ដោយគិតគូរពិសេសទៅលើបញ្ហាប្រឈមរបស់អ្នកសិក្សាដែលប្រើប្រាស់ភាសាខ្មែរ និងជួយអភិវឌ្ឍសមត្ថភាពប្រើប្រាស់ចំណេះដឹងសូរសព្ទក្នុងការបង្រៀនផងដែរ។ មុខវិជ្ជានេះផ្តោតលើ សកម្មភាពហាត់ស្តាប់និងបំបែកសំឡេង ការបញ្ចេញសំឡេង និងការសិក្សាសំឡេងដែលពិបាកដោយប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាជាជំនួយ។ លើសពីនេះទៀត ក៏មានរួមបញ្ចូលនូវការអនុវត្តលើការលើកដាក់សម្លេង (intonation) ការយល់ដឹងតាមរយៈការស្តាប់ និងសកម្មភាពសម្តែងតួនាទី (Jeux de rôle) ក្នុងបរិបទទំនាក់ទំនង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គុរនិស្សិតអាចបំបែកនិងបញ្ចេញសំឡេងភាសាបារាំងបានត្រឹមត្រូវ និងពន្យល់មូលដ្ឋានសូរសព្ទបានយ៉ាងច្បាស់។ ពួកគេក៏អាចយល់ពីឯកសារសំឡេង និងប្រើឧបករណ៍បច្ចេកវិទ្យា ដើម្បីកែលម្អការបញ្ចេញសំឡេងរបស់ខ្លួន និងសិស្សរបស់ពួកគេបានផងដែរ។

៤.២.១០.១.៥. Civilisation / Vidéo [៣ (៣-០-៦)]

Les études Civilisation / Vidéo visent à développer les compétences en compréhension et en expression orales et écrites, ainsi qu'en civilisation française à partir des documents vidéo.

Elles préparent les étudiants-professeurs à analyser des documents authentiques en intégrant la dimension linguistique et culturelle. Le contenu de ce cours propose l'analyse de documents vidéo variés, en travaillant la compréhension orale, l'expression, et l'identification des éléments culturels et visuels. Il inclut aussi des activités de résumé, de description, de débats, ainsi que la conception de séquences pédagogiques avec des outils numériques. À la fin de ce cours, les étudiants-professeurs seront capables de comprendre, analyser et résumer des documents vidéo en identifiant les informations essentielles et les indices culturels. Ils pourront également utiliser ces supports pour enseigner la langue et la civilisation française de manière adaptée.

មុខវិជ្ជា Civilisation / Vidéo មានគោលបំណងអភិវឌ្ឍសមត្ថភាពស្តាប់ និយាយ សរសេរ និងចំណេះដឹងអំពីវប្បធម៌បារាំងតាមរយៈឯកសារវីដេអូ និងវិភាគឯកសារដើមដោយបញ្ចូលទាំងផ្នែកភាសា និងវប្បធម៌។ មុខវិជ្ជានេះផ្តោតលើការវិភាគវីដេអូផ្សេងៗគ្នា ដើម្បីអភិវឌ្ឍសមត្ថភាពយល់ដឹងតាមការស្តាប់ ការបញ្ចេញមតិ និងការស្គាល់ធាតុផ្សំវប្បធម៌និងរូបភាព ដោយរួមបញ្ចូលសកម្មភាពសង្ខេប ពិពណ៌នា ការពិភាក្សា និងការរៀបចំលំដាប់មេរៀន ដោយប្រើឧបករណ៍ឌីជីថលផងដែរ។ នៅពេលបញ្ចប់ មុខវិជ្ជាសិក្សានេះ គរុនិស្សិតអាចយល់វិភាគ និងសង្ខេបមាតិកាវីដេអូ ដោយកំណត់ព័ត៌មានសំខាន់ៗ និងសញ្ញាណវប្បធម៌ ដោយអាចប្រើវីដេអូជាមធ្យោបាយបង្រៀនភាសា និងវប្បធម៌បារាំងបានយ៉ាងសមស្រប។

៤.២.១០.១.៦. Initiation à la littérature [៣ (៣-០-៦)]

Les études d'initiation à la littératures visent à initier les étudiants-professeurs à une méthode rigoureuse d'analyse des textes littéraires, en développant leur capacité à comprendre la structure et le style. Elles préparent les étudiants-professeurs à utiliser des outils d'analyse pour exploiter les textes dans une perspective pédagogique. Le contenu de ce cours aborde la lecture méthodique, les genres littéraires et la lecture intégrale, en étudiant les notions de style, de registre, de narration et de mouvements littéraires. Il inclut des activités pratiques, des ateliers d'écriture, l'analyse de textes bilingues et l'utilisation des outils d'analyse textuelle. À la fin de ce cours, les étudiants-professeurs seront capables d'analyser la structure et le style des textes littéraires à l'aide d'outils méthodologiques adaptés. Ils pourront également concevoir des activités pédagogiques pour enseigner la littérature en contexte scolaire.

មុខវិជ្ជា Les études d'initiation à la littératures មានគោលបំណងអភិវឌ្ឍការយល់ដឹងរបស់គរុនិស្សិតអំពីវិធីសាស្ត្រវិភាគអត្ថបទអក្សរសិល្ប៍ និងសមត្ថភាពយល់ដឹងអំពីរចនាសម្ព័ន្ធ និងរចនាបទ ថែមទាំងបណ្តុះបណ្តាលគរុនិស្សិតឱ្យចេះប្រើប្រាស់ឧបករណ៍វិភាគក្នុងការបង្រៀនអក្សរសិល្ប៍ក្នុងបរិបទអប់រំ។ មុខវិជ្ជានេះផ្តោតលើ ការអានតាមវិធីសាស្ត្រ ប្រភេទអក្សរសិល្ប៍ និងការអានអត្ថបទពេញលេញ ដោយសិក្សាអំពីរចនាបទ បែបបទ និងចលនាអក្សរសិល្ប៍រួមមាន សកម្មភាពអនុវត្តន៍ វគ្គសិក្សាផ្តោតលើការសរសេរ ការវិភាគអត្ថបទពីរភាសា និងការប្រើប្រាស់ឧបករណ៍វិភាគអត្ថបទ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតអាចវិភាគរចនាសម្ព័ន្ធ និងរចនាបទនៃអត្ថបទអក្សរសិល្ប៍ ដោយប្រើវិធីសាស្ត្រសមស្រប និងអាចបង្កើតសកម្មភាពបង្រៀនអក្សរសិល្ប៍សមស្របសម្រាប់បរិបទសាលារៀន។

៤.២.១០.១.៧. Rédaction académique I [៣ (៣-០-៦)]

La rédaction académique I vise à développer les compétences fondamentales en écriture des étudiants-professeurs. Le contenu de ce cours fournit une base solide en grammaire et en éléments de la phrase, notamment les parties du discours, la ponctuation, les règles de rédaction, les formes verbales, les mots de liaison ainsi que la structure des propositions et des phrases. À la fin de ce cours, les étudiants-professeurs seront capables de construire des phrases de manière correcte et appropriée.

មុខវិជ្ជា La rédaction academique I មានគោលបំណងអភិវឌ្ឍសមត្ថភាពសរសេររបស់គរុនិស្សិត។ មុខវិជ្ជានេះផ្តោតលើមូលដ្ឋានគ្រឹះវេយ្យាករណ៍ និងសមាសធាតុនៃប្រយោគដែលរួមមាន ថ្នាក់ពាក្យ វណ្ណយុត្តិ ជំហាននៃការសរសេរ ទម្រង់កិរិយាសព្ទ ពាក្យឬឃ្លាភ្ជាប់សេចក្តី និងរចនាសម្ព័ន្ធប្រយោគ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងទទួលបានសមត្ថភាពក្នុងការសរសេរប្រយោគបានត្រឹមត្រូវ។

៤.២.១០.១.៨. Rédaction académique II [៣ (៣-០-៦)]

La rédaction académique II vise à renforcer davantage les compétences en écriture des étudiants-professeurs. Le contenu de ce cours consolide les connaissances grammaticales et la structure de la phrase tout en introduisant la rédaction de paragraphes, notamment la phrase thématique, les idées de soutien, la cohérence et la cohésion. À la fin de ce cours, les étudiants-professeurs seront capables de rédiger des phrases et des paragraphes de manière correcte et appropriée.

មុខវិជ្ជា La rédaction academique II មានគោលបំណងអភិវឌ្ឍសមត្ថភាពសរសេររបស់គរុនិស្សិត។ មុខវិជ្ជានេះផ្តោតលើមូលដ្ឋានគ្រឹះវេយ្យាករណ៍ និងសមាសធាតុនៃប្រយោគ ដែលរួមមាន ថ្នាក់ពាក្យ វណ្ណយុត្តិ ជំហាននៃការសរសេរ ទម្រង់កិរិយាសព្ទ ពាក្យឬឃ្លាភ្ជាប់សេចក្តី និងរចនាសម្ព័ន្ធប្រយោគ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងទទួលបានសមត្ថភាពក្នុងការសរសេរប្រយោគ និងកថាខណ្ឌបានត្រឹមត្រូវ។

៤.២.១០.២. មុខវិជ្ជា បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (សូមមើល ៤.២.៨.២)

៤.២.១១. ឯកទេសបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ -ភាសាបារាំង

៤.២.១១.១. មុខវិជ្ជា បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (សូមមើល ៤.២.៩.១)

៤.២.១១.២. មុខវិជ្ជាភាសាបារាំង

៤.២.១១.២.១. Langue Française I [៣ (៣-០-៦)] (សូមមើល ៤.២.១០.១.១)

៤.២.១១.២.២. Langue Française II [៣ (៣-០-៦)] (សូមមើល ៤.២.១០.១.២)

៤.២.១០.១.៤. Phonétique [២ (២-០-៤)] (សូមមើល ៤.២.១០.១.៤)

៤.២.១០.១.៦. Civilisation / Vidéo [២ (២-០-៤)] (សូមមើល ៤.២.១០.១.៥)

៤.២.១០.១.៧. Initiation à la littérature [៣ (៣-០-៦)] (សូមមើល ៤.២.១០.១.៦)

៤.២.១១.២.៨. Rédaction académique I [៣ (៣-០-៦)] (សូមមើល ៤.២.១០.១.៧)

៤.២.១១.២.៩. Rédaction académique II [៣ (៣-០-៦)] (សូមមើល ៤.២.១០.១.៨)

៤.៣. ការសិក្សាពីកម្មវិធីសិក្សា (២០ ក្រេឌីត)

៤.៣.១. ភាសាខ្មែរ

៤.៣.១.១. វិធីសាស្ត្របង្រៀនភាសាខ្មែរ I [២ (១-២-៣)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាខ្មែរ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវសមត្ថភាពវិភាគអំពីកម្មវិធីសិក្សាលម្អិត ការប្រៀបធៀបខ្លឹមសារសៀវភៅសិក្សាគោល (ថ្នាក់ទី១-១២) និងការបង្កើតផែនការបង្រៀនស្របតាមកម្រិតថ្នាក់មានលំហូរច្បាស់លាស់។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការវិវឌ្ឍនៃកម្មវិធីសិក្សាលម្អិតតាមសម័យកាល (ឆ្នាំ១៩៨០-បច្ចុប្បន្ន) ការប្រៀបធៀប គ្នារវាងកម្មវិធីសិក្សាលម្អិតនិងសៀវភៅសិក្សាគោលថ្នាក់ទី១-១២ និងការបង្កើតផែនការបង្រៀនថ្នាក់ទី៧-៩ប្រចាំឆ្នាំ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពវិភាគស៊ីជម្រៅលើខ្លឹមសារមេរៀន លំហូរខ្លឹមសារពីដំពូក និងមេរៀននីមួយៗតាមកម្រិតថ្នាក់ និងនិមិត្តសញ្ញាផ្សេងៗនៅក្នុងភាសាខ្មែរ ដែលជាមូលដ្ឋានគ្រឹះនៅក្នុងវិធីសាស្ត្របង្រៀនសមត្ថភាពផ្សេងៗនៅអនុវិទ្យាល័យ។

៤.៣.១.២. វិធីសាស្ត្របង្រៀនភាសាខ្មែរ II [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាខ្មែរ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការបង្រៀនគ្រប់ទម្រង់នៃអត្ថបទដោយផ្សារភ្ជាប់នឹងបំណិនផ្សេងៗ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមានធាតុសំខាន់ៗនៃអំណាន វិធីសាស្ត្របង្រៀនសមត្ថភាពអាន ការរៀបចំផែនការបង្រៀន និងកិច្ចតែងការបង្រៀន ការអនុវត្តការបង្រៀនសមត្ថភាពអានរបស់គរុនិស្សិត និងការឆ្លុះបញ្ចាំង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្រៀនសមត្ថភាពអាន និងជ្រើសរើសវិធីសាស្ត្របង្រៀនបានសមស្របតាមខ្លឹមសារ និងតម្រូវការរបស់សិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព។

៤.៣.១.៣. វិធីសាស្ត្របង្រៀនភាសាខ្មែរ III [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាខ្មែរ III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការបង្រៀនគ្រប់ទម្រង់នៃអត្ថបទស្តាប់ដោយផ្សារភ្ជាប់នឹងបំណិនផ្សេងៗ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមានការស្តាប់ វិធីសាស្ត្របង្រៀនសមត្ថភាពស្តាប់ ការរៀបចំផែនការបង្រៀននិងកិច្ចតែងការបង្រៀន ការអនុវត្តការបង្រៀនសមត្ថភាពស្តាប់ និងការឆ្លុះបញ្ចាំង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្រៀនសមត្ថភាពស្តាប់បានសមស្របតាមខ្លឹមសារ និងតម្រូវការរបស់សិស្ស។

៤.៣.១.៤. វិធីសាស្ត្របង្រៀនភាសាខ្មែរ IV [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាខ្មែរ IV មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការបង្រៀនសមត្ថភាពនិយាយដោយផ្សារភ្ជាប់នឹងបំណិនផ្សេងៗ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមានធាតុសំខាន់ៗនៃការនិយាយ វិធីសាស្ត្របង្រៀនសមត្ថភាពនិយាយ ការរៀបចំផែនការបង្រៀននិងកិច្ចតែងការបង្រៀន ការអនុវត្តការបង្រៀនសមត្ថភាពនិយាយ និងការឆ្លុះបញ្ចាំង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្រៀនសមត្ថភាពនិយាយ និងជ្រើសរើសវិធីសាស្ត្របង្រៀនបានសមស្របតាម ខ្លឹមសារនិងតម្រូវការរបស់សិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព។

៤.៣.១.៥. វិធីសាស្ត្របង្រៀនភាសាខ្មែរ V [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាខ្មែរ V មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការបង្រៀនសមត្ថភាពសរសេរដោយផ្សារភ្ជាប់នឹងបំណិនផ្សេងៗ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន

ធាតុសំខាន់ៗនៃសំណេរ វិធីសាស្ត្របង្រៀនសមត្ថភាពសរសេរ ការរៀបចំផែនការបង្រៀននិងកិច្ចតែងការបង្រៀន ការអនុវត្តការបង្រៀនសំណេរ និងការឆ្លុះបញ្ចាំង។ នៅពេលបញ្ចប់ មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្រៀនសមត្ថភាពសរសេរ និងជ្រើសរើសវិធីសាស្ត្របង្រៀនបានសមស្របតាមខ្លឹមសារស្របតាមតម្រូវការរបស់សិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព។

៤.៣.១.៦. វិធីសាស្ត្របង្រៀនភាសាខ្មែរ VI [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាខ្មែរ VI មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការបង្រៀនវេយ្យាករណ៍និងបំណិនផ្សេងៗ ដោយផ្សារភ្ជាប់នឹងសមត្ថភាពទាំងបួននៃការរៀនភាសា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ធាតុសំខាន់ៗនៃវេយ្យាករណ៍និងបំណិនផ្សេងៗ វិធីសាស្ត្របង្រៀនវេយ្យាករណ៍និងបំណិនផ្សេងៗ ការរៀបចំផែនការបង្រៀននិងកិច្ចតែងការបង្រៀន ការអនុវត្តការបង្រៀនវេយ្យាករណ៍និងបំណិនផ្សេងៗ និងការឆ្លុះបញ្ចាំង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្រៀនវេយ្យាករណ៍និងបំណិនផ្សេងៗ និងប្រើប្រាស់វិធីសាស្ត្របង្រៀនបានសមស្របតាមតម្រូវការរបស់សិស្ស។

៤.៣.១.៧. ការវាយតម្លៃការសិក្សាមុខវិជ្ជាភាសាខ្មែរ [៣ (២-២-៥)]

មុខវិជ្ជា ការវាយតម្លៃការសិក្សាមុខវិជ្ជាភាសាខ្មែរ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការវាយតម្លៃការសិក្សា និងការបង្រៀនភាសាខ្មែរ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការរំឭកឡើងវិញពីខ្លឹមសារសំខាន់ៗទាក់ទងនឹងការវាយតម្លៃការសិក្សា (មុខវិជ្ជាការវាយតម្លៃការសិក្សា) ការបង្កើតតេស្តតាមប្រភេទផ្សេងៗ (តេស្ត PISA ស្តង់ដាតេស្តថ្នាក់ទី៨) ការអនុវត្តតេស្ត ការវិភាគលទ្ធផលតេស្ត ស្វ័យឆ្លុះបញ្ចាំងពីចំណុចភ័ន្តច្រឡំដែលកើតចេញពីលទ្ធផលតេស្តរបស់សិស្ស និងការជួយគាំទ្រដល់ការសិក្សារបស់សិស្សស្របពេល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំតេស្តនិងវិភាគលទ្ធផលតេស្តតាមកម្រិតថ្នាក់ និងប្រើប្រាស់លទ្ធផលតេស្តក្នុងការជួយគាំទ្រការសិក្សារបស់សិស្សឱ្យប្រសើរឡើង។

៤.៣.២. គណិតវិទ្យា

៤.៣.២.១. វិធីសាស្ត្របង្រៀនគណិតវិទ្យា I [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនគណិតវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើ ខ្លឹមសារគរុកោសល្យ (PCK) គោលដៅអប់រំ និងទិដ្ឋភាពទូទៅនៃកម្មវិធីសិក្សាជាតិ តាមរយៈការអនុវត្តសកម្មភាពនិងការដោះស្រាយបញ្ហាដោយផ្សារភ្ជាប់ទំនាក់ទំនងរវាងគណិតវិទ្យាកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទិដ្ឋភាពទូទៅ និងវត្ថុបំណងនៃការអប់រំគណិតវិទ្យា ខ្លឹមសារគរុកោសល្យក្នុងការបង្រៀន (នព្វន្ត ពីជគណិត ប្រូបាប៊ីលីតេ និងស្ថិតិ) និងកិច្ចតែងការបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពប្រើប្រាស់ចំណេះដឹងខ្លឹមសារគរុកោសល្យ (PCK) ដើម្បីរៀបចំការបង្រៀន ធ្វើការឆ្លុះបញ្ចាំង និងកែលម្អវិធីសាស្ត្របង្រៀនដើម្បីអភិវឌ្ឍសមត្ថភាពសិក្សារបស់សិស្សឱ្យកាន់តែ មានប្រសិទ្ធភាព ខ្ពស់។

៤.៣.២.២. វិធីសាស្ត្របង្រៀនគណិតវិទ្យា II [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនគណិតវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើខ្លឹមសារគរុកោសល្យ (PCK) វិធីសាស្ត្របង្រៀន ការប្រើប្រាស់បច្ចេកវិទ្យា និងការអនុវត្តផ្ទាល់។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វិធីបង្រៀនមុខវិជ្ជារងទាំងបី (ធរណីមាត្រ រង្វាស់រង្វាល់ និងអនុគមន៍) ខ្លឹមសារគរុកោសល្យក្នុងការបង្រៀន និងកិច្ចតែងការបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមាន

សមត្ថភាពប្រើប្រាស់ចំណេះដឹងខ្លឹមសារគរុកោសល្យ (PCK) ដើម្បីរៀបចំការបង្រៀន ធ្វើការឆ្លុះបញ្ចាំង និងកែលម្អវិធីសាស្ត្របង្រៀនដើម្បីអភិវឌ្ឍសមត្ថភាពសិក្សារបស់សិស្សឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

៤.៣.២.៣. វិធីសាស្ត្របង្រៀនគណិតវិទ្យា III [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនគណិតវិទ្យា III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើវិធីសាស្ត្របង្រៀនគណិតវិទ្យា ការប្រើប្រាស់បច្ចេកវិទ្យា ការរៀបចំកិច្ចតែងការបង្រៀន ហ្វឹកហ្វឺនគរុកោសល្យ និងឆ្លុះបញ្ចាំងកែលម្អ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការប្រើប្រាស់ GeoGebra និងការប្រើប្រាស់បញ្ញាសិប្បនិមិត្ត (AI) ការសិក្សាវិធីសាស្ត្របង្រៀនតាមបែបរិះរក (IBL) វិធីសាស្ត្របង្រៀនតាមទម្រង់ 5Es វិធីសាស្ត្របង្រៀនតាមបែបគម្រោង (PjBL) វិធីសាស្ត្របង្រៀនតាមបែបដោះស្រាយបញ្ហា (PrBL) វិធីសាស្ត្របង្រៀនតាមរយៈការដោះស្រាយបញ្ហា (TTP) វិធីបង្រៀនតាមអនុមាណរួម និងវិធីបង្រៀនតាមអនុមាណញែក។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពរៀបចំកិច្ចតែងការបង្រៀន ការបង្រៀនដោយបញ្ចូលវិធីសាស្ត្របង្រៀន ធ្វើការឆ្លុះបញ្ចាំងនិងកែលម្អការបង្រៀន និងប្រើប្រាស់បច្ចេកវិទ្យាខាងលើប្រកបដោយប្រសិទ្ធិភាព។

៤.៣.២.៤. ការវាយតម្លៃការសិក្សាគណិតវិទ្យា I [២ (១-២-៣)]

មុខវិជ្ជា ការវាយតម្លៃការសិក្សាគណិតវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានគ្រឹះលើវិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សាគណិតវិទ្យានៅអនុវិទ្យាល័យ ផ្តោតលើមុខវិជ្ជារងចំនួនបីគឺ នព្វន្ត ធរណីមាត្រ និងវង្វាស់វង្វាល់។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន គោលបំណង របៀប និងប្រភេទនៃការវាយតម្លៃ ប្រភេទសំណួរតេស្ត តេស្តស្តង់ដា តេស្តPISA ការបង្កើតសំណួរតេស្ត លក្ខណៈវិនិច្ឆ័យនៃការដាក់ពិន្ទុ និងការវិភាគសំណួរតេស្ត។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពបង្កើតសំណួរតេស្ត និងអនុវត្តការវិភាគលទ្ធផលតេស្តលើមុខវិជ្ជារងទាំងបីប្រកបដោយភាពជឿជាក់។

៤.៣.២.៥. ការវាយតម្លៃការសិក្សាគណិតវិទ្យា II [២ (១-២-៣)]

មុខវិជ្ជា ការវាយតម្លៃការសិក្សាគណិតវិទ្យា II មានគោលបំណងឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានគ្រឹះលើវិធីវាយតម្លៃលទ្ធផលសិក្សាគណិតវិទ្យានៅអនុវិទ្យាល័យ ផ្តោតលើមុខវិជ្ជារងចំនួនបីគឺ ពីជគណិត ស្ថិតិ និងប្រូបាប៊ីលីតេ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការបង្កើតសំណួរតេស្ត (តេស្តស្តង់ដា តេស្តPISA) លក្ខណៈវិនិច្ឆ័យនៃការដាក់ពិន្ទុ ការវិភាគសំណួរតេស្ត និងការវិភាគលទ្ធផលសិក្សារបស់សិស្ស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពបង្កើតសំណួរតេស្ត និងវិភាគលទ្ធផលតេស្តនិងលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជារងទាំងបីប្រកបដោយភាពជឿជាក់។

៤.៣.២.៦. វិធីសាស្ត្របង្រៀនគណិតវិទ្យា IV [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនគណិតវិទ្យា IV មានគោលបំណងផ្តល់ឱ្យ គរុនិស្សិតនូវចំណេះដឹងបន្ថែមលើខ្លឹមសារគរុកោសល្យ (PCK) លើមុខវិជ្ជារងទាំង៦ របស់គណិតវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការគិតច្រើនរបៀប ម៉ូឌែលគណិតវិទ្យា វិធីរកពហុចម្លើយត្រឹមត្រូវ ការបណ្តុះគំនិតក្នុងការបង្កើតលំហាត់សមត្ថភាពគណិតវិទ្យារបស់សិស្ស និងការវិភាគចម្លើយខុសរបស់សិស្ស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពទទួលបានចំណេះដឹងស៊ីជម្រៅលើខ្លឹមសារគរុកោសល្យ នៅក្នុងមុខវិជ្ជារងទាំង៦ និងមានសមត្ថភាពបង្រៀនគណិតវិទ្យានៅកម្រិតអនុវិទ្យាល័យប្រកបដោយភាពច្នៃប្រឌិត និងមានប្រសិទ្ធិភាព។

៤.៣.២.៧. ការបង្រៀន និងរៀនមុខវិជ្ជាឯកទេសគណិតវិទ្យា I [២ (១-២-៣)]

មុខវិជ្ជា ការបង្រៀន និងរៀនមុខវិជ្ជាឯកទេសគណិតវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងពីទំនាក់ទំនងនៃខ្លឹមសារគណិតវិទ្យានៅកម្រិតអនុវិទ្យាល័យទៅវិទ្យាល័យ និងការគិតអំពីការបង្រៀនដែលដឹកនាំសិស្សនៅកម្រិតអនុវិទ្យាល័យឱ្យយល់កាន់តែច្បាស់ពីគណិតវិទ្យាកម្រិតវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ប្រធានបទមួយចំនួននៃគណិតវិទ្យានៅកម្រិតអនុវិទ្យាល័យដោយសង្កត់ធ្ងន់ជាពិសេសទៅលើទំនាក់ទំនងរវាងចំណេះដឹងមូលដ្ឋានគណិតវិទ្យានៅវិទ្យាល័យ និងគណិតវិទ្យាកម្រិតអនុវិទ្យាល័យ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពវិភាគទៅលើទំនាក់ទំនងនៃខ្លឹមសារគណិតវិទ្យា និងវិធីបង្រៀនដែលអាចជួយសិស្សក្នុងការផ្សារភ្ជាប់ចំណេះដឹងនៅកម្រិតអនុវិទ្យាល័យ ទៅវិទ្យាល័យប្រកបដោយភាពច្នៃប្រឌិត និងមានប្រសិទ្ធិភាព។

៤.៣.២.៨. ការបង្រៀន និងរៀនមុខវិជ្ជាឯកទេសគណិតវិទ្យា II [២ (១-២-៣)]

មុខវិជ្ជា ការបង្រៀន និងរៀនមុខវិជ្ជាឯកទេសគណិតវិទ្យា II មានគោលបំណងគាំទ្រគរុនិស្សិតកំណត់ប្រធានបទស្រាវជ្រាវ និងអនុវត្តការស្រាវជ្រាវដើម្បីបង្កើតឯកសារបង្រៀន និងសម្ភារៈបង្រៀនដោយខ្លួនឯងនៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការជ្រើសរើសប្រធានបទស្រាវជ្រាវដើម្បីផលិតសម្ភារៈឧបទេសបង្រៀននិងរៀនគណិតវិទ្យានៅកម្រិតអនុវិទ្យាល័យលើមុខវិជ្ជារងដូចជា ចំនួន ពីជគណិត រង្វាស់រង្វាល់ ប្រូបាបប៊ីលីតេ ស្ថិតិ ធរណីមាត្រ និងអនុគមន៍។ នៅពេលបញ្ចាប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតទទួលបានចំណេះដឹង និងវិធីក្នុងការគិតដើម្បីបន្តអភិវឌ្ឍខ្លួនជា "គ្រូបង្រៀនជាអ្នកស្រាវជ្រាវ" តាមរយៈការធ្វើបទបង្ហាញអំពីដំណើរការ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវប្រកបដោយភាពច្នៃប្រឌិត និងមានប្រសិទ្ធិភាព។

៤.៣.៣. រូបវិទ្យា

៤.៣.៣.១. វិធីសាស្ត្របង្រៀនរូបវិទ្យា I៖ វិធីសាស្ត្របង្រៀនរូបវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនរូបវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានអំពីវិធីសាស្ត្របង្រៀនតាមបែបសកម្ម និងយុទ្ធវិធីក្នុងការបង្រៀននិងរៀន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទ្រឹស្តីនៃការបង្រៀន គោលវិធីសិស្សមជ្ឈមណ្ឌល វិធីវិទ្យាសាស្ត្រ វិធីសាស្ត្រង្រៀន (IBL, 5Es, PBL, PjBL, TTP) និងយុទ្ធវិធីបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតទទួលបានចំណេះដឹងលើទ្រឹស្តីវិធីសាស្ត្របង្រៀនតាមបែបសកម្ម និងយុទ្ធវិធីបង្រៀនសម្រាប់អនុវត្តក្នុងការបង្រៀននិងរៀនមុខវិជ្ជារូបវិទ្យាស្របតាមបរិបទនៃមេរៀនវិទ្យាសាស្ត្រ និងប្រកបដោយបរិយាបន្ន។

៤.៣.៣.២. វិធីសាស្ត្របង្រៀនរូបវិទ្យា II៖ ការសិក្សាកម្មវិធីសិក្សារូបវិទ្យា [២ (១-២-៣)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនរូបវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងក្នុងការវិភាគកម្មវិធីសិក្សាមុខវិជ្ជារូបវិទ្យានិងការរៀបចំផែនការបង្រៀនសម្រាប់មុខវិជ្ជារូបវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមានទម្រង់មូលដ្ឋានគ្រឹះកម្មវិធីសិក្សា ការវិភាគកម្មវិធីសិក្សារូបវិទ្យាតាមកម្រិត ការបន្សុំកម្មវិធីសិក្សា ការអនុវត្តកម្មវិធីសិក្សា និងការរៀបចំផែនការបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការវិភាគលើកម្មវិធីសិក្សារូបវិទ្យានៅចំណេះទូទៅនិងរៀបចំផែនការបង្រៀនមុខវិជ្ជារូបវិទ្យាដែលឆ្លើយតបទៅនឹងលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធីសិក្សាតាមកម្រិតថ្នាក់នីមួយៗ។

៤.៣.៣.៣. វិធីសាស្ត្របង្រៀនរូបវិទ្យា III៖ ការណែនាំការបង្រៀន និងថ្នាក់និទស្សន៍ I [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនរូបវិទ្យា III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីរបៀបសរសេរកិច្ចតែងការបង្រៀនដោយការជ្រើសរើសវិធីសាស្ត្របង្រៀនតាមបែបសកម្ម ព្រមទាំងការដាក់បញ្ចូលនូវយុទ្ធវិធីបង្រៀន និងអភិវឌ្ឍសម្ភារៈឧបទ្ទេសបង្រៀនដែលសមស្របទៅនឹងខ្លឹមសារមេរៀន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន របៀបសរសេរកិច្ចតែងការបង្រៀន និងការអភិវឌ្ឍសម្ភារៈឧបទ្ទេសបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពសរសេរកិច្ចតែងការបង្រៀនដោយមានការប្រើប្រាស់វិធីសាស្ត្របង្រៀនយុទ្ធវិធីបង្រៀនសកម្មភាពនានា និងសម្ភារៈឧបទ្ទេសបង្រៀនបានត្រឹមត្រូវសមស្របតាមខ្លឹមសារមេរៀនសម្រាប់មុខវិជ្ជារូបវិទ្យានៅចំណេះទូទៅ។

៤.៣.៣.៤. វិធីសាស្ត្របង្រៀនរូបវិទ្យា IV៖ គន្លឹះគរុកោសល្យក្នុងការបង្រៀនរូបវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនរូបវិទ្យា IV មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើមូលដ្ឋានគ្រឹះសម្រាប់ការយល់ដឹងអំពីពាក្យគន្លឹះគរុកោសល្យនៃការអប់រំរូបវិទ្យា របៀបរៀបចំមេរៀន របៀបរៀននិងដោះស្រាយបញ្ហាការគាន់ច្រឡំរបស់សិស្សជាក់ស្តែង។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទំនាក់ទំនងរវាងខ្លឹមសាររូបវិទ្យា និងពាក្យគន្លឹះគរុកោសល្យនៃការអប់រំរូបវិទ្យាដោយស្វែងយល់ពីបញ្ញត្តិនៃគន្លឹះគរុកោសល្យសំខាន់ៗ ដូចជា បញ្ញត្តិគាន់ច្រឡំ(Naïve concept) ផែនទីបញ្ញត្តិ (Concept mapping) ស្គីមម៉ា (Schema) បរិបទមិនឯករាជ្យ (Context dependency) អក្ខរកម្មវិទ្យាសាស្ត្រ (Science-literacy)ជាដើម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពរៀបចំសកម្មភាពបង្រៀនមេរៀនរូបវិទ្យាដោយបានកំណត់អត្តសញ្ញាណដើម្បីដោះស្រាយតាមភាពជាក់ស្តែងសម្រាប់គាំទ្រដល់ការបង្រៀនប្រកបដោយប្រសិទ្ធភាពនៅអនុវិទ្យាល័យ។

៤.៣.៣.៥. វិធីសាស្ត្របង្រៀនរូបវិទ្យា V៖ ការពិភាក្សាការបង្រៀន និងថ្នាក់និទស្សន៍ II [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនរូបវិទ្យា V មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងនិងបំណិន លើការអនុវត្តការបង្រៀនមុខវិជ្ជារូបវិទ្យាតាមរយៈការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន (Lesson Study)។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការសិក្សាស្រាវជ្រាវមេរៀន ការប្រើប្រាស់ឧបករណ៍វាយតម្លៃកិច្ចតែងការបង្រៀន ឧបករណ៍សង្កេតការបង្រៀន និងការអនុវត្តការបង្រៀននិងរៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះគរុនិស្សិតមានសមត្ថភាពក្នុងការបង្រៀនមេរៀនរូបវិទ្យាប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវនៅកម្រិតអនុវិទ្យាល័យ។

៤.៣.៣.៦. វិធីសាស្ត្របង្រៀនរូបវិទ្យា VI៖ ការវាយតម្លៃការសិក្សារូបវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនរូបវិទ្យា VI មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងក្នុងការកសាងតេស្តវាយតម្លៃ និងបំណិនលើការអនុវត្តតេស្តវាយតម្លៃបង្រៀនមុខវិជ្ជារូបវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការបង្កើតទម្រង់គម្រោងផែនការតេស្ត(Blueprint), Item test, analyze test, និងរៀបចំវិញ្ញាសាសម្រាប់ការបង្រៀនមុខវិជ្ជារូបវិទ្យា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការរៀបចំតេស្តស្តង់ដា និងតេស្តអន្តរជាតិ(PISA) ស្របតាមកម្មវិធីសិក្សាសម្រាប់ប្រើប្រាស់ក្នុងការបង្រៀនរូបវិទ្យា។

៤.៣.៣.៧. វិធីសាស្ត្របង្រៀនរូបវិទ្យា VII៖ ការឆ្លុះបញ្ចាំង និងការអភិវឌ្ឍក្នុងការបង្រៀនរូបវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនរូបវិទ្យា VII មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការអភិវឌ្ឍការបង្រៀនមុខវិជ្ជារូបវិទ្យាតាមរយៈការអនុវត្តកិច្ចការគម្រោង (Project Work)។ មុខវិជ្ជានេះផ្តោត

លើខ្លឹមសាររួមមាន ការកំណត់ប្រធានបទកិច្ចការគម្រោងស្រាវជ្រាវ ការរៀបចំផែនការកិច្ចការគម្រោងស្រាវជ្រាវ ដំណើរការអភិវឌ្ឍគម្រោងស្រាវជ្រាវ និងការធ្វើបទបង្ហាញលទ្ធផលកិច្ចការគម្រោងស្រាវជ្រាវ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការដោះស្រាយបញ្ហាជាក់ស្តែងតាមរយៈកិច្ចការគម្រោងស្រាវជ្រាវ។

៤.៣.៤. គីមីវិទ្យា

៤.៣.៤.១. វិធីសាស្ត្របង្រៀនគីមីវិទ្យា I៖ វិធីសាស្ត្របង្រៀនគីមីវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនគីមីវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើវិធីសាស្ត្របង្រៀនតាមបែបសកម្មក្នុងការបង្រៀនគីមីវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទ្រឹស្តី និងការអនុវត្តការបង្រៀន និងរៀន វិធីវិទ្យាសាស្ត្រ វិធីសាស្ត្របង្រៀនតាមបែបសកម្ម (វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក (IBL), វិធីសាស្ត្របង្រៀនតាមគំរូ5Es, វិធីសាស្ត្របង្រៀន និងរៀនផ្អែកលើបញ្ហា (PBL), វិធីសាស្ត្របង្រៀនតាមរយៈការដោះស្រាយបញ្ហា (TTP), វិធីសាស្ត្របង្រៀន និងរៀនតាមបែបគម្រោង (Pj-BL)) និងយុទ្ធវិធីបង្រៀនផ្សេងៗ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពបកស្រាយទ្រឹស្តី និងអនុវត្តវិធីសាស្ត្របង្រៀនតាមបែបសកម្មលើមុខវិជ្ជាគីមីវិទ្យាស្របតាមបរិបទមេរៀន និងប្រកបដោយបរិយាបន្ន។

៤.៣.៤.២. វិធីសាស្ត្របង្រៀនគីមីវិទ្យា II៖ ការសិក្សាកម្មវិធីសិក្សាគីមីវិទ្យា [២ (១-២-៣)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនគីមីវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានក្នុងការវិភាគកម្មវិធីសិក្សាមុខវិជ្ជាគីមីវិទ្យា និងការរៀបចំផែនការបង្រៀនសម្រាប់មុខវិជ្ជាគីមីវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទម្រង់មូលដ្ឋានគ្រឹះកម្មវិធីសិក្សា ការវិភាគកម្មវិធីសិក្សាគីមីវិទ្យាតាមកម្រិត ការបន្សុីកម្មវិធីសិក្សា ការអនុវត្តកម្មវិធីសិក្សា និងការរៀបចំផែនការបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការវិភាគលើកម្មវិធីសិក្សាគីមីវិទ្យានៅចំណេះទូទៅ និងរៀបចំផែនការបង្រៀនមុខវិជ្ជាគីមីវិទ្យាដែលឆ្លើយតបទៅនឹងលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធីសិក្សាលម្អិតមុខវិជ្ជាគីមីវិទ្យានៅអនុវិទ្យាល័យ។

៤.៣.៤.៣. វិធីសាស្ត្របង្រៀនគីមីវិទ្យា III៖ ការណែនាំការបង្រៀន និងថ្នាក់និទស្សន៍ I [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនគីមីវិទ្យា III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីរបៀបសរសេរកិច្ចតែងការបង្រៀនដោយការជ្រើសរើសវិធីសាស្ត្របង្រៀនតាមបែបសកម្ម ព្រមទាំងការដាក់បញ្ចូលនូវយុទ្ធវិធីបង្រៀន និងអភិវឌ្ឍសម្ភារៈឧបទេសបង្រៀនដែលសមស្របទៅនឹងខ្លឹមសារមេរៀន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន របៀបសរសេរកិច្ចតែងការបង្រៀន និងការអភិវឌ្ឍសម្ភារៈឧបទេសបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពសរសេរកិច្ចតែងការបង្រៀនដោយមានការប្រើប្រាស់វិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀន សកម្មភាពនានា និងសម្ភារៈឧបទេសបង្រៀនបានត្រឹមត្រូវសមស្របតាមខ្លឹមសារមេរៀនសម្រាប់មុខវិជ្ជាគីមីវិទ្យានៅចំណេះទូទៅ។

៤.៣.៤.៤. វិធីសាស្ត្របង្រៀនគីមីវិទ្យា IV៖ គន្លឹះគរុកោសល្យក្នុងការបង្រៀនគីមីវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនគីមីវិទ្យា IV មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើពាក្យគន្លឹះគរុកោសល្យនៃការអប់រំគីមីវិទ្យា របៀបរៀបចំមេរៀន របៀបរៀន និងរបៀបដោះស្រាយបញ្ហា ការកាន់ច្រឡំរបស់សិស្សជាក់ស្តែង។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទំនាក់ទំនងរវាងខ្លឹមសារគីមីវិទ្យានិងពាក្យគន្លឹះគរុកោសល្យនៃការអប់រំគីមីវិទ្យាដោយស្វែងយល់ពីបញ្ញត្តិនៃគន្លឹះគរុកោសល្យសំខាន់ៗមានដូចជា បញ្ញត្តិកាន់ច្រឡំ (Naïve concept) ផែនទីបញ្ញត្តិ (Concept mapping) ស្គីមម៉ា (Schema) បរិបទមិនឯករាជ្យ (Context dependency) អក្ខរកម្មវិទ្យាសាស្ត្រ (Science literacy) ជាដើម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិត

មានសមត្ថភាពរៀបចំសកម្មភាពបង្រៀនមេរៀនគីមីវិទ្យាដោយប្រើប្រាស់ពាក្យគន្លឹះគរុកោសល្យ និងការកំណត់អត្តសញ្ញាណ និងដោះស្រាយការយល់ខុសរបស់សិស្សជាក់ស្តែង ដើម្បីគាំទ្រដល់ការបង្រៀនប្រកបដោយប្រសិទ្ធភាព។

៤.៣.៤.៥. វិធីសាស្ត្របង្រៀនគីមីវិទ្យា V៖ ការពិភាក្សាការបង្រៀន និងថ្នាក់និទស្សន៍ II [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនគីមីវិទ្យា V មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការអនុវត្តការបង្រៀនមុខវិជ្ជាគីមីវិទ្យាតាមរយៈការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន (Lesson Study)។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារួមមាន ការសិក្សាស្រាវជ្រាវមេរៀន ការប្រើប្រាស់ឧបករណ៍វាយតម្លៃកិច្ចតែងការបង្រៀន ឧបករណ៍សង្កេតការបង្រៀន ការអនុវត្តការបង្រៀន និងរៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការបង្រៀនមេរៀនគីមីវិទ្យា ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ។

៤.៣.៤.៦. វិធីសាស្ត្របង្រៀនគីមីវិទ្យា VI៖ ការវាយតម្លៃការសិក្សាគីមីវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនគីមីវិទ្យា VI មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងក្នុងការកសាងតេស្តរង្វាយតម្លៃ និងបំណិនលើការអនុវត្តតេស្តរង្វាយតម្លៃបង្រៀនមុខវិជ្ជាគីមីវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារួមមាន ការបង្កើតទម្រង់គម្រោងផែនការតេស្ត (Blueprint) សំណួរតេស្ត (Item Test) វិភាគតេស្ត (Analyze Test) និងរៀបចំវិញ្ញាសារសម្រាប់ការបង្រៀនមុខវិជ្ជាគីមីវិទ្យា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការរៀបចំតេស្តស្តង់ដា និងតេស្តអន្តរជាតិ (PISA) ស្របតាមកម្មវិធីសិក្សាសម្រាប់ប្រើប្រាស់ក្នុងការបង្រៀនគីមីវិទ្យា។

៤.៣.៤.៧. វិធីសាស្ត្របង្រៀនគីមីវិទ្យា VII៖ ការឆ្លុះបញ្ចាំង និងការអភិវឌ្ឍក្នុងការបង្រៀនគីមីវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនគីមីវិទ្យា VII មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការអភិវឌ្ឍការបង្រៀនមុខវិជ្ជាគីមីវិទ្យាតាមរយៈការអនុវត្តកិច្ចការគម្រោង (Project Work)។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារួមមាន ការកំណត់ប្រធានបទកិច្ចការគម្រោងស្រាវជ្រាវ ការរៀបចំផែនការកិច្ចការគម្រោងស្រាវជ្រាវ ដំណើរការអភិវឌ្ឍគម្រោងស្រាវជ្រាវ ការឆ្លុះបញ្ចាំង និងការធ្វើបទបង្ហាញលទ្ធផលកិច្ចការគម្រោងស្រាវជ្រាវ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការដោះស្រាយបញ្ហាជាក់ស្តែងតាមរយៈកិច្ចការគម្រោងស្រាវជ្រាវ។

៤.៣.៥. ជីវវិទ្យា

៤.៣.៥.១. វិធីសាស្ត្របង្រៀនជីវវិទ្យា I៖ វិធីសាស្ត្របង្រៀនជីវវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនជីវវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើវិធីសាស្ត្របង្រៀនតាមបែបសកម្មក្នុងការបង្រៀនជីវវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារួមមាន ទ្រឹស្តី និងការអនុវត្តការបង្រៀន និងរៀន វិធីវិទ្យាសាស្ត្រ វិធីសាស្ត្របង្រៀនតាមបែបសកម្ម (វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក (IBL) វិធីសាស្ត្របង្រៀនតាមគំរូ5Es, វិធីសាស្ត្របង្រៀន និងរៀនផ្អែកលើបញ្ហា (PBL) វិធីសាស្ត្របង្រៀនតាមរយៈការដោះស្រាយបញ្ហា (TTP) វិធីសាស្ត្របង្រៀន និងរៀនតាមបែបគម្រោង (Pj-BL)) និងយុទ្ធវិធីបង្រៀនផ្សេងៗ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពបកស្រាយទ្រឹស្តី និងអនុវត្តវិធីសាស្ត្របង្រៀនតាមបែបសកម្មលើមុខវិជ្ជាជីវវិទ្យាស្របតាមបរិបទមេរៀន និងប្រកបដោយបរិយាបន្ន។

៤.៣.៥.២. វិធីសាស្ត្របង្រៀនជីវវិទ្យា II៖ ការសិក្សាកម្មវិធីសិក្សាជីវវិទ្យា [២ (១-២-៣)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនជីវវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានក្នុងការវិភាគកម្មវិធីសិក្សាមុខវិជ្ជាជីវវិទ្យា និងការរៀបចំផែនការបង្រៀនសម្រាប់មុខវិជ្ជាជីវវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទម្រង់មូលដ្ឋានគ្រឹះកម្មវិធីសិក្សា ការវិភាគកម្មវិធីសិក្សាជីវវិទ្យាតាមកម្រិត ការបន្សុីកម្មវិធីសិក្សា ការអនុវត្តកម្មវិធីសិក្សា និងការរៀបចំផែនការបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការវិភាគលើកម្មវិធីសិក្សាជីវវិទ្យានៅចំណេះទូទៅ និងរៀបចំផែនការបង្រៀនមុខវិជ្ជាជីវវិទ្យាដែលឆ្លើយតបទៅនឹងលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធីសិក្សាលម្អិតមុខវិជ្ជាជីវវិទ្យានៅអនុវិទ្យាល័យ។

៤.៣.៥.៣. វិធីសាស្ត្របង្រៀនជីវវិទ្យា III៖ ការណែនាំការបង្រៀន និងថ្នាក់និទស្សន៍ I [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនជីវវិទ្យា III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីរបៀបសរសេរកិច្ចតែងការបង្រៀន ដោយការជ្រើសរើសវិធីសាស្ត្របង្រៀនតាមបែបសកម្មព្រមទាំងការដាក់បញ្ចូលនូវយុទ្ធវិធីបង្រៀន និងអភិវឌ្ឍសម្ភារៈឧបទេសបង្រៀនដែលសមស្របទៅនឹងខ្លឹមសារមេរៀន។ មុខវិជ្ជានេះផ្តោតលើរបៀបសរសេរកិច្ចតែងការបង្រៀន និងការអភិវឌ្ឍសម្ភារៈឧបទេសបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពសរសេរកិច្ចតែងការបង្រៀនដោយមានការប្រើប្រាស់វិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀនសកម្មភាពនានា និងសម្ភារៈឧបទេសបង្រៀនបានត្រឹមត្រូវសមស្របតាមខ្លឹមសារមេរៀនសម្រាប់មុខវិជ្ជាជីវវិទ្យានៅអនុវិទ្យាល័យ។

៤.៣.៥.៤. វិធីសាស្ត្របង្រៀនជីវវិទ្យា IV៖ គន្លឹះគរុកោសល្យនៃការបង្រៀនមុខវិជ្ជាជីវវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនជីវវិទ្យា IV មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើពាក្យគន្លឹះគរុកោសល្យនៃការអប់រំជីវវិទ្យា របៀបរៀបចំមេរៀន របៀបរៀន និងរបៀបដោះស្រាយបញ្ហាការកាន់ច្រឡំរបស់សិស្សជាក់ស្តែង។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទំនាក់ទំនងរវាងខ្លឹមសារជីវវិទ្យានិងពាក្យគន្លឹះគរុកោសល្យនៃការអប់រំជីវវិទ្យាដោយស្វែងយល់ពីបញ្ញត្តិនៃគន្លឹះគរុកោសល្យសំខាន់ៗមានដូចជា បញ្ញត្តិកាន់ច្រឡំ (Naïve concept) ផែនទីបញ្ញត្តិ (Concept mapping) ស្គីមម៉ា (Schema) បរិបទមិនឯករាជ្យ Context dependency អក្ខរកម្មវិទ្យាសាស្ត្រ (Science literacy) ជាដើម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពរៀបចំសកម្មភាពបង្រៀនមេរៀនជីវវិទ្យាដោយប្រើប្រាស់ពាក្យគន្លឹះគរុកោសល្យ និងការកំណត់អត្តសញ្ញាណ និងដោះស្រាយការយល់ខុសរបស់សិស្សជាក់ស្តែង ដើម្បីគាំទ្រដល់ការបង្រៀនប្រកបដោយប្រសិទ្ធភាព។

៤.៣.៥.៥. វិធីសាស្ត្របង្រៀនជីវវិទ្យា V៖ ការពិភាក្សាការបង្រៀន និងថ្នាក់និទស្សន៍ II [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនជីវវិទ្យា V មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការអនុវត្តការបង្រៀនមុខវិជ្ជាជីវវិទ្យាតាមរយៈការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន (Lesson Study)។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការសិក្សាស្រាវជ្រាវមេរៀន ការប្រើប្រាស់ឧបករណ៍វាយតម្លៃកិច្ចតែងការបង្រៀន ឧបករណ៍សង្កេតការបង្រៀន ការអនុវត្តការបង្រៀននិងរៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការបង្រៀនមេរៀនជីវវិទ្យា ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ។

៤.៣.៥.៦. វិធីសាស្ត្របង្រៀនជីវវិទ្យា VI៖ ការវាយតម្លៃការសិក្សាជីវវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនជីវវិទ្យា VI មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងក្នុងការកសាងតេស្តវាយតម្លៃ និងបំណិនលើការអនុវត្តតេស្តវាយតម្លៃបង្រៀនមុខវិជ្ជាជីវវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារ

រួមមាន ការបង្កើតទម្រង់គម្រោងផែនការតេស្ត (Blueprint) សំណួរតេស្ត (Item Test) វិភាគតេស្ត (Analyze Test) និងរៀបចំវិញ្ញាសាសម្រាប់ការបង្រៀនមុខវិជ្ជាជីវិទ្យា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការរៀបចំតេស្តស្តង់ដា និងតេស្តអន្តរជាតិ (PISA) ស្របតាមកម្មវិធីសិក្សាសម្រាប់ប្រើប្រាស់ក្នុងការបង្រៀនជីវិទ្យា។

៤.៣.៥.៧. វិធីសាស្ត្របង្រៀនជីវិទ្យា VII៖ ការឆ្លុះបញ្ចាំង និងការអភិវឌ្ឍក្នុងការបង្រៀនជីវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនជីវិទ្យា VII មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការអភិវឌ្ឍការបង្រៀនមុខវិជ្ជាជីវិទ្យាតាមរយៈការអនុវត្តកិច្ចការគម្រោង (Project Work)។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការកំណត់ប្រធានបទកិច្ចការគម្រោងស្រាវជ្រាវ ការរៀបចំផែនការកិច្ចការគម្រោងស្រាវជ្រាវ ដំណើរការអភិវឌ្ឍគម្រោងស្រាវជ្រាវ ការឆ្លុះបញ្ចាំង និងការធ្វើបទបង្ហាញលទ្ធផលកិច្ចការគម្រោងស្រាវជ្រាវ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការដោះស្រាយបញ្ហាជាក់ស្តែងតាមរយៈកិច្ចការគម្រោងស្រាវជ្រាវ។

៤.៣.៦. ផែនដីនិងបរិស្ថានវិទ្យា

៤.៣.៦.១. វិធីសាស្ត្របង្រៀនផែនដីវិទ្យានិងបរិស្ថានវិទ្យា I៖វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើវិធីសាស្ត្របង្រៀនតាមបែបសកម្មក្នុងការបង្រៀនផែនដីនិងបរិស្ថានវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមានទ្រឹស្តីនិងការអនុវត្តការបង្រៀននិងរៀន វិធីសាស្ត្របង្រៀន វិធីសាស្ត្របង្រៀនតាមបែបសកម្ម (IBL, 5Es, PBL, TTP, Pj-BL) និងយុទ្ធវិធីបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការបកស្រាយទ្រឹស្តីនៃវិធីសាស្ត្របង្រៀនតាមបែបសកម្មលើមុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យា ស្របតាមបរិបទមេរៀននិងប្រកបដោយបរិយាបន្ន។

៤.៣.៦.២. វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា II៖ ការសិក្សាកម្មវិធីសិក្សាផែនដីនិងបរិស្ថានវិទ្យា [២ (១-២-៣)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងក្នុងការវិភាគកម្មវិធីសិក្សាមុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យា និងការរៀបចំផែនការបង្រៀនសម្រាប់មុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទម្រង់មូលដ្ឋានគ្រឹះកម្មវិធីសិក្សា ការវិភាគនិងបន្សុំកម្មវិធីសិក្សាផែនដី និងបរិស្ថានវិទ្យាតាមកម្រិត ការបន្សុំកម្មវិធីសិក្សា ការអនុវត្តកម្មវិធីសិក្សា និងការរៀបចំផែនការបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការវិភាគលើកម្មវិធីសិក្សាផែនដីនិងបរិស្ថានវិទ្យានៅអនុវិទ្យាល័យ និងរៀបចំផែនការបង្រៀនមុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យាដែលឆ្លើយតបទៅនឹងលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធីសិក្សាតាមកម្រិតថ្នាក់នីមួយៗ។

៤.៣.៦.៣. វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា III៖ ការណែនាំការបង្រៀន និងថ្នាក់និទស្សន៍ I [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីរបៀបសរសេរកិច្ចតែងការបង្រៀន ដោយការជ្រើសរើសវិធីសាស្ត្របង្រៀនតាមបែបសកម្ម ព្រមទាំងការដាក់

បញ្ចូលនូវយុទ្ធវិធីបង្រៀន និងអភិវឌ្ឍសម្ភារៈឧបទេសបង្រៀនដែលសមស្របទៅនឹងខ្លឹមសារមេរៀន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន របៀបសរសេរកិច្ចតែងការបង្រៀន និងការអភិវឌ្ឍសម្ភារៈឧបទ្ទេសបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពសរសេរកិច្ចតែងការបង្រៀនដោយមានការប្រើប្រាស់វិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀន សកម្មភាពនានា និងសម្ភារៈឧបទ្ទេសបង្រៀនបានត្រឹមត្រូវសមស្របតាមខ្លឹមសារមេរៀនសម្រាប់មុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យានៅចំណោះទូទៅ។

៤.៣.៦.៤. វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា IV៖ គន្លឹះគរុកោសល្យក្នុងការបង្រៀនផែនដីវិទ្យានិងបរិស្ថានវិទ្យា I [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា IV មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីពាក្យគន្លឹះគរុកោសល្យនៃការអប់រំផែនដីនិងបរិស្ថានវិទ្យា របៀបរៀបចំមេរៀន របៀបរៀន និងដោះស្រាយបញ្ហាការគាន់ច្រឡំរបស់សិស្សជាក់ស្តែង។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទំនាក់ទំនងរវាងខ្លឹមសារផែនដីនិងបរិស្ថានវិទ្យានិងពាក្យគន្លឹះគរុកោសល្យនៃការអប់រំផែនដីនិងបរិស្ថានវិទ្យាដោយស្វែងយល់ពីបញ្ញត្តិនៃគន្លឹះគរុកោសល្យសំខាន់ៗមានដូចជា បញ្ញត្តិគាន់ច្រឡំ(Naïve concept) ផែនទីបញ្ញត្តិ (Concept mapping) ស្គីម៉ា(Schema) បរិបទមិនឯករាជ្យ Context dependency អក្ខរកម្មវិទ្យាសាស្ត្រ (Science literacy) ជាដើម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពរៀបចំសកម្មភាពបង្រៀនមេរៀនផែនដីនិងបរិស្ថានវិទ្យាដោយប្រើប្រាស់ពាក្យគន្លឹះគរុកោសល្យនិងការកំណត់អត្តសញ្ញាណ និងដោះស្រាយការយល់ខុសរបស់សិស្សជាក់ស្តែង ដើម្បីគាំទ្រដល់ការបង្រៀនប្រកបដោយប្រសិទ្ធភាព។

៤.៣.៦.៥. វិធីសាស្ត្របង្រៀនផែនដីវិទ្យានិងបរិស្ថានវិទ្យា V៖ ការពិភាក្សាការបង្រៀន និងថ្នាក់និទស្សន៍ II [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា V មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងនិងបំណិនលើការអនុវត្តការបង្រៀនមុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យា តាមរយៈការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន (Lesson Study)។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការសិក្សាស្រាវជ្រាវមេរៀន ការប្រើប្រាស់ឧបករណ៍វាយតម្លៃកិច្ចតែងការបង្រៀន ឧបករណ៍សង្កេតការបង្រៀន និងការអនុវត្តការបង្រៀននិងរៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការបង្រៀនមេរៀនផែនដីនិងបរិស្ថានវិទ្យាប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវ។

៤.៣.៦.៦. វិធីសាស្ត្របង្រៀនផែនដីវិទ្យានិងបរិស្ថានវិទ្យា VI៖ ការវាយតម្លៃការសិក្សាផែនដីនិងបរិស្ថានវិទ្យា [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា VI មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងរៀបចំតេស្តរង្វាយតម្លៃ និងបំណិនលើការអនុវត្តតេស្តរង្វាយតម្លៃបង្រៀនមុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យា។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការបង្កើតទម្រង់គម្រោងផែនការតេស្ត (Blueprint), Item test, analyze test, និងរៀបចំវិញ្ញាសាសម្រាប់ការបង្រៀនមុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពក្នុងការរៀបចំតេស្តស្តង់ដា និងតេស្តអន្តរជាតិ(PISA) ស្របតាមកម្មវិធីសិក្សាសម្រាប់ប្រើប្រាស់ក្នុងការបង្រៀនផែនដីនិងបរិស្ថានវិទ្យា។

៤.៣.៦.៧. វិធីសាស្ត្របង្រៀនផែនដីវិទ្យា VII៖ ការឆ្លុះបញ្ចាំង និងការអភិវឌ្ឍក្នុងការបង្រៀនការបង្រៀនផែនដីវិទ្យា និងបរិស្ថាន [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនផែនដីនិងបរិស្ថានវិទ្យា VII មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការអភិវឌ្ឍការបង្រៀនមុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យាតាមរយៈការអនុវត្តកិច្ចការគម្រោង (Project Work)។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការកំណត់ប្រធានបទកិច្ចការគម្រោងស្រាវជ្រាវ ការរៀបចំផែនការកិច្ចការគម្រោងស្រាវជ្រាវ ដំណើរការអភិវឌ្ឍគម្រោងស្រាវជ្រាវ និងការធ្វើបទបង្ហាញលទ្ធផលកិច្ចការគម្រោងស្រាវជ្រាវ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពក្នុងការដោះស្រាយបញ្ហាជាក់ស្តែងតាមរយៈកិច្ចការគម្រោងស្រាវជ្រាវ។

៤.៣.៧. ប្រវត្តិវិទ្យា-ភូមិវិទ្យា

៤.៣.៧.១. ប្រវត្តិវិទ្យា

៤.៣.៧.១.១. វិធីសាស្ត្រប្រវត្តិវិទ្យា I [២ (១-២-៣)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនប្រវត្តិវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនជាមូលដ្ឋានលើការបង្រៀនប្រវត្តិវិទ្យានៅអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ កម្មវិធីសិក្សាលម្អិតមុខវិជ្ជាប្រវត្តិវិទ្យាកម្រិតអនុវិទ្យាល័យ សៀវភៅសិក្សាគោល កម្រិតសំណួរតាមប្លឹមតាក់សូណូមី ការសិក្សាស្រាវជ្រាវមេរៀន ការរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន និងការផលិតសម្ភារឧបទេស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពប្រើប្រាស់កម្មវិធីសិក្សាលម្អិតមុខវិជ្ជាប្រវត្តិវិទ្យាកម្រិតអនុវិទ្យាល័យនិងសៀវភៅសិក្សាគោល និងសំណួរតាមកម្រិតប្លឹមតាក់សូណូមី រៀបចំផែនការបង្រៀន និងរៀបចំកិច្ចតែងការបង្រៀនប្រកបដោយភាពបត់បែននិងមានប្រសិទ្ធភាព។

៤.៣.៧.១.២. វិធីសាស្ត្រប្រវត្តិវិទ្យា II [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនប្រវត្តិវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនប្រវត្តិវិទ្យានៅអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ថ្នាក់និទស្សន៍ ការសង្កេតការបង្រៀននិងឆ្លុះបញ្ចាំង និងការបង្រៀនសាកល្បង។ គរុនិស្សិតត្រូវអនុវត្តរៀបចំកិច្ចតែងការបង្រៀនដោយបញ្ចូលនូវវិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀនបែបសកម្មនិងមានប្រសិទ្ធភាព ចុះសង្កេតការបង្រៀននៅសាលាអនុវត្តន៍ និងអនុវត្តហ្វឹកហ្វឺនគរុកោសល្យបន្ថែមតាមរយៈការបង្រៀនសាកល្បងឆ្លើយតបទៅនឹងទ្រឹស្តីស្ថាបនានិយម និងគោលវិធីសិស្សមជ្ឈមណ្ឌល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពរៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាពបង្រៀននិងរៀនប្រកបដោយភាពបត់បែន និងមានប្រសិទ្ធភាព។

៤.៣.៧.១.៣. វិធីសាស្ត្របង្រៀនប្រវត្តិវិទ្យា III [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនប្រវត្តិវិទ្យា III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនប្រវត្តិវិទ្យានៅអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើយុទ្ធវិធីបង្រៀន វិធីសាស្ត្របង្រៀន ការអនុវត្តរៀបចំកិច្ចតែងការ និងការបង្រៀនសាកល្បង។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងលើការរៀបចំកិច្ចតែងការបង្រៀន និងការបង្រៀនសាកល្បងដោយបញ្ចូលនូវវិធីសាស្ត្របង្រៀនយុទ្ធវិធីសាស្ត្របង្រៀនបែបសកម្មសមស្របនិងមានប្រសិទ្ធភាព ឆ្លើយតបទៅនឹងទ្រឹស្តីស្ថាបនានិយម និង

គោលវិធីសិស្សមជ្ឈមណ្ឌល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពរៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាពបង្រៀននិងរៀនប្រកបដោយភាពបត់បែននិងមានប្រសិទ្ធភាព។

៤.៣.៧.១.៤. ការវាយតម្លៃការសិក្សាមុខវិជ្ជាប្រវត្តិវិទ្យា [២ (១-២-៣)]

មុខវិជ្ជា ការវាយតម្លៃការសិក្សាមុខវិជ្ជាប្រវត្តិវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការវាយតម្លៃការសិក្សាមុខវិជ្ជាប្រវត្តិវិទ្យានៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន បញ្ញត្តិ គោលការណ៍ វិធីសាស្ត្រ និងឧបករណ៍នៃការវាយតម្លៃការសិក្សារបស់សិស្សលើមុខវិជ្ជាប្រវត្តិវិទ្យា ដោយផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងលើការរៀបចំឧបករណ៍វាយតម្លៃជាសន្លឹកកិច្ចការនិងប្រើប្រាស់កម្មវិធីបច្ចេកវិទ្យា និងអនុវត្តរៀបចំតេស្តស្តង់ដាសម្រាប់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាប្រវត្តិវិទ្យាស្របតាមលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពរៀបចំការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយភាពបត់បែន និងមានប្រសិទ្ធភាព និងប្រើប្រាស់លទ្ធផលវាយតម្លៃការសិក្សាជាមូលដ្ឋានក្នុងការកែលម្អគុណភាពនៃការបង្រៀននិងរៀនប្រវត្តិវិទ្យា។

៤.៣.៧.២. ភូមិវិទ្យា

៤.៣.៧.២.១. កម្មវិធីសិក្សា និងបញ្ញត្តិនៃការបង្រៀន និងរៀន មុខវិជ្ជាភូមិវិទ្យា [២ (១-២-៣)]

៤.៣.៧.២.២. វិធីសាស្ត្របង្រៀនភូមិវិទ្យា I [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនភូមិវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនមុខវិជ្ជាភូមិវិទ្យានៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ក្របខ័ណ្ឌកម្មវិធីសិក្សាកម្រិតអនុវិទ្យាល័យ កម្មវិធីសិក្សាលម្អិតមុខវិជ្ជាភូមិវិទ្យាកម្រិតអនុវិទ្យាល័យ សៀវភៅសិក្សាគោលកម្រិតសំណួរតាមប្លូមតាក់សូណូមី ការសិក្សាស្រាវជ្រាវមេរៀន ការរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន និងការផលិតសម្ភារឧបទេស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់កម្មវិធីសិក្សាលម្អិតមុខវិជ្ជាភូមិវិទ្យាកម្រិតអនុវិទ្យាល័យ សៀវភៅសិក្សាគោល និងសំណួរតាមកម្រិតប្លូមតាក់សូណូមី រៀបចំផែនការបង្រៀន និងរៀបចំកិច្ចតែងការបង្រៀនប្រកបដោយភាពបត់បែននិងមានប្រសិទ្ធភាព។

៤.៣.៧.២.៣. វិធីសាស្ត្របង្រៀនភូមិវិទ្យា II [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនភូមិវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនភូមិវិទ្យានៅអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វិធីសាស្ត្របង្រៀន យុទ្ធវិធីសាស្ត្របង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ថ្នាក់និទស្សន៍ ការសង្កេតនិងការសង្កេតការបង្រៀន នឹងការផ្តល់ព័ត៌មានត្រឡប់។ គរុនិស្សិតត្រូវអនុវត្តរៀបចំកិច្ចតែងការបង្រៀនដោយបញ្ចូលនូវវិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀនបែបសកម្ម និងមានប្រសិទ្ធភាព ចុះសង្កេតការបង្រៀននៅសាលាអនុវត្តន៍ និងអនុវត្តហ្វឹកហ្វឺនគរុកោសល្យបន្ថែមតាមរយៈការបង្រៀនសាកល្បងឆ្លើយតបទៅនឹងទ្រឹស្តីស្ថាបនានិយម និងគោលវិធីសិស្សមជ្ឈមណ្ឌល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាពបង្រៀននិងរៀនប្រកបដោយភាពបត់បែន និងមានប្រសិទ្ធភាព។

៤.៣.៧.២.៤. ការវាយតម្លៃការសិក្សាមុខវិជ្ជាភូមិវិទ្យា [២ (១-២-៣)]

មុខវិជ្ជា ការវាយតម្លៃការសិក្សាមុខវិជ្ជាភូមិវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការវាយតម្លៃការសិក្សាលើមុខវិជ្ជាភូមិវិទ្យានៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារ

រួមមាន បញ្ញត្តិ គោលការណ៍ វិធីសាស្ត្រ និងឧបករណ៍នៃការវាយតម្លៃការសិក្សារបស់សិស្ស។ ការសិក្សាមុខវិជ្ជានេះត្រូវមានការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងលើការរៀបចំឧបករណ៍វាយតម្លៃជាសន្លឹកកិច្ចការ និងប្រើប្រាស់កម្មវិធីបច្ចេកវិទ្យា និងអនុវត្តរៀបចំតេស្តស្តង់ដាសម្រាប់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សស្របតាមលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាលម្អិត តាមរយៈការងារបុគ្គល និងក្រុម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព និងប្រើប្រាស់លទ្ធផលវាយតម្លៃការសិក្សាជាមូលដ្ឋានក្នុងការកែលម្អគុណភាពនៃការបង្រៀននិងរៀន។

៤.៣.៨. សីលធម៌-ពលរដ្ឋវិជ្ជា-គេហសេដ្ឋកិច្ចវិទ្យា

៤.៣.៨.១. សីលធម៌-ពលរដ្ឋវិជ្ជា

៤.៣.៨.១.១. កម្មវិធីសិក្សា និងបញ្ញត្តិនៃការបង្រៀននិងរៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា [២ (១-២-៣)]

មុខវិជ្ជា កម្មវិធីសិក្សា និងបញ្ញត្តិនៃការបង្រៀននិងរៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនសីលធម៌- ពលរដ្ឋវិជ្ជានៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ក្របខ័ណ្ឌកម្មវិធីសិក្សាកម្រិតអនុវិទ្យាល័យ កម្មវិធីសិក្សាលម្អិតមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាកម្រិតអនុវិទ្យាល័យ សៀវភៅសិក្សាគោល កម្រិតសំណួរតាមបិូមតាក់សូណូមី ការសិក្សាស្រាវជ្រាវ មេរៀន ការរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន និងការផលិតសម្ភារឧបទេស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាព ប្រើប្រាស់កម្មវិធីសិក្សាលម្អិតមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាកម្រិតអនុវិទ្យាល័យ សៀវភៅសិក្សាគោល សំណួរតាម កម្រិតបិូមតាក់សូណូមី រៀបចំផែនការបង្រៀន និងរៀបចំកិច្ចតែងការបង្រៀនប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព។

៤.៣.៨.១.២. វិធីសាស្ត្របង្រៀនសីលធម៌-ពលរដ្ឋវិជ្ជា I [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនសីលធម៌-ពលរដ្ឋវិជ្ជា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងនិងបំណិនលើការបង្រៀនសីលធម៌-ពលរដ្ឋវិជ្ជានៅអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វិធីសាស្ត្របង្រៀន យុទ្ធវិធីសាស្ត្របង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ថ្នាក់និទស្សន៍ ការសង្កេតការបង្រៀន និងផ្តល់ពត៌មានត្រឡប់។ គរុនិស្សិតត្រូវអនុវត្តរៀបចំកិច្ចតែងការបង្រៀនដោយបញ្ចូលនូវវិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀនបែបសកម្ម និងមានប្រសិទ្ធភាព ចុះសង្កេតការបង្រៀននៅសាលាអនុវត្តន៍ និងអនុវត្តហ្វឹកហ្វឺនគរុកោសល្យ បន្ថែមតាមរយៈការបង្រៀនសាកល្បងឆ្លើយតបទៅនឹងទ្រឹស្តីស្ថាបនានិយម និងគោលវិធីសិស្សមជ្ឈមណ្ឌល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាព បង្រៀន និងរៀនប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព។

៤.៣.៨.១.៣. វិធីសាស្ត្របង្រៀនសីលធម៌-ពលរដ្ឋវិជ្ជា II [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនសីលធម៌-ពលរដ្ឋវិជ្ជា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងនិងបំណិនលើវិធីសាស្ត្របង្រៀនសីលធម៌-ពលរដ្ឋវិជ្ជានៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន យុទ្ធវិធីបង្រៀន វិធីសាស្ត្របង្រៀន ការអនុវត្តរៀបចំកិច្ចតែងការ និងការបង្រៀនសាកល្បង។ ការសិក្សាមុខវិជ្ជានេះត្រូវផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងលើការរៀបចំកិច្ចតែងការបង្រៀន និងការបង្រៀនសាកល្បង ដោយបញ្ចូលនូវវិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀនបែបសកម្មសមស្រប និងមានប្រសិទ្ធភាព ឆ្លើយតបទៅនឹង

ទ្រឹស្តីស្ថាបនានិយម និងគោលវិធីសិស្សមជ្ឈមណ្ឌល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាពបង្រៀន និងរៀនប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព។

៤.៣.៨.១.៤. ការវាយតម្លៃការសិក្សាមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា [២ (១-២-៣)]

មុខវិជ្ជា ការវាយតម្លៃការសិក្សាមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការវាយតម្លៃការសិក្សាមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជានៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះ ផ្តោតលើខ្លឹមសាររួមមាន បញ្ញត្តិ គោលការណ៍ វិធីសាស្ត្រ និងឧបករណ៍នៃការវាយតម្លៃការសិក្សារបស់សិស្ស។ ការសិក្សាមុខវិជ្ជានេះត្រូវផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងលើការរៀបចំឧបករណ៍វាយតម្លៃជាសន្លឹកកិច្ចការ និងប្រើប្រាស់កម្មវិធីបច្ចេកវិទ្យា និងអនុវត្តរៀបចំតេស្តស្តង់ដាសម្រាប់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សស្របតាមលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាលម្អិត តាមរយៈការងារបុគ្គល និងក្រុម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការវាយតម្លៃការសិក្សា របស់សិស្សប្រកបដោយភាពបត់បែននិងប្រសិទ្ធភាព និងប្រើប្រាស់លទ្ធផលវាយតម្លៃការសិក្សាជាមូលដ្ឋានក្នុងការកែលម្អគុណភាពនៃការបង្រៀន និងរៀន។

៤.៣.៨.២. គេហសេដ្ឋកិច្ចវិទ្យា

៤.៤.៣.៨.២.១. កម្មវិធីសិក្សា និងបញ្ញត្តិនៃការបង្រៀននិងរៀនមុខវិជ្ជាគេហសេដ្ឋកិច្ចវិទ្យា [២ (១-២-៣)]

មុខវិជ្ជា កម្មវិធីសិក្សា និងបញ្ញត្តិនៃការបង្រៀននិងរៀនមុខវិជ្ជាគេហសេដ្ឋកិច្ចវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនគេហសេដ្ឋកិច្ចវិទ្យានៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ កម្មវិធីសិក្សាលម្អិតមុខវិជ្ជាគេហសេដ្ឋកិច្ចវិទ្យា កម្រិតអនុវិទ្យាល័យ សៀវភៅសិក្សាគោល កម្រិតសំណួរតាមប៊ូមតាក់សូណូមី ការសិក្សាស្រាវជ្រាវរមៀន ការរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន និងការផលិតសម្ភារឧបទេស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់កម្មវិធីសិក្សាមុខវិជ្ជាគេហសេដ្ឋកិច្ចវិទ្យាកម្រិតអនុវិទ្យាល័យ ប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព។

៤.៣.៨.២.២. វិធីសាស្ត្របង្រៀនគេហសេដ្ឋកិច្ចវិទ្យា I [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀន និងរៀនគេហសេដ្ឋកិច្ចវិទ្យា I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនគេហសេដ្ឋកិច្ចវិទ្យានៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ថ្នាក់និទស្សន៍ ការសង្កេតការបង្រៀននិងឆ្លុះបញ្ចាំង និងការបង្រៀនសាកល្បង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតមានសមត្ថភាពរៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាពបង្រៀននិងរៀនប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព។

៤.៣.៨.២.៣. វិធីសាស្ត្របង្រៀនគេហសេដ្ឋកិច្ចវិទ្យា II [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀន និងរៀនគេហសេដ្ឋកិច្ចវិទ្យា II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនវិធីសាស្ត្របង្រៀនគេហសេដ្ឋកិច្ចវិទ្យានៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន យុទ្ធវិធីបង្រៀន វិធីសាស្ត្របង្រៀន ការអនុវត្តរៀបចំកិច្ចតែងការបង្រៀន និងការបង្រៀនសាកល្បង។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាពបង្រៀននិងរៀនប្រកបដោយភាពបត់បែននិងប្រសិទ្ធភាព។

៤.៣.៨.២.៤. ការវាយតម្លៃការសិក្សាមុខវិជ្ជាគេហសេដ្ឋកិច្ចវិទ្យា [២ (១-២-៣)]

មុខវិជ្ជា ការវាយតម្លៃការសិក្សាមុខវិជ្ជាគេហសេដ្ឋកិច្ចវិទ្យា មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការវាយតម្លៃការសិក្សាលើមុខវិជ្ជាគេហសេដ្ឋកិច្ចវិទ្យានៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ខ្លឹមសារ បញ្ញត្តិ គោលការណ៍ វិធីសាស្ត្រ និងឧបករណ៍នៃការវាយតម្លៃការសិក្សារបស់សិស្ស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការវាយតម្លៃការសិក្សាសិស្សប្រកបដោយភាពបត់បែននិងប្រសិទ្ធភាព និងប្រើប្រាស់លទ្ធផលវាយតម្លៃការសិក្សាជាមូលដ្ឋានក្នុងការកែលម្អគុណភាពនៃការបង្រៀននិងរៀន។

៤.៣.៩. អប់រំសុខភាព-គេហសេដ្ឋកិច្ចវិទ្យា

៤.៣.៩.១. អប់រំសុខភាព

៤.៣.៩.១.១. កម្មវិធីសិក្សា និងបញ្ញត្តិនៃការបង្រៀននិងរៀនមុខវិជ្ជាអប់រំសុខភាព [២ (១-២-៣)]

មុខវិជ្ជា កម្មវិធីសិក្សា និងបញ្ញត្តិនៃការបង្រៀននិងរៀនមុខវិជ្ជាអប់រំសុខភាព មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនសុខភាពសិក្សានៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ក្របខណ្ឌកម្មវិធីសិក្សាកម្រិតអនុវិទ្យាល័យ កម្មវិធីសិក្សា លម្អិតមុខវិជ្ជាសុខភាពសិក្សាកម្រិតអនុវិទ្យាល័យ សៀវភៅសិក្សាគោល កម្រិតសំណួរតាមប្លូមតាក់សូណូមី ការសិក្សាស្រាវជ្រាវមេរៀន ការរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន និងការផលិតសម្ភារឧបទេស។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់កម្មវិធីសិក្សាលម្អិតមុខវិជ្ជាសុខភាពសិក្សាកម្រិតអនុវិទ្យាល័យ សៀវភៅសិក្សាគោល និងសំណួរតាមកម្រិតប្លូមតាក់សូណូមី រៀបចំផែនការបង្រៀន និងរៀបចំកិច្ចតែងការបង្រៀនប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព។

៤.៣.៩.១.២. វិធីសាស្ត្របង្រៀនអប់រំសុខភាព I [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនអប់រំសុខភាព I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនសុខភាពសិក្សានៅអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ថ្នាក់និទស្សន៍ ការសង្កេតការបង្រៀននិងឆ្លុះបញ្ចាំង និងការបង្រៀនសាកល្បង។ គរុនិស្សិតត្រូវអនុវត្តរៀបចំកិច្ចតែងការបង្រៀនដោយបញ្ចូលនូវ វិធីសាស្ត្របង្រៀន យុទ្ធវិធីសាស្ត្របង្រៀនបែបសកម្ម និងមានប្រសិទ្ធភាព ចុះសង្កេតការបង្រៀននៅសាលាអនុវត្តន៍ និងអនុវត្តហ្វឹកហ្វឺនគរុកោសល្យបន្ថែមតាមរយៈការបង្រៀនសាកល្បងឆ្លើយតបទៅនឹងទ្រឹស្តីស្ថាបនានិយម និងគោលវិធីសិស្សមជ្ឈមណ្ឌល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាពបង្រៀននិងរៀនប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព។

៤.៣.៩.១.៣. វិធីសាស្ត្របង្រៀនអប់រំសុខភាព II [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនអប់រំសុខភាព II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនវិធីសាស្ត្របង្រៀនសុខភាពសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន យុទ្ធវិធីបង្រៀន វិធីសាស្ត្របង្រៀន ការអនុវត្តរៀបចំកិច្ចតែងការ និងការបង្រៀនសាកល្បង។ ការសិក្សាមុខវិជ្ជានេះត្រូវផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងលើការរៀបចំកិច្ចតែងការបង្រៀន និងការបង្រៀនសាកល្បងដោយបញ្ចូលនូវវិធីសាស្ត្របង្រៀន យុទ្ធវិធីសាស្ត្របង្រៀនបែបសកម្មភាព សមស្រប និងមានប្រសិទ្ធភាព

ឆ្លើយតបទៅនឹងទ្រឹស្តីស្ថាបនានិយម និងគោលវិធីសិស្សមជ្ឈមណ្ឌល។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាពបង្រៀននិងរៀនប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព។

៤.៣.៩.១.៤. ការវាយតម្លៃការសិក្សាមុខវិជ្ជាអប់រំសុខភាព [២ (១-២-៣)]

មុខវិជ្ជា ការវាយតម្លៃការសិក្សាមុខវិជ្ជាអប់រំសុខភាព មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការវាយតម្លៃការសិក្សាលើមុខវិជ្ជាសុខភាពសិក្សានៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន បញ្ញត្តិ គោលការណ៍ វិធីសាស្ត្រ និងឧបករណ៍នៃការវាយតម្លៃការសិក្សារបស់សិស្ស។ ការសិក្សាមុខវិជ្ជានេះត្រូវផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងលើការរៀបចំឧបករណ៍វាយតម្លៃជាសន្លឹកកិច្ចការ និងប្រើកម្មវិធីបច្ចេកវិទ្យា និងអនុវត្តរៀបចំតេស្តស្តង់ដាសម្រាប់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សស្របតាមលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាលម្អិត តាមរយៈការងារបុគ្គល និងក្រុម។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព និងប្រើប្រាស់លទ្ធផលវាយតម្លៃការសិក្សាជាមូលដ្ឋានក្នុងការកែលម្អ គុណភាពនៃការបង្រៀន និងរៀន។

៤.៣.៩.២. គេហសេដ្ឋកិច្ចវិទ្យា (សូមមើល ៤.៣.៨.២)

៤.៣.១០. អប់រំសិល្បៈ

៤.៣.១០.១. វិធីសាស្ត្របង្រៀនសិល្បៈ I៖ កម្មវិធីសិក្សា និងបញ្ញត្តិនៃការបង្រៀន និងរៀនមុខវិជ្ជាអប់រំសិល្បៈ [២ (១-២-៣)]

មុខវិជ្ជានេះ វិធីសាស្ត្របង្រៀនសិល្បៈ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនជាមូលដ្ឋានលើការបង្រៀនអប់រំសិល្បៈនៅអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើ ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ កម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំសិល្បៈកម្រិតអនុវិទ្យាល័យ សៀវភៅសិក្សាគោល កម្រិតសំណួរតាមប៊្លូមតាក់សូណូមី ការសិក្សាស្រាវជ្រាវមេរៀន ការរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន និងការផលិតសម្ភារឧបទេស។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់កម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំសិល្បៈកម្រិតអនុវិទ្យាល័យ សៀវភៅសិក្សាគោល និងសំណួរតាមកម្រិតប៊្លូមតាក់សូណូមី ព្រមទាំងរៀបចំផែនការបង្រៀន និងកិច្ចតែងការបង្រៀនប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព។

៤.៣.១០.២. វិធីសាស្ត្របង្រៀនសិល្បៈ II៖ វិធីសាស្ត្របង្រៀនគំនូរ- ហត្ថកម្ម [៣ (២-២-៥)]

មុខវិជ្ជានេះ វិធីសាស្ត្របង្រៀនសិល្បៈ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនគំនូរ-ហត្ថកម្មនៅអនុវិទ្យាល័យ។ ការសិក្សាមុខវិជ្ជានេះផ្តោតលើ វិធីសាស្ត្របង្រៀន យុទ្ធវិធីសាស្ត្របង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ថ្នាក់និទស្សន៍ ការសង្កេតការបង្រៀននិងឆ្លុះបញ្ចាំង និងការបង្រៀនសាកល្បង។ គរុនិស្សិតត្រូវអនុវត្តរៀបចំកិច្ចតែងការបង្រៀនដោយបញ្ចូលនូវវិធីសាស្ត្របង្រៀន យុទ្ធវិធីសាស្ត្របង្រៀនបែបសកម្មនិងមានប្រសិទ្ធភាព ចុះសង្កេតការបង្រៀននៅសាលាអនុវត្តន៍ និងអនុវត្តហ្វឹកហ្វឺនគរុកោសល្យបន្ថែមតាមរយៈការបង្រៀនសាកល្បងឆ្លើយតបទៅនឹងទ្រឹស្តីស្ថាបនានិយម និងគោលវិធីសិស្សមជ្ឈមណ្ឌល។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាព បង្រៀននិងរៀនប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព។

៤.៣.១០.៣. វិធីសាស្ត្របង្រៀនសិល្បៈ III៖ វិធីសាស្ត្របង្រៀនតន្ត្រី [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនសិល្បៈ III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនលើការបង្រៀនតន្ត្រីនៅអនុវិទ្យាល័យ។ ការសិក្សាមុខវិជ្ជានេះផ្តោតលើ វិធីសាស្ត្របង្រៀន យុទ្ធវិធីសាស្ត្របង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ថ្នាក់និទស្សន៍ ការសង្កេតការបង្រៀននិងឆ្លុះបញ្ចាំង និងការបង្រៀនសាកល្បង។ គរុនិស្សិតត្រូវអនុវត្តរៀបចំកិច្ចតែងការបង្រៀនដោយបញ្ចូលនូវវិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀនបែបសកម្ម និងមានប្រសិទ្ធភាព ចុះសង្កេតការបង្រៀននៅសាលាអនុវត្តន៍ និងអនុវត្តហ្វឹកហ្វឺនគរុកោសល្យបន្ថែម តាមរយៈការបង្រៀនសាកល្បងឆ្លើយតបទៅនឹងទ្រឹស្តីស្ថាបនានិយម និងគោលវិធីសិស្សមជ្ឈមណ្ឌល។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាពបង្រៀន និងរៀនប្រកបដោយភាពបត់បែន និងមានប្រសិទ្ធភាព។

៤.៣.១០.៤. វិធីសាស្ត្របង្រៀនសិល្បៈ IV៖ វិធីសាស្ត្របង្រៀនរបាំ [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនសិល្បៈ IV នេះមានគោលបំណង ផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិន លើការបង្រៀនរបាំនៅអនុវិទ្យាល័យ។ ការសិក្សាមុខវិជ្ជានេះផ្តោតលើ វិធីសាស្ត្របង្រៀន យុទ្ធវិធីសាស្ត្របង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ថ្នាក់និទស្សន៍ ការសង្កេតការបង្រៀននិងឆ្លុះបញ្ចាំង និងការបង្រៀនសាកល្បង។ គរុនិស្សិតត្រូវអនុវត្តរៀបចំកិច្ចតែងការបង្រៀនដោយបញ្ចូលនូវវិធីសាស្ត្របង្រៀន យុទ្ធវិធីសាស្ត្របង្រៀនបែបសកម្ម និងមានប្រសិទ្ធភាព ចុះសង្កេតការបង្រៀននៅសាលាអនុវត្តន៍ និងអនុវត្តហ្វឹកហ្វឺនគរុកោសល្យ បន្ថែមតាមរយៈការបង្រៀនសាកល្បងឆ្លើយតបទៅនឹងទ្រឹស្តីស្ថាបនានិយម និងគោលវិធីសិស្សមជ្ឈមណ្ឌល។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាពបង្រៀននិងរៀនប្រកបដោយភាពបត់បែន និងមានប្រសិទ្ធភាព។

៤.៣.១០.៥. វិធីសាស្ត្របង្រៀនសិល្បៈ V៖ ការវាយតម្លៃការសិក្សាផ្នែកគំនូរ-ហត្ថកម្ម [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនសិល្បៈ V នេះមានគោលបំណងអភិវឌ្ឍសមត្ថភាពគរុនិស្សិតលើចំណេះដឹង និងបំណិនលើការវាយតម្លៃការសិក្សាលើមុខវិជ្ជាគំនូរ-ហត្ថកម្មនៅកម្រិតអនុវិទ្យាល័យ។ ខ្លឹមសារនៃមុខវិជ្ជានេះផ្តោតលើបញ្ញត្តិ គោលការណ៍ វិធីសាស្ត្រ និងឧបករណ៍នៃការវាយតម្លៃការសិក្សារបស់គរុនិស្សិត។ ការសិក្សាមុខវិជ្ជានេះត្រូវមានការផ្សារភ្ជាប់ទ្រឹស្តីទៅនឹង ការអនុវត្តជាក់ស្តែងលើការរៀបចំឧបករណ៍វាយតម្លៃជាសន្លឹកកិច្ចការ និងប្រើប្រាស់កម្មវិធីបច្ចេកវិទ្យា និងអនុវត្តរៀបចំតេស្តសម្រាប់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ស្របតាមលទ្ធផល សិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាលម្អិត តាមរយៈការងារបុគ្គល និងក្រុម។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព និងប្រើប្រាស់លទ្ធផលវាយតម្លៃការសិក្សាជាមូលដ្ឋានក្នុងការកែលម្អគុណភាពនៃការបង្រៀននិងរៀន។

៤.៣.១០.៦. វិធីសាស្ត្របង្រៀនសិល្បៈ VI៖ ការវាយតម្លៃការសិក្សាផ្នែកតន្ត្រី [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនសិល្បៈ VI នេះមានគោលបំណងអភិវឌ្ឍសមត្ថភាពគរុនិស្សិតលើចំណេះដឹង និងបំណិនលើការវាយតម្លៃការសិក្សាលើមុខវិជ្ជាតន្ត្រីនៅកម្រិតអនុវិទ្យាល័យ។ ខ្លឹមសារនៃមុខវិជ្ជានេះផ្តោតលើបញ្ញត្តិ គោលការណ៍ វិធីសាស្ត្រ និងឧបករណ៍នៃការវាយតម្លៃការសិក្សារបស់គរុនិស្សិត។ ការសិក្សាមុខវិជ្ជានេះត្រូវមានការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងលើការរៀបចំឧបករណ៍វាយតម្លៃជាសន្លឹកកិច្ចការ និងប្រើប្រាស់កម្មវិធីបច្ចេកវិទ្យា និងអនុវត្តរៀបចំតេស្តសម្រាប់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ស្របតាម

លទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាលម្អិត តាមរយៈការងារបុគ្គល និងក្រុម។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយភាពបត់បែន និងប្រសិទ្ធភាព និងប្រើប្រាស់លទ្ធផលវាយតម្លៃការសិក្សាជាមូលដ្ឋានក្នុងការកែលម្អគុណភាពនៃ ការបង្រៀននិងរៀន។

៤.៣.១០.៧. វិធីសាស្ត្របង្រៀនសិល្បៈ VII៖ ការវាយតម្លៃការសិក្សាផ្នែករបាំ [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនសិល្បៈ VII នេះមានគោលបំណងអភិវឌ្ឍសមត្ថភាពគរុនិស្សិតលើចំណេះដឹង និងបំណិនលើការវាយតម្លៃការសិក្សាលើមុខវិជ្ជារបាំនៅកម្រិតអនុវិទ្យាល័យ។ ខ្លឹមសារនៃមុខវិជ្ជានេះផ្តោតលើបញ្ញត្តិ គោលការណ៍ វិធីសាស្ត្រ និងឧបករណ៍នៃការវាយតម្លៃការសិក្សារបស់គរុនិស្សិត។ ការសិក្សាមុខវិជ្ជានេះត្រូវមានការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងលើការរៀបចំឧបករណ៍វាយតម្លៃជាសន្លឹកកិច្ចការ និងប្រើប្រាស់កម្មវិធីបច្ចេកវិទ្យា និងអនុវត្តរៀបចំតេស្តសម្រាប់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សស្របតាមលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាលម្អិត តាមរយៈការងារបុគ្គល និងក្រុម។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយភាពបត់បែននិងប្រសិទ្ធភាព និងប្រើប្រាស់លទ្ធផលវាយតម្លៃការសិក្សាជាមូលដ្ឋានក្នុងការកែលម្អគុណភាពនៃការបង្រៀននិងរៀន។

៤.៣.១១. ភាសាអង់គ្លេស-បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

៤.៣.១១.១. ភាសាអង់គ្លេស

៤.៣.១១.១.១. វិធីសាស្ត្របង្រៀនភាសាអង់គ្លេស I (Receptive Skills) [៣ (២-២-៥)]

Teaching Methodology I aims to provide student teachers with the knowledge and skills required to teach English listening and reading skills at lower secondary school. The content of this course covers methodologies for teaching listening and reading by incorporating interactive methods, demonstrations, lesson planning, teaching materials development, and pedagogical practices. By the end of this course, student teachers will be competent in teaching English listening and reading skills at lower secondary school.

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាអង់គ្លេស I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការបង្រៀនភាសាអង់គ្លេសលើជំនាញស្តាប់ និងអាននៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វិធីសាស្ត្របង្រៀនជំនាញស្តាប់និងអានដោយបញ្ចូលវិធីបង្រៀនអន្តរកម្ម ការរៀបចំកិច្ចតែងការបង្រៀន សម្ភារៈបង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្រៀនភាសាអង់គ្លេសលើជំនាញស្តាប់ និងអាននៅកម្រិតអនុវិទ្យាល័យ។

៤.៣.១១.១.២. វិធីសាស្ត្របង្រៀនភាសាអង់គ្លេស II (Productive Skills) [៣ (២-២-៥)]

Teaching Methodology II aims to provide student teachers with the knowledge and skills required to teach English writing and speaking skills at lower secondary school. The content of this course covers methodologies for teaching writing and speaking by incorporating interactive methods, demonstrations, lesson planning, teaching materials development, and pedagogical practices. By the end of this course, student teachers will be competent in teaching English writing and speaking skills at lower secondary school.

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាអង់គ្លេស II នេះមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការបង្រៀនភាសាអង់គ្លេសលើជំនាញសរសេរ និងនិយាយនៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វិធីសាស្ត្រសម្រាប់ការបង្រៀនសរសេរនិងនិយាយដោយបញ្ចូលវិធីសាស្ត្រ អន្តរកម្ម ការរៀបចំកិច្ចតែងការ សម្ភារៈបង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្រៀនភាសាអង់គ្លេសលើជំនាញសរសេរ និងនិយាយនៅកម្រិតអនុវិទ្យាល័យ។

៤.៣.១១.១.៣. វិធីសាស្ត្របង្រៀនអង់គ្លេស III [២ (១-២-៣)]

Teaching Methodology III aims to provide a comprehensive exploration of major approaches and methods in language teaching. The content of this course covers the theoretical principles and classroom techniques that underpin influential methods such as Grammar-Translation, Direct Method, Audio-Lingual Method, Communicative Language Teaching, Task-Based Instruction, and others. By the end of the course, students are expected to articulate informed perspectives on language teaching, select and adapt appropriate techniques, and develop reflective practices that support ongoing professional growth and effective language learning outcomes.

មុខវិជ្ជា វិធីសាស្ត្របង្រៀនអង់គ្លេស III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីគោលវិធី និងវិធីបង្រៀនភាសាអង់គ្លេស។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន គោលការណ៍ទ្រឹស្តីនិងបច្ចេកទេសដែលគាំទ្រវិធីបង្រៀនដូចជា Grammar-Translation, Direct Method, Audio-Lingual Method, Communicative Language Teaching, Task-Based Instruction និងវិធីបង្រៀនផ្សេងៗទៀតឱ្យមានប្រសិទ្ធភាព។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្រៀនភាសាអង់គ្លេសដោយជ្រើសរើស កែលម្អបច្ចេកទេសបង្រៀន និងការឆ្លុះបញ្ចាំងពីការអនុវត្តការបង្រៀន។

៤.៣.១១.១.៤. ការវាយតម្លៃការសិក្សាលើមុខវិជ្ជាភាសាអង់គ្លេស [២ (១-២-៣)]

Assessment on English Language aims to provide student teachers with knowledge about the development of English language tests for teaching and learning. The content of this course covers the key concepts and principles of test construction, as well as the analysis and assessment of language competency within the context of lower secondary education. By the end of this course, student-teachers will be competent in constructing tests, analyzing, and evaluating learning outcomes to reflect their teaching practices.

មុខវិជ្ជា ការវាយតម្លៃការសិក្សាមុខវិជ្ជាភាសាអង់គ្លេស មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងទាក់ទងនឹងការបង្កើតតេស្តភាសាអង់គ្លេសក្នុងការបង្រៀននិងរៀន។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន បញ្ញត្តិ និងគោលការណ៍សំខាន់ៗក្នុងការបង្កើតតេស្ត ការវិភាគនិងវាយតម្លៃសមត្ថភាពភាសានៅក្នុងបរិបទនៃការអប់រំនៅអនុវិទ្យាល័យ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្កើតតេស្ត វិភាគនិងវាយតម្លៃលទ្ធផលការសិក្សាដើម្បីឆ្លុះបញ្ចាំងពីការបង្រៀន។

៤.៣.១១.២. បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

៤.៣.១១.២.១. វិធីសាស្ត្របង្រៀនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ I [២ (១-២-៣)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើវិធីសាស្ត្របង្រៀនមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ នៅកម្រិតថ្នាក់ទី៧។ មុខវិជ្ជា

នេះផ្តោតលើខ្លឹមសាររួមមាន វិធីសាស្ត្របង្រៀនបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន ទំនាក់ទំនងនិងអក្ខរកម្ម មេឌា លំហូរក្បួនដោះស្រាយ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ស្មែមនិងនវានុវត្តន៍ និងការស្រាវជ្រាវនិងធនធានអប់រំអេឡិចត្រូនិក។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់វិធីសាស្ត្របង្រៀនមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍នៅកម្រិតថ្នាក់ទី៧ប្រកបដោយប្រសិទ្ធភាព។

៤.៣.១១.២.២. វិធីសាស្ត្របង្រៀនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ II [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើវិធីសាស្ត្របង្រៀនមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ នៅកម្រិតថ្នាក់ទី៨។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វិធីសាស្ត្របង្រៀនមុខវិជ្ជាបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាន ទំនាក់ទំនង និងអក្ខរកម្ម មេឌា លំហូរក្បួនដោះស្រាយ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ស្មែមនិងនវានុវត្តន៍ ការស្រាវជ្រាវ និងធនធានអប់រំអេឡិចត្រូនិក។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់វិធីសាស្ត្របង្រៀនមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍នៅកម្រិតថ្នាក់ទី៨ប្រកបដោយប្រសិទ្ធភាព។

៤.៣.១១.២.៣. វិធីសាស្ត្របង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ III [៣ (២-២-៥)]

មុខវិជ្ជា វិធីសាស្ត្របង្រៀនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើវិធីសាស្ត្របង្រៀនមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ នៅកម្រិតថ្នាក់ទី៩។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វិធីសាស្ត្របង្រៀនមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ទំនាក់ទំនងនិងអក្ខរកម្មមេឌា លំហូរក្បួនដោះស្រាយ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ស្មែមនិងនវានុវត្តន៍ ការស្រាវជ្រាវ និងធនធានអប់រំអេឡិចត្រូនិក។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់វិធីសាស្ត្របង្រៀនមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍នៅកម្រិតថ្នាក់ទី៩ ប្រកបដោយប្រសិទ្ធភាព។

៤.៣.១១.២.៤. ការវាយតម្លៃការសិក្សាមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ [២ (១-២-៣)]

មុខវិជ្ជា ការវាយតម្លៃការសិក្សាមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការវាយតម្លៃការសិក្សា និងការបង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការគិតបែបកុំព្យូទ័រ វិទ្យាសាស្ត្រទិន្នន័យ និងវិទ្យាសាស្ត្រកុំព្យូទ័រ វិធីសាស្ត្របង្រៀនក្នុងការអប់រំវិទ្យាសាស្ត្រកុំព្យូទ័រ វិធីបង្រៀនក្នុងបន្ទប់កុំព្យូទ័រ និងការវាយតម្លៃការសិក្សា។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំតេស្តនិងវិភាគលទ្ធផលតេស្តតាមកម្រិតថ្នាក់ និងប្រើប្រាស់លទ្ធផលតេស្តក្នុងការជួយគាំទ្រការសិក្សារបស់សិស្សឱ្យប្រសើរឡើង។

៤.៣.១២. បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT)-ភាសាអង់គ្លេស

៤.៣.១២.១. បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) (សូមមើល ៤.៣.១១.២)

៤.៣.១២.២. ភាសាអង់គ្លេស (សូមមើល ៤.៣.១១.១)

៤.៣.១៣. ភាសាបារាំង-បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT)

៤.៣.១៣.១. ភាសាបារាំង

៤.៣.១៣.១.១. វិធីសាស្ត្របង្រៀនភាសាបារាំង I [៣ (២-២-៥)]

Le cours de Méthodologie d'enseignement du français I vise à fournir aux étudiants-professeurs les connaissances et les compétences nécessaires pour enseigner la compréhension

orale et la compréhension écrite au niveau secondaire. Ce cours met l'accent sur l'utilisation de méthodes interactives, de démonstrations, de la planification des leçons, du développement de matériels didactiques et des pratiques pédagogiques. À la fin du cours, les étudiants-professeurs seront capables d'enseigner efficacement les compétences d'écoute et de lecture des documents en français au niveau secondaire du premier cycle.

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាបារាំង I មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការបង្រៀនជំនាញស្តាប់ និងអាននៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការប្រើប្រាស់វិធីបង្រៀនអន្តរកម្ម ការបង្ហាញ ការរៀបចំផែនការមេរៀន ការបង្កើតសម្ភារៈបង្រៀន និងការអនុវត្តគរុកោសល្យ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្រៀនជំនាញស្តាប់ និងអានឯកសារជាភាសាបារាំងប្រកបដោយប្រសិទ្ធភាពនៅកម្រិតអនុវិទ្យាល័យ។

៤.៣.១៣.១.២. វិធីសាស្ត្របង្រៀនភាសាបារាំង II [២ (១-២-៣)]

Le cours de Méthodologie d'enseignement du français II vise à développer les connaissances et les compétences nécessaires pour enseigner la production orale et la production écrite au niveau secondaire du premier cycle. Ce cours met l'accent sur l'approche communicative, les activités interactives, les jeux de rôle, la planification des leçons, la conception des activités pédagogiques et la pratique de l'enseignement. À la fin du cours, les étudiants-professeurs seront capables d'enseigner efficacement les compétences d'oral et d'écrit au niveau secondaire du premier cycle.

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាបារាំង II មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនក្នុងការបង្រៀនជំនាញនិយាយ និងសរសេរ នៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន វិធីសាស្ត្រប្រាស្រ័យទាក់ទង ការប្រើសកម្មភាពអន្តរកម្ម ការលេងល្បែងដើរតួ ការរៀបចំផែនការមេរៀន និងការអនុវត្តការបង្រៀន។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងអាចបង្រៀនជំនាញនិយាយ និងសរសេរប្រកបដោយប្រសិទ្ធភាព។

៤.៣.១៣.១.៣. វិធីសាស្ត្របង្រៀនភាសាបារាំង III [៣ (២-២-៥)]

Le cours de Méthodologie d'enseignement du français III vise à fournir aux étudiants-professeurs la compréhension approfondie des principes et des approches didactiques du français. Ce cours met l'accent sur les fondements théoriques et les techniques pédagogiques en classe, soutenant l'efficacité de différentes approches telles que la méthode traditionnelle (grammaire-traduction), la méthode directe, la méthode audio-orale, l'approche communicative, l'approche actionnelle, la classe inversée, ainsi que d'autres méthodes d'enseignement. À la fin du cours, les étudiants-professeurs seront capables de mobiliser des connaissances en didactique du français, de sélectionner et d'adapter des techniques pédagogiques pertinentes, et de développer une réflexion professionnelle contribuant à l'amélioration des apprentissages.

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាបារាំង III មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិន អំពីគោលវិធី និងវិធីសាស្ត្របង្រៀនភាសាបារាំង។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ទ្រឹស្តី និងបច្ចេកទេស ក្នុងថ្នាក់រៀន ដែលគាំទ្រប្រសិទ្ធភាពនៃវិធីបង្រៀនដូចជា méthode traditionnelle (grammaire-traduction), méthode directe, méthode audio-orale, approche communicative, approche actionnelle, classe inversée និងវិធីសាស្ត្របង្រៀនផ្សេងៗទៀត។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្រៀនភាសាបារាំង ជ្រើសរើសនិងការកែសម្រួលបច្ចេកទេសបង្រៀនសមស្រប និងឆ្លុះបញ្ចាំងពីការអនុវត្តដែលគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈ និងការលើកកម្ពស់លទ្ធផលសិក្សាប្រកបដោយ ប្រសិទ្ធភាព។

៤.៣.១៣.១.៤. វិធីសាស្ត្របង្រៀនភាសាបារាំង IV [២ (១-២-៣)]

Le cours de Méthodologie d'enseignement du français IV vise à développer les compétences professionnelles des étudiants-professeurs dans la planification des leçons, l'évaluation des apprentissages et la pratique pédagogique au niveau secondaire. Ce cours met l'accent sur l'approche par compétences, la conception des plans de leçon, l'utilisation des outils d'évaluation formative et sommative, ainsi que la pratique du micro-enseignement. À la fin du cours, les étudiants-professeurs seront capables de planifier, enseigner et évaluer efficacement l'apprentissage du français.

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាបារាំង IV មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិន ក្នុងការរៀបចំផែនការមេរៀន ការវាយតម្លៃការសិក្សា និងការអនុវត្តគរុកោសល្យនៅកម្រិតអនុវិទ្យាល័យ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសាររួមមាន ការបង្រៀនតាមសមត្ថភាព ការរៀបចំផែនការមេរៀន ការប្រើឧបករណ៍វាយតម្លៃ និងការអនុវត្ត micro-enseignement។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងអាចរៀបចំបង្រៀន និងវាយតម្លៃការសិក្សាភាសាបារាំងបានយ៉ាងមានប្រសិទ្ធភាព។

៤.៣.១៣.២. បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) (សូមមើល ៤.៣.១១.២)

៤.៣.១៤. បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) - ភាសាបារាំង

៤.៣.១៤.១. បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) (សូមមើល ៤.៣.១១.២)

៤.៣.១៤.២. ភាសាបារាំង (សូមមើល ៤.៣.១៣.១)

៤.៤. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)

៤.៤.១. ការដេកពិសោធនៅសាលារៀន (២ ក្រេឌីត)

កម្មសិក្សាគរុកោសល្យ I " ការដេកពិសោធនៅក្នុងសាលារៀន " រយៈពេល២សប្តាហ៍មានគោលបំណងផ្តល់ឱ្យកម្មសិក្សាការី ការិនី នូវឱកាសក្នុងការសង្កេតដំណើរការបង្រៀននិងរៀន នៅអនុវិទ្យាល័យដោយផ្អែកលើមុខវិជ្ជាឯកទេស និងទិដ្ឋភាពផ្សេងៗទៀតនៃវិជ្ជាជីវៈបង្រៀន។ នៅអំឡុងពេល ២សប្តាហ៍ នៃការអនុវត្តកម្មសិក្សាគរុកោសល្យឆ្នាំទី I ស្តីពីការដេកពិសោធក្នុងសាលារៀន កម្មសិក្សាការី ការិនីនឹងសង្កេតលើតួនាទីនិងភារកិច្ចរបស់គ្រូ ការផ្សារភ្ជាប់ទ្រឹស្តីនិងការអនុវត្តជាក់ស្តែង ការគ្រប់គ្រងថ្នាក់រៀន ការរៀបចំសម្រាប់ការសន្ទនាឆ្លុះបញ្ចាំង និងរៀបចំផលបត្ររបស់ពួកគេសម្រាប់ការសង្កេតរយៈពេល ២សប្តាហ៍។ ក្នុងករណីគរុនិស្សិតសិក្សាពីរមុខវិជ្ជាឯកទេស គរុនិស្សិតត្រូវឱ្យអនុវត្តការសង្កេតការបង្រៀនទាំងពីរមុខវិជ្ជាឯកទេសក្នុង

អំឡុងពេលចុះកម្មសិក្សា ២សប្តាហ៍នេះ។ តាមរយៈការសង្កេត និងឆ្លុះបញ្ចាំងប្រចាំសប្តាហ៍ កម្មសិក្សាការី ការិនីផ្សារភ្ជាប់រវាងទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងដោយសង្កេត កត់ចំណាំ ពិភាក្សាជាមួយមិត្តកក្តិរបស់ពួកគេ និងរៀនពីគ្រូណែនាំ ដើម្បីត្រៀមខ្លួនសម្រាប់កម្មសិក្សាឆ្នាំទី២ និងឆ្នាំបន្ទាប់ៗទៀត។

៤.៤.២. ភាពជាជំនួយការបង្រៀន (៥ ក្រេឌីត)

កម្មសិក្សាគរុកោសល្យ II "ភាពជាជំនួយការបង្រៀន" រយៈពេល ៥សប្តាហ៍ មានគោលបំណងផ្តល់ឱ្យកម្មសិក្សាការី ការិនីនូវបទពិសោធភាពជាជំនួយការបង្រៀន។ អំឡុងពេលចុះកម្មសិក្សា កម្មសិក្សាការី ការិនីនឹងសង្កេតការបង្រៀនរបស់គ្រូណែនាំ ចូលរួមសន្ទនាឆ្លុះបញ្ចាំងប្រចាំសប្តាហ៍ជាមួយ គ្រូឧទ្ទេសដឹកនាំ រៀបចំការបង្រៀនផ្នែកណាមួយនៃមេរៀន រៀបចំកិច្ចតែងការបង្រៀន ផលិតសម្ភារឧបទេស គ្រប់គ្រងធនធានសិក្សា និងគ្រប់គ្រងថ្នាក់រៀន។ ក្នុងសប្តាហ៍នីមួយៗ កម្មសិក្សាការី ការិនី ត្រូវកត់ត្រាការសង្កេតនៅលើសន្លឹកកិច្ចការដើម្បីចងក្រងផលបត្រ។ សម្រាប់គរុនិស្សិតសិក្សាពីរមុខវិជ្ជាឯកទេស ពួកគេនឹង ត្រូវអនុវត្តជាជំនួយការបង្រៀនលើមុខវិជ្ជាឯកទេសទាំងពីរនៅក្នុងរយៈពេល ៥សប្តាហ៍។ នៅពេលបញ្ចប់ កម្មសិក្សាគរុកោសល្យ II កម្មសិក្សាការី ការិនីនឹងមានសមត្ថភាពរៀបចំកិច្ចតែងការបង្រៀន ផលិតសម្ភារ ឧបទេស គ្រប់គ្រងថ្នាក់រៀន និងបង្រៀនផ្នែកណាមួយនៃមេរៀន។

៤.៤.៣. ការអនុវត្តការបង្រៀន I (៥ ក្រេឌីត)

ការអនុវត្តការបង្រៀន I រយៈពេល ៥សប្តាហ៍ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវឱកាសប្រើប្រាស់ចំណេះដឹង និងបំណិនក្នុងការបង្រៀនក្នុងថ្នាក់រៀនជាក់ស្តែងនៅអំឡុងពេលសិក្សាឆ្នាំទី៣។ ក្នុងអំឡុងពេលអនុវត្តការបង្រៀននេះ កម្មសិក្សាការី ការិនីនឹងបង្រៀនមុខវិជ្ជាឯកទេស សង្កេតនិងកំណត់បញ្ហាប្រឈមជ្រើសរើសប្រធានបទ និងសរសេរសំណើស្រាវជ្រាវប្រតិបត្តិ។ សម្រាប់គរុនិស្សិតសិក្សាពីរមុខវិជ្ជាឯកទេសតម្រូវឱ្យអនុវត្តការបង្រៀនលើមុខវិជ្ជាឯកទេសទាំងពីរក្នុងរយៈពេល៥សប្តាហ៍ ប៉ុន្តែសម្រាប់ប្រធានបទនៃការស្រាវជ្រាវគរុនិស្សិតអាចជ្រើសរើសមុខវិជ្ជាណាមួយក្នុងចំណោមមុខវិជ្ជាឯកទេសទាំងពីរ ដើម្បីសរសេរសំណើស្រាវជ្រាវប្រតិបត្តិ។ នៅពេលបញ្ចប់ការអនុវត្តការបង្រៀន I កម្មសិក្សាការី ការិនីមានសមត្ថភាពរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន និងសម្ភារឧបទេស បង្រៀនក្នុងថ្នាក់ដោយឯករាជ្យ និងរៀបចំសំណើស្រាវជ្រាវប្រតិបត្តិ។

៤.៤.៤. ការអនុវត្តការបង្រៀន II (១០ ក្រេឌីត)

ការអនុវត្តការបង្រៀន II រយៈពេល ១០សប្តាហ៍ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវឱកាសប្រើប្រាស់ ចំណេះដឹងនិងបំណិនក្នុងការអនុវត្តការបង្រៀនក្នុងថ្នាក់រៀនជាក់ស្តែងនៅឆ្នាំទី៤។ ក្នុងអំឡុងពេលអនុវត្តការបង្រៀន II នេះកម្មសិក្សាការី ការិនី នឹងបង្រៀនពេញលេញដោយរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន សម្ភារឧបទេស ធនធានសិក្សា គ្រប់គ្រងថ្នាក់រៀន បរិស្ថានសិក្សាដែលគាំទ្រដល់ការសិក្សារបស់សិស្ស ការវាយតម្លៃការសិក្សារបស់សិស្ស និងកិច្ចការផ្សេងៗទៀតទាំងក្នុងថ្នាក់និងក្រៅថ្នាក់។ កម្មសិក្សាការី ការិនី ត្រូវរៀបចំផែនការសកម្មភាពសម្រាប់ការសង្កេតថ្នាក់និងបង្រៀនជាផ្លូវការជូនគ្រូណែនាំ និងគ្រូឧទ្ទេសដឹកនាំ ត្រូវចូលរួមប្រជុំសន្ទនាឆ្លុះបញ្ចាំង និងសរសេរចូលទៅក្នុងទម្រង់របាយការណ៍ សន្ទនាឆ្លុះបញ្ចាំងដើម្បីចងក្រងផលបត្រ។ សម្រាប់គរុនិស្សិតសិក្សាពីរឯកទេស តម្រូវឱ្យបង្រៀន ទាំងពីរឯកទេស នឹងអាចជ្រើសរើសឯកទេសមួយក្នុងការប្រមូលទិន្នន័យសម្រាប់សរសេររបាយការណ៍ស្រាវជ្រាវប្រតិបត្តិ ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន អនុវិទ្យាល័យ។ នៅពេលបញ្ចប់ការអនុវត្តការបង្រៀន II កម្មសិក្សាការី ការិនីនឹងមានសមត្ថភាពប្រើប្រាស់ទ្រឹស្តីនិង គោលការណ៍នៃការបង្រៀននៅក្នុងថ្នាក់រៀន

យល់ដឹងពីតួនាទីនិងការកិច្ចសំខាន់ៗរបស់គ្រូបង្រៀន ស្គាល់សិស្ស (តម្រូវការ របៀបរៀន ជាដើម) ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការ ផលប្រយោជន៍ និងសមត្ថភាពរបស់សិស្ស។

៤.៥. ការស្រាវជ្រាវ (៦ ក្រេឌីត)

៤.៥.១. ការស្រាវជ្រាវអប់រំ [៣ (៣-០-៦)]

មុខវិជ្ជាការស្រាវជ្រាវអប់រំមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិន ជាមូលដ្ឋានសម្រាប់ធ្វើការស្រាវជ្រាវអប់រំ និងការស្រាវជ្រាវប្រតិបត្តិ។ មុខវិជ្ជានេះផ្តោតលើខ្លឹមសារដូចជា សញ្ញាណទូទៅនៃការស្រាវជ្រាវអប់រំដោយផ្តោតសំខាន់លើការស្រាវជ្រាវប្រតិបត្តិ ការកំណត់បញ្ហា និង ប្រធានបទស្រាវជ្រាវ វត្ថុបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សម្មតិកម្មស្រាវជ្រាវ វិធីសាស្ត្រ ស្រាវជ្រាវ ការប្រមូលទិន្នន័យ ការវិភាគ ទិន្នន័យ ការបកស្រាយលទ្ធផល និងការរៀបចំសំណើ ស្រាវជ្រាវប្រតិបត្តិ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងមានសមត្ថភាពសរសេរសំណើស្រាវជ្រាវប្រតិបត្តិ ដើម្បីឈានទៅរកការសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ដែលអាចបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀនអនុវិទ្យាល័យ។

៤.៥.២. គម្រោងស្រាវជ្រាវប្រតិបត្តិ (៣ ក្រេឌីត)

គម្រោងស្រាវជ្រាវប្រតិបត្តិ មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវការអនុវត្តការស្រាវជ្រាវប្រតិបត្តិនៅក្នុងថ្នាក់រៀនស្របតាមសំណើស្រាវជ្រាវប្រតិបត្តិរបស់ខ្លួនដែលបានរៀបចំ។ ការអនុវត្តគម្រោងនេះផ្តល់ឱកាសឱ្យគរុនិស្សិតពិនិត្យ និងកែលម្អគម្រោងស្រាវជ្រាវប្រតិបត្តិ អនុវត្តផែនការស្រាវជ្រាវ ប្រតិបត្តិតាមដំណាក់កាលដូចជាការរៀបចំ ឧបករណ៍ ប្រមូលទិន្នន័យ ការប្រមូលទិន្នន័យ ការវិភាគ និងការបកស្រាយទិន្នន័យ ព្រមទាំងធ្វើបទបង្ហាញលទ្ធផល និងសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ ក្រោមការណែនាំពីគ្រូឧទ្ទេសដឹកនាំស្រាវជ្រាវ។ ក្រោយបញ្ចប់គម្រោងនេះ គរុនិស្សិតនឹងមានសមត្ថភាពធ្វើការស្រាវជ្រាវប្រតិបត្តិ ដើម្បីកែលម្អគុណភាពនៃការបង្រៀន និងរៀនក្នុងថ្នាក់រៀន ជាក់ស្តែងដើម្បីឆ្លើយតបនឹងលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈអប់រំ គ្រូបង្រៀនអនុវិទ្យាល័យ ព្រមទាំងចែករំលែកចំណេះដឹងដល់អ្នកពាក់ព័ន្ធផ្សេងៗ។

ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា (២០២៣) *ក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀន មត្តេយ្យសិក្សា អនុវិទ្យាល័យ និងមធ្យមសិក្សាបឋមភូមិ* នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០២៣) *ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០* នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០២៥) *ផែនការយុទ្ធសាស្ត្រកែទម្រង់ការអប់រំគ្រូបង្រៀននៅកម្ពុជា ឆ្នាំ២០២៤-២០៣០* ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០២៤) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨* ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០២១) *ក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យ* ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៦) *ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស* នាយកដ្ឋានអភិវឌ្ឍកម្មវិធី ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) *ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន* ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) *កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននៅកម្រិតអនុវិទ្យាល័យ ១២+២* នាយកដ្ឋាន បណ្តុះបណ្តាលនិងវិក្រឹតការ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១១) *កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ ១២+២* នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១០) *ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន* នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (២០០៤) *សេចក្តីសម្រេចប្រព័ន្ធក្រេឌីតនិងការផ្ទេរក្រេឌីតនៅ កម្រិតឧត្តមសិក្សា លេខ០៤/០៤គ.ទ.ក.សសរ* ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

Nanyang Technological University, National Institute of Education (2017). *Bachelor of Arts (Education) Bachelor of Science (Education)*, July 2017. NTU, NIE, Singapore.

Voskuilen, Wim. (2016). *Recommendations for developing a framework for a Bachelor of Education (B.Ed.)*, TTD/VSO, 2016. Phnom Penh.